

សង្ខេបរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល

២០១៩

# ការធ្វើចំណាកស្រុក ការផ្លាស់ទីលំនៅដោយបង្ខំ និងការអប់រំ៖ សង់ស្ពានចម្លង មិនមែនសង់ជញ្ជាំងនោះទេ

United Nations
Educational, Scientific and
Cultural Organization

Sustainable
Development
Goals

Global
Education
Monitoring
Report

សង្ខេបរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល

២០១៩

# ការធ្វើចំណាកស្រុក ការផ្លាស់ទីលំនៅដោយបង្ខំ និងការអប់រំ៖

## សង់ស្ពានចម្លង មិនមែនសង់ជញ្ជាំងនោះទេ

សេចក្ដីប្រកាសអ៊ីនឈ័ន និងក្របខ័ណ្ឌសកម្មភាពវិស័យអប់រំ ឆ្នាំ ២០៣០ ចែងថា របាយការណ៍ពិនិត្យតាមដានការអប់រំជាសកល មានតួនាទីជា "យន្តការសម្រាប់ពិនិត្យតាមដាន និងរាយការណ៍ពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ និងពីការអប់រំ ដែលត្រូវបានបញ្ចូលទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្សេងទៀត" និង "រាយការណ៍ពីការអនុវត្តយុទ្ធសាស្ត្រជាតិ និងអន្តរជាតិ ដើម្បីទាមទារឱ្យគ្រប់ដៃគូពាក់ព័ន្ធទាំងអស់មានគណនេយ្យភាពចំពោះអ្វីដែលពួកគេបានសន្យា ជាផ្នែកមួយនៃការតាមដានបន្ត និងការពិនិត្យលើគោលដៅអភិវឌ្ឍន៍ដោយចីរភាពជារួម"។ របាយការណ៍នេះត្រូវបានរៀបចំឡើងដោយអ្នកជំនាញឯករាជ្យមួយក្រុម ក្រោមការដឹកនាំរបស់យូណេស្កូ។

ឈ្មោះតួនាទី ដែលត្រូវបានប្រើប្រាស់ និងព័ត៌មានដែលបង្ហាញក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនមែនជាការបញ្ចេញមតិរបស់យូណេស្កូ ពាក់ព័ន្ធនឹងស្ថានភាពស្របច្បាប់របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយ ឬសមត្ថកិច្ចរបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់នេះ ឬពាក់ព័ន្ធនឹងការកំណត់ព្រំប្រទល់ដែនរបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ទាំងនេះឡើយ។

ក្រុមការងាររៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកលនេះ គឺជាអ្នកទទួលខុសត្រូវលើការជ្រើសរើស និងការបង្ហាញអង្គហេតុ ក្នុងឯកសារបោះពុម្ពផ្សាយនេះ និងលើទស្សនៈដែលត្រូវបានបញ្ចេញក្នុងឯកសារនេះ។ ទស្សនៈទាំងនេះមិនមែនជាទស្សនៈយូណេស្កូ ហើយមិនតម្រូវឲ្យយូណេស្កូជាប់កាតព្វកិច្ចអ្វីមួយឡើយ។ ប្រធានក្រុមការងារនេះ ជាអ្នកទទួលខុសត្រូវជារួមលើគំនិតយោបល់ និងទស្សនៈយល់ឃើញ ដែលត្រូវបានលើកឡើងក្នុងរបាយការណ៍នេះ។

## ក្រុមការងាររៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល

**ប្រធានក្រុម៖** Manos Antoninis

Daniel April, Bilal Barakat, Madeleine Barry, Nicole Bella, Anna Cristina D'Addio, Glen Hertelendy, Sébastien Hine, Priyadarshani Joshi, Katarzyna Kubacka, Kate Linkins, Leila Loupis, Kassiani Lythrangomitis, Alasdair McWilliam, Anissa Mechtar, Claudine Mukizwa, Yuki Murakami, Carlos Alfonso Obregón Melgar, Judith Randrianatoavina, Kate Redman, Maria Rojnov, Anna Ewa Ruszkiewicz, Will Smith, Rosa Vidarte និង Lema Zekrya.

របាយការណ៍ពិនិត្យតាមដានការអប់រំជាសកលនេះ គឺជាឯកសារបោះពុម្ពផ្សាយឯករាជ្យប្រចាំឆ្នាំ។ របាយការណ៍ GEM នេះ ត្រូវបានរៀបចំឡើង ក្រោមការឧបត្ថម្ភថវិកាពីរដ្ឋាភិបាល ទីភ្នាក់ងារពហុភាគី និងមូលនិធិឯកជន និងមានការសម្របសម្រួល និងការគាំទ្រពីយូណេស្កូ។

ឯកសារបោះពុម្ពផ្សាយនេះត្រូវបានផ្សព្វផ្សាយឱ្យមានការប្រើប្រាស់ជាចំហ ក្រោមអាជ្ញាប័ណ្ណ Attribution-Share Alike 3.0 IGO ( CC-BY-SA 3.0 IGO ) license ( http://creativecommons.org/licenses/by-sa/3.0/igo/ ) ។ តាមរយៈការដកស្រង់ខ្លឹមសារពីឯកសារបោះពុម្ពផ្សាយនេះទៅប្រើប្រាស់ អ្នកប្រើប្រាស់ទទួលថាខ្លួននឹងជាប់កាតព្វកិច្ច គោរពតាមលក្ខខណ្ឌនៃការប្រើប្រាស់ ដែលកំណត់ដោយបណ្ណាល័យដែលអាចចូលប្រើប្រាស់ដោយសេរីរបស់យូណេស្កូ ( http://www.unesco.org/open-access/terms-use-ccbysa-en ) ។ អាជ្ញាប័ណ្ណនេះអនុវត្តទាំងស្រុងចំពោះខ្លឹមសារអត្ថបទនៃឯកសារនេះ។ សម្រាប់ការប្រើប្រាស់ខ្លឹមសារទាំងឡាយដែលពុំត្រូវបានកំណត់ជាក់ច្បាស់ថាជារបស់យូណេស្កូ ចាំបាច់ត្រូវមានការស្នើសុំការអនុញ្ញាតជាមុនពី៖ publication.copyright@unesco.org ឬ UNESCO Publishing, 7, place de Fontenoy, 75352 Paris 07 SP France.

ចំណងជើងដើមជាភាសាអង់គ្លេស៖ Global Education Monitoring Report Summary 2019: Migration, displacement and education: Building bridges, not walls

ឈ្មោះឯកសារយោង នៃរបាយការណ៍នេះ៖ UNESCO. 2018. **សង្ខេបរបាយការណ៍ពិនិត្យតាមដាន ការអប់រំជាសកល ឆ្នាំ ២០១៩: ការធ្វើចំណាកស្រុក ការផ្លាស់ទីលំនៅដោយបង្ខំ និងការអប់រំ៖ សង់ស្ពានចម្លង មិនមែនសង់ជញ្ជាំងនោះទេ** , UNESCO.

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានស្ថានភាពនៃការអប់រំទូទាំងសកលលោក
អង្គការយូណេស្កូ អាសយដ្ឋាន
7, place de Fontenoy
75352 Paris 07 SP, France
Email: gemreport@unesco.org
Tel.: +33 1 45 68 07 41
www.unesco.org/gemreport
https://gemreportunesco.wordpress.com

រាល់កំហុស ឬការខ្វះព័ត៌មាន ដែលរកឃើញក្រោយពេលបោះពុម្ពនឹងត្រូវកែតម្រូវក្នុងសំណៅអនឡាញនៃឯកសារនេះ ដែលអាចរកបានតាមរយៈគេហទំព័រ
www.unesco.org/gemreport

© UNESCO, 2018
រក្សាសិទ្ធិគ្រប់បែបយ៉ាង
កំណែទីមួយ
បោះពុម្ពផ្សាយក្នុងឆ្នាំ ២០១៧ ដោយអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ

7, Place de Fontenoy, 75352
Paris 07 SP, France

វាយអត្ថបទដោយយូណេស្កូ
រចនាក្រាហ្វិចដោយ FHI 360
រចនាសម្រាប់បោះពុម្ពដោយយូណេស្កូ

**របាយការណ៍ពិនិត្យតាមដានស្ថានភាពនៃការអប់រំជាសកល៖**

- ២០១៩ ការធ្វើចំណាកស្រុក ការផ្លាស់ទីលំនៅដោយបង្ខំ និងការអប់រំ៖សង់ស្ពានចម្លងមិនមែនសង់ជញ្ជាំងនោះទេ
- ២០១៧/៨ គណនេយ្យភាពក្នុងវិស័យអប់រំ៖ គោរពតាមអ្វីដែលយើងបានសន្យា
- ២០១៦ ការអប់រំសម្រាប់មនុស្ស និងផែនដី៖ បង្កើតអនាគតប្រកបដោយចីរភាពសម្រាប់ទាំងអស់គ្នា

**របាយការណ៍ពិនិត្យតាមដានទូទាំងសកលលោកសម្រាប់ការអប់រំសម្រាប់ទាំងអស់គ្នា**

- ២០១៥ ការអប់រំសម្រាប់ទាំងអស់គ្នា ២០០០-២០១៥ ៖ សមិទ្ធផលសម្រេចបាន និងបញ្ហាប្រឈម
- ២០១៣/៤ ការបង្រៀន និងរៀន៖ សម្រេចឱ្យបាននូវគុណភាពសម្រាប់ទាំងអស់គ្នា
- ២០១២ យុវជន និងជំនាញ៖ ប្រែក្លាយការអប់រំ ឲ្យទៅជាការងារ
- ២០១១ វិបត្តិលាក់មុខ៖ជម្លោះប្រដាប់អាវុធនិងការអប់រំ
- ២០១០ ការផ្តល់សេវាដល់ក្រុមដែលពុំមានឱកាស
- ២០០៩ ការជម្នះវិសមភាព៖ ហេតុអ្វីបានជាអភិបាលកិច្ចមានសារៈសំខាន់
- ២០០៨ ការអប់រំសម្រាប់ទាំងអស់គ្នាត្រឹមឆ្នាំ២០១៥៖ តើយើងអាចសម្រេចវាបានដែរឬទេ ?
- ២០០៧ មូលដ្ឋានរឹងមាំ៖ ការគាំពារ និងអប់រំកុមារតូច
- ២០០៦ អក្ខរកម្ម ដើម្បីជីវិត
- ២០០៥ ការអប់រំសម្រាប់ទាំងអស់គ្នា៖ លក្ខខណ្ឌតម្រូវផ្នែកគុណភាព
- ២០០៣/៤ យេនឌ័រ និងការអប់រំសម្រាប់ទាំងអស់គ្នា៖ ការបោះជំហានទៅរកសមភាព
- ២០០២ ការអប់រំសម្រាប់ទាំងអស់គ្នា៖ តើពិភពលោកស្ថិតតាមផែនការដែលបានគ្រោងទុកដែរឬទេ ?

រូបថតគ្របមុខ និងគ្របក្រោយ៖ Rushdi Sarra/UNRWA
អត្ថបទក្រោមរូបភាព៖ សិស្សជាជនភៀសខ្លួនប៉ាឡេស្ទីនមករៀនថ្ងៃដំបូង ក្នុងសាលារៀន UNRWA ក្នុងឆមាសទីពីរនៅតំបន់កាហ្សា

រចនាសក្រាហ្វិចព័ត៌មានដោយ Housatonic Design Network

របាយការណ៍សង្ខេប និងឯកសារពាក់ព័ន្ធនានា អាចដោនឡូតពី៖http://bit.ly/2019gemreport

# អារម្ភកថា

បច្ចុប្បន្ននេះ មនុស្សបានផ្លាស់ទីពីកន្លែងមួយ ទៅកន្លែងមួយទៀតរួចទៅហើយ។ អ្នកខ្លះ ផ្លាស់ទីដើម្បីស្វែងរកឱកាសប្រសើរជាងមុនអ្នកខ្លះរត់គេចពីគ្រោះថ្នាក់។ការផ្លាស់ទីទាំងនេះមានឥទ្ធិពលយ៉ាងធំធេងមកលើប្រព័ន្ធអប់រំ។ របាយការណ៍ពិនិត្យតាមដានការអប់រំសកលឆ្នាំ ២០១៩ គឺជារបាយការណ៍លើកទីមួយ ដែលធ្វើការស្វែងយល់ស៊ីជម្រៅអំពីបញ្ហាទាំងនេះ នៅគ្រប់ទិសទីក្នុងពិភពលោក។

ការរៀបចំរបាយការណ៍នេះ ធ្វើឡើងទាន់ពេលវេលា ខណៈពេលដែលសហគមន៍អន្តរជាតិកំពុងរៀបចំបញ្ចប់កិច្ចព្រមព្រៀងអន្តរជាតិសំខាន់ៗចំនួនពីរគឺកិច្ចព្រមព្រៀងសកលស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព មានសណ្តាប់ធ្នាប់ និងស្របច្បាប់ និងកិច្ចព្រមព្រៀងសកលស្តីពីជនភៀសខ្លួន។

កិច្ចព្រមព្រៀងពុំធ្លាប់មានទាំងពីរនេះ រួមនឹងការប្តេជ្ញាចិត្តជាអន្តរជាតិចំពោះការអប់រំ គឺជាប្រធានបទដែលត្រូវបានបញ្ចូលក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ របស់អង្គការសហប្រជាជាតិ ដែលរំលេចឱ្យឃើញពីភាពចាំបាច់ ក្នុងការឆ្លើយតបចំពោះតម្រូវការអប់រំរបស់ជនចំណាកស្រុក និងជនដែលត្រូវបានគេបង្ខំឱ្យចាក់ចេញពីផ្ទះសម្បែង។ របាយការណ៍ពិនិត្យតាមដានការអប់រំជាសកលនេះ គឺជាឯកសារយោងដ៏សំខាន់សម្រាប់អ្នកតាក់តែងគោលនយោបាយ ដែលជាអ្នកទទួលខុសត្រូវ ក្នុងការជួយឱ្យយើងសម្រេចគោលបំណងរបស់យើងទាំងនេះ។

បច្ចុប្បន្ននេះ ច្បាប់ និងគោលនយោបាយនានា ពុំបានផ្តល់ភាពអនុគ្រោះដល់កុមារដែលជាជនចំណាកស្រុក និងជនភៀសខ្លួននោះឡើយ ព្រោះពុំបានផ្តល់សិទ្ធិដល់ពួកគេ និងថែមទាំងព្រងើយកន្តើយចំពោះតម្រូវការរបស់ពួកគេផង។ ជនចំណាកស្រុក ជនភៀសខ្លួន និងជនដែលត្រូវបានបង្ខំឱ្យចាកចេញពីផ្ទះសម្បែង គឺជាអ្នកដែលស្ថិតក្នុងចំណោមក្រុមដែលងាយរងគ្រោះជាងគេក្នុងពិភពលោក ដែលក្រុមនេះមាន ដូចជា អ្នកដែលរស់នៅតាមតំបន់អនាធិបតេយ្យ អ្នកដែលធ្វើចំណាកស្រុកតាមរដូវ ដើម្បីស្វែងរកចំណូលទ្រទ្រង់ជីវភាពរស់នៅ និងកុមារដែលកំពុងជាប់ឃុំឃាំង។ ទោះជាយ៉ាងណាក៏ដោយអ្នកទាំងនេះ ត្រូវបានគេបដិសេធមិនឱ្យទទួលបានការអប់រំតាមសាលារៀនដែលជាកន្លែងផ្តល់ឱ្យពួកគេនូវជម្រកសុវត្ថិភាព និងកសាងគ្រឹះដើម្បីទទួលបានអនាគតកាន់តែល្អប្រសើរជាងមុន។

ការមិនយកចិត្តទុកដាក់ចំពោះការអប់រំរបស់ជនចំណាកស្រុក នាំឱ្យមានការខាតបង់សក្តានុពលរបស់មនុស្ស ក្នុងកម្រិតមួយធំធេង។ ពេលខ្លះ ត្រឹមតែជាការបំពេញឯកសារក៏សាមញ្ញការខ្វះទិន្នន័យ ឬប្រព័ន្ធដែលមានលក្ខណៈការិយាធិបតេយ្យ និងការពុំមានការស្របសម្រួលជាមួយគ្នាឱ្យបានល្អធ្វើឱ្យមនុស្សជាច្រើននាក់ពុំបានទទួលសេវា។ ទោះជាយ៉ាងណាក៏ដោយការវិនិយោគលើការអប់រំ សម្រាប់ជនចំណាកស្រុក និងជនភៀសខ្លួន ដែលមានទេពកោសល្យនិងការតាំងចិត្តខ្ពស់អាចជម្រុញឱ្យមានការអភិវឌ្ឍនិងកំណើនសេដ្ឋកិច្ចមិនត្រឹមតែតាមប្រទេសដែលទទួល ពួកគេឱ្យរស់នៅតែប៉ុណ្ណោះទេ ថែទាំងក្នុងប្រទេសដើមកំណើតរបស់ ពួកគេទៀតផង។

ការផ្ដល់ការអប់រំតែមួយគត់គឺមិនគ្រប់គ្រាន់នោះឡើយ។បរិយាកាសក្នុងសាលារៀនចាំបាច់ត្រូវសម្រប និងត្រូវផ្ដល់ការគាំទ្រដល់តម្រូវការជាក់លាក់របស់អ្នកដែលធ្វើចំណាកស្រុកទៀតផង។ ការដាក់ជនអន្តោប្រវេសន៍ និងជនភៀសខ្លួនឱ្យរៀនក្នុងសាលាតែមួយ ជាមួយនឹងប្រជាជនម្ចាស់ស្រុក គឺជាចំណុចចាប់ផ្តើមយ៉ាងសំខាន់ ដើម្បីកសាងភាពចុះសម្រុងគ្នាក្នុងសង្គម។ ទោះជាយ៉ាងណាក៏ដោយ វិធីសាស្ត្របង្រៀន និងភាសាប្រើប្រាស់សម្រាប់ការបង្រៀន ព្រមទាំងការរើសអើង អាចជាកត្តាដែលធ្វើឱ្យអ្នកទាំងនេះ ត្រូវចាកឆ្ងាយពីសាលារៀន។

គ្រូបង្រៀនដែលទទួលបានការបណ្ដុះបណ្ដាលបានល្អ មានតួនាទីយ៉ាងសំខាន់ក្នុងការធានាឱ្យមានការផ្ដល់ការអប់រំ ដល់សិស្សជាជនអន្តោប្រវេសន៍ និងជនភៀសខ្លួន ដូចគ្នានឹងសិស្សដទៃទៀតប៉ុន្តែគ្រូបង្រៀនទាំងនេះក៏ត្រូវការការគាំទ្រផងដែរ ដើម្បីឱ្យពួកគេអាចគ្រប់គ្រងថ្នាក់រៀនពហុភាសា ដែលមានវប្បធម៌ចម្រុះ ហើយដែលជារឿយៗ ថ្នាក់រៀនទាំងនេះក៏មានសិស្សដែលមានតម្រូវការចិត្តសង្គមពិសេសផងដែរ។

កម្មវិធីសិក្សាដែលរៀបចំបានល្អ ដែលជំរុញលើកកម្ពស់ភាពចម្រុះ និងផ្ដល់ជំនាញសំខាន់ៗ ក៏ដូចជាជម្នះតតាំងនឹងបុរេវិនិច្ឆ័យ ក៏មានសារៈសំខាន់ផងដែរ និងអាចមានឥទ្ធិពលសាយភាយជាវិជ្ជមានទៅខាងក្រៅជញ្ជាំងបន្ទប់រៀនទៀតផង។ ពេលខ្លះ សៀវភៅសិក្សាបែរជាបញ្ចូលរូបភាពចាស់គម្រឹលអំពីស្ថានភាពចំណាកស្រុក និងបន្ទុចបង្អាក់ដល់កិច្ចខិតខំប្រឹងប្រែងធានាឱ្យមានបរិយាបន្នទៅវិញ។ កម្មវិធីសិក្សាជាច្រើនក៏ពុំមានភាពបទបែនគ្រប់គ្រាន់ ដើម្បីសម្របទៅតាមបែបផែនការរស់នៅ របស់អ្នកដែលធ្វើចំណាកស្រុកម្ដងម្កាលផងដែរ។

ការពង្រីកការផ្ដល់សេវា និងការធានាឱ្យមានការផ្ដល់សេវាប្រកបដោយបរិយាបន្ន តម្រូវឱ្យមានការវិនិយោគ ដែលប្រទេសម្ចាស់ផ្ទះជាច្រើន ពុំអាចបំពេញតែឯកឯងបាននោះឡើយ។បច្ចុប្បន្ននេះ ជំនួយមនុស្សធម៌មិនទាន់បំពេញទៅតាមតម្រូវការរបស់កុមារនោះឡើយ ព្រោះថាជារឿយៗ ជំនួយទាំងនេះនៅមានកំណត់ និងពុំអាចព្យាករណ៍ដឹងមុនបាន។ មូលនិធិអប់រំមិនអាចរង់ចាំបាន ( Education Cannot Wait ) ដែលជាមូលនិធិថ្មី គឺជាយន្តការដ៏សំខាន់ ដើម្បីនាំសេវាទៅដល់ក្រុមងាយរងគ្រោះជាងគេមួយចំនួន។

សារដែលត្រូវបានបញ្ជាក់ក្នុងរបាយការណ៍នេះ គឺជាសារដែលមានភាពច្បាស់លាស់៖ ការវិនិយោគលើការអប់រំរបស់អ្នកដែលកំពុងធ្វើចំណាកស្រុក គឺជាអ្វីដែលនាំឱ្យមានការខុសប្លែកគ្នារវាងការត្រួសត្រាយផ្លូវនាំមកនូវការខកចិត្ត និងការប្រឆាំងបះបោរ និងការត្រួសត្រាយផ្លូវដែលនាំមកនូវភាពចុះសម្រុងគ្នា និងសន្តិភាពក្នុងសង្គម។

Audrey Azoulay<br>
អគ្គនាយក UNESCO



# អារម្ភកថា

របាយការណ៍ពិនិត្យ តាមដានការអប់រំសកល ឆ្នាំ ២០១៩ ត្រូវ បាន រៀបចំឡើងដោយជនចំណាកស្រុកអន្តរជាតិមួយក្រុម។ សមាជិកចំនួនបួននាក់របស់ក្រុមនេះ គឺជាកូនជនភៀសខ្លួន។ ពួកគេមិនជំទាស់ចំពោះការណ៍ដែលមនុស្សមើលមកការធ្វើចំណាកស្រុក និងជនចំណាកស្រុក ចេញពីទស្សនៈយល់ឃើញខុសៗគ្នា នោះឡើយ។ ការស្រាវជ្រាវ របស់ពួកគេ បង្ហាញពីកម្រិត ដែលការអប់រំ អាចជួយឱ្យការយល់ឃើញទាំងនេះកាន់តែបើកចំហជាងមុន និងផ្តល់ឱកាសកាន់តែប្រសើរសម្រាប់ទាំងអស់គ្នា។

សម្រាប់ជនចំណាកស្រុក ជនភៀសខ្លួន និងសហគមន៍ដែលទទួលពួកគេឱ្យរស់នៅមានរឿងដែលគេដឹង និងរឿងដែលគេមិនដឹងជាច្រើន។ ទោះជាយ៉ាងណាក៏ដោយ អ្វីៗគ្រប់បែបយ៉ាងដែលមនុស្សមួយចំនួនដឹង គឺការខ្វះខាត និងភាពចាំបាច់ ដើម្បីរត់គេចពីស្ថានភាព ដែលមានការខ្វះខាតបែបនេះ។ ពួកគេមិនដឹងថាតើនៅកន្លែងមួយទៀតដែលពួកគេចង់ទៅនឹងមានឱកាសសម្រាប់ពួកគេឬអត់នោះឡើយ។នៅតាមសហគមន៍ដែលទទួលអ្នកទាំងនេះ ឱ្យរស់នៅ មនុស្សអាចមិនដឹងថាតើអ្នកជិតខាងពួកគេ ដែលទើបផ្លាស់ចូលមកនៅដែលស្លៀកសម្លៀកបំពាក់ខុសប្លែកពីពួកគេមាន ទំនៀមទម្លាប់ខុសៗគ្នា និងនិយាយជាមួយនឹងការលើកដាក់សំឡេងខុសៗគ្នា និងធ្វើឱ្យជីវិតរបស់ពួកគេមានការផ្លាស់ប្តូរដែរឬទេ ហើយប្រសិនបើមានការផ្លាស់ប្តូរនឹងមានការផ្លាស់ប្តូរដោយរបៀបណានោះឡើយ។

ការធ្វើចំណាកស្រុកកើតឡើងទាំងស្របច្បាប់ ទាំងមិនស្របច្បាប់។ ជារឿយៗ សង្គមត្រូវខិតខំគ្រប់គ្រងការផ្លាស់ទីរបស់ប្រជាជន ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សង្គមនានាអាចជួបប្រទះនឹងលំហូរចូលប្រជាជនក្នុងកម្រិតមួយ ដែលគេពុំអាចព្យាករណ៍ដឹងបានជាមុន។ ការផ្លាស់ទីបែបនេះអាចនាំឱ្យមានបញ្ហាបែកបាក់គ្នា ហើយការផ្លាស់ទីមួយចំនួន បានផ្តល់នូវប្រយោជន៍ដល់ប្រទេសប្រភពដើមផង និងប្រទេសគោលដៅផង។

នៅក្នុងលំហូរជនចំណាកស្រុក យើងសង្កេតឃើញមានការធ្វើចំណាកស្រុកដោយឆន្ទៈខ្លួនឯងផង និងដោយការបង្ខិតបង្ខំផង។មនុស្សមួយចំនួនផ្តួចផ្តើមគំនិតផ្លាស់ប្តូរកន្លែងរស់នៅដើម្បីស្វែងរកការងារធ្វើនិងបន្តការសិក្សា ខណៈពេលដែលមនុស្សមួយចំនួនទៀតត្រូវបានបង្ខំចិត្តរត់គេចពីការធ្វើទុក្ខបុកម្នេញ និងការគំរាមកំហែង ដល់ជីវភាពរស់នៅរបស់ពួកគេ។ សហគមន៍ដែលទទួល ជន ចំណាកស្រុក ឱ្យ រស់នៅ និង អ្នកនយោបាយអាចលើកជាអំណះអំណាងផ្សេងៗគ្នាថា ជនចំណាកស្រុកធ្វើចំណាកស្រុកដោយខ្លួនឯង ឬមានគេបង្ខំឱ្យធ្វើចំណាកស្រុក ធ្វើចំណាកស្រុកដោយស្របច្បាប់ ឬខុសច្បាប់ នាំមកនូវការរីកចម្រើន ឬបង្កជាការគំរាមកំហែងឬជាធនធានឬជាបន្ទុកទៅវិញ។មានការស្វាគមន៍និងការមិនទទួលយកជនចំណាកស្រុកនិងជនភៀសខ្លួនកើតមានទន្ទឹមគ្នា។មនុស្សមួយចំនួនសម្របខ្លួនទៅតាមបរិយាកាសថ្មីខណៈពេលដែលមនុស្សផ្សេងទៀតពុំអាចសម្របខ្លួនបែបនេះឡើយ។មានអ្នកដែលចង់ជួយហើយក៏មានអ្នកដែលចង់ផាត់អ្នកទាំងនេះចេញពីសង្គមពួកគេផងដែរ។

ដូច្នេះនៅជុំវិញពិភពលោកយើងមើលឃើញការធ្វើចំណាកស្រុកនិងការបង្ខំឱ្យចាកចេញពីផ្ទះសម្បែងជាកត្តាដែលបំផុសឱ្យមានរឿងរ៉ាវជាច្រើន។ ទោះជាយ៉ាងណាក៏ដោយ មានការសម្រេចចិត្តដែលត្រូវធ្វើ ការធ្វើចំណាកស្រុក ទាមទារឱ្យមានការឆ្លើយតប។ យើងអាចលើករបាំង ឬយើងអាចបោះដៃទៅម្ខាងទៀត ដើម្បីកសាងទំនុកចិត្តបញ្ចូលជនចំណាកស្រុក និងជនភៀសខ្លួនទៅក្នុងសង្គម និងផ្តល់ការធានាដល់ពួកគេ។

នៅកម្រិតសកល អង្គការសហប្រជាជាតិបានខិតខំកៀរគរប្រមូលផ្តុំបណ្តាប្រជាជាតិនានា ជុំវិញដំណោះស្រាយដែលនៅស្ថិតស្ថេរបានយូរសម្រាប់ឆ្លើយតបចំពោះបញ្ហាប្រឈមដែលបង្កឡើង ដោយការ ធ្វើចំណាកស្រុក និងការបង្ខំឱ្យចាកចេញពីផ្ទះសម្បែង។ ក្នុងអំឡុងកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិស្តីពីជនភៀសខ្លួននិងជនចំណាកស្រុកកាលពីឆ្នាំ២០១៦ខ្ញុំបានអំពាននាវឱ្យមានការវិនិយោគការបង្ការជម្លោះការផ្សះផ្សាអភិបាលកិច្ចល្អ នីតិរដ្ឋ និងដំណើនសេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន។ ខ្ញុំបានទាញការយកចិត្តទុកដាក់ចំពោះភាពចាំបាច់ ក្នុងការពង្រីកលទ្ធភាពទទួលបានសេវាកម្រិតមូលដ្ឋានសម្រាប់ជនចំណាកស្រុក ដើម្បីឆ្លើយតបចំពោះបញ្ហាវិសមភាព។

របាយការណ៍នេះ ធ្វើការពិភាក្សាបន្ថែមទៀតពីចំណុចចុងក្រោយខាងលើ តាមរយៈការក្រើនរំឭកប្រាប់យើងទាំងអស់គ្នាថាការអប់រំមិនត្រឹមជាកាតព្វកិច្ចសីលធម៌របស់អ្នកដែលទទួលខុសត្រូវលើវិស័យអប់រំប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាដំណោះស្រាយ ជាក់ស្តែង សម្រាប់បញ្ហាជាច្រើន ដែលបង្កឡើងដោយសារក្រុមប្រជាជនដែលធ្វើចំណាកស្រុកផងដែរ។ ការអប់រំត្រូវតែ និងជានិច្ចការគួរតែជាផ្នែកមួយដ៏សំខាន់នៃការឆ្លើយតបចំពោះបញ្ហាចំណាកស្រុក និងការបង្ខំឱ្យចាកចេញពីផ្ទះសម្បែង ហើយវាក៏ជាកំនិតមួយដែលដល់ពេលដែលសមនឹងយកការចិត្តទុកដាក់ ដូចដែលបង្ហាញក្នុងខ្លឹមសារកិច្ចព្រមព្រៀងសកលចំនួនពីរស្តីពីជនចំណាកស្រុក និងជនភៀសខ្លួន។

សម្រាប់អ្នកដែលពុំបានទទួលការអប់រំ ការជួបការលំបាក និងការខកចិត្តអាចជាលទ្ធផលដែលកើតឡើង ដោយសារតែការពុំបានទទួលបានការអប់រំបែបនេះ។ នៅពេលដែលពួកគេទទួលបានការបង្រៀនមិនត្រឹមត្រូវការអប់រំអាចបំភាន់ប្រវត្តិសាស្ត្រនិងនាំឱ្យមានការយល់ច្រឡំប៉ុន្តែដូចដែលរបាយការណ៍បង្ហាញប្រាប់យើង ក្នុងទម្រង់ជាឧទាហរណ៍ល្អៗជាច្រើនពីប្រទេសកាណាដា ឆាត កូឡុំប៊ី អៀកឡង់ ឡេបាណន់ ហ្វីលីពីនទួគី និងអ៊ូហ្កាន់ដា ការអប់រំក៏អាចបំពេញតួនាទីជាស្ពាន ចម្លង ផង ដែរ។ ការអប់រំអាចនាំឱ្យមនុស្សសម្រេចសក្តានុពលពេញលេញបំផុតរបស់ខ្លួននិងនាំឱ្យមានការលុបបំបាត់ផ្នត់គំនិតបុរេវិនិច្ឆ័យនិងការរើសអើងជាថ្នូរនឹងការត្រិះរិះពិចារណាល្អិតល្អន់សាមគ្គីភាព និងភាពបើកចំហ។ ការអប់រំអាចជួយដល់អ្នកដែលទទួលរងការឈឺចាប់ និងជាស្ពានចម្លងសម្រាប់អ្នកដែលកំពុងត្រូវការឱកាសជាចាំបាច់។

របាយការណ៍នេះបង្ហាញដោយផ្ទាល់ពីបញ្ហាប្រឈមដ៏ធំមួយ៖ នោះថាតើអាចមានការផ្តល់ការគាំទ្រដល់អ្វីខ្លះដល់គ្រូបង្រៀន ដើម្បីឱ្យពួកគេចេះអនុវត្តបរិយាបន្ន? របាយការណ៍នេះង្ហាញគំនិតយល់ឃើញស៊ីជម្រៅដ៏អស្ចារ្យអំពីមនុស្សជាតិ និងបាតុភូតចំណាកស្រុកដែលកើតមានរាប់ជំនាន់មកហើយ។ ខ្ញុំសូមអញ្ជើញឱ្យអ្នកទាំងអស់គ្នាធ្វើការពិចារណាពីអនុសាសន៍ដែលផ្តល់ក្នុងរបាយការណ៍នេះ និងយកអនុសាសន៍ទៅអនុវត្តជាក់ស្តែង។

លោកជំទាវ Helen Clark
ប្រធានក្រុមប្រឹក្សាភិបាលរៀបបំរបាយការណ៍
ពិនិត្យតាមដាន ការអប់រំជាសកល



# ការធ្វើចំណាកស្រុក ការផ្លាស់ទីលំនៅដោយបង្ខំ និងការអប់រំ

មានរឿងរ៉ាវរំជួលចិត្តជាច្រើន ដែលបង្ហាញការធ្វើចំណាកស្រុក ការផ្លាស់ទីលំនៅដោយបង្ខំ នៅជុំវិញពិភពលោក។ រឿងរ៉ាវដែលបង្ហាញពីមហិច្ឆតា ក្តីសង្ឃឹម ការភ័យខ្លាច ការរំពឹងទុក ភាពប៉ិនប្រសប់ ការសម្រេចបាននូវក្តីប្រាថ្នា ការលះបង់ សេចក្តីក្លាហាន ភាពអំណត់ និងទុក្ខសោករំឭកប្រាប់យើងថា "ការធ្វើចំណាកស្រុកគឺជាការសម្តែងចេញនូវបំណងប្រាថ្នារបស់មនុស្ស ដែលចង់បានសេចក្តីថ្លៃថ្នូរ សុវត្ថិភាព និងអនាគតកាន់តែប្រសើរជាងមុន។ វាគឺជាផ្នែកមួយនៃសង្គមជាផ្នែកមួយនៃកត្តាដែលបង្កើតនូវក្រុមគ្រួសារមនុស្ស"។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើចំណាកស្រុក ការផ្លាស់ទីលំនៅដោយបង្ខំ "ជាប្រភពនៃការបែកបាក់ក្នុងរដ្ឋ និងក្នុងសង្គមមួយ និងរវាងរដ្ឋមួយ និងរដ្ឋមួយទៀត និងរវាងសង្គមមួយ និងសង្គមមួយទៀតផងដែរ... ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការផ្លាស់ទីរបស់អ្នកដែលជួបនឹងការលំបាកក្នុងចំនួនមួយដ៏ច្រើន ដែលក្នុងនោះមានទាំងជនចំណាកស្រុក និងជនភៀសខ្លួនផងដែរ បានក្លាយជាស្រមោលបិទបាំងអត្ថប្រយោជន៍ធំៗ ដែលគេអាចទទួលបានពីការធ្វើចំណាកស្រុក"។

ខណៈពេលដែលការសម្រេចនូវជោគវាសនារួមដែលត្រូវបានដាក់ចេញក្នុងរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០គឺជាការទទួលខុសត្រូវរួមរបស់យើងទាំងអស់គ្នាការធ្វើចំណាកស្រុកការផ្លាស់ទីលំនៅដោយបង្ខំ នៅតែបន្តទទួលបានការឆ្លើយតបជាអវិជ្ជមានមួយចំនួនពីសង្គមសម័យទំនើប។ បញ្ហាទាំងនេះ ត្រូវបានជនឱកាសនិយម ដែលមើលឃើញពីអត្ថប្រយោជន៍ពីការសាងសង់ជញ្ជាំង និងមិនមែនជាការសាងសង់ស្ពានចម្លងប្រើប្រាស់សម្រាប់ប្រយោជន៍របស់ពួកគេ។នៅទីនេះការអប់រំមានតួនាទី "លើកកម្ពស់ការយោគយល់គ្នាការយល់អធ្យាស្រ័យឱ្យគ្នា និងមិត្តភាព រវាងគ្រប់ប្រជាជាតិ គ្រប់ជាតិសាសន៍ និងគ្រប់ក្រុមសាសន៍ទាំងអស់" ដែលនេះជាការប្តេជ្ញាចិត្តដ៏សំខាន់មួយ នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ របាយការណ៍នេះ ពិនិត្យមើលការចំណាកស្រុក និងការខ្វាត់ខ្វាយពីផ្ទះសម្បែង។

របាយការណ៍នេះ ពិនិត្យមើលការធ្វើចំណាកស្រុក និងការផ្លាស់ទីលំនៅដោយបង្ខំតាមរយៈក្រសែភ្នែករបស់គ្រូបង្រៀន និងអ្នកគ្រប់គ្រងការងារអប់រំ ដែលជាអ្នកមើលឃើញទិដ្ឋភាពជាក់ស្តែងក្នុងថ្នាក់រៀន ក្នុងបរិវេណសាលារៀន សហគមន៍ ទីផ្សារការងារ និងសង្គម។ ប្រព័ន្ធអប់រំនៅទូទៅទាំងសកលលោកកំពុងរួបរួមគ្នា តាមរយៈការប្តេជ្ញាចិត្តដើម្បី "ធានានូវការអប់រំប្រកបដោយបរិយាបន្ន សមធម៌ និងគុណភាព និងលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា" និង "មិនទុកនរណាម្នាក់ចោល"។ ដើម្បី ឱ្យសិស្សទាំងអស់សម្រេចតាមការសន្យារបស់ពួកគេ ប្រព័ន្ធចាំបាច់ត្រូវធ្វើការកែសម្រួលទៅតាមតម្រូវការរបស់ពួកគេ ដោយមិនគិតពីសាវតាររបស់ពួកគេនោះឡើយ។ ពួកគេក៏ចាំបាច់ត្រូវឆ្លើយតបចំពោះតម្រូវការរបស់សង្គម ដើម្បីមានភាពធន់ និងសម្របខ្លួនទៅតាមបញ្ហានៃការធ្វើចំណាកស្រុក ការផ្លាស់ទីលំនៅដោយបង្ខំ ជាបញ្ហាប្រឈមមួយចំពោះប្រទេសដែលមានប្រជាជនចំណាកស្រុក និងជនភៀសខ្លួនក្នុងចំនួនច្រើន និងតិចជួបប្រទះដូចៗគ្នា។

ការផ្លាស់ទីរបស់ប្រជាពលរដ្ឋគ្រប់ប្រភេទទាំងអស់ ត្រូវបានលើកឡើងក្នុងរបាយការណ៍នេះ។ ជាមធ្យមក្នុងចំណោមមនុស្ស ៨ នាក់ មានម្នាក់ដែលធ្វើចំណាកស្រុកក្នុងប្រទេស។ ការធ្វើចំណាកស្រុកនេះ អាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ឱកាសទទួលបានការអប់រំរបស់អ្នកដែលធ្វើចំណាកស្រុក និងអ្នកដែលត្រូវបានគេមើលរំលង ជាពិសេសក្នុងប្រទេសចំណូលកម្រិតទាប និងប្រទេសចំណូលមធ្យមដែលកំពុងមានការអភិវឌ្ឍនិងការពង្រីកទីក្រុងយ៉ាងឆាប់រហ័ស។ មានមនុស្សម្នាក់ក្នុងចំណោមមនុស្ស ៣០ នាក់ រស់នៅក្នុងប្រទេស ដែល

មិនមែនជាប្រទេសកំណើតរបស់ពួកគេ។ ជិតពីរភាគបីនៃជនចំណាកស្រុកអន្តរជាតិ មានគោលបំណងធ្វើចំណាកស្រុកទៅកាន់ប្រទេសដែលមានចំណូលខ្ពស់។ ខណៈពេលដែលពួកគេភាគច្រើនធ្វើចំណាកស្រុកដើម្បីធ្វើការងារ ពួកគេមួយចំនួនក៏ធ្វើចំណាកស្រុក ដើម្បីទទួលបានការអប់រំផងដែរ។ លើសពីនេះ ការធ្វើចំណាកស្រុកអន្តរជាតិ ក៏បង្កផលប៉ះពាល់ដល់ការអប់រំកូនៗរបស់ពួកគេផងដែរ។ មានមនុស្សម្នាក់ក្នុងចំណោមមនុស្ស ៨០ នាក់ ការផ្លាស់ទីលំនៅដោយបង្ខំក្នុងប្រទេសរបស់ពួកគេ ឬទៅកាន់ប្រទេសផ្សេងទៀត ដោយសារជម្លោះ ឬគ្រោះមហន្តរាយធម្មជាតិ។ ក្នុងចំណោមអ្នកទាំងនេះ ១០ នាក់ មាន ៩ នាក់ ដែលរស់នៅក្នុងប្រទេសចំណូលទាប និងមធ្យម។ ការបញ្ចូលពួកគេទៅក្នុងប្រព័ន្ធជាតិ មានសារៈសំខាន់យ៉ាងខ្លាំង ប៉ុន្តែក៏ត្រូវមានការកែសម្រួលទៅតាមបរិបទពិសេសនៃការផ្លាស់ទីលំនៅដោយបង្ខំរបស់ពួកគេផងដែរ។

ការធ្វើចំណាកស្រុក ការផ្លាស់ទីលំនៅដោយបង្ខំមានទំនាក់ទំនងជាមួយនឹងការអប់រំជាលក្ខណៈទ្វេទិស ដែលប៉ះពាល់ដល់អ្នកដែលធ្វើចំណាកស្រុកផង អ្នកដែលមិនធ្វើចំណាកស្រុកផង និងអ្នកដែល ឬអាចទទួលយកជនចំណាកស្រុក និងជនភៀសខ្លួនឱ្យស្នាក់នៅផង (**តារាងទី ១**)។ ពេលដែលមនុស្សពិចារណាចង់ធ្វើចំណាកស្រុក ឬធ្វើចំណាកស្រុកក្នុងវដ្តជីវិតរបស់ពួកគេ គឺជាការសំខាន់ ដែលកំណត់ពីការវិនិយោគលើការអប់រំ ការបង្អាក់ការអប់រំ បទពិសោធន៍ និងលទ្ធផលនៃការអប់រំ។ កុមារដែលធ្វើចំណាកស្រុកពីតំបន់ ដែលការអភិវឌ្ឍការអប់រំមានកម្រិតទាប អាចទទួលបានឱកាសដែលមិនមានសម្រាប់ពួកគេ ប្រសិនបើពួកគេមិនធ្វើចំណាកស្រុក។ ជារឿយៗ លទ្ធផលសិក្សារបស់សិស្សចំណាកស្រុក ច្រើនទាបជាងសិស្សដែលរៀនជាមួយនឹងពួកគេក្នុងសហគមន៍ដែលពួកគេធ្វើចំណាកស្រុកទៅ។

## តារាងទី ១៖
### ឧទាហរណ៍មួយចំនួនបង្ហាញពីទំនាក់ទំនងរវាងការអប់រំ និងការធ្វើចំណាកស្រុក / ការផ្លាស់ទីលំនៅដោយបង្ខំ

| | | ផលប៉ះពាល់ នៃការធ្វើចំណាកស្រុក/ ការផ្លាស់ទីលំនៅដោយបង្ខំ លើការអប់រំ | ផលប៉ះពាល់នៃការអប់រំលើការធ្វើចំណាកស្រុក / ការផ្លាស់ទីលំនៅដោយបង្ខំ |
|---|---|---|---|
| ទីកន្លែងដែលជាប្រភពដើម | ជនចំណាកស្រុក | • ការធ្វើចំណាកស្រុកនាំឱ្យមានបញ្ហាប្រឈមពាក់ព័ន្ធនឹងការផ្តល់សេវានៅតាមតំបន់តាំងទីលំនៅមិនរៀបរយ។<br>• ប្រព័ន្ធអប់រំចាំបាច់ត្រូវការកែសម្រួលទៅតាមតម្រូវការរបស់មនុស្សដែលធ្វើចំណាកស្រុកតាមរដូវ ឬធ្វើចំណាកស្រុកយូរៗម្តង | • អ្នកដែលមានការអប់រំកាន់តែខ្ពស់ កាន់តែទំនងជាធ្វើចំណាកស្រុក។ |
| | ជនដែលត្រូវបានគេទុកចោល | • ការធ្វើចំណាកស្រុក ធ្វើឱ្យមានមនុស្សកាន់តែតិចទៅៗក្នុងតំបន់ជនបទ និងបង្កឱ្យមានការលំបាកដល់ការផ្តល់សេវាអប់រំ។<br>• ប្រាក់ដែលផ្ញើមក មានឥទ្ធិពលលើការអប់រំក្នុងសហគមន៍ប្រភពដើម។<br>• អវត្តមានឪពុកម្តាយបង្កផលប៉ះពាល់ដល់កុមារដែលត្រូវបានគេទុកចោល។<br>• លទ្ធផលភាពធ្វើចំណាកស្រុកចេញពីតំបន់ដែលជាដើមកំណើតរបស់ខ្លួន ធ្វើឱ្យគេមិនចង់វិនិយោគលើការអប់រំឡើយ។<br>• កម្មវិធីថ្មីៗអាចធ្វើឱ្យអ្នកដែលមានបំណងចង់ធ្វើចំណាកស្រុកត្រៀមរៀបចំខ្លួន។ | • ការធ្វើចំណាកស្រុកចេញរបស់អ្នកដែលទទួលបានការអប់រំបង្កផលវិបាកដល់ការអភិវឌ្ឍតំបន់ ដែលរងផលប៉ះពាល់ដូចជា តាមរយៈការហូរចេញនូវធនធានមនុស្សជាដើម។ |
| តំបន់គោលដៅ | ជនអន្តោប្រវេសន៍ និងជនភៀសខ្លួន | • ការទទួលបាន និងការសម្រេចបាននូវលទ្ធផលនៃការអប់រំរបស់ជនអន្តោប្រវេសន៍ និងកូនៗរបស់ពួកគេជាធម្មតានៅមានកម្រិតទាបជាងប្រជាជនម្ចាស់ស្រុក។<br>• ចាំបាច់ត្រូវតែមានការបញ្ចូលជនភៀសខ្លួនទៅក្នុងប្រព័ន្ធអប់រំរបស់ជាតិ។<br>• ចាំបាច់ត្រូវតែមានការធានាសិទ្ធិរបស់ជនភៀសខ្លួន ក្នុងការទទួលបានសេវាអប់រំ។ | • ជនចំណាកស្រុក ច្រើនតែមានគុណវុឌ្ឍិខ្ពស់លើសកម្រិតជំនាញរបស់ពួកគេពុំត្រូវបានគេទទួលស្គាល់ប្រើប្រាស់ឱ្យបានពេញលេញ ហើយជីវភាពរស់នៅរបស់ពួកគេមានការប្រែប្រួល។<br>• ការធ្វើអន្តរភាវូពាណិជ្ជកម្មការអប់រំកម្រិតឧត្តមសិក្សា ជាកត្តាជំរុញឱ្យសិស្សធ្វើការផ្លាស់ទីពីប្រទេសមួយទៅប្រទេសមួយទៀត។ |
| | ជនម្ចាស់ស្រុក | • ភាពចម្រុះនៅក្នុងថ្នាក់រៀន ទាមទារឱ្យមានការរៀបចំគ្រូបង្រៀនឱ្យកាន់តែប្រសើរជាងមុន រៀបចំកម្មវិធីផ្តោតចំគោលដៅ ដើម្បីផ្តល់ការគាំទ្រអ្នកដែលទើបមកដល់ថ្មី និងបង្ការមិនឱ្យមានការបំបែកសិស្សទៅតាមប្រភេទ និងត្រូវមានការប្រមូលទិន្នន័យបែងចែកទៅតាមប្រភេទសិស្ស។ | • ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ អាចកសាងនូវសង្គមឱ្យកាន់តែមានភាពធន់ទ្រាំ កាត់បន្ថយបុរេនិច្ឆ័យ និងការរើសអើង។ |

ការធ្វើចំណាកស្រុក និងការផ្លាស់ទីលំនៅដោយបង្ខំតម្រូវឱ្យប្រព័ន្ធសម្របទៅតាមតម្រូវការរបស់អ្នកដែលបានធ្វើចំណាកស្រុក និងអ្នកដែលត្រូវបានគេមើលរំលង។ ប្រទេសនានា ចាំបាច់ត្រូវទទួលស្គាល់ពីសិទ្ធិទទួលបានការអប់រំរបស់ជនចំណាកស្រុក និងជនភៀសខ្លួនក្នុងច្បាប់ និងត្រូវបំពេញសិទ្ធិនេះ ក្នុងការអនុវត្តជាក់ស្តែង។ ប្រទេសទាំងនេះ ចាំបាច់ត្រូវកែសម្រួលសេវាអប់រំសម្រាប់អ្នកដែលរស់នៅកកុញក្នុងតំបន់តាំងទីលំនៅមិនរៀបរយ  អ្នកដែលតែងតែបំលាស់ទី ឬអ្នកដែលរង់ចាំក្លាយខ្លួនជាជនភៀសខ្លួន។ ប្រព័ន្ធអប់រំចាំបាច់ត្រូវតែមានបរិយាបន្ន និងសម្រេចឱ្យបាននូវសមធម៌។ ចាំបាច់ត្រូវមានរៀបចំគ្រូ ដើម្បីឆ្លើយតបចំពោះភាពចម្រុះ និងការប៉ះទង្គិចផ្លូវចិត្តពាក់ព័ន្ធនឹងការធ្វើចំណាកស្រុក និងជាពិសេសការផ្លាស់ទីលំនៅដោយបង្ខំ។ ចាំបាច់ត្រូវធ្វើទំនើបកម្មការទទួលស្គាល់គុណវុឌ្ឍិ និងការរៀនសូត្រកន្លងមក ដើម្បីទាញប្រយោជន៍ឱ្យបានច្រើនបំផុតពីជំនាញរបស់ជនទេសន្តប្រវេសន៍និងជនភៀសខ្លួនដែលរួមចំណែកយ៉ាងសម្បើមដល់វិបុលភាពក្នុងរយៈពេលវែង។

> “ ការធ្វើចំណាកស្រុកនិងការផ្លាស់ទីលំនៅត្រូវការប្រព័ន្ធអប់រំដើម្បីបំពេញតាមតម្រូវការរបស់អ្នកដែលផ្លាស់ទីលំនៅនិងអ្នកដែលនៅសល់ ”

ការអប់រំក៏បង្កផលប៉ះពាល់យ៉ាងច្រើន ដល់ការធ្វើចំណាកស្រុក  និងការផ្លាស់ទីលំនៅដោយបង្ខំផងដែរ  ទាំងក្នុងបរិមាណ ទាំងការយល់ឃើញចំពោះការធ្វើចំណាកស្រុក ការផ្លាស់ទីលំនៅដោយបង្ខំ។ ការអប់រំគឺជាកម្លាំងចលករដ៏ធំមួយ ដែលនាំឱ្យមានការធ្វើសេចក្តីសម្រេចចិត្តធ្វើចំណាកស្រុក   ដើម្បីស្វែងរកជីវិតដែលកាន់តែល្អប្រសើរជាមុន។ វាមានឥទ្ធិពលលើឥរិយាបថ បំណងប្រាថ្នា និងជំនឿរបស់អ្នកធ្វើចំណាកស្រុក និងកម្រិតដែលពួកគេគិតថាខ្លួនឯងជាសមាជិកនៅក្នុងសហគមន៍នៃប្រទេសគោលដៅ។ ការកើនឡើងនូវភាពចម្រុះនៅក្នុងថ្នាក់រៀន ក៏បង្កជាបញ្ហាប្រឈមផងដែរ ដូចជាបញ្ហាប្រឈមសម្រាប់ជនម្ចាស់ស្រុក (ជាពិសេសក្រុមជនក្រីក្រ និងជនដែលបាត់បង់ឱកាស) ប៉ុន្តែវាក៏ផ្តល់ឱកាសឱ្យមានការរៀនសូត្រពីវប្បធម៌ និងបទពិសោធន៍ផ្សេងទៀតផងដែរ។ កម្មវិធីសិក្សាដែលគិតគូរឆ្លើយតបចំពោះឥរិយាបថអវិជ្ជមាន គឺជាប្រភេទកម្មវិធីសិក្សា ដែលគេត្រូវការជាចាំបាច់ជាងពេលណាៗទាំងអស់។

ខណៈពេលដែលការធ្វើចំណាកស្រុក និងការផ្លាស់ទីលំនៅដោយបង្ខំ ក្លាយទៅជាប្រធានបទនយោបាយដ៏ក្តៅគគុក ការអប់រំគឺជាគន្លឹះដ៏សំខាន់ ដើម្បីផ្តល់ឱ្យប្រជាពលរដ្ឋនូវការយល់ដឹងអំពីបញ្ហាដែលពាក់ព័ន្ធ។ ការអប់រំ អាចគាំទ្រដល់ការប្រើប្រាស់ព័ត៌មាន និងជំរុញឱ្យមានភាពចុះសម្រុងក្នុងសង្គម ជាពិសេសនេះជាអ្វីដែលសំខាន់ក្នុងពិភពសកលភាវូបនីយកម្ម។ ទោះជាយ៉ាងណាក៏ដោយ  ការអប់រំគួរមានវិសាលភាពលើសពីការយល់អធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក។ វាគឺជាឧបករណ៍ដែលសំខាន់ ក្នុងការប្រយុទ្ធប្រឆាំងនឹងបុរេនិច្ឆ័យ ផ្នត់គំនិត និងការរើសអើង។ ប្រសិនបើរៀបចំមិនបានល្អ ប្រព័ន្ធអប់រំអាចនាំឱ្យមានការមើលមកជនអន្តោប្រវេសន៍និងជនភៀសខ្លួនដោយអវិជ្ជមាន លម្អៀង ពោពេញដោយផ្នត់គំនិត ឬថាជាក្រុមដែលមិនមានតម្លៃ។

*របាយការណ៍ស្តីពីការពិនិត្យតាមដានការអប់រំជាសកល* ឆ្នាំ ២០១៩ ពិនិត្យមើលកស្តុតាងជាសកលស្តីពីការធ្វើចំណាកស្រុក ការផ្លាស់ទីលំនៅដោយបង្ខំ និងការអប់រំ និងមានគោលបំណងឆ្លើយតបទៅនឹងសំណួរខាងក្រោម៖

- តើការផ្លាស់ទីរបស់ប្រជាជនបង្កផលប៉ះពាល់អ្វីខ្លះ ដល់ការទទួលបានការអប់រំ និងគុណភាពនៃការអប់រំ? តើមានភាពពាក់ព័ន្ធអ្វីខ្លះ ដល់ជនចំណាកស្រុក និងជនភៀសខ្លួនម្នាក់ៗ?
- តើការអប់រំអាចនាំមកនូវភាពល្អប្រសើរក្នុងជីវិតរស់នៅរបស់អ្នក ដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត និងក្នុងសហគមន៍ដែលទទួលគេឱ្យរស់នៅដែរឬទេ?

## ប្រអប់ទី ១៖

**ពិភពលោកកំពុងឆ្លើយតបចំពោះតម្រូវការអប់រំ និងតម្រូវការផ្សេងទៀតរបស់ជនចំណាកស្រុក ជនដែលការផ្លាស់ទីលំនៅដោយបង្ខំ និងក្រុមប្រជាជនម្ចាស់ស្រុក**

ការឆ្លើយតបចំពោះតម្រូវការអប់រំ និងតម្រូវការផ្សេងទៀតរបស់ជនចំណាកស្រុក ជនដែលត្រូវផ្លាស់ទីលំនៅដោយបង្ខំ និងក្រុមប្រជាជនម្ចាស់ស្រុកនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ តម្រូវឱ្យមានការកៀរគរធនធាន និងការសម្របសម្រួលសកម្មភាពនានា។ ពិភពលោកកំពុងផ្លាស់ទីទៅរកទិសដៅនោះ។ កាលពីខែវិច្ឆិកា ឆ្នាំ២០១៦ រដ្ឋជាសមាជិកអង្គការសហប្រជាជាតិចំនួន ១៩៣ បានចុះហត្ថលេខាលើសេចក្តីប្រកាសទីក្រុងញូវយ៉កស្តីពីជនភៀសខ្លួន និងជនចំណាកស្រុក ដើម្បីពង្រឹង និងកែសម្រួលយន្តការចែករំលែកការទទួលខុសត្រូវដាក់ចេញនូវដំណើរការសម្រាប់រៀបចំកិច្ចព្រមព្រៀងជាសកលចំនួនពីរ៖ កិច្ចព្រមព្រៀងមួយស្តីពីទេសន្តប្រវេសន៍ និងកិច្ចព្រមព្រៀងមួយទៀតស្តីពីជនភៀសខ្លួន។

សេចក្តីព្រៀងកិច្ចព្រមព្រៀងជាសកល ស្តីពីការធ្វើទេសន្តប្រវេសន៍ប្រកបដោយសុវត្ថិភាព សណ្តាប់ធ្នាប់ និងទៀងទាត់ បានយកបញ្ហាភាគច្រើន ដែលត្រូវបានលើកឡើងក្នុងរបាយការណ៍នេះ ទៅដាក់ក្នុងរបៀបវារៈ។ កិច្ចព្រមព្រៀងនេះគ្របដណ្តប់លើលទ្ធភាពទទួលបានសេវាជាមូលដ្ឋាន ដូចជា សេវាអប់រំទាំងក្នុងសាលារៀន ទាំងក្រៅសាលារៀន។ បើទោះបីជាមានការផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនជាងមុន នូវការទទួលស្គាល់ជំនាញយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងនេះបញ្ជូនសញ្ញាជាវិជ្ជមាន អំពីការអប់រំដោយចាត់ទុកថាការអប់រំជាឱកាស ដើម្បីឱ្យមានការទាញប្រយោជន៍ឱ្យបានច្រើនបំផុតពីលំហូរទេសន្តប្រវេសន៍។ ហើយបើទោះបីជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងនេះ ពុំមែនជាកិច្ចព្រមព្រៀងចងកាតព្វកិច្ចនោះឡើយ ហើយនៅបើកចំហពីវិធីសាស្ត្រ ដែលប្រទេសនានា អាចបំពេញទៅតាមការប្តេជ្ញាចិត្តទាំងនេះបាន។

ការផ្តល់ការអប់រំដល់ជនដែល ផ្លាស់ទីលំនៅដោយបង្ខំ ទាមទារឱ្យមានការគាំទ្របន្ថែម ដើម្បីជួយឱ្យពួកគេសម្របខ្លួនតាមបរិយាកាសថ្មី និងដោះស្រាយបញ្ហាផ្លាស់ទីលំនៅដោយបង្ខំដែលអូសបន្លាយក្នុងរយៈពេលយូរ។ បើទោះបីជាសិទ្ធិទទួលបានការអប់រំជនភៀសខ្លួនក្នុងប្រទេសម្ចាស់ស្រុក ត្រូវបានធានាក្នុងអនុសញ្ញាសហប្រជាជាតិ ពាក់ព័ន្ធនឹងស្ថានភាពជនភៀសខ្លួនឆ្នាំ ១៩៥១ យ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងសកលស្តីពីជនភៀសខ្លួនមានគោលបំណងបង្កើតដាក់ចេញនូវការប្តេជ្ញាចិត្តនេះសារជាថ្មីម្តងទៀត។ ពង្រាងចុងក្រោយនៃកិច្ចព្រមព្រៀងនេះ មានកថាខណ្ឌចំនួនពីរស្តីពីការអប់រំ ផ្តោតលើការផ្តល់ហិរញ្ញប្បទាន និងការប្រើប្រាស់ការអប់រំ ដើម្បីគាំទ្រដល់គោលនយោបាយជាក់លាក់។ កិច្ចព្រមព្រៀងនេះ បញ្ជាក់យ៉ាងច្បាស់ពីភាពចាំបាច់នៃការរៀបចំគោលនយោបាយជាតិ ស្តីពីបរិយាបន្ន។

# ចំណាកស្រុកក្នុងប្រទេស

ប្រជាជនប្រមាណ ៧៦៣ លាននាក់ រស់នៅក្រៅតំបន់ដែលជាទីកន្លែងកំណើតរបស់ខ្លួន។ ក្នុងចំណោមចលនាចំណាកស្រុកនានាជាច្រើនដូចជា ចំណាកស្រុកអចិន្ត្រៃយ៍ ឬចំណាកស្រុកបណ្តោះអាសន្ន ចំណាកស្រុកនៅក្នុងរង្វង់ ឬចេញពីតំបន់ប្រជុំជន និងជនបទជាដើម យើងឃើញថាលំហូរប្រជាជននៅក្នុងចំណាកស្រុកពីទីជនបទទៅទីប្រជុំជន និងលំហូរតាមរដូវ ឬក្នុងលក្ខណៈជាវដ្តវិលជុំ ច្រើនតែបង្កឱ្យមានបញ្ហាប្រឈមធំជាងគេបំផុតសម្រាប់ប្រព័ន្ធអប់រំ។

> “ប្រជាជនប្រមាណ ៧៦៣ លាននាក់រស់នៅក្រៅតំបន់ជាទីកន្លែងកំណើតរបស់ខ្លួន។”

ថ្វីបើចំណាកស្រុកសំខាន់ៗពីតំបន់ជនបទ ទៅតំបន់ទីប្រជុំជន ដែលអមមកជាមួយនូវ កំណើនសេដ្ឋកិច្ចក្នុងសតវត្សទី ១៩ ដល់ពាក់កណ្តាលសតវត្សទី ២០ កើតមានក្នុងបណ្តាប្រទេសមានចំណូលខ្ពស់ក្តី ប៉ុន្តែការផ្លាស់ទីរបស់ប្រជាជនក្នុងផ្ទៃប្រទេសធំជាងគេបំផុតនាពេលបច្ចុប្បន្ន កើតមានក្នុងបណ្តាប្រទេសមានចំណូលមធ្យម ជាពិសេសគឺប្រទេសចិន និងប្រទេសឥណ្ឌា។ នៅក្នុងអនុតំបន់សាហារ៉ានៃទ្វីបអាហ្វ្រិក ចំណាកស្រុកពីទីជនបទទៅទីប្រជុំជន ក៏បានធ្វើឱ្យការធ្វើផែនការអភិវឌ្ឍន៍ទីក្រុងជួបការលំបាកផងដែរ។ អត្រាចំណាកស្រុក គឺមានកម្រិតផ្សេងៗគ្នាទៅតាមអាយុរបស់ប្រជាជន ហើយច្រើនតែឡើងខ្ពស់បំផុតនៅក្នុងចំណោមប្រជាជនក្នុងអាយុខ្ទង់ ២០ ឆ្នាំ។ បើមើលចេញពីទស្សនវិស័យអប់រំ ការធ្វើចំណាកស្រុកក្នុងប្រទេស ប៉ះពាល់តិចតួចប៉ុណ្ណោះ ចំពោះកុមារក្នុងអាយុសិក្សានៅថ្នាក់បឋមសិក្សា ហើយប៉ះពាល់ចំពោះយុវជនក្នុងអាយុសិក្សាថ្នាក់មធ្យមសិក្សាច្រើនជាងកុមារនៅថ្នាក់បឋមសិក្សាបន្តិច។ម្យ៉ាងទៀតការអប់រំនៅតំបន់ទីប្រជុំជនដែលមានគុណភាពប្រសើរជាងនៅទីជនបទ គឺជាមូលហេតុធំជាងគេបំផុតធ្វើឱ្យមានចំណាកស្រុករបស់ប្រជាជនវ័យក្មេង។ នៅប្រទេសថៃ យុវជន ២១% និយាយថា ពួកគេបានធ្វើការចំណាកស្រុកដើម្បីទទួលបានការអប់រំ។

អ្នកមានការអប់រំច្រើនតែងផ្លាស់ទីដោយសង្ឃឹមថាពួកគេនឹងបានទទួលចំណូលកាន់តែខ្ពស់ពីការអប់រំរបស់ខ្លួននៅកន្លែងផ្សេង (រូបភាពទី ១)។ ចំណូលចិត្ត និងក្តីប្រាថ្នាដែលជាលទ្ធផលកើតចេញពីការអប់រំ ក៏ជំរុញឱ្យមនុស្សចាកចេញពីតំបន់ជនបទដែរ មិនថាសក្តានុពលនៃការរកចំណូលមានលក្ខណៈបែបណាក្តី។ ក្នុងចំណោមប្រទេសចំនួន ៥៣ បើប្រៀបធៀបជាមួយអ្នកពុំមានការអប់រំ លទ្ធភាពនៃការធ្វើចំណាកស្រុកកើនឡើងពីរដងក្នុងចំណោមអ្នកមានការអប់រំថ្នាក់បឋមសិក្សា កើនឡើងបីដងក្នុងចំណោមអ្នកមានការអប់រំថ្នាក់មធ្យមសិក្សា និងកើនឡើងបួនដងក្នុងចំណោមអ្នកមានដែលសិក្សានៅថ្នាក់ឧត្តមសិក្សា។

## រូបភាពទី ១៖

**អ្នកមានការអប់រំកាន់តែខ្ពស់ច្រើនតែធ្វើចំណាកស្រុកកាន់តែច្រើន**

អត្រាភាពខ្លាំងក្លានៃការធ្វើចំណាកស្រុកយោងទៅតាមការអប់រំក្នុងប្រទេសដែលត្រូវបានជ្រើសរើសក្នុងចន្លោះរយៈពេលរៀងរាល់ប្រាំឆ្នាំម្តង ចាប់ពីឆ្នាំ ១៩៩៩-២០១០




GEM StatLink: http://bit.ly/fig2_3

ប្រភព៖ Bernard et al. (2018).




ច្រើនតែធ្វើចំណាកស្រុកពីតំបន់ជនបទទៅតំបន់ទីក្រុងលើសពីអ្នកគ្មានការអប់រំសោះ

# ចំណាកស្រុកជួយធ្វើឱ្យលទ្ធផលការអប់រំមានភាពប្រសើរឡើងសម្រាប់មនុស្សមួយចំនួន ប៉ុន្តែពុំមែនសម្រាប់មនុស្សគ្រប់រូបឡើយ

ចំណាកស្រុកពីតំបន់ជនបទទៅតំបន់ទីក្រុង អាចជួយបង្កើនលទ្ធផលជោគជ័យក្នុងការអប់រំ ក្នុងបណ្តាប្រទេសដែលលទ្ធភាពទទួលបានការអប់រំមានកម្រិតទាបនៅក្នុង តំបន់ជនបទ។ ក្នុងចំណោមមនុស្សមួយក្រុមកើតនៅស្រុកជនបទដែលត្រូវបានជ្រើសរើសក្នុងប្រទេសឥណ្ឌូណេស៊ី អ្នកដែលធ្វើចំណាកស្រុកទៅកាន់ទីក្រុងតាំងពីកុមារ សម្រេចបានការអប់រំចំនួនបីឆ្នាំច្រើនជាងអ្នកដែលពុំបានធ្វើចំណាកស្រុកទៅទីក្រុង។

ទោះយ៉ាងណាក្តី កុមារចំណាកស្រុកជួនកាលមិនអាចទទួលបានលទ្ធផលផ្នែកការអប់រំ ដូចមិត្តភក្តិរបស់ខ្លួនឡើយ។ នៅប្រទេសប្រេស៊ីល ក្នុងចំណោមមនុស្សវ័យជំទង់កើតនៅឆ្នាំ ២០០០/០១ ក្នុងតំបន់ភាគឦសាន្ត អ្នកដែលបានធ្វើចំណាកស្រុកក្នុងអំឡុងពេលរៀនថ្នាក់មធ្យមសិក្សា មានអត្រារីកចម្រើនអន់ជាងអ្នកដែលមិនបានធ្វើចំណាកស្រុក។ ឱកាសការអប់រំរបស់កុមារដែលរងផលប៉ះពាល់ដោយការធ្វើចំណាកស្រុកក្នុងប្រទេសអាចត្រូវថមថយដោយសារមូលហេតុជាច្រើន រាប់ចាប់តាំងពីស្ថានភាពផ្នែកច្បាប់មិនទៀងទាត់ រហូតដល់ភាពក្រីក្រ ការយកចិត្តទុកដាក់របស់រដ្ឋាភិបាលមិនគ្រប់គ្រាន់ ភាពលម្អៀង និងផ្នត់គំនិតសង្គម។

## ការទប់ស្កាត់ចំណាកស្រុកក្នុងប្រទេស ជះឥទ្ធិពលលើលទ្ធភាពទទួលបានការអប់រំ

ក្នុងបណ្តាប្រទេសជាច្រើន ក្តីភ័យខ្លាចចំពោះនគរូបនីយកម្មមិនមានចីរភាព និងអតុល្យភាពរវាងតំបន់ជនបទជាមួយទីក្រុង បានជំរុញឱ្យមានគោលនយោបាយរឹតបន្តឹងដល់ការធ្វើចំណាកស្រុក ដែលក្នុងករណីមួយចំនួនអាចជះឥទ្ធិពលដល់លទ្ធភាពរបស់ជនចំណាកស្រុកក្នុងការទទួលបានការអប់រំ។ ប្រព័ន្ធហូខៅ (*ho-khau*) របស់វៀតណាម បានរឹតត្បិតលទ្ធភាពរបស់ជនចំណាកស្រុកមិនឱ្យទទួលបានការអប់រំសាធារណៈ ហើយជនចំណាកស្រុកក្រីក្រពីទីជនបទទៅកាន់ទីក្រុង បានផ្លាស់ទីទៅកាន់តំបន់ដែលមានសេវាសាលារដ្ឋពុំគ្រប់គ្រាន់។ កំណែទម្រង់នាពេលថ្មីៗនេះ មានគោលបំណងលុបបំបាត់ការរឹតបន្តឹងនេះ ប៉ុន្តែកេរ្តិ៍ដំណែលនៃគោលនយោបាយនាពេលអតីតកាល នៅតែធ្វើឱ្យជនចំណាកស្រុកជួបការលំបាកដោយសារស្ថានភាពរស់នៅបណ្តោះអាសន្នរបស់ខ្លួន។

ប្រព័ន្ធចុះបញ្ជីហ៊ុខូវ (*hukou*) របស់ចិនដែលតភ្ជាប់លទ្ធភាពទទួលបានសេវាទៅជាមួយទីកន្លែងកំណើតដែលបានចុះបញ្ជី បានផាត់កុមារចំណាកស្រុកពីទីជនបទមិនឱ្យមានឱកាសចូលរៀនក្នុងសាលាសាធារណៈ។ នាពេលថ្មីៗនេះ មានការកែសម្រួលឡើងវិញគួរជាទីកត់សម្គាល់។ នៅឆ្នាំ ២០០៦ រដ្ឋាភិបាលតម្រូវឱ្យអាជ្ញាធរមូលដ្ឋាន ត្រូវផ្តល់ការអប់រំដល់កុមារចំណាកស្រុក។ រដ្ឋាភិបាលបាន លុបបំបាត់ថ្លៃបង់សាលាសម្រាប់សាលារៀនសាធារណៈចំពោះកុមារចំណាកស្រុកពីទីជនបទក្នុងឆ្នាំ ២០០៨ និង បានចាប់ផ្តើមបំបែកការចុះបញ្ជីលំនៅដ្ឋានចេញពីលទ្ធភាពទទួលបានសេវាក្នុងឆ្នាំ ២០១៤។ ចាប់ពីឆ្នាំ ២០១៦ មក រដ្ឋាភិបាលចិនបានសុំឱ្យក្រុងទាំងអស់ លើកលែងតែទីក្រុងធំៗជាងគេបំផុត ត្រូវជួយបន្ធូរការរឹតបន្តឹងនេះបន្ថែមទៀត។

ទោះជាយ៉ាងណាក្តី ឧបសគ្គក្នុងការទទួលបានការអប់រំនៅតែបន្តកើតមានចំពោះជនចំណាកស្រុក។ ការតម្រូវឱ្យមានឯកសារ និងការចុះឈ្មោះនានា អាចធ្វើឱ្យលទ្ធភាពទទួលបានសេវាអប់រំ មានកម្រិតកំណត់។ នៅទីក្រុង ប៉េកាំង ជនចំណាកស្រុកត្រូវការលិខិតបញ្ជាក់ចំនួន ៥ ប្រភេទដើម្បីចុះឈ្មោះចូលរៀនក្នុងសាលារដ្ឋ។ គ្រូបង្រៀនអាចមានទស្សនៈរើសអើងចំពោះយុវជនចំណាកស្រុក។

គ្រូបង្រៀននៅសាលារៀនរបស់ជនចំណាកស្រុកដែលគ្មានការអនុញ្ញាតត្រឹមត្រូវ អាចជួបបញ្ហាប្រាក់ឈ្នួលទាបនិងខ្វះសន្តិសុខការងារហើយជារឿយៗឪពុកម្តាយតែងត្អូញត្អែរអំពីបញ្ហាគុណភាពគ្រូនៅក្នុងសាលារៀនទាំងអស់នេះ។

## កុមារដែលត្រូវបានទុកចោលនៅស្រុកកំណើត ជួបប្រទះបញ្ហាប្រឈមជាក់លាក់ផ្នែកការអប់រំ

ការធ្វើចំណាកស្រុកក៏ប៉ះពាល់ដល់ការអប់រំរបស់កុមាររាប់លាននាក់ដែលត្រូវបានទុកនៅស្រុកកំណើតជាមួយឪពុកឬម្តាយឬសមាជិកគ្រួសារដទៃទៀតផងដែរ។ក្នុងប្រទេសកម្ពុជាកុមារដែលត្រូវបានទុកឱ្យនៅស្រុកកំណើត ជាពិសេសគឺក្មេងស្រី ច្រើនតែបោះបង់ចោលការសិក្សា។

*របាយការណ៍អភិវឌ្ឍន៍គ្រួសារចិនឆ្នាំ ២០១៥* បានប៉ាន់ប្រមាណថា មានកុមារជនបទចំនួនប្រមាណ ៣៥%ដែលត្រូវបានទុកឱ្យនៅស្រុកកំណើត។ ភស្តុតាងអំពីឥទ្ធិពលនៃចំណាកស្រុកមកលើការអប់រំ និងសុខុមាលភាពរបស់កុមារ ដែលត្រូវបានទុកឱ្យនៅស្រុកកំណើតគឺ មានទាំងទិដ្ឋភាពល្អផង និងអាក្រក់ផងចម្រុះគ្នា។ ការសិក្សាមួយចំនួនបង្ហាញផលប៉ះពាល់ជាវិជ្ជមានលើលទ្ធផលសិក្សារៀនសូត្រ ប៉ុន្តែ ការសិក្សាមួយចំនួនទៀតបង្ហាញថា កុមារដែលត្រូវបានទុកឱ្យនៅស្រុកកំណើតមានពិន្ទុទាប និងបញ្ហាសុខភាពផ្លូវចិត្តច្រើនជាងមិត្តភក្តិរបស់គេ។

ចាប់ពីឆ្នាំ២០១៦មក ប្រទេសចិនបានបង្កើតឱ្យមានគោលនយោបាយដែលមានគោលដៅកែលម្អការថែទាំកុមារដែលត្រូវបានទុកឱ្យនៅស្រុកកំណើត រួមទាំងការអំពាវនាវឱ្យរដ្ឋាភិបាលមូលដ្ឋាន ជួយជំរុញឪពុកម្តាយឱ្យចាត់តាំងអាណាព្យាបាលសម្រាប់កុមារទាំងនោះ។ សាលារៀនផ្តល់កន្លែងស្នាក់នៅពេញមួយថ្ងៃ គឺជាយុទ្ធសាស្ត្រគន្លឹះមួយ ប៉ុន្តែជារឿយៗស្ថាប័នទាំងនេះ ច្រើនតែមានបុគ្គលិក និងបរិក្ខារមិនគ្រប់គ្រាន់។ ការបណ្តុះបណ្តាល សម្រាប់បុគ្គលិករដ្ឋបាលដើម្បីកែលម្អការគ្រប់គ្រង គឺមានភាពចំបាច់ណាស់សម្រាប់ការកែលម្អសុខុមាលភាពកុមារ។

នៅមានកង្វះខាតស្ថិតិស្តីពីសាលារៀនផ្តល់ការស្នាក់នៅពេញមួយថ្ងៃ និងសិស្សក្នុងសាលាទាំងនេះ បើទោះបីជាសាលាទាំងនេះមានច្រើនសន្ធឹកសន្ធាប់ក្នុងប្រទេសមួយចំនួនក្តី។ក្នុងប្រទេសអ៊ូហ្គង់ដា ( Uganda ) សមាមាត្រនៃសិស្សនៅក្នុងសាលារៀនផ្តល់ការស្នាក់នៅពេញមួយថ្ងៃមានចំនួនប្រមាណ ១៥% គិតត្រឹមអាយុ ១៣ ឆ្នាំ ហើយឡើងទៅដល់ ៤០% នៅក្នុងឆ្នាំសិក្សាចុងក្រោយនៃការអប់រំថ្នាក់មធ្យមសិក្សាទុតិយភូមិ។

## ចំណាកស្រុកស្វែងរកការងារធ្វើតាមរដូវជះឥទ្ធិពលដល់ឱកាសការអប់រំ

> ក្នុងឆ្នាំ ២០១២ កុមារប្រមាណ ១៧,២ លាននាក់ មានអាយុចាប់ពី ៥ ដល់១៧ ឆ្នាំ ធ្វើការងារតាមផ្ទះដែលមានប្រាក់ឈ្នួល ឬគ្មានប្រាក់ឈ្នួលនៅក្នុងផ្ទះរបស់និយោជក។

ចំណាកស្រុកតាមរដូវដែលជាយុទ្ធសាស្ត្ររស់រានសម្រាប់ជនក្រីក្រ អាចរំខានដល់ការអប់រំ និងធ្វើអោយកុមារត្រូវប្រឈមមុខជាមួយពលកម្មកុមារ និងគ្រោះថ្នាក់នៅកន្លែងការងារ។ ក្នុងប្រទេសឥណ្ឌា ការសិក្សាមួយបានបង្ហាញថាប្រមាណ ៨០% នៃកុមារចំណាកស្រុកបណ្ដោះអាសន្នក្នុងក្រុងចំនួនប្រាំពីរ ខ្វះលទ្ធភាពទទួលបានការអប់រំនៅក្បែរការដ្ឋានការងារ ហើយកុមារ ៤០% បានធ្វើការងារ ជួបបទពិសោធន៍ការរំលោភបំពាន និងការកេងប្រវ័ញ្ចន៍។ ការផ្ដួចផ្ដើមគំនិតថ្មីៗ របស់រដ្ឋាភិបាលថ្នាក់ជាតិរបស់ឥណ្ឌា ក្នុងបំណងធានាឱ្យមានវត្តមានទៀងទាត់នៅសាលារបស់កុមារចំណាកស្រុកតាមរយៈការលើកទឹកចិត្តឱ្យមានការចុះឈ្មោះចូលរៀន ដែលមានលក្ខណៈបត់បែន ការផ្ដល់ការអប់រំចល័ត និងការបង្កើនការសម្របសម្រួលឱ្យកាន់តែប្រសើររវាងរដ្ឋបញ្ជូន និងរដ្ឋទទួល ប៉ុន្តែនៅមានបញ្ហាប្រឈមជាច្រើនក្នុងការអនុវត្ត។ កម្មវិធីអនុវត្តសាកល្បងក្នុងរដ្ឋ Rajasthan ឆ្នាំ ២០១០-២០១១ នៅការដ្ឋានឡឥដ្ឋ បានជួបបញ្ហាអវត្តមានរបស់គ្រូ និងសិស្សដ៏ច្រើនសន្ធឹកសន្ធាប់ អាស្រ័យដោយលក្ខខណ្ឌបង្រៀន និងរៀនសូត្រអន់ខ្សោយ និងសេចក្តីត្រូវការឱ្យសិស្សធ្វើការងារ។

## កុមារជាអ្នកធ្វើការងារតាមផ្ទះមានភាពងាយរងគ្រោះចំពោះការផ្ដាច់ចេញពីការអប់រំ

ក្នុងឆ្នាំ ២០១២ កុមារប្រមាណ ១៧,២ លាននាក់មានអាយុចាប់ពី ៥ ដល់១៧ ឆ្នាំ ធ្វើការងារតាមផ្ទះដែលមានប្រាក់ឈ្នួលឬគ្មានប្រាក់ឈ្នួលនៅក្នុងផ្ទះរបស់និយោជក។២ ភាគ ៣ នៃកុមារទាំងអស់នេះ គឺជាក្មេងស្រី។ ក្មេងស្រីតូចៗ ឧទាហរណ៍ ដូចជានៅលីម៉ាជាដើម មើលឃើញការងារតាមផ្ទះថាជាវិធីដើម្បីចាកចេញពីតំបន់ជនបទ និងបន្តការអប់រំ ប៉ុន្តែនៅទីបំផុតបន្ទុកការងាររបស់ពួកគេជារឿយៗ តែងរារាំងមិនឱ្យពួកគេអាចចូលរួមរៀនសូត្របាន។

ការចិញ្ចឹមបីបាច់ដោយឪពុកម្ដាយធម៌ គឺជាយុទ្ធសាស្ត្រដែលគេនិយមប្រើនៅក្នុងបណ្ដាប្រទេសអាហ្វ្រិកជាច្រើន។ ជិត ១០% នៃកុមារសេណេហ្គាល់ (Senegalese) ត្រូវបានទទួលចិញ្ចឹមដោយឪពុកម្ដាយធម៌។ ស្របពេលដែលក្មេងប្រុសច្រើនតែត្រូវបានបញ្ជូន ទៅកាន់គ្រួសារដែលសង្កត់ធ្ងន់ខ្លាំងលើការអប់រំ ជាហេតុធ្វើឱ្យពួកគេបានទទួលការអប់រំច្រើនជាងបងប្អូនបង្កើតរបស់ខ្លួន ក្មេងស្រីក្នុងចំនួនប្រមាណ ៤ ដង តិចជាងក្មេងប្រុស ច្រើនតែត្រូវជួយកិច្ចការងារផ្ទះរបស់ម្ចាស់ផ្ទះ ហើយច្រើនតែមិនត្រូវបានទទួលយកទៅចិញ្ចឹម ដោយសារមូលហេតុការអប់រំឡើយ។

## តម្រូវការផ្នែកការអប់រំរបស់ប្រជាជនពនេចរ និងប្រជាជនផ្លាស់ទីតាមហ្វូងសត្វចិញ្ចឹមពុំត្រូវបានឆ្លើយតបទេ

ការផ្លាស់ទី គឺជាផ្នែកកាត់ផ្តាច់ចេញមិនបានពីជីវិតរបស់ប្រជាជនពនេចរ និងប្រជាជនផ្លាស់ទីតាមហ្វូងសត្វចិញ្ចឹម ហើយអន្តរាគមន៍ ចំបាច់ត្រូវទទួលស្គាល់សេចក្តីត្រូវការរបស់ពួកគេ។ អត្រាការចុះឈ្មោះចូលរៀនរបស់ពួកគេ ច្រើនតែមានកម្រិតទាប ដោយមានភាពឡើងចុះតាមរដូវគួរជាទីកត់សម្គាល់ ហើយសិស្សជួបការលំបាកក្នុងការអភិវឌ្ឍជំនាញអក្ខរកម្ម និងជំនាញលេខនព្វន្ត នៅក្នុងកម្រិតដូចគ្នាជាមួយមិត្តរួមថ្នាក់របស់គេ។ ក្នុងប្រទេសម៉ុងហ្គោលី កង្វះខាតមូលនិធិ បានធ្វើឱ្យសាលាផ្តល់ការស្នាក់នៅពេញមួយថ្ងៃ *soum* ដែលផ្តល់ចំណីអាហារដល់ប្រជាជនពនេចរ មានភាពចុះខ្សោយ ជាលទ្ធផលធ្វើឱ្យមានគម្លាតផ្នែកការរៀនសូត្ររវាងកុមារពនេចរ និងកុមារមិនពនេចរ។

ប្រទេសជាច្រើនដែលមានប្រជាជនពនេចរ ឬប្រជាជនផ្លាស់ទីតាមហ្វូងសត្វចិញ្ចឹមក្នុងចំនួនច្រើន មាននាយកដ្ឋាន គណៈកម្មាធិការ ឬ ក្រុមប្រឹក្សាជាច់ដោយឡែករបស់រដ្ឋាភិបាល ដូចជានាយកដ្ឋានអប់រំសម្រាប់ជនពនេចរក្នុងប្រទេសស៊ូដង់ជាដើម។ កិច្ចខិតខំផ្តោតការយកចិត្តទុកដាក់លើការកែសម្រួលការអប់រំឱ្យស្របទៅតាមរដូវ និងការផ្លាស់ទី ឧទាហរណ៍មានដូចជា សាលារៀនផ្តល់កន្លែងស្នាក់នៅ និងសាលារៀនចល័តជាដើម។

ក្នុងប្រទេសនីហ្សេរីយ៉ា *almajiri* ("សិស្សចំណាកស្រុកដែលមានចំណេះដឹងផ្នែកសាសនាឥស្លាម") ជាច្រើន គឺជាក្រុមពនេចរផ្លាស់ទីតាមហ្វូងសត្វ។ នៅរដ្ឋខាណូ (Kano) អន្តរាគមន៍មួយដែលផ្តោតគោលដៅលើគ្រូបង្រៀនតាមបែបប្រពៃណីចំនួន ៧០០ នាក់ បានផ្តោតការយកចិត្តទុកដាក់លើការធ្វើឱ្យមានការចូលរួមជាមួយសហគមន៍ និងកិច្ចសហការដើម្បីជ្រើសរើសគ្រូបង្រៀនលើមុខវិជ្ជាពុំមែនបែបសាសនា។

បណ្តាញសាលារៀនដែលសិស្សអាចចេញនិងចូលនៅពេលណាឬកន្លែងណាក៏បានអាចជាដំណោះស្រាយប្រកបដោយសក្តានុពលមួយ ប៉ុន្តែក៏ប្រាកដជាទាមទារឱ្យមានប្រព័ន្ធតាមដានប្រកបដោយប្រសិទ្ធិផល និងប្រសិទ្ធិភាពខ្ពស់។ ប្រទេសមួយចំនួន រួមទាំងប្រទេសកេនយ៉ា និងសូម៉ាលីផងដែរ បានធ្វើឱ្យគ្រូត្រូវចល័តកាន់តែខ្លាំងឡើង ដោយពួកគាត់ត្រូវធ្វើដំណើរជាមួយប្រជាជនពនេចរដើម្បីផ្តល់ការអប់រំ។

ការអប់រំសម្រាប់ប្រជាជនពនេចរគួរត្រូវបានទទួលស្គាល់និងឱ្យតម្លៃវិថីជីវិតរបស់ពួកគេ។ការអប់រំវិជ្ជាជីវៈសម្រាប់បែបបទជីវិតបែបពនេចរ អាចមានភាពពាក់ព័ន្ធជាពិសេសចំពោះប្រជាជនចិញ្ចឹមសត្វជាហ្វូង ដែលផ្លាស់ទីតាមហ្វូងសត្វ។ អង្គការស្បៀងអាហារ និងកសិកម្ម (Food and Agriculture Organization) នៃអង្គការសហប្រជាជាតិ បានចាប់ផ្តើមការងារជាមួយសហគមន៍ពនេចរដែលជាអ្នកផ្លាស់ទីតាមហ្វូងសត្វ ទៅលើប្រធានបទស្តីពីសាលារៀនទីវាលរបស់អ្នកចិញ្ចឹមសត្វក្នុងប្រទេសជីប៊ូទី,អេត្យូពី,កេនយ៉ា,ស៊ូដង់ខាងត្បូង និងអ៊ូហ្គង់ដា តាំងពីឆ្នាំ ២០១២ មក ដោយមានវគ្គសិក្សាផ្តោតការយកចិត្តទុកដាក់លើប្រសិទ្ធិភាពការគ្រប់គ្រងបសុសត្វ និងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

### ក្រុមជនជាតិដើមភាគតិចជួបការលំបាកក្នុងការរក្សាអត្តសញ្ញាណរបស់ខ្លួននៅក្នុងទីក្រុង

នៅកន្លែងជាច្រើន ការអប់រំសម្រាប់ជនជាតិដើមភាគតិច គឺរួមមានទាំងការបង្ខំឱ្យមកប្រមូលផ្តុំចម្រុះគ្នា តាមរយៈការទៅសាលារៀន។ កេរដំណែលនេះ ត្រូវបានធ្វើឱ្យអាក្រក់ទៅឡើងដោយសារភាពក្រីក្រ និងចំណាកស្រុកមកកាន់តំបន់ទីប្រជុំជន ដែលជារឿយៗតែងមានន័យថា ជាការរិចរឹលវប្បធម៌ ការបាត់បង់ភាសា និងការរើសអើងបន្ថែមទៀត។ ការបាត់បង់ភាសា គឺជាបញ្ហាដ៏ធំមួយសម្រាប់ប្រជាជនជនជាតិដើមភាគតិចនៅទីប្រជុំជន។ មនុស្សជំនាន់ក្រោយនៅក្នុងទីក្រុងរបស់ប្រទេសអេក្វាទ័រ ម៉ិកស៊ិក និងប៉េរូ ច្រើនតែមិនសូវនិយាយភាសាជនជាតិដើមភាគតិចក្នុងចំនួនគួរជាទីកត់សម្គាល់ ប្រសិនបើធៀបជាមួយអ្នករស់នៅក្នុងតំបន់ទីប្រជុំជន។

ក្របខ័ណ្ឌការងារ ផ្នែកនិយ័តកម្មលើសិទ្ធិជនជាតិដើមភាគតិច លើកឡើងតិចតួចប៉ុណ្ណោះ អំពីជនជាតិដើមភាគតិចរស់នៅក្នុងទីក្រុង។ ជាង ៥០% នៃប្រជាជនជនជាតិដើមភាគតិចរបស់កាណាដារស់នៅក្នុងទីក្រុង។ ការវិភាគលើប្រជាជនជនជាតិដើមនៅទីប្រជុំជន បង្ហាញឱ្យឃើញនូវសារៈសំខាន់នៃការអប់រំក្នុងការកែលម្អគុណភាពជីវិតរបស់ពួកគេ និងបានរកឃើញថា ការដាក់បញ្ចូលកម្មវិធីសិក្សា និងការអនុវត្តដែលមានភាពសមស្របផ្នែកវប្បធម៌ អាចជួយកែលម្អលទ្ធផលការអប់រំកុមារតូចបានកាន់តែប្រសើរ។

## ចំណាកស្រុកធ្វើឱ្យអ្នកធ្វើផែនការនៅតាមភូមិ និងក្រុងនានាជួបការលំបាក

ការថយចុះប្រជាជននៅទីជនបទ មានន័យថា អ្នកធ្វើផែនការផ្នែកការអប់រំ ជាពិសេស គឺអ្នកធ្វើផែនការការងារអប់រំនៅតាមបណ្តាប្រទេសមានចំណូលខ្ពស់ ចាំបាច់ត្រូវរក្សាតុល្យភាពរវាងការចាត់ធនធានប្រកបដោយប្រសិទ្ធផល ជាមួយសុខុមាលភាពនៃសហគមន៍រងផលប៉ះពាល់។ ប្រទេសហ្វាំងឡង់ បានបិទទ្វារ ឬច្របាច់បញ្ចូលសាលារៀន ៨០% ដែលមានសិស្សតិចជាង ៥០ នាក់ ក្នុងចំនួនសរុបជាង ១៦០០ សាលានៅចន្លោះចាប់ពីឆ្នាំ ១៩៩០ ដល់ ឆ្នាំ២០១៥។ នគរូបនីយកម្ម និងការបង្កកំណើតទាប បង្កឱ្យមានបញ្ហាប្រឈមប្រហាក់ប្រហែលគ្នានេះដែរ នៅក្នុងបណ្តាប្រទេសមានចំណូលមធ្យមជាច្រើន។ ចំនួនសាលារៀននៅទីជនបទក្នុងសហភាពរុស្ស៊ី បានថយចុះពី ៤៥ ០០០ មកនៅតិចជាង ២៦ ០០០ ចាប់ពីឆ្នាំ ២០០០ ដល់ ឆ្នាំ២០១៥។ ក្នុងប្រទេសចិន ចំនួនសាលាបឋមសិក្សានៅទីជនបទបានថយចុះក្នុងអត្រា ៥២% ចាប់ពីឆ្នាំ ២០០០ ដល់ ២០១០។

ក្នុងការពិចារណាអំពីការច្របាច់សាលារៀនបញ្ចូលគ្នា ដើម្បីបង្កើនប្រសិទ្ធិផល រដ្ឋាភិបាលចាំបាច់ត្រូវទទួលស្គាល់តួនាទីផ្នែកសង្គមដ៏សំខាន់របស់សាលារៀននៅក្នុងសហគមន៍ ក៏ដូចជាអត្ថប្រយោជន៍ដទៃទៀត។ ការវិភាគលើទិន្នន័យ បានមកពីកម្មវិធីសម្រាប់វាយតម្លៃសិស្សអន្តរជាតិ (PISA) ឆ្នាំ ២០១៥ បានបង្ហាញឱ្យឃើញថា សិស្សមកពីសាលាតូចៗ មានបញ្ហាផ្នែកវិន័យ ភាពយឺតយ៉ាវ និងអវត្តមានតិចជាងសិស្សមកពីសាលាធំៗ។

ការច្របាច់សាលារៀនបញ្ចូលគ្នាប្រកបដោយជោគជ័យ ទាមទារឱ្យមានការពិគ្រោះយោបល់ជាមួយភាគីទាំងអស់ ដែលរងផលប៉ះពាល់ និងការពិចារណាអំពីថ្លៃចំណាយ។ រដ្ឋាភិបាលប្រទេសលីទុយអានីបានបង្កើតឱ្យមានវិធានការអាទិភាព ដើម្បីរក្សាសាលារៀនបឋមសិក្សានៅទីជនបទតូចៗ និងផ្តល់មធ្យោបាយធ្វើដំណើរប្រកបដោយប្រសិទ្ធិភាព ដោយមានរថយន្តក្រុងថ្មីៗរាប់រយគ្រឿង។

ប្រទេសមួយចំនួនលើកទឹកចិត្តសាលារៀនជនបទឱ្យចែករំលែកធនធាន និងការរៀនសូត្រពីគ្នាដើម្បីអាចនៅបន្តភាពរស់រវើកតទៅទៀត។ ប្រទេសស៊ីលី មានមជ្ឈមណ្ឌលខ្នាតតូចចំនួន ៣៧៤ សម្រាប់គ្រូបង្រៀនជនបទដើម្បីជួបប្រជុំ និងពិភាក្សាបញ្ហាប្រឈមរួម។ ចាប់ពីឆ្នាំ ២០១១ មក រដ្ឋាភិបាលចិនបានចូលរួមក្នុងការជួសជុល និងស្ថាបនាគ្រឹះស្ថានសាលារៀនជនបទតូចៗជាច្រើន ហើយអង្គការមិនមែនរដ្ឋាភិបាល (NGOs) សហគមន៍ក្នុងមូលដ្ឋាន និងសាលារៀន បានបង្កើតឱ្យមានបណ្តាញចែករំលែកធនធាន។

## ជនចំណាកស្រុកក្នុងតំបន់ទីប្រជុំជនអនាធិបតេយ្យមានឱកាសអប់រំតិច

មានប្រជាជនយ៉ាងហោចណាស់ ៨០០ លាននាក់ រស់នៅក្នុងទីប្រជុំជនអនាធិបតេយ្យ។ និយមន័យថ្នាក់ជាតិ ឬវិធីសាស្ត្រប៉ាន់ប្រមាណ អាចមានតួលេខតិចជាងជាក់ស្តែង។ អ្នកតាំងលំនៅតាមទីប្រជុំជនអនាធិបតេយ្យជាច្រើន គឺជាជនចំណាកស្រុកពីតំបន់ជនបទមកកាន់តំបន់ទីក្រុង ហើយខ្វះលទ្ធភាពទទួលបានសេវាជាមូលដ្ឋាននានារួមទាំងការអប់រំសាធារណៈផងដែរ។ ការជន្លៀសចេញ និងការដោះស្រាយផលប៉ះពាល់សម្រាប់អ្នកតាំងលំនៅក្នុង តំបន់ទីប្រជុំជនអនាធិបតេយ្យ បង្កឱ្យមានការបោះបង់ការសិក្សា និងមានវត្តមានទាបនៅសាលារៀន។ ក្នុងប្រទេសបង់ក្លាដេសក្នុងឆ្នាំ ២០១៦ អត្រានៃមនុស្សវ័យជំទង់ក្នុងវ័យសិក្សាថ្នាក់មធ្យមសិក្សាដែលនៅក្រៅសាលារៀនក្នុងតំបន់ទីប្រជុំជនអនាធិបតេយ្យ មានចំនួន ២ ដង លើសពីក្នុងតំបន់ទីប្រជុំជនដទៃទៀត។

ការអប់រំក្នុងតំបន់ទីប្រជុំជនអនាធិបតេយ្យ ពុំមែនជាអាទិភាពសម្រាប់ការប្រមូលទិន្នន័យ ដោយហេតុថាការពិភាក្សាដេញដោលអំពីនគរូបនីយកម្ម ផ្តោតការយកចិត្តទុកដាក់លើបញ្ហាប្រឈមផ្នែកលំនៅដ្ឋាន និងទឹក និងអនាម័យ។ បណ្តាញអន្តរជាតិនៃអ្នកតាំងលំនៅក្នុងតំបន់ទីប្រជុំជនអនាធិបតេយ្យ/Shack ប្រមូលទិន្នន័យក្នុងប្រទេសជាង ៣០ ប៉ុន្តែទិន្នន័យស្តីពីការអប់រំនៅមានកម្រិតកំណត់នៅឡើយ។ សកម្មភាពការអប់រំនៅក្នុងតំបន់ទីប្រជុំជនអនាធិបតេយ្យ ប្រហែលជាត្រូវបានគេមើលស្រាល ដោយសារតែសាលាឯកជនមិនមានចុះបញ្ជីដែលដំណើរការប៉ះប៉ូវសងចំពោះកង្វះសាលារដ្ឋ។ ក្នុងតំបន់ គីប៊ីរ៉ា (Kibera) ប្រទេសកេនយ៉ា (Kenya) គម្រោងធ្វើផែនទីបើកចំហមួយ បានរកឃើញសាលាចំនួន ៣៣០ ស្របពេលដែលការប៉ាន់ប្រមាណ

ផ្លូវការមានចំនួនតែ ១០០ សាលា។ សាលារៀនឯកជន ដែលជារឿយៗគឺជាជម្រើសតែមួយគត់សម្រាប់អ្នកនៅក្នុងតំបន់ទីប្រជុំជនអនាធិបតេយ្យ ច្រើនតែមានការមើលខុសត្រូវខ្សោយ ហើយជួលអ្នកអប់រំពុំបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវឱ្យបម្រើការងារ។ ការផ្តួចផ្តើមគំនិតមួយដើម្បីលើកកម្ពស់គុណភាពគ្រូក្នុងទីប្រជុំជនប្រទេសណារ៉ូប៊ី (Nairobi) បានកែលម្អសមត្ថភាពផ្នែកអក្ខរកម្ម និងលេខនព្វន្តរបស់សិស្ស។

ការអប់រំចាំបាច់ត្រូវតែជាអាទិភាពមួយ ក្នុងកិច្ចពិភាក្សាផ្នែកនគរូបនីយកម្មទាក់ទងជាមួយតំបន់ទីប្រជុំជនអនាធិបតេយ្យ។ការធានាឱ្យមានលិខិតបញ្ជាក់សិទ្ធិរបស់អ្នកតាំងលំនៅនិងការបង្កើតសិទ្ធិគឺជាជំហានគន្លឹះឆ្ពោះទៅផ្តល់ការអប់រំ ដោយហេតុថា ជារឿយៗ រដ្ឋាភិបាលតែងមានភាពស្ទាក់ស្ទើរមិនហ៊ានវិនិយោគក្នុងហេដ្ឋារចនាសម្ព័ន្ធការអប់រំសម្រាប់ប្រជាជនដែលតាំងលំនៅលើដីដែលពួកគេពុំមែនជាម្ចាស់កម្មសិទ្ធិ។ ក្នុងប្រទេសអាហ្សង់ទីន (Argentina) លទ្ធភាពទទួលបានលិខិតកាន់កាប់ដី គឺពាក់ព័ន្ធជាមួយការកែលម្អការអប់រំរយៈពេលវែង។

ការចុះបញ្ជី បែបរឹងត្អឹង និងការតម្រូវឯកសារ ជារឿយៗតែងរារាំងមិនឱ្យជនចំណាកស្រុកអាចចូលរួមក្នុងកម្មវិធីកិច្ចគាំពារសង្គម ដែលអាចផ្តល់អត្ថប្រយោជន៍ដល់ការអប់រំរបស់ពួកគេ។ ក្នុងទីប្រជុំជនអនាធិបតេយ្យប្រទេសកេនយ៉ា (Kenya) កម្មវិធីកិច្ចគាំពារសង្គមនៅតំបន់ទីប្រជុំជន តម្រូវឱ្យមានអត្តសញ្ញាណប័ណ្ណជាតិ ជាហេតុធ្វើឱ្យកម្មវិធីនេះផាត់ចេញរួចជាស្រេចនូវអ្នកទទួលផល ៥% ដែលជាជនភៀសខ្លួន ដោយពួកគាត់ពុំអាចមានលទ្ធភាពផ្តល់ភស្តុតាងបញ្ជាក់សញ្ជាតិកេនយ៉ា (Kenya) ឬអ្នកដែលស្ថិតក្នុងគ្រួសារមានកុមារជាមេគ្រួសារ។

# ចំណាកស្រុកអន្តរជាតិ

នៅពេលមនុស្សធ្វើចំណាកស្រុកដើម្បីរកការងារ និងឱកាសជីវិតកាន់តែប្រសើរ ពួកគេចាំបាច់ត្រូវតែសម្របខ្លួនជាមួយប្រព័ន្ធថ្មីៗ ដោះស្រាយជាមួយបញ្ហាប្រឈមផ្នែកច្បាប់ និងផ្នែករដ្ឋបាល និងជម្នះឧបសគ្គផ្នែកភាសា និងការរើសអើងជាសក្តានុពល។ ចំណែកនៅក្នុងប្រទេសទទួលវិញ ប្រព័ន្ធអប់រំត្រូវប្រឈមជាមួយការចំណាយក្នុងការកែសម្រួលដើម្បីទទួលយកអ្នកមកដល់ថ្មីៗ។

ក្នុងឆ្នាំ ២០១៧ មានជនចំណាកស្រុកអន្តរជាតិចំនួន ២៥៨ លាននាក់ ស្មើ និង ៣,៤% នៃប្រជាជនសរុបទូទាំងពិភពលោក។ ពួកគេប្រមាណ ៦៤% តាំងទីលំនៅក្នុងប្រទេសមានចំណូលខ្ពស់ ដោយក្នុងនោះចំណែករបស់ជនចំណាកស្រុកនៅក្នុងចំណោមប្រជាជនសរុប ធ្វើឱ្យកើនឡើងចាប់ពី ១០% ក្នុងឆ្នាំ ២០០០ ដល់ ១៤% ក្នុងឆ្នាំ ២០១៧។ នៅក្នុងរដ្ឋជាច្រើននៅតាមតំបន់ឈូងសមុទ្រ រួមមានដូចជាប្រទេសគុយវ៉ែត (Kuwait) កាតា (Qatar) និងសហភាពអារ៉ាប់រួម ជនចំណាកស្រុកគឺជាក្រុមភាគច្រើន។

អត្រាចំណាកស្រុកមានកម្រិត ២ ទៅ ៣ ដង នៃមធ្យមភាគសាកលនៅក្នុងបណ្តាប្រទេសមានចំណូលមធ្យមដែលមានលក្ខណៈចម្រុះគ្នាជាច្រើនដូចជា កូស្តារីកា, កូតឌីវ័រ, ម៉ាឡេស៊ី និងអាហ្វ្រិកខាងត្បូង។ ផ្ទុយមកវិញបណ្តាប្រទេសមានអត្រាចំណាកស្រុកលើសពី ៥%នៃប្រជាជនសរុបរួមមានដូចជាប្រទេសអាល់បានី, ហ្សកហ្ស៊ី, ហ្សាម៉ាអ៊ីក, គីហ្ស៊ីស្ថាន និង នីការ៉ាហ្គា។ ច្រករបៀងចំណាកស្រុកធំជាងគេបំផុត គឺច្រករវាងប្រទេសម៉ិចស៊ិចកូ ចូលទៅកាន់សហរដ្ឋអាមេរិក។ ច្រករបៀងដទៃទៀត រួមមានដូចជាច្រកនៅអឺរ៉ុបខាងកើត ចូលទៅកាន់អឺរ៉ុបខាងលិច អាហ្វ្រិកខាងជើង ចូលទៅកាន់អាហ្វ្រិកខាងត្បូង និងអាស៊ីខាងត្បូង ចូលទៅកាន់បណ្តារដ្ឋនៅឈូងសមុទ្រ។

នៅក្នុងបណ្តាប្រទេសភាគច្រើនក្នុងអង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍសេដ្ឋកិច្ច (OECD) សិស្សអាយុ ១៥ ឆ្នាំ យ៉ាងហោចណាស់ម្នាក់ក្នុងចំណោមសិស្ស ៥ នាក់ គឺជាជនចំណាកស្រុកឬមានសាវតារជាជនចំណាកស្រុកក្នុងឆ្នាំ ២០១៥ (**រូបភាពទី២**)។ ការប៉ាន់ប្រមាណសម្រាប់របាយការណ៍នេះ បង្ហាញឱ្យឃើញថាក្នុង ៨០% នៃសាលាមធ្យមសិក្សាក្នុងបណ្តាប្រទេសមានចំណូលខ្ពស់ សិស្សយ៉ាងហោចណាស់ ៥% មានសាវតារជាជនចំណាកស្រុក ក្នុងសាលាចំនួន ៥២% មានសិស្សយ៉ាងហោចណាស់ ១៥% មានសាវតារជាជនចំណាកស្រុក។

## រូបភាពទី ២៖

**ក្នុងបណ្តាប្រទេស OECD ភាគច្រើន សិស្សយ៉ាងហោចណាស់ម្នាក់ក្នុងចំណោមសិស្សប្រាំនាក់ដែលមានអាយុ ១៥ ឆ្នាំ គឺជាជនចំណាកស្រុក ឬមានសាវតារជាជនចំណាកស្រុក**

របាយណ៍សិស្សអាយុ ១៥ ឆ្នាំ ចែកទៅតាមប្រភេទសាវតារចំណាកស្រុកនៅក្នុងប្រទេសដែលបានជ្រើសរើស ក្នុងឆ្នាំ ២០១៥




GEM StatLink: http://bit.ly/fig3_4

សម្គាល់៖ តួលេខនេះ ផាត់ចេញប្រទេស និងដែនដីចំនួនប្រាំ ដែលមានអត្រាសិស្សមានសាវតារចំណាកស្រុកខ្ពស់ជាងនេះថែមទៀត រួមមាន ហុងកុង ចិន លុយសំបួ ម៉ាកាវ ចិន កាតា និងសហភាពអារ៉ាប់រួម។

ប្រភព៖ ការវិភាគរបស់ក្រុមរបាយការណ៍ GEM ផ្អែកលើ PISA ឆ្នាំ ២០០៦ និង ២០១៥ និង TIMSS ២០១៥។

# ចំណាកស្រុកជះឥទ្ធិពលលើការអប់រំ ហើយទទួលឥទ្ធិពលពីការអប់រំផងដែរ

ជនចំណាកស្រុកពុំមែនជាក្រុមប្រជាជនមិនដឹងមុខនោះទេ។ ក្នុងចំណោមភាពខុសគ្នាផ្សេងទៀតជាមួយជនមិនមែនចំណាកស្រុក យើងឃើញថា ជនចំណាកស្រុកច្រើនតែមានការអប់រំច្រើន ដែលជួយពួកគេក្នុងការប្រមូលព័ត៌មានឆ្លើយតបជាមួយឱកាសសេដ្ឋកិច្ច ប្រើប្រាស់ជំនាញដែលអាចផ្ទេរឱ្យអ្នកដទៃបាន និងផ្តល់ហិរញ្ញវត្ថុសម្រាប់ការធ្វើចំណាកស្រុក។

> ក្នុងឆ្នាំ ២០០០ អត្រាអន្តោប្រវេសន៍សាកលលោក មានចំនួនប្រមាណ ៥,៤٪ សម្រាប់អ្នកមានការអប់រំកម្រិតឧត្តមសិក្សា ១,៨٪ សម្រាប់អ្នកមានការអប់រំថ្នាក់មធ្យមសិក្សា និង ១,១٪ សម្រាប់អ្នកមានការអប់រំថ្នាក់បឋមសិក្សា។

ការសម្រេចបានផ្នែកការអប់រំនៅក្នុងពេលធ្វើអន្តោប្រវេសន៍ក៏អាស្រ័យលើលក្ខខណ្ឌដែលជនចំណាកស្រុកឆ្លងដែនផងដែរ៖ ជនអន្តោប្រវេសន៍សហរដ្ឋអាមេរិកមកពីប្រទេសអែលសាល់វ៉ាឌ័រ, ហៃទី, ម៉ិកស៊ិក និង នីការ៉ាហ្គា ដោយគ្មានឯកសារត្រឹមត្រូវ ជាមធ្យមគឺ មានការអប់រំច្រើនជាងអ្នកដែលមានកិច្ចសន្យាធ្វើការរយៈបណ្តោះអាសន្ន ប៉ុន្តែតិចជាងអ្នកដែលក្លាយជាអ្នកតាំងលំនៅស្របច្បាប់។

ដោយយល់អំពីផលប៉ះពាល់នៃចំណាកស្រុកមកលើការសម្រេចបានផ្នែកការអប់រំ ហើយការសម្រេចបានគឺរួមមានការប្រៀបធៀបសំខាន់ៗពីរ ទីមួយ គឺរវាងអ្នកដែលធ្វើចំណាកស្រុក ឬពុំធ្វើចំណាកស្រុក បើទោះបីជាក្រុមទាំងអស់នេះខុសប្លែកគ្នាមិនត្រឹមតែសេចក្តីសម្រេចចិត្ត ក្នុងការធ្វើចំណាកស្រុកតែប៉ុណ្ណោះទេ (ឧ. ជនចំណាកស្រុកអាចមានការអប់រំច្រើនជាង បើទោះបីជាពួកគេមិនធ្វើចំណាកស្រុកក្តី)។ ទីពីរ គឺរវាងអ្នកធ្វើចំណាកស្រុក និងប្រជាជនដើមនៅក្នុងស្រុក ដែលមានឋានៈខ្ពស់ជាងអ្នកធ្វើចំណាកស្រុក។ ក្នុងករណីមួយចំនួន គោលនយោបាយចំណាកស្រុកបែបជ្រើសរើសអាចមានន័យថា ជនចំណាកស្រុកត្រូវមានការអប់រំខ្ពស់ជាងអ្នកក្នុងស្រុក ក្នុងករណីដទៃទៀត ជនចំណាកស្រុកអាចរស់នៅក្នុងតំបន់ក្រីក្រដែលមានសេវាសាលារៀនគុណភាពទាបជាងជនម្ចាស់ស្រុក ជាហេតុធ្វើឱ្យកូនរបស់ពួកគេមានការសម្រេចបាន និងជោគជ័យផ្នែកការអប់រំទាបជាង។

## ចំណាកស្រុកជះឥទ្ធិពលលើការអប់រំរបស់អ្នកដែលត្រូវបានទុកឱ្យនៅស្រុកកំណើត

ជារឿយៗ ជនចំណាកស្រុកតែងទុកកូនរបស់ខ្លួននៅស្រុកកំណើត។ ក្នុងប្រទេសហ្វីលីពីន កុមារប្រមាណ ១,៣ លាននាក់ ដល់ ៣ លាននាក់ មានយ៉ាងហោចណាស់ឪពុក ឬម្តាយជាជនចំណាកស្រុកអន្តរជាតិ។ ឥទ្ធិពលនៃការផ្ទេរសាច់ប្រាក់មកលើការអប់រំអាចមានភាពចាំបាច់យ៉ាងខ្លាំង។

នៅទូទាំងសាកលលោក គ្រួសារទទួលប្រាក់ចំនួន ៦១៣ ពាន់លានដុល្លារ នៅក្នុងការផ្ទេរសាច់អន្តរជាតិក្នុងឆ្នាំ ២០១៧ ដោយក្នុងនោះ ទឹកប្រាក់ចំនួន ៤៦៦ ពាន់លានដុល្លារ គឺត្រូវបានបញ្ជូនទៅឱ្យគ្រួសារនៅក្នុងបណ្ដាប្រទេសមានចំណូលទាប និងមធ្យម ពោលគឺជាចំនួនទឹកប្រាក់ ៣ ដង ច្រើនជាងជំនួយអភិវឌ្ឍផ្លូវការ។ ប្រទេសឥណ្ឌា និងប្រទេសចិន ទទួលទឹកប្រាក់ច្រើនជាងគេបំផុតក្នុងន័យដាច់ខាត ប៉ុន្តែប្រទេសគីហ្ស៊ីស្ថាន និងតុងហ្គា នាំមុខគេបើគិតជាភាគរយនៃផលិតផលដុលក្នុងស្រុក។

បើតាមទ្រឹស្ដី ការផ្ទេរសាច់ប្រាក់អាចមានឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមានមកលើការអប់រំ។ ការធ្វើពិពិធកម្មប្រភពចំណូល ផ្ដល់ឱ្យមានផលជះជាការធានារ៉ាប់រង៖ គ្រួសារច្រើនតែមិនសូវចាំបាច់ត្រូវកាត់ការចំណាយផ្នែកការអប់រំ។ ទោះយ៉ាងណាក្ដី បើទោះបីជាចំណូលបន្ថែមជួយបង្កើនការចំណាយក្នុងគ្រួសារក្ដី ប៉ុន្តែការអប់រំត្រូវប្រជែងជាមួយការចំណាយដទៃទៀត កុមារប្រហែលត្រូវជួយ ធ្វើការជំនួសកម្លាំងពលកម្មរបស់អ្នកដែលបានធ្វើចំណាកស្រុក ហើយកង្វះជាតុចូលពីឪពុកម្ដាយ អាចជាឧបសគ្គរាំងដល់ការអប់រំ។ ការផ្ញើសាច់ប្រាក់ក៏អាចបង្កើតឱ្យមាន "វប្បធម៌ចំណាកស្រុក" ដែលក្នុងនោះ ប្រាក់ចំណូលខ្ពស់មកលើពលកម្មមានជំនាញទាប ឬជំនាញមធ្យមនៅក្រៅប្រទេស ជាកត្តាបន្ទច់បង្អាក់ការបន្តការសិក្សា។

តាមន័យជាក់ស្ដែង ករណីការផ្ញើប្រាក់អន្តរជាតិ បង្កើនការចំណាយលើការអប់រំជាមធ្យម ៣៥% យោងទៅតាមកម្រងការសិក្សាក្នុងប្រទេសចំនួន ១៨ ក្នុងអនុតំបន់សាហារ៉ានៃទ្វីបអាហ្រ្វិក និងតំបន់អាស៊ីកណ្ដាល អាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍។ ឥទ្ធិពលមានទំហំធំធេងជាងនេះថែមទៀតនៅក្នុងតំបន់អាមេរិកឡាទីន (៥៣%)។

ចំនុចដៅទី ១០C របស់ SDGs អំពាវនាវឱ្យកាត់បន្ថយថ្លៃចំណាយលើប្រតិបត្តិការផ្ញើសាច់ប្រាក់មកនៅក្នុងអត្រាជាមធ្យមទាបជាង ៣%។ អត្រាមធ្យមនាពេលបច្ចុប្បន្នគឺ ៧,១%។ ធនាគារតាមបែបប្រពៃណីគឺជាបណ្ដាញមានតម្លៃថ្លៃជាងគេបំផុត ហើយអន្តរការីមួយចំនួនក្នុងទ្វីបអាហ្រ្វិក យកថ្លៃសេវាលើស ២០%។ ឧបមាថាចំណែកនៃការចំណាយសរុបក្នុងគ្រួសារលើការអប់រំមានចំនួន ៤% នោះការកាត់បន្ថយការចំណាយថ្លៃបញ្ជូនសាច់ប្រាក់មកនៅត្រឹម ៣% អាចអនុញ្ញាតឱ្យគ្រួសារមានប្រាក់ចំណាយបន្ថែមចំនួន ១ ពាន់លានដុល្លារលើការអប់រំក្នុងមួយឆ្នាំ។

ការសិក្សាជាច្រើនស្នើឱ្យឃើញថា ឥទ្ធិពលជាទូទៅនៃការផ្ទេរសាច់ប្រាក់មកលើលទ្ធផលការអប់រំ គឺមានលក្ខណៈជាវិជ្ជមាន។ ក្នុងប្រទេសហ្វីលីពីន ការកើនឡើង ១០% នៃការផ្ទេរសាច់ប្រាក់អន្តរជាតិ បានបង្កើនវត្តមានទៀងទាត់នៅសាលាក្នុងអត្រាលើស ១០% ហើយកាត់បន្ថយពលកម្មកុមារលើសបីម៉ោងក្នុងមួយសប្ដាហ៍។ ឥទ្ធិពលអាចមានលក្ខណៈខុសប្លែកគ្នាពីយេនឌ័រមួយ ទៅយេនឌ័រមួយ។ ក្នុងប្រទេសហ្ស៊កដានី ការផ្ទេរសាច់ប្រាក់មានផលប៉ះពាល់ជាវិជ្ជមាន លើវត្តមានក្នុងការអប់រំក្រោយថ្នាក់ ដែលតម្រូវជាកាតព្វកិច្ចតែសម្រាប់មនុស្សប្រុសប៉ុណ្ណោះ។

## ការបញ្ចុះតម្លៃសម្រាប់ការបញ្ជូនប្រាក់មកផ្ទះវិញរបស់អ្នកចំណាកស្រុក




គំហើញជាវិជ្ជមាន អាចផ្ទុះបញ្ចាំងច្រករបៀងចំណាកស្រុកដែលត្រូវបានជ្រើសរើសជាក់លាក់ ឬបរិបទដែលមានការចុះឈ្មោះចូលរៀនទាប ដើម្បីជាកិច្ចចាប់ផ្តើម។ នៅក្នុងច្រករបៀងចំណាកស្រុកមានជំនាញទាបមួយចំនួន មានភស្តុតាងបង្ហាញអំពីផលប៉ះពាល់ជាអវិជ្ជមានលើលទ្ធផលនៃការសិក្សា។ ការផ្ទេរប្រាក់អន្តរជាតិគឺពាក់ព័ន្ធជាមួយការថយចុះយ៉ាងច្រើននៅក្នុងលទ្ធភាពនៃការចុះឈ្មោះចូលរៀនក្នុងប្រទេសក្វាតេម៉ាឡា បើទោះបីជាអ្នកដែលបានចុះឈ្មោះចូលរៀនទទួលបានលទ្ធផលសិក្សាល្អ ជាលទ្ធផលនៃការបញ្ជូនប្រាក់មកក៏ដោយ។ ក្នុងតំបន់ជនបទប្រទេសម៉ិកស៊ិក កូនសិស្សដែលត្រូវបានទុកចោលឱ្យនៅស្រុកកំណើត មានលទ្ធផលការអប់រំអន់ជាងកុមារដទៃ អាស្រ័យដោយការផ្ញើប្រាក់ត្រឡប់មកផ្ទះ។

## ជនចំណាកស្រុកចំណាយប្រាក់ច្រើនសម្រាប់ការអប់រំនៅក្នុងបណ្តាប្រទេសគោលដៅ

នៅតាមបណ្តាប្រទេសគោលដៅ ជនចំណាកស្រុកជារឿយៗតែងឈប់រៀនតាំងពីនៅក្មេង។ ក្នុងសហគមន៍អឺរ៉ុប ១០% នៃប្រជាជនម្ចាស់ស្រុក និង ១៩% នៃប្រជាជនកើតនៅបរទេសមានអាយុ ១៨ ដល់ ២៤ ឆ្នាំ ឈប់រៀនតាំងពីនៅក្មេងក្នុងឆ្នាំ ២០១៧។ ការបោះបង់ការសិក្សា អាចអាស្រ័យទៅលើអាយុនៃការមកដល់ លទ្ធផលខុសប្លែកគ្នាគួរជាទីកត់សម្គាល់ថាតើសិស្ស ចូលទៅក្នុងប្រព័ន្ធរបស់ប្រទេសម្ចាស់ផ្ទះនៅពេលចាប់ផ្តើម នៅពាក់កណ្តាល ឬចុងការអប់រំជាកាតព្វកិច្ច។ នៅសហរដ្ឋអាមេរិក ៤០% នៃជនចំណាកស្រុកម៉ិកស៊ិក ដែលបានមកដល់នៅអាយុ ៧ ឆ្នាំ ពុំបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាទេ បើប្រៀបនឹង ៧០% នៃអ្នកដែលបានមកដល់នៅអាយុ ១៤ ឆ្នាំ។

ទោះយ៉ាងណាក្តី ស្ថានភាពការអប់រំរបស់ជនចំណាកស្រុកមានភាពប្រសើរឡើងយ៉ាងឆាប់រហ័សជាងជនម្ចាស់ស្រុក និងអ្នកដែលត្រូវបានទុកចោលនៅស្រុកកំណើត។ ក្នុងប្រទេសអាល្លឺម៉ង់ ជនម្ចាស់ស្រុកដែលមានឪពុកម្តាយមានការអប់រំទាបជាងកម្រិតមធ្យម មានការរីកចម្រើនក្នុងការសិក្សាយឺតជាងមិត្តភក្តិដែលជាជនចំណាកស្រុក។ មានប្រទេស ៨ ក្នុងចំណោម ១០ ប្រទេសនៅអាមេរិកឡាទីន និងការ៉ាប៊ីន កូនរបស់ជនចំណាកស្រុកជាមធ្យមមានការអប់រំ ១,៤ ឆ្នាំលើសកូនរបស់ឪពុកម្តាយដែលពុំធ្វើចំណាកស្រុក។

គម្លាតក្នុងការសម្រេចបានការអប់រំ លាតសន្ធឹងឆ្លងជំនាន់។ នៅក្នុងការប្រឡង PISA ឆ្នាំ ២០១៥ សិស្សជាជនចំណាកស្រុកជំនាន់ទី ១ ចំនួន ៤៩% និងជំនាន់ទី ២ ចំនួន ៦១% សម្រេចបានយ៉ាងហោចណាស់កម្រិត ២ នៃតេស្តសមត្ថភាពអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ បើធៀបជាមួយលទ្ធផល ៧២% នៃអ្នកម្ចាស់ស្រុក។ ក្នុងប្រទេសកាណាដា អាល្លឺម៉ង់ និងអ៊ីតាលី ជនម្ចាស់ស្រុកបន្តទទួលបានគុណសម្បត្តិលើសជនចំណាកស្រុកជំនាន់ទី ២ ជាពិសេសក្នុងការអប់រំថ្នាក់ឧត្តមសិក្សា។

ការប្រៀបធៀបមួយទៅលើជនចំណាកស្រុកតួកគីជំនាន់ទី២ក្នុងបណ្តាប្រទេសចំនួន៦បានបង្ហាញឱ្យឃើញថា មានតែ ៥% ប៉ុណ្ណោះនៃអ្នកនៅក្នុងប្រទេសអាល្លឺម៉ង់ ប៉ុន្តែមាន ៣៧% នៃអ្នកនៅក្នុងប្រទេសបារាំងមានលទ្ធភាពទទួលបានការអប់រំថ្នាក់ឧត្តមសិក្សា។កត្តាផ្នែកស្ថាប័ននៅក្នុងប្រទេសបារាំងដូចជាលទ្ធភាពទទួលបានការអប់រំមុនថ្នាក់បឋមសិក្សាតាំងពីនៅតូច ភាពយឺតយ៉ាវក្នុងការតាមដានចូលទៅក្នុងចរន្តសមត្ថភាពក្នុងការអប់រំមធ្យមសិក្សា និងលទ្ធភាពទទួលបានការអប់រំឧត្តមសិក្សា បើទោះបីជាមានចរន្តសមត្ថភាពទាបជាងក្តី អាចជួយពន្យល់អំពីគម្លាតគ្នានេះ។

ស្ថានភាពសង្គមសេដ្ឋកិច្ចទាប ជួយពន្យល់ប្រមាណ ២០% នៃគម្លាតផ្នែកការសិក្សារៀនសូត្ររបស់ជនចំណាកស្រុកនៅក្នុងបណ្តាប្រទេស OECD ក្នុងប្រទេសមួយចំនួន រួមទាំងប្រទេសបារាំង និងក្រិក ទិដ្ឋភាពនេះអាចជាការពន្យល់រហូតដល់ពាក់កណ្តាល។ សិស្សជាជនចំណាកស្រុកក្នុងបណ្តាប្រទេស OECD ច្រើនតែត្រូវរៀនត្រួតថ្នាក់ក្នុងអត្រាពីរដង បើធៀបជាមួយអ្នកម្ចាស់ស្រុក។

## គោលនយោបាយអន្តោប្រវេសន៍ និងភាពជាពលរដ្ឋរារាំងលទ្ធភាពនៅសាលារៀន

សិទ្ធិទទួលបានការអប់រំ និងគោលការណ៍មិនរើសអើងជាទូទៅ គឺមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ សន្ធិសញ្ញាអន្តរជាតិ ផ្តោតជាក់លាក់លើទេសន្តប្រវេសន៍ ផ្តល់ការអះអាងបញ្ជាក់ថា ជនចំណាកស្រុក និងជនភៀសខ្លួនអាចទទួលបានការប្រព្រឹត្តចំពោះខ្លួនប្រៀបដូចជាពលរដ្ឋដទៃនៅក្នុងការអប់រំ ប៉ុន្តែ បើគិតមកដល់ពេលនេះមានតែប្រទេសតែមួយភាគបួនប៉ុណ្ណោះ ដោយក្នុងនោះស្ទើរតែទាំងអស់សុទ្ធតែជាបណ្តាប្រទេសបញ្ជូនជនចំណាកស្រុក ដែលបានផ្តល់សច្ចាប័នលើអនុញ្ញានេះ។ ក្នុងការអនុវត្តជាក់ស្តែង គោលនយោបាយអន្តោប្រវេសន៍តឹងរឹង ច្បាប់មិនស៊ីសង្វាក់គ្នា និងការរឹតត្បិតលើការតម្រូវផ្នែកឯកសារក្នុងប្រទេសម្ចាស់ផ្ទះ អាចរារាំងការសម្រេចបានសិទ្ធិនេះ។

ច្បាប់ជាតិមួយចំនួនអាចបំផ្លាញដល់សិទ្ធិដែលមានចែងក្នុងធម្មនុញ្ញក្នុងការទទួលបានការអប់រំ។ នៅក្នុងប្រទេសស៊ីប្រូស និងស្លូវ៉ាគី សាលារៀនមានកាតព្វកិច្ចត្រូវរាយការណ៍អំពីគ្រួសារដែលគ្មានឯកសារត្រឹមត្រូវទៅដល់អាជ្ញាធរអន្តោប្រវេសន៍។ ក្នុងប្រទេសអាហ្វ្រិកខាងត្បូង ច្បាប់អន្តោប្រវេសន៍ឆ្នាំ ២០០២ បានរារាំងមិនឱ្យជនចំណាកស្រុកដែលគ្មានឯកសារត្រឹមត្រូវអាចចុះឈ្មោះចូលរៀនក្នុងសាលាបានឡើយ។

ច្បាប់ដែលប្រគល់សិទ្ធិអប់រំដល់ប្រជាជនមានកំណើតនៅបរទេស បង្កើនលទ្ធភាពដើម្បីអាចបំពេញនូវសិទ្ធិទទួលបានការអប់រំ។ ក្នុងប្រទេសអាហ្សង់ទីន ច្បាប់ការអប់រំជាតិឆ្នាំ ២០១៦ បញ្ជាក់អះអាងអំពីសិទ្ធិទទួលបានការអប់រំសម្រាប់អ្នកតាំងលំនៅទាំងអស់។ ច្បាប់សាលាបឋមសិក្សារបស់ប្រទេសស្លូវេនី បានពង្រីកសិទ្ធិនេះយ៉ាងជាក់ច្បាស់ទៅដល់ការអប់រំជូនដល់ប្រជាជនគ្មានរដ្ឋ។

ក្របខ័ណ្ឌការងារផ្នែកច្បាប់ដែលមានលក្ខណៈបរិយាបន្ន មិនមែនសុទ្ធតែអាចទប់ស្កាត់ការអនុវត្តដែលមានលក្ខណៈរើសអើងនៅថ្នាក់តំបន់ឬថ្នាក់មូលដ្ឋានឡើយ។ សាលារៀនអាចទាមទារសំបុត្រកំណើត ការបញ្ជាក់ការអប់រំពីមុនមក ឯកសារកំណត់អត្តសញ្ញាណសញ្ជាតិ ឬភស្តុតាងបញ្ជាក់កន្លែងរស់នៅ ដើម្បីអាចចុះឈ្មោះចូលរៀន។ នៅប្រទេសស៊ីលីដែលចំនួនជនចំណាកស្រុកហៃទីបានកើនឡើងពីចំនួនតិចជាង ៥០០០ នាក់ក្នុងឆ្នាំ ២០១០ មកដល់ ១០៥ ០០០ នាក់ក្នុងឆ្នាំ ២០១៧ គោលនយោបាយតម្រូវឱ្យការអប់រំសាធារណៈ ត្រូវផ្តល់ដល់ កុមារក្នុងការអនុវត្តជាក់ស្តែង ការផ្តល់ការអប់រំ គឺស្រេចទៅតាមឆន្ទានុសិទ្ធិរបស់មន្ត្រីរដ្ឋាភិបាល ថ្នាក់មូលដ្ឋាន។ មន្ត្រីសាលារៀនក្នុងប្រទេសអ៊ូបេគីស្ថាន (Uzbekistan) ជារឿយៗតែងទាមទារភស្តុតាងបញ្ជាក់ទីលំនៅ លិខិតឆ្លងដែន ឬសមត្ថភាពប្រើប្រាស់ភាសាជាតិមុនពេលចុះឈ្មោះចូលរៀន។

ការបកស្រាយបញ្ជាក់ផ្លូវការ អាចជួយធានាឱ្យអ្នកពិនិត្យតាមដាននៅថ្នាក់សាលារៀនដឹងថា ច្បាប់ពុំតម្រូវឱ្យមានការបំពេញឯកសារ ហើយក្របខ័ណ្ឌការងារផ្នែកច្បាប់ថ្នាក់ជាតិដ៏រឹងមាំ អាចផ្តល់ច្រកផ្លូវសម្រាប់បុគ្គល ដើម្បីអាចលើកឡើងនូវពាក្យបណ្តឹងផ្សេងៗ។ ក្នុងឆ្នាំ ២០១៤ ប្រទេសអ៊ីតាលី និងតួកគី បានបកស្រាយបញ្ជាក់ថា ការផ្តល់ឯកសារពុំមែនជាកាតព្វកិច្ចចាំបាច់ខានពុំបានសម្រាប់ការចុះឈ្មោះចូលរៀនឡើយ។ ក្នុងប្រទេសបារាំង ឪពុកម្តាយអាចដាក់បណ្តឹងឧទ្ធរណ៍ទៅកាន់ការិយាល័យពលរដ្ឋ ឬតុលាការ ដើម្បីសុំការដោះស្រាយចំពោះសេចក្តីសម្រេចចិត្តចុះឈ្មោះចូលរៀនដែលមានលក្ខណៈរើសអើង។

ទោះយ៉ាងណាក្តី ជនចំណាកស្រុកគ្មានឯកសារត្រឹមត្រូវ បន្តជួបឧបសគ្គក្នុងការទទួលបានលទ្ធភាពក្នុងការអប់រំ។ នៅសហរដ្ឋអាមេរិក ដែលមានជនចំណាកស្រុកពុំបានទទួលការអនុញ្ញាតត្រឹមត្រូវ ១១ លាននាក់ក្នុងឆ្នាំ ២០១៤ ការគំរាមក្នុងការបញ្ជូនត្រឡប់ទៅប្រទេសវិញ អាចធ្វើឱ្យកុមារនៅក្រៅសាលារៀន៖ ក្នុងខែកុម្ភៈ ឆ្នាំ ២០១៧ អវត្តមាននៅសាលាក្នុងសាលារៀននៅស្រុកឡាគ្រូស (Las Cruces) ក្នុងរដ្ឋញូម៉ិចស៊ិចកូ បានកើនឡើងដល់ ៦០% បន្ទាប់ពីមានការចុះចាប់ជនភៀសខ្លួន។ ក្នុងឆ្នាំ ២០១២ កម្មវិធីសកម្មភាពពន្យាសម្រាប់ការមកដល់នៅវ័យកុមារ (Deferred Action for Childhood Arrivals (DACA)) ផ្តោតគោលដៅលើយុវជនគ្មានឯកសារត្រឹមត្រូវចំនួន ១,៣ លាននាក់ ដែលបានមកដល់នៅពេល នៅជាកុមារ ដោយផ្តល់ការការពារពីការបញ្ជូនត្រលប់ទៅប្រទេសវិញ និងមានលក្ខណៈសម្បត្តិអាចទទួលបានលិខិតអនុញ្ញាតឱ្យធ្វើការ។ កម្មវិធីនេះបានបង្កើនអត្រាបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាក្នុងអត្រាប្រមាណ ១៥% ដោយហេតុថា ជនអន្តោប្រវេសន៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ព្យាយាមឆ្លើយតបតាមលក្ខខណ្ឌតម្រូវ។

តម្រូវការការអប់រំរបស់អនីតិជនជាជនចំណាកស្រុកគ្មានអ្នកអមដំណើរមកជាមួយ ដែលមានភាពងាយរងគ្រោះ ជាពិសេសចំពោះការកេងប្រវ័ញ្ចន៍ ជារឿយៗពុំត្រូវបានឆ្លើយតបទេ។ ចំនួនរបស់ជនចំណាក

ស្រុកប្រភេទនេះនៅទូទាំងពិភពលោកបានកើនឡើងពី ៦៦ ០០០ នាក់ក្នុងឆ្នាំ ២០១០-២០១១ ឡើងទៅដល់ ៣០០ ០០០ នាក់ក្នុងឆ្នាំ ២០១៥-២០១៦។ ក្នុងប្រទេសជាច្រើន រួមទាំងប្រទេសអូស្ត្រាលី ក្រិក ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ម៉ិកស៊ិក ណូរូ និងប្រទេសថៃ កុមារ និងយុវជននៅក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍ជារឿយៗតែងមានលទ្ធភាពទទួលបានការអប់រំក្នុងកម្រិតកំណត់ ឬពុំទទួលបានទាល់តែសោះ។ ប្រមាណ ៧៣% នៃអនីតិជនចំនួន ៨៦ ០០០ នាក់ដែលបានមកដល់ប្រទេសអ៊ីតាលីក្នុងចន្លោះ ២០១១ ដល់ ២០១៦ គឺពុំមានអ្នកអមដំណើរមកជាមួយទេ។ ថ្វីបើច្បាប់ក្នុងឆ្នាំ ២០១៥ និង ២០១៧ មានបំណងក្នុងការការពារកុមារទាំងនោះក្តី ប៉ុន្តែមានកុមារភាគតិចប៉ុណ្ណោះដែលបានមករៀនទៀងទាត់។

កង្វះឯកសារអាចបង្កើតឧបសគ្គដល់ប្រជាជនគ្មានរដ្ឋចំនួន ១០ លាននាក់ទូទាំងពិភពលោក ដោយពួកគេមួយចំនួនគឺជាកូនចៅរបស់ជនចំណាកស្រុក។ នៅប្រទេសកូតឌីវ័រ (Côte d'Ivoire) ដែលមានប្រជាជនគ្មានរដ្ឋចំនួន ៧០០ ០០០ នាក់ លទ្ធភាពទទួលបានការអប់រំតម្រូវឱ្យមានភស្តុតាងបញ្ជាក់សញ្ជាតិ។ នៅសាធារណរដ្ឋដូមីនីក (Dominican Republic) ដែលជនចំណាកស្រុកហៃទីរាប់ពាន់នាក់ត្រូវបានដកហូតសញ្ជាតិ ក្នុងឆ្នាំ ២០១២ អត្រាវត្តមានទៀងទាត់សុទ្ធសាធនៅសាលារៀនថ្នាក់បឋមសិក្សាសម្រាប់សិស្សអាយុ ៦ ដល់ ១៣ ឆ្នាំ មាន ៥២% ក្នុងចំណោមអ្នកដែលបានកើតនៅប្រទេសហៃទី ប៉ុន្តែ ៨២% ក្នុងចំណោមជនចំណាកស្រុកដែលបានកើតនៅប្រទេសដទៃទៀត។

## គោលនយោបាយអប់រំអាចគាំទ្រលទ្ធភាពនៅសាលារៀនរបស់ជនចំណាកស្រុក

កម្មវិធីអប់រំកុមារតូច កម្មវិធីគាំទ្រផ្នែកភាសា និងគោលនយោបាយនានាទាក់ទងជាមួយការបន្សុីការជ្រើសរើស និងការបំបែក គឺជាគន្លឹះដើម្បីកែលម្អលទ្ធភាពទទួលបានការអប់រំ។

ការចូលរួមរបស់ជនចំណាកស្រុកនៅក្នុងកម្មវិធីអប់រំកុមារតូច គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់។ ជាមធ្យម ពិន្ទុអំណានរបស់ជនចំណាកស្រុកអាយុ ១៥ ឆ្នាំ ដែលបានចូលរៀនថ្នាក់មត្តេយ្យសិក្សា មានកម្រិតខ្ពស់ក្នុងចំនួនមួយ ដែលឆ្លើយតបជាមួយបរិមាណច្រើនជាងមួយឆ្នាំនៃការទៅសាលារៀន។ អាចមានការលំបាកសម្រាប់ជនចំណាកស្រុកគ្មានឯកសារត្រឹមត្រូវដើម្បីបានទទួលលទ្ធភាពចូលទៅកាន់កម្មវិធីអប់រំកុមារតូច។ នៅសហរដ្ឋអាមេរិក ការចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យសិក្សារបស់កុមារគ្មានឯកសារត្រឹមត្រូវអាយុ ៣ ដល់ ៤ ឆ្នាំមានភាពយឺតយ៉ាវជាងជនចំណាកស្រុកដែលមានឯកសារត្រឹមត្រូវ ក៏ដូចជាជនម្ចាស់ស្រុក។

កង្វះសមត្ថភាពផ្នែកភាសាគឺជាគុណវិបត្តិបង្កការលំបាកក្នុងការអប់រំដោយហេតុថាចំណុចនេះរារាំងការចូលរួមជាសង្គម ការស្ថាបនាទំនាក់ទំនង និងអារម្មណ៍ជាផ្នែកមួយនៃសហគមន៍ និងបង្កើនហានិភ័យនៃការរើសអើង។ ក្នុងឆ្នាំ ២០១២, ៥៣% នៃសិស្សជាជនចំណាកស្រុកជំនាន់ទីមួយ មានអត្រាការចេះអាន

ទាប ស្ថិតក្នុងវគ្គសិក្សាថ្នាក់អក្ខរកម្មសម្រាប់អ្នកនៅក្រៅសាលារៀននៅក្នុងបណ្តាប្រទេសមានចំណូលខ្ពស់ចំនួន ២៣ ប្រទេស។

រយៈពេលនៃថ្នាក់ត្រៀមខ្លួនមុនពេលចូលសាលា មានរយៈពេលខុសៗគ្នា ចាប់ពីមួយឆ្នាំនៅប្រទេសបែលហ្ស៊ិក បារាំង និងលីទុយអានី ដល់បួនឆ្នាំនៅប្រទេសក្រិក។ "ថ្នាក់ស្វាគមន៍" របស់អាល្លឺម៉ង់ ផ្តល់ការបង្រៀនផ្នែកភាសាខ្លាំងក្លាដាច់ដោយឡែក សម្រាប់សិស្សដែលមានសាវតារជាជនចំណាកស្រុក ។ នៅប្រទេសអេស្ប៉ាញ តំបន់នានាច្រើនតែអនុវត្តតាមគំរូណាមួយក្នុងចំណោមគំរូទាំងបី គឺ ថ្នាក់បណ្តោះអាសន្នដែលសិស្សចូលរៀននៅក្នុងផ្នែកណាមួយនៃថ្ងៃ ថ្នាក់លាយឡំគ្នា និងថ្នាក់អន្តរវប្បធម៌ ដែលពង្រីកទៅផ្តោតការយកចិត្តទុកដាក់ ចាប់ពីការគាំទ្រផ្នែកភាសា រហូតដល់ការកសាងចំណងទាក់ទងរវាងគ្រួសារ និងសាលារៀន។ រដ្ឋាភិបាលត្រូវចៀសវាងកុំបំបែកការ ទៅសាលាសម្រាប់រយៈពេលវែង ព្រោះអាចធ្វើឱ្យបញ្ហាចន្លោះខ្វះខាត និងការលំបាកមានការកើនឡើងកាន់តែខ្ពស់។

ការជ្រើសរើសផ្អែកលើសមត្ថភាពតាំងពីដំបូង ច្រើនបង្កជាគុណវិបត្តិសម្រាប់សិស្សជាជនចំណាកស្រុក កាត់បន្ថយឱកាស និងនាំទៅដល់វិសមភាព និងពាក់ព័ន្ធច្រើនរវាងសាវតារផ្នែកសង្គម និងលទ្ធផលរបស់សិស្សនៅក្នុងប្រទេសរបស់សិស្ស។ ក្នុងប្រទេសអ៊ីតាលី ៥៩% នៃជនចំណាកស្រុកដែលបានបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាទូទៅ បានឆ្លងភូមិសិក្សាទៅថ្នាក់សាកលវិទ្យាល័យ បើប្រៀបធៀបជាមួយចំនួន ៣៣% នៃសាលាវិជ្ជាជីវៈអាជីព និង ១៣% នៃអ្នកបញ្ចប់ការសិក្សានៅសាលាបច្ចេកទេស។

សិស្សជាជនចំណាកស្រុក ច្រើនតែប្រមូលផ្តុំនៅក្នុងតំបន់ទីប្រជុំជនតូចៗ ហើយសាលារៀន ដែលមានស្តង់ដារការសិក្សារៀនសូត្រ និងលទ្ធផលការងារមានកម្រិតទាប។ ការបំបែកត្រូវបានធ្វើឱ្យកាន់តែអាក្រក់ ដោយសិស្សជនជាតិដើមផ្លាស់ទៅតំបន់ដែលមានទ្រព្យស្តុកស្តម្ភជាង ។ អ្នកពុំមែនជាជនជាតិដើមក្នុងចក្រភពអង់គ្លេស ច្រើនតែទៅរៀននៅសាលារបស់ជនជាតិដើម ដែលជួបការលំបាក ។ ចំណែករបស់ជនចំណាកស្រុក ក៏អាចរារាំងដល់លទ្ធផលការអប់រំរបស់ជនជាតិដើមដែលជួបការលំបាកផងដែរ។ នៅប្រទេសន័រវែស, ការកើនឡើង ១០% នៃចំណែករបស់ជនចំណាកស្រុកនៅក្នុងសាលារៀន គឺពាក់ព័ន្ធជាមួយការកើនឡើង ៣% នៃអត្រាបោះបង់ការសិក្សារបស់ជនម្ចាស់ស្រុក។

ប្រទេសនានាប្រើប្រាស់ឧបករណ៍ផ្សេងៗ ដើម្បីប្រយុទ្ធប្រឆាំងការបំបែកចេញពីគ្នា។ នៅប្រទេសអ៊ីតាលី កម្មវិធីសិក្សាឆ្នាំ ២០១០ បានកំណត់ឱ្យថ្នាក់រៀនមួយ ត្រូវមានជនចំណាកស្រុកជំនាន់ទីមួយយ៉ាងច្រើនបំផុត ៣០% ។ ក្នុងការអនុវត្តជាក់ស្តែង ១៧% នៃថ្នាក់រៀននៅកម្រិតបឋមសិក្សា មានតួលេខលើសការកំណត់។ ថ្វីបើមានគោលនយោបាយ និងកំណែទម្រង់ ដើម្បីដាក់កំហិតការបំបែកចេញពីគ្នាក្នុងសាលារៀនក្តី ប៉ុន្តែ នៅក្នុងប្រទេសបារាំង និងប្រទេសអាល្លឺម៉ង់ ឪពុកម្តាយបានគេចចេញពីសាលាដែលបានកំណត់ ហើយសាលារៀនរកវិធីដើម្បីផ្តល់ការបង្រៀនថ្នាក់ផ្សេងពីគ្នា ផ្អែកលើជម្រើសរបស់ឪពុកម្តាយទៅលើសាសនា ឬការបង្រៀនជាភាសាបរទេស។ ការវិភាគលើតំបន់ចាប់យកសាលាបឋមសិក្សាចំនួន ១០៨ សាលាក្នុងស្រុកចំនួន

បួន នៅក្នុង ប៉ែរឡាំង បង្ហាញថាសាលាមួយក្នុងចំណោមសាលាចំនួន ៥, ចំនួនសិស្សមានសាវតារជាជនចំណាកស្រុកដែលបានចុះឈ្មោះចូលរៀន គឺមានចំនួនទ្វេដងនៃចំនួនអ្នករស់នៅក្នុងតំបន់។

## រដ្ឋាភិបាលមួយចំនួន ផ្តោតគោលដៅការគាំទ្រទៅឱ្យសាលារៀន ដែលមានចំណែកសិស្សជាជនចំណាកស្រុកច្រើន

សាលារៀនដែលមានចំនួនសិស្សជាជនចំណាកស្រុក ឬជាជនភៀសខ្លួនខ្ពស់ ច្រើនតែមានតម្រូវការការផ្តល់មូលនិធិខ្ពស់ជាង។ ការផ្តល់មូលនិធិផ្អែកតាមរូបមន្ត ក្នុងបំណងដើម្បីបង្កើនសមធម៌តាមរយៈការចាត់ធនធានបន្ថែមឱ្យសាលាដែលត្រូវបានកំណត់លក្ខណៈដោយកត្តានានាពាក់ព័ន្ធជាមួយការលំបាកដែលជួបប្រទះ។ កម្មវិធីមួយចំនួនដាក់បញ្ចូលជនចំណាកស្រុក ជាកត្តាបង្ហាញយ៉ាងច្បាស់នៅក្នុងមូលនិធិរបស់សាលា។ នៅប្រទេសលីទុយអានី ហិរញ្ញប្បទានថវិកាសាលារៀនបន្ថែមចំនួន ២០% សម្រាប់សិស្សដែលស្ថិតក្នុងក្រុមជនជាតិភាគតិច និង ៣០% សម្រាប់សិស្សជនចំណាកស្រុកនៅក្នុងឆ្នាំដំបូងនៃការចូលរៀនរបស់ពួកគេនៅក្នុងប្រទេស។

ការអនុវត្តបែបនេះ គឺជាករណីលើកលែង ប៉ុន្តែសិស្សជាជនចំណាកស្រុក និងជនភៀសខ្លួន នៅតែញ៉ាំងឱ្យមានការផ្តល់មូលនិធិបន្ថែមដោយប្រយោល។ ការផ្តល់មូលនិធិអាចត្រូវបានធ្វើឡើង ដោយសារតែសមត្ថភាពទាបនៅក្នុងភាសាបង្រៀន ឬភាពខ្វះខាតផ្នែកសង្គមសេដ្ឋកិច្ចនៅកម្រិតសហគមន៍ ដោយកត្តាទាំងពីរនេះ គឺជាកត្តាដែលច្រើនតែកើតមានជាទូទៅក្នុងចំណោមជនចំណាកស្រុក។ រូបមន្តការផ្តល់មូលនិធិជាតិថ្មីក្នុងប្រទេសអង់គ្លេស (ចក្រភពអង់គ្លេស) លុបបំបាត់ការផ្តល់មូលនិធិដាក់លាក់សម្រាប់ជនចំណាកស្រុក ប៉ុន្តែក៏បានចាត់កញ្ចប់មូលនិធិ ដើម្បីប៉ះប៉ូវសងសម្រាប់ការលំបាកប្រភេទនេះថាជា "ការបាត់បង់" "ការទទួលបានកន្លងមកកម្រិតទាប" និង "ការសិក្សាភាសាអង់គ្លេសបន្ថែម"។

ធនធានបន្ថែមដើម្បីគាំទ្រសិស្សជាជនចំណាកស្រុក និងជនភៀសខ្លួន ជារឿយៗ គឺមានជូនសម្រាប់សាលារៀនលើសពីរូបមន្តការផ្តល់មូលនិធិជាមូលដ្ឋាន។ រដ្ឋាភិបាលដាណឺម៉ាកចាត់ចែងកញ្ចប់ថវិការ ជិត ៣ លានដុល្លារក្នុងឆ្នាំ ២០០៨-២០១១ សម្រាប់សកម្មភាព និងធនធាននានា ដូចជាអ្នកប្រឹក្សាយោបល់នៅសាលារៀន និងនៅផ្ទះ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងគ្រួសារជនចំណាកស្រុកជាមួយសាលារៀន។

ប្រទេសមួយចំនួនផ្តោតគោលដៅការគាំទ្រសម្រាប់កម្មវិធីភាសានៅក្រៅរូបមន្តការផ្តល់មូលនិធិ។កម្មវិធីការទទួលបានភាសាអង់គ្លេសរបស់សហរដ្ឋអាមេរិក ចាត់ចែងថវិកាប្រមាណ ៧៤០ លានដុល្លារក្នុងមួយឆ្នាំនៅក្នុងហិរញ្ញប្បទានរូបមន្តរបស់រដ្ឋផ្អែកលើចំណែកនៃអ្នករៀនភាសាអង់គ្លេស។ សាលារៀនទាញយកការផ្តល់មូលនិធិទាំងនេះ ដើម្បីអនុវត្តការបង្រៀនភាសា។ ការគាំទ្របន្ថែមទៀត ក៏អាចផ្តោតគោលដៅលើគ្រូបង្រៀន ដែលអាចជួបប្រទះការលំបាកទាក់ទងជាមួយសិស្ស និងគ្រួសារជនចំណាកស្រុកផងដែរ។

ការគាំទ្រផ្តោតគោលដៅជាក់លាក់តភ្ជាប់ជាមួយសិស្សជាជនចំណាកស្រុក និងជនភៀសខ្លួន អាចមើលរំលងលើបញ្ហាប្រឈមផ្នែករចនាសម្ព័ន្ធ និងផ្នែករដ្ឋបាលសាលារៀន។ ជនចំណាកស្រុក និងជនភៀសខ្លួនដែលមានកម្រិតការអប់រំទាប ច្រើនតែចងក្រងគ្នាក្នុងសហគមន៍ដែលអាជ្ញាធរសាលារៀនមានបុគ្គលិកខ្សត់ខ្សោយរួចទៅហើយ។ ការផ្តល់ការលើកទឹកចិត្តដើម្បីទាក់ទាញគ្រូបង្រៀនឱ្យមកកាន់សាលាដែលកំពុងមានតម្រូវការ គឺពិបាកសម្រេចបាននៅខាងក្រៅកញ្ចប់ថវិកាសាលារៀនប្រក្រតី។ បន្ថែមលើនេះ សេចក្តីសម្រេចចិត្តផ្នែកនយោបាយ អាចប៉ះពាល់គួរជាទីកត់សម្គាល់ដល់មូលនិធិបណ្តោះអាសន្ន ឬការគាំទ្រថវិកាបន្ថែមសម្រាប់កម្មវិធីនានា ដូចជាក្នុងសហរដ្ឋអាមេរិកជាដើម។

## កម្មវិធីអក្ខរកម្ម និងកម្មវិធីភាសា គឺជាសសរស្តម្ភនៃបរិយាបន្នសម្រាប់ជនចំណាកស្រុក និងជនភៀសខ្លួនជាមនុស្សពេញវ័យ

បំណិនអានរបស់ជនចំណាកស្រុក និងជនភៀសខ្លួន មានភាពខុសៗគ្នាយ៉ាងខ្លាំង។ ការស្ទាបស្ទង់មតិមួយទៅលើអ្នកស្វែងរកសិទ្ធិជ្រកកោន ក្នុងប្រទេសអាល្លឺម៉ង់ ក្នុងឆ្នាំ ២០១៦ បានបង្ហាញឱ្យឃើញថា អ្នកស្វែងរកសិទ្ធិជ្រកកោន ១៥% ពុំចេះអាន ឬសរសេរទេ ៣៤% ចេះអានសរសេរជាអក្សរឡាតាំង និង ៥១% ចេះអានសរសេរនៅក្នុងសំណេរណាមួយផ្សេងទៀត។ ការចេះអានសរសេររបស់មនុស្សពេញវ័យ អាចបង្កើនអារម្មណ៍ថា បានទទួលការស្វាគមន៍ និងភាពជាផ្នែកមួយនៃសហគមន៍របស់ជនចំណាកស្រុក និងជនភៀសខ្លួន ព្រមទាំងសមត្ថភាពរបស់ពួកគេដើម្បីប្រាស្រ័យទាក់ទង និងឆ្លើយតបសេចក្តីត្រូវការប្រចាំថ្ងៃ។ សមត្ថភាពកាន់តែខ្ពស់ក្នុងការប្រើប្រាស់ភាសារបស់ប្រទេសម្ចាស់ផ្ទះ គឺពាក់ព័ន្ធជាមួយការមានឱកាសការងារកាន់តែច្រើនឡើង រកចំណូលបានកាន់តែច្រើន និងស្វ័យរាយការណ៍អំពីសុខភាពកាន់តែប្រសើរ។ ទោះយ៉ាងណាក្តី កម្មវិធីអក្ខរកម្មសាធារណៈទ្រង់ទ្រាយធំ ផ្តោតគោលដៅទាំងទៅលើជនចំណាកស្រុក និងជនភៀសខ្លួនជាមនុស្សពេញវ័យ គឺនៅមានភាពស្តួចស្តើងនៅឡើយ។

ដោយការទទួលស្គាល់ភាពចម្រុះគ្នារបស់ជនចំណាកស្រុក និងជនភៀសខ្លួន កម្មវិធីចាំបាច់ត្រូវមានភាពបត់បែន ហើយភាពខ្លាំងក្លា និងខ្លឹមសារ ព្រមទាំងកាលវិភាគរបស់កម្មវិធីទាំងនោះ គួរមានលក្ខណៈចម្រុះគ្នាផងដែរ។ អ្នកសិក្សាដែលពុំចេះអានសរសេរភាសាកំណើតរបស់ខ្លួន ជួបបញ្ហាប្រឈមជាពិសេស។ ការប៉ាន់ប្រមាណមួយស្នើឡើងថា អ្នកដែលពុំមានការអប់រំផ្លូវការ ឬមានការអប់រំផ្លូវការទាប អាចត្រូវចំណាយពេលប្រាំបីដងយូរជាងអ្នកផ្សេងទៀត ដើម្បីអាចឈានដល់កម្រិតមូលដ្ឋាននៃការចេះអានភាសាទីពីរ។ ក្នុងប្រទេសហ្វាំងឡង់ ល្បឿនការសិក្សាយឺតយ៉ាវ មានន័យថា ការបណ្តុះបណ្តាលដែលត្រូវបានផ្តល់ឱ្យ អាចមានរយៈពេលខ្លីពេកសម្រាប់មនុស្សពេញវ័យដែលមិនចេះអានសរសេរ។

ដើម្បីជួយអ្នកសិក្សាប្រភេទនេះ គ្រូត្រូវការជំនាញក្នុងការប្រើប្រាស់សម្ភារៈដែលឆ្លើយតបចំពោះបញ្ហាប្រឈមដែលជនចំណាកស្រុកជួបប្រទះនៅក្នុងជីវិតប្រចាំថ្ងៃ។ នៅក្នុងកម្មវិធី Vienna's AlfaZentrum für MigrantInnen អ្នកសិក្សាផ្តល់សម្ភារៈពីកន្លែងធ្វើការ ឬផ្ទះ ដែលពួកគេចង់យល់។

ការរៀន និងការបង្រៀននៅក្នុងភាសាទីមួយរបស់ជនចំណាកស្រុកពេញវ័យ អាចជាវិធីប្រកបដោយប្រសិទ្ធភាពមួយ ដើម្បីគាំទ្រដល់ការទទួលបានសមត្ថភាពចេះអានសរសេរដំបូងរបស់ពួកគេ។ ក្នុងប្រទេសន័រវែស មជ្ឈមណ្ឌលសិក្សាជនពេញវ័យ បានចាប់ផ្តើមធ្វើការជាមួយអ្នកសិក្សាជាជនចំណាកស្រុកមានការអប់រំខ្ពស់បំផុត ជាជំនួយការនៅក្នុងថ្នាក់អក្ខរកម្មបឋម ដើម្បីបិទភ្ជិតការលំបាកក្នុងការយល់រវាងគ្រូ និងអ្នកសិក្សា។

ការមានមូលនិធិមិនគ្រប់គ្រាន់អាចដាក់ដែនកំណត់លើការអនុវត្តកម្មវិធីជាពិសេស ប្រសិនបើធនធាន និងការគាំទ្ររបស់រដ្ឋាភិបាល ពុំបន្សីជាមួយគោលនយោបាយ ដូចជានៅក្នុងចក្រភពអង់គ្លេសជាដើម។ ភាពក្រីក្រ កង្វល់ផ្នែកសន្តិសុខ និងកង្វះកម្មវិធីដែលមានលក្ខណៈសមស្របផ្នែកវប្បធម៌ អាចបន្ទចប់បង្អាក់ដល់បុគ្គល ជាពិសេសស្ត្រី មិនឱ្យទៅសាលារៀន។ ការប្រមូលផ្តុំអ្នកមកដល់ថ្មីៗនៅក្នុងសហគមន៍យោងទៅតាមភាសា ជាតិពន្ធុ អាចកាត់បន្ថយការសិក្សាភាសា ដោយសារតម្រូវការនៃការជួបជាមួយភាសានោះមានកម្រិតកំណត់។ ម៉្យាងវិញទៀត លក្ខណៈជាបណ្តោះអាសន្ននៃចំណាកស្រុកមួយចំនួន អាចកាត់បន្ថយការជំរុញទឹកចិត្តឱ្យរៀនសូត្រភាសាថ្មី។

កម្មវិធីភាសា គួរតែមានលក្ខណៈអាចកែសម្រួល យកចិត្តទុកដាក់ចំពោះផ្នែកវប្បធម៌ និងមានធនធានគ្រប់គ្រាន់។ ការដាក់បញ្ចូលជនចំណាកស្រុក និងជនភៀសខ្លួនទៅក្នុងការធ្វើផែនការ និងការបង្រៀនអាចជួយបានផងដែរ។ នៅក្នុងការតាក់តែងកម្មវិធីរបស់ប្រទេសនូវែលសេឡង់ រដ្ឋាភិបាលបានពិគ្រោះយោបល់ជាមួយអតីតជនភៀសខ្លួន និងជនភៀសខ្លួននាពេលបច្ចុប្បន្នទៅលើលក្ខណសម្បត្តិគួរជាទីចង់បាននៃវគ្គសិក្សា និងឧបសគ្គដែលអាចរារាំងលទ្ធភាពទទួលបានការសិក្សា។

ដោយហេតុថា មុខរបរគឺជាអាទិភាពរបស់ជនចំណាកស្រុក និងជនភៀសខ្លួននៅពេលទើបមកដល់ភ្លាម ការរួមបញ្ចូល និងការទទួលបានចំណេះដឹងផ្នែកភាសា អាចផ្សារភ្ជាប់ជាមួយការចូលរួមក្នុងកម្លាំងពលកម្ម។ ក្នុងប្រទេសកាប់វែរ ( Cabo Verde) កម្មវិធីលើកកម្ពស់អក្ខរភាព និងការបណ្តុះបណ្តាលរបស់ជនចំណាកស្រុកនៅក្នុងសហគមន៍អាហ្វ្រិករស់នៅក្នុងកាប់វែរ ( Cabo Verde) គ្របដណ្តប់លើថ្នាក់អក្ខរកម្ម ថ្នាក់ភាសាព័រទុយហ្គាល់ ( Portugual) និងការបណ្តុះបណ្តាលវិជ្ជាជីវដូចជាជំនាញកុំព្យូទ័រ និងជាងឈើជាដើម។ វគ្គសិក្សាការរួមបញ្ចូលរបស់រដ្ឋាភិបាលអាល្លឺម៉ង់ ( German ) ដាក់បញ្ចូលការបង្រៀនភាសាអាល្លឺម៉ង់ ( German ) រយៈពេល ៦០០ម៉ោង ហើយជនភៀសខ្លួនដែលឈានដល់កម្រិតសមត្ថភាព B1 មានលក្ខណសម្បត្តិទទួលបានការបណ្តុះបណ្តាលភាសាពាក់ព័ន្ធជាមួយការងារ។

## ជនចំណាកស្រុកត្រូវការទទួលយកការអប់រំផ្នែកហិរញ្ញវត្ថុ

ចំណេះដឹងផ្នែកហិរញ្ញវត្ថុ មានកម្រិតទាបនៅក្នុងបណ្តាប្រទេសបញ្ចូលពលករតាមបែបប្រពៃណីជាច្រើន និងក្នុងសហគមន៍ជនចំណាកស្រុកមានជំនាញទាបដែលធ្វើឱ្យជនចំណាកស្រុក និងជនភៀសខ្លួនមានឱកាសត្រូវបានគេបោកបន្លំ ឬកេងប្រវ័ញ្ចន៍ផ្នែកហិរញ្ញវត្ថុ។ ដោយឡែក ប្រព័ន្ធហិរញ្ញវត្ថុ និងសុខុមាលភាពក្នុងប្រទេសម្ចាស់ផ្ទះ ក៏ដូចជាបណ្តាញបញ្ជូនសាច់ប្រាក់នៅពេលដំបូង អាចមានលក្ខណៈស្រពិចស្រពិល។

ការផ្តួចផ្តើមគំនិតថ្នាក់សាកល ដូចជាបណ្តាញអន្តរជាតិ OECD ស្តីពីការអប់រំផ្នែកហិរញ្ញវត្ថុ ដាក់បញ្ចូលការផ្តោតការយកចិត្តទុកដាក់លើជនចំណាកស្រុក ជាផ្នែកមួយនៃរបៀបវារៈទូលំ ទូលាយ ដើម្បីលើកកម្ពស់បរិយាបន្ន ផ្នែកហិរញ្ញវត្ថុ។ កម្មវិធីអប់រំហិរញ្ញវត្ថុសម្រាប់ជនចំណាកស្រុក ជារឿយៗ តែងមានបន្សំរវាងភាគីពាក់ព័ន្ធអន្តរជាតិ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន។

ប្រទេសឥណ្ឌូណេស៊ី បានអនុញ្ញាតឱ្យមានយុទ្ធសាស្រ្តចំណេះដឹងហិរញ្ញវត្ថុថ្នាក់ជាតិក្នុងឆ្នាំ ២០១៣។ យុទ្ធសាស្រ្តនេះ ផ្អែកលើភស្តុតាងបង្កើតឡើងដោយកម្មវិធីរួមគ្នាមួយជាមួយធនាគារពិភពលោក ដោយការបណ្តុះបណ្តាលផ្តោតគោលដៅលើចំណុចពេលវេលាដែលជនចំណាកស្រុកជាសក្តានុពល ត្រូវជួបប្រទះការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុធំៗ។ មូលនិធិ Morocco សម្រាប់ការអប់រំផ្នែកហិរញ្ញវត្ថុ បានចាប់ដៃគូជាមួយអង្គការអន្តរជាតិខាងពលកម្ម ដើម្បីបង្កើតកម្មវិធីអប់រំផ្នែកហិរញ្ញវត្ថុសម្រាប់ជន ចំណាកស្រុកនៅ Morocco ។ ក្នុងប្រទេសរូម៉ានី អង្គការទេសន្តប្រវេសន៍អន្តរជាតិ បានដាក់សម្ពោធការផ្តួចផ្តើមគំនិតរួមគ្នាមួយជាមួយមូលនិធិ MasterCard ដើម្បីគាំទ្រការដាក់បញ្ចូលជនចំណាកស្រុក និងជនភៀសខ្លួន ចាត់អាទិភាពក្រុមងាយរងគ្រោះ រួមទាំងកុមារ ស្រ្តី និងជនមានតម្រូវពិសេស។

សូម្បីតែអ្នកដែលមានចំណេះដឹងល្អផ្នែកហិរញ្ញវត្ថុហើយក្តី ក៏ជនចំណាកស្រុកទាំងនោះប្រហែលជាមិនទាន់យល់ច្បាស់អំពីសព្វហិរញ្ញវត្ថុ និងលក្ខណសម្បត្តិនៃផលិតផលហិរញ្ញវត្ថុនៅឡើយ។ ពួកគេអាចខ្វះទំនុកចិត្តចំពោះស្ថាប័នហិរញ្ញវត្ថុទាំងនៅក្នុងស្រុក និងនៅប្រទេសម្ចាស់ផ្ទះ។ ជនចំណាកស្រុកគ្មានឯកសារត្រឹមត្រូវ និងជនភៀសខ្លួនដែលទើបមកដល់ថ្មី ជារឿយៗតែងភ័យខ្លាចថា ព័ត៌មានដែលត្រូវបានស្នើសុំដើម្បីមានលទ្ធភាពចូលទៅរកសេវាហិរញ្ញវត្ថុ នឹងត្រូវបានប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណ និងមានសក្តានុពលបញ្ជូន ពួកគេត្រលប់ទៅស្រុកកំណើតវិញ។ ឧស្សាហកម្មហិរញ្ញវត្ថុខ្វះខាតផលិតផលដែលមានលក្ខណៈពាក់ព័ន្ធ និងយកចិត្តទុកដាក់ចំពោះផ្នែកវប្បធម៌សម្រាប់ជនចំណាកស្រុក និងសម្រាប់គ្រួសាររបស់ពួកគេដែលនៅឯស្រុកកំណើត។

ភស្តុតាងស្តីពីផលប៉ះពាល់នៃការអប់រំផ្នែកហិរញ្ញវត្ថុលើសុខុមាលភាពសេដ្ឋកិច្ចរបស់ជនចំណាកស្រុក គឺមានរួមទាំងល្អផង និងមិនល្អផង។ ការសិក្សាមួយទៅលើជនចំណាកស្រុកឥណ្ឌាក្នុងប្រទេសកាតា រកឃើញថាការអប់រំផ្នែកហិរញ្ញវត្ថុ មានផលប៉ះពាល់ បើទោះបីជាតិចតួចក្តីទៅលើការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ។ ការសិក្សានៅប្រទេសអូស្ត្រាលី និងនូវែលសេឡង់ រកឃើញថា កម្មវិធីចំណេះដឹងហិរញ្ញវត្ថុពុំជះឥទ្ធិពលគួរជាទីកត់សម្គាល់លើការប្រើប្រាស់ប្រព័ន្ធធនាគារផ្លូវការឡើយ។

# ការផ្លាស់ទីលំនៅដោយបង្ខំ

ចំនួនប្រជាជនដែលផ្លាស់ទីលំនៅដោយបង្ខំគឺ ស្ថិតក្នុងកម្រិតខ្ពស់បំផុត ចាប់តាំងពីចុងសង្គ្រាមលោកលើកទី២ មក។ ប្រជាជនដែលផ្លាស់ទីលំនៅដោយបង្ខំ ច្រើនតែមកពីបណ្តាប្រទេសដែលក្រីក្របំផុត និងមានសេវាតិចតួចបំផុតក្នុងពិភពលោក ហើយភាពងាយរងគ្រោះរបស់ពួកគេ ត្រូវបានធ្វើឱ្យកាន់តែអាក្រក់ឡើង នៅពេលដែលការផ្លាស់ទីលំនៅដោយបង្ខំ ដកហូតការអប់រំពីពួកគេ។

> ភាពងាយរងគ្រោះនៃប្រជាជនខ្វាត់ខ្វាយពីផ្ទះសម្បែងដោយបង្ខំ គឺត្រូវបានធ្វើឱ្យកាន់តែអាក្រក់ឡើងថែមទៀត ពេលការអប់រំរបស់ពួកគេត្រូវបានដកហូត

មានជនភៀសខ្លួន ១៩,៩លាននាក់ស្ថិតក្រោមការការពាររបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) ដោយក្នុងនោះ ៥២% គឺមានអាយុក្រោម១៨ឆ្នាំ។មានជនភៀសខ្លួនប៉ាឡេស្ទីន(Palestine) ចំនួន ៥,៤ លាននាក់ស្ថិតក្រោមការការពាររបស់ទីភ្នាក់ងារសង្គ្រោះ និងការងាររបស់អង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួនប៉ាឡេស្ទីននៅតំបន់អាយបូព៌ា(UNRWA)។ប្រមាណ៣៩%នៃជនភៀសខ្លួនរស់នៅក្នុងជំរំដែលស្ថិតក្រោមការគ្រប់គ្រងជំរុំតាំងនៅដោយខ្លួនឯងឬជំរំឆ្លងកាត់ឬមជ្ឈមណ្ឌលប្រមូលផ្តុំក្នុងអនុតំបន់សាហារ៉ានៃទ្វីបអាហ្វ្រិក។ ចំណែកភាគច្រើននៃអ្នកដែលនៅសល់ រស់នៅក្នុងលំនៅជាបុគ្គលនៅក្នុងតំបន់ទីប្រជុំជន។ បន្ថែមលើនេះ ជម្លោះបានបន្សល់ទុកប្រជាជនដែលត្រូវផ្លាស់ទីលំនៅដោយបង្ខំនៅក្នុងប្រទេស (IDPs) ចំនួន ៤០លាននាក់ ដោយចំនួនភាគច្រើនរស់នៅក្នុងសាធារណរដ្ឋស៊ីរីអារ៉ាប់ ចំណែកប្រជាជនចំនួន ១៩ លាននាក់ ទៀតត្រូវបានផ្លាស់ទីលំនៅដោយបង្ខំដោយសារគ្រោះធម្មជាតិ ដោយក្នុងនោះប្រទេសចិន មានចំនួនប្រជាជនប្រភេទនេះ ច្រើនជាងគេបំផុត។

# ការអប់រំសម្រាប់ប្រជាជនផ្លាស់ទីលំនៅដោយបង្ខំដំបូងមានលទ្ធភាពទទួលបាន និងគុណភាពស្ថិតនៅពីក្រោយអ្នកដទៃ

ការកំណត់ស្ថានភាពការអប់រំរបស់ប្រជាជនផ្លាស់ទីលំនៅដោយបង្ខំ គឺជាបញ្ហាប្រឈម ប៉ុន្តែអង្គការ UNHCR ប៉ាន់ប្រមាណសមាមាត្រការចុះឈ្មោះចូលរៀនរបស់ជនភៀសខ្លួនក្នុងកម្រិត ៦១% នៅថ្នាក់បឋមសិក្សា និង ២៣% នៅថ្នាក់មធ្យមសិក្សា។ នៅក្នុងបណ្តាប្រទេសមានចំណូលទាប សមាមាត្រនេះ គឺទាបជាង ៥០% ក្នុងថ្នាក់បឋមសិក្សា និង១១% នៅថ្នាក់មធ្យមសិក្សា (រូបភាពទី៣)។ ជាទូទៅជនភៀសខ្លួនប្រមាណ ៤ លាននាក់ ដែលមានអាយុ ៥ ដល់ ១៧ឆ្នាំ គឺស្ថិតនៅក្រៅសាលារៀនក្នុងឆ្នាំ ២០១៧។

**រូបភាពទី ៣៖**

**មានតែមនុស្សវ័យជំទង់ជាជនភៀសខ្លួន ១១% ប៉ុណ្ណោះ ក្នុងបណ្តាប្រទេសមានចំណូលទាបដែលបានចុះឈ្មោះ ចូលរៀនក្នុងថ្នាក់មធ្យមសិក្សា**

ភាគរយនៃជនភៀសខ្លួនអាយុ ៥ ដល់ ១៧ ឆ្នាំ ដែលបានចុះឈ្មោះចូលរៀនចែកទៅតាមកម្រិតការអប់រំឆ្នាំ ២០១៧




GEM StatLink: http://bit.ly/fig4_2

ប្រភព៖ UNHCR (2018).

សមាមាត្រការចុះឈ្មោះចូលរៀនរបស់ជនភៀសខ្លួន អាចមានភាពខុសប្លែកគ្នាគួរជាទីកត់សម្គាល់នៅក្នុងបណ្តាប្រទេសនានា។ក្នុងឆ្នាំ ២០១៦ សមាមាត្រចុះឈ្មោះចូលរៀនដុលនៅថ្នាក់មធ្យមសិក្សាសម្រាប់ជនភៀសខ្លួនសម្រាប់ប្រទេសអេត្យូពី ចែកទៅតាមស្រុកស្ថិតក្នុងលំដាប់ចាប់ពី ១% នៅក្នុងស្រុក Samara ដល់ ៤៧% ក្នុងស្រុក Jijiga ។ នៅប្រទេសប៉ាគីស្ថាន អត្រាចុះឈ្មោះចូលរៀនសុទ្ធសាធថ្នាក់បឋមសិក្សាក្នុងឆ្នាំ ២០១១ របស់ជនភៀសខ្លួន Afghan (២៩%) គឺតិចជាងពាក់កណ្តាលនៃកម្រិតថ្នាក់ជាតិ (៧១%) ចំណែកអត្រាការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីជនភៀសខ្លួនជនជាតិ Afghan (១៨%) មិនបានស្មើពាក់កណ្តាលផងនៃអត្រារបស់ក្មេងប្រុស (៣៤%) ប៉ុន្តែក៏តិចជាងពាក់កណ្តាលនៃអត្រាការចូលរៀនថ្នាក់បឋមសិក្សារបស់ក្មេងស្រីជនជាតិ Afghan ។ ជនភៀសខ្លួន ជារឿយៗបានមកដល់ក្នុងតំបន់មានសេវាមិនគ្រប់គ្រាន់ក្នុងប្រទេសម្ចាស់ផ្ទះ។ ជនភៀសខ្លួនមកពីប្រទេសស៊ូដង់ខាងត្បូង ដែលចូលមករស់នៅក្នុងប្រទេសអ៊ូហ្គង់ដា តាំងលំនៅក្នុងអនុតំបន់ក្រីក្រនៅតំបន់ទន្លេនីលខាងលិច ដោយនៅក្នុងនោះ អត្រាការចូលរៀនថ្នាក់មធ្យមសិក្សាសុទ្ធសាធ គឺតិចជាងពាក់កណ្តាលនៃអត្រាថ្នាក់ជាតិឆ្នាំ ២០១៦។

មិនសូវមានព័ត៌មានច្រើនទេស្តីពីគុណភាពនៃការអប់រំរបស់ជនភៀសខ្លួន ប៉ុន្តែយោងតាមទិន្នន័យដែលមានរូបភាពនៃគុណភាពការអប់រំហាក់ ដូចជាខ្សោយស្រអាប់យ៉ាងខ្លាំង។ នៅក្នុងជំរុំជនភៀសខ្លួន Dadaab ក្នុងប្រទេសកេនយ៉ា ៨% នៃគ្រូបង្រៀនថ្នាក់បឋមសិក្សា គឺជាគ្រូបង្រៀនមានវិញ្ញាបនបត្របញ្ជាក់ ថ្នាក់ជាតិ ហើយគ្រូ ៦នាក់ក្នុងចំណោមគ្រូជនភៀសខ្លួន ១០នាក់ គឺពុំមានការបណ្តុះបណ្តាលឡើយ។

### ការពិនិត្យតាមដានច្រកអប់រំរបស់ប្រជាជនដែលផ្លាស់ទីលំនៅដោយបង្ខំគឺ មានការលំបាក

ក្នុងបណ្តាប្រទេសជាច្រើនដែលរងផលប៉ះពាល់ដោយជម្លោះ ការផ្លាស់ទីលំនៅដោយបង្ខំក្នុងប្រទេសបង្កឱ្យមានភាពតឹងតែងចំពោះប្រព័ន្ធអប់រំដែលជួបការលំបាកស្រាប់ទៅហើយ។ នៅភាគឦសានប្រទេសនីហ្សេរីយ៉ា ការវាយតម្លៃសេចក្តីត្រូវការការអប់រំលើកចុងក្រោយបំផុតបានរកឃើញថា ក្នុងចំណោមសាលារៀនចំនួន ២៦០ កន្លែង ២៨% បានរងការខូចខាតដោយសារគ្រាប់កាំភ្លើងគ្រាប់បែក ឬកម្ទេចគ្រាប់, ២០% ត្រូវបានគេដុតឱ្យឆេះដោយចេតនា, ៣២% ត្រូវបានគេលួចយកទ្រព្យសម្បត្តិ និង ២៩% នៅកៀកជាមួយក្រុមប្រដាប់អាវុធ ឬយោធា។

អង្គការ UNHCR បានរាយការណ៍ថាប្រជាជន ១,៨ លាននាក់ ត្រូវផ្លាស់ទីលំនៅដោយបង្ខំនៅប្រទេសអ៊ុយក្រែន គិតត្រឹម ខែ មករា ឆ្នាំ ២០១៨។ នៅតំបន់ Dnipro, Kharkiv, Kiev និង Zaporizhzhia ដែលជាកន្លែងមាន IDPs ច្រើនជាងគេបំផុតស្ថាប័នអប់រំជួបប្រទះកង្វះខាតទីកន្លែងសាលារៀន និងធនធាន។ ជាកិច្ចឆ្លើយតប រដ្ឋាភិបាលបានបង្កើតសាលារៀនបន្ថែម ផ្លាស់ទីសាកលវិទ្យាល័យរដ្ឋចេញពីតំបន់មានជម្លោះ ធ្វើឱ្យនីតិវិធីទទួលចូលរៀនមានភាពសាមញ្ញ ចេញថ្លៃចុះឈ្មោះចូលរៀន និងផ្តល់ការលើកទឹកចិត្ត រួមទាំងកម្ចីសៀវភៅពុម្ពដែលសម្រាប់ IDP។

គ្រោះធម្មជាតិក៏រំខានដល់ការអប់រំដែរ ជាពិសេសនៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិច។ ព្យុះទីហ្វុងជាមធ្យមចំនួន ២០ លើកក្នុងមួយឆ្នាំ នៅក្នុងប្រទេសហ្វីលីពីន ព្រមទាំងហានិភ័យខ្ពស់ចំពោះបន្ទុះភ្នំភ្លើង ការរញ្ជួយដី និងការបាក់ធ្លាក់ដី។ ប្រទេសនេះបានចាត់វិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ហើយសាលារៀនធន់ជាមួយព្យុះទីហ្វុង ដែលមានបំពាក់ដោយធនធានបង្រៀន បាននាំឱ្យមានការកើនឡើងនៃការអប់រំចំនួន ០,៣ ឆ្នាំ។

## មានភាពចាំបាច់ក្នុងការដាក់បញ្ចូលជនភៀសខ្លួននៅក្នុងប្រព័ន្ធអប់រំថ្នាក់ជាតិ

ដោយជួបជាមួយវិបត្តិ ការឆ្លើយតបបែបឆ្លុះបញ្ចាំងរបស់រដ្ឋាភិបាលច្រើន គឺផ្តល់ការអប់រំជូនដល់ជនភៀសខ្លួននៅក្នុងប្រព័ន្ធដើរទន្ទឹមគ្នា។ ប៉ុន្តែមតិជាឯកច្ឆន្ទបានលើកឡើងថា ការធ្វើបែបនេះ ពុំមែនជាដំណោះស្រាយប្រកបដោយនិរន្តរភាពនោះទេ។ ការខ្វាត់ខ្វាយពីផ្ទះសម្បែង ជារឿយៗតែងមានភាពអូសបន្លាយ។ ប្រព័ន្ធដើរទន្ទឹមគ្នាតាមធម្មតា តែងខ្វះគ្រូដែលមានគុណវុឌ្ឍិ។ ការប្រឡងពុំអាចមានវិញ្ញាបនបត្របញ្ជាក់បាន។ប្រភពការផ្តល់មូលនិធិប្រឈមហានិភ័យដែលអាចត្រូវបានកាត់ចេញក្រោយពីមានការជូនដំណឹងរយៈពេលខ្លី។

យុទ្ធសាស្ត្រអប់រំសាកលរបស់អង្គការ UNHCR ឆ្នាំ ២០១២-២០១៦ បានជំរុញបណ្តាប្រទេសនានាជាលើកដំបូង ផ្តល់លទ្ធភាពជូនដល់កុមារជនភៀសខ្លួននូវឱកាសការសិក្សារៀនសូត្រដែលមានការទទួលស្គាល់គុណភាព និងមានវិញ្ញាបនបត្របញ្ជាក់ត្រឹមត្រូវ ដើម្បីអនុញ្ញាតឱ្យពួកគេអាចបន្តការអប់រំបាន។ គោលបំណងរបស់យុទ្ធសាស្ត្រនេះគឺ ដើម្បី អាចដាក់បញ្ចូលជនភៀសខ្លួនយ៉ាងពេញលេញនៅក្នុងប្រព័ន្ធអប់រំជាតិ ដើម្បីឱ្យពួកគេអាចសិក្សាក្នុងថ្នាក់រៀនតែមួយជាមួយកុមារក្នុងប្រទេសម្ចាស់ផ្ទះ បន្ទាប់ពីមានថ្នាក់បំប៉នបន្ថែមរយៈពេលខ្លីតាមការចាំបាច់ ដើម្បីពួកគេអាចត្រៀមខ្លួនចូលសាលារៀននៅក្នុងកម្រិតអាយុសមស្របទៅតាមកម្រិតថ្នាក់រៀន។ ប៉ុន្តែកម្រិតនៃបរិយាប័ន្នជនភៀសខ្លួនមានភាពប្លែកៗគ្នាទៅតាមបរិបទនៃការផ្លាស់ទីលំនៅដោយបង្ខំបែបនេះ។ ភូមិសាស្ត្រ ប្រវត្តិសាស្ត្រ ធនធានដែលមាន និងសមត្ថភាពប្រព័ន្ធ គឺសុទ្ធតែជះឥទ្ធិពលលើលក្ខណៈប្រែប្រួលឥតឈប់ឈររបស់បរិយាប័ន្ន។

> “កម្រិតនៃការដាក់បញ្ចូលជនភៀសខ្លួនមានលក្ខណៈខុសៗគ្នាក្នុងបរិបទនៃការផ្លាស់ទីលំនៅដែលត្រូវបានរងផលប៉ះពាល់ដោយភូមិសាស្ត្រ ប្រវត្តិសាស្ត្រ លទ្ធភាពប្រើប្រាស់ធនធាន និងសមត្ថភាពប្រព័ន្ធ”

ក្នុងករណីមួយចំនួន ការផ្លាស់ទីឈានទៅរកបរិយាប័ន្ន គឺមានលក្ខណៈសន្សឹមៗ។ ប្រទេសតួកគី ដែលជាម្ចាស់ផ្ទះទទួលជនភៀសខ្លួនចំនួន ៣,៥ លាននាក់ បានផ្តល់ការទទួលស្គាល់គុណភាពលើកដំបូងដល់សាលារៀនមិនមែនជារបស់រដ្ឋ ជាមជ្ឈមណ្ឌលអប់រំបណ្តោះអាសន្ន បន្ទាប់មក ចាត់ចំណាត់ប្រភេទសាលាទាំងនោះជាសាលារៀនក្នុងដំណាក់កាលអន្តរកាលហើយនៅត្រឹមឆ្នាំ ២០២០ នឹងដាក់បញ្ចូលកុមារស៊ីរីទាំងអស់ទៅក្នុងសាលារៀនសាធារណៈ។ ក្នុងករណីដទៃទៀត ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលមានលក្ខណៈមិនជាប់លាប់។ នៅក្នុងសាធារណៈរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ គោលនយោបាយក្នុងការដាក់បញ្ចូលជនភៀសខ្លួន Afghan បានជួបជាមួយការឈានថយក្រោយម្តងម្កាលក្នុងអំឡុង ៤ ទសវត្សកន្លងទៅ។

ក្នុងករណីជាច្រើន គេពុំអាចសម្រេចបានបរិយាបន្នពេញលេញឡើយ ថ្វីបើមានការប្តេជ្ញាចិត្តក្នុងការស្ថាបនាបរិយាបន្ន ពេញលេញក្តី។ ជនភៀសខ្លួនអាចប្រើប្រាស់តាមវិធីសិក្សា ការវាយតម្លៃ និងភាសានៃការបង្រៀនរួមជាមួយប្រទេសម្ចាស់ផ្ទះ ប៉ុន្តែមានតែមួយផ្នែកប៉ុណ្ណោះដែលត្រូវបានដាក់បញ្ចូល អាស្រ័យដោយការញែកពីគ្នាផ្នែកភូមិសាស្ត្រ ដូចជាក្នុងជំរុំនៅប្រទេសកេនយ៉ា ឬកង្វះខាតសមត្ថភាព ដូចជានៅក្នុងសាលារៀនពីរវេនក្នុងប្រទេសលីបង់ និង ហ្ស៊កដានី ។ សូម្បីតែនៅក្នុងប្រទេសមានធនធានច្រើន ដូចជានៅប្រទេសក្រិកជាដើម ក៏ជួបប្រទះបញ្ហាប្រឈមក្នុងការផ្តល់ការអប់រំដល់ជនភៀសខ្លួនតាមរយៈប្រព័ន្ធថ្នាក់ជាតិផងដែរ។

ក្នុងបរិបទជាច្រើន ការអប់រំរបស់ជនភៀសខ្លួន គឺនៅតែត្រូវបានផ្តល់ឱ្យដាច់ដោយឡែក។ ប្រព័ន្ធការអប់រំប៉ាឡេស្ទីន គឺជាករណីពិសេសខុសប្លែកពីគេ។ ជនភៀសខ្លួនប៊ូរុនឌីនៅក្នុងសាធារណៈរដ្ឋសហភាពតង់សានី និងជនភៀសខ្លួនការ៉ែនមកពីប្រទេសមីយ៉ាន់ម៉ានៅក្នុងប្រទេសថៃ ចូលរៀននៅក្នុងសាលានៅតាមសហគមន៍ក្រៅប្រព័ន្ធដាច់ដោយឡែក ឬនៅសាលាឯកជន។

## មានឧបសគ្គជាច្រើនចំពោះបរិយាប័ន្នដែលចាំបាច់ត្រូវជម្នះ

ការលំបាកនានាទាក់ទងជាមួយការរួមបញ្ចូលជនភៀសខ្លួននៅក្នុងប្រព័ន្ធការអប់រំថ្នាក់ជាតិ គឺជាបញ្ហាដ៏ស្រួចស្រាវមួយនៅក្នុងបរិបទដែលសមត្ថភាពខ្សោយ ហើយតម្រូវការឱ្យមានការសម្របសម្រួល និងការធ្វើផែនការខ្ពស់។ ផែនការចាំបាច់ត្រូវទទួលស្គាល់បញ្ហានានា រាប់ចាប់តាំងពីកង្វះឯកសាររហូតដល់សមត្ថភាពផ្នែកភាសាមានកម្រិតកំណត់ និងរាប់ចាប់តាំងពីការរំខានដល់គន្លងវិថីការអប់រំរហូតដល់ភាពក្រីក្រ។

> កង្វះឯកសារតាមការតម្រូវ ឧបសគ្គផ្នែកភាសា ការខកខានមិនបានទទួលការអប់រំ និងការចំណាយលាក់មុខ តែងរាងរាំងដល់បរិយាបន្នពេញលេញ។

វិទ្យាស្ថានអន្តរជាតិសម្រាប់ការធ្វើផែនការការអប់រំរបស់អង្គការ យូណេស្កូ បានបង្កើតគោលការណ៍ណែនាំ ស្តីពីផែនការអប់រំអន្តរកាលដែលផ្តោតការយកចិត្តទុកដាក់លើសេចក្តីត្រូវការចំពោះមុខ និងការដាក់បញ្ចូលជនភៀសខ្លួន និង IDPs។ ប្រទេសឆាដ គឺជាប្រទេសដំបូង ដែលបានអភិវឌ្ឍឱ្យមានផែនការប្រភេទនេះក្នុងឆ្នាំ២០១៣។ក្នុងឆ្នាំ២០១៨រដ្ឋាភិបាលបានបង្វែរសាលាចំនួន ១០៨ កន្លែងក្នុងជំរុំចំនួន ១៩ និងទីតាំងជនភៀសខ្លួនឱ្យទៅជាសាលារៀនសាធារណៈជាប្រក្រតី។

ជារឿយៗ ជនភៀសខ្លួនតែងខ្វះឯកសារដែលធ្វើឱ្យមានការលំបាកក្នុងការចូលទៅរកប្រព័ន្ធអប់រំជាតិ។ ក្នុងប្រទេសហ្ស៊ែកដានី (Jordan) ជនភៀសខ្លួនត្រូវការ "កាតសេវា" ដើម្បីអាចទៅសាលារៀន ហើយត្រូវទទួលបានលិខិតបញ្ជាក់សំបុត្រកំណើតដែលជាការតម្រូវ។ ទោះយ៉ាងណាក្តី នៅចុងឆ្នាំ ២០១៦ ប្រទេសហ្ស៊ែកដានីបានចាប់ផ្តើមអនុញ្ញាតឱ្យសាលារៀនសាធារណៈចុះឈ្មោះកុមារ ដោយពុំចាំបាច់តម្រូវឱ្យមានកាតសេវា។

កង្វះចំណេះដឹងអំពីភាសាក្នុងមូលដ្ឋាន គឺជាឧបសគ្គមួយទៀត។ ជនភៀសខ្លួនប៊ូរុនឌីក្នុងប្រទេសរវ៉ាន់ដា (Rwanda) ចូលមកក្នុងវគ្គសិក្សាតម្រង់ទិសសព្វជ្រុងជ្រោយ មានរយៈពេលរហូតដល់ ៦ ខែ ហើយចូលរៀនក្នុងសាលារដ្ឋ នៅពេលដែលពួកគេមានចំណេះដឹងភាសាអង់គ្លេសក្នុងកម្រិតត្រឹមត្រូវ។ ថ្នាក់ត្រៀមដូចដែលមាន ផ្តល់ជូនក្នុងប្រទេសអាល្លឺម៉ង់ អាចជួយដោះស្រាយបញ្ហានេះបាន ប៉ុន្តែរយៈពេលអូសបន្លាយរបស់វគ្គនេះ អាចរុញច្រានជនភៀសខ្លួនឱ្យចេញទៅក្រៅប្រព័ន្ធអប់រំ។ សេចក្តីត្រូវការផ្នែកភាសារបស់ជនភៀសខ្លួន ពាក់ព័ន្ធមិនត្រឹមតែការប្រាស្រ័យទាក់ទងតាមពាក្យសម្តីតែប៉ុណ្ណោះទេ ប៉ុន្តែក៏ពាក់ព័ន្ធជាមួយការអនុវត្តមិនមែនពាក្យសម្តីដែលពួកគេអាចរៀនសូត្របាន លុះត្រាណាតែពួកគេមានអន្តរទំនាក់ទំនងជាមួយសហគមន៍ម្ចាស់ផ្ទះ។

កម្មវិធីជាច្រើនប្រភេទ ដូចជា កម្មវិធីតភ្ជាប់ ការរៀនបំប៉ន ថ្នាក់បន្ថែម និងថ្នាក់ពន្លឿន គឺជាការចាំបាច់ដើម្បីជួយ ឱ្យកុមារដែលត្រូវបានផ្លាស់ទីលំនៅដោយបង្ខំមាន លទ្ធភាពចូលទៅក្នុងប្រព័ន្ធអប់រំ ឬវិលត្រលប់ចូលទៅក្នុងប្រព័ន្ធអប់រំវិញ។ កម្មវិធីការសិក្សាពន្លឿនរបស់ក្រុមប្រឹក្សាជនភៀសខ្លួនន័រវែសក្នុងក្រុង Dadaab បង្រួមកម្មវិធីសិក្សារយៈពេល ៨ ឆ្នាំរបស់ប្រទេសកេនយ៉ា ទៅជា ៤ ឆ្នាំ ដោយមានចំណុចចូល និងចំណុចចេញ

ជាច្រើនកន្លែង។ ការធ្វើបែបនេះ បានជួយបង្កើនលទ្ធភាពទទួលបានការអប់រំរបស់ក្មេងប្រុស បើទោះបីជាបានជួយបង្កើនលទ្ធភាពតិចសម្រាប់ក្មេងស្រីក្តី។ ជាការល្អ កម្មវិធីប្រភេទនេះ គួរត្រូវបានផ្តល់ឱ្យដោយរដ្ឋាភិបាល នឹងត្រូវដាក់បញ្ចូលទៅតាមផែនការវិស័យអប់រំ។

សូម្បីតែក្នុងករណីដែលការអប់រំ គឺមិនត្រូវបង់ថ្លៃសេវាក្តី ប៉ុន្តែការចំណាយផ្សេងៗ ដូចជាការចំណាយលើសៀវភៅពុម្ព និងមធ្យោបាយធ្វើដំណើរ អាចមានតម្លៃខ្ពស់។ គម្រោងសាកល្បងមួយនៅក្នុងប្រទេសលីបង់ (Lebanon) ដែលផ្តល់សាច់ប្រាក់ដើម្បីគ្របដណ្តប់លើថ្លៃធ្វើដំណើរ និងប៉ះប៉ូវសងដល់ប្រាក់ចំណូលដែលត្រូវបាត់បង់ពេលកុមារទៅរៀននៅសាលាជំនួសឱ្យទៅធ្វើការ បានបង្កើនអត្រាវត្តមាននៅសាលារៀនបានចាប់ពី ០,៥ ដល់ ០,៧ ថ្ងៃក្នុងមួយសប្តាហ៍ ឬប្រមាណ ២០%។ រដ្ឋាភិបាលតួកគី បានពង្រីកកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដោយមានលក្ខខណ្ឌទៅដល់ជនភៀសខ្លួន ហើយបានចូលទៅដល់កុមារស៊ីរីចំនួន ៣៦៨ ០០០ នាក់ គិតត្រឹមឆ្នាំ ២០១៨។

## គ្រូបង្រៀន គឺជាគន្លឹះសម្រាប់ការដាក់បញ្ចូលដោយជោគជ័យ

កង្វះគ្រូបង្រៀន ជាពិសេសកង្វះគ្រូដែលមានគុណវុឌ្ឍិ គឺកើតមាននៅគ្រប់បរិយាកាសនៃការនៃការផ្លាស់ទីលំនៅដោយបង្ខំទាំងអស់។ ការចុះឈ្មោះចូលរៀនរបស់សិស្សជនជាតិស៊ីរីទាំងអស់នៅក្នុងប្រទេសតួកគី និងតម្រូវឱ្យមានគ្រូបន្ថែម ៨០ ០០០ នាក់ទៀត។ ក្នុងប្រទេសអាល្លឺម៉ង់ គេត្រូវការអ្នកអប់រំបន្ថែមចំនួន ១៨ ០០០ នាក់ និងគ្រូបង្រៀន ២៤ ០០០ នាក់ថែមទៀត។ ប្រទេសអ៊ូហ្គង់ដា ត្រូវការគ្រូបឋមសិក្សាបន្ថែមចំនួន ៧ ០០០ នាក់ សម្រាប់ការអប់រំដល់ជនភៀសខ្លួន។

> “ គ្រូបង្រៀននៅក្នុងបរិបទ នៃការការផ្លាស់ទីលំនៅដោយបង្ខំ ទាមទារឱ្យមានការបណ្តុះបណ្តាល ដើម្បីទប់ទល់ជាមួយថ្នាក់រៀនដែលមានសិស្សលើសចំនួនមានអាយុចម្រុះគ្នា និងនិយាយភាសាផ្សេងគ្នា ប៉ុន្តែជារឿយៗ ពួកគេទទួលបានការគាំទ្រម្តងម្កាលប៉ុណ្ណោះ។ ”

ការផ្តល់ប្រាក់កម្រៃប្រកបដោយសមធម៌ និងអាចព្យាករណ៍បាន សម្រាប់គ្រូ គឺជាមូលដ្ឋានគ្រឹះនៃការផ្គត់ផ្គង់ការជ្រើសរើសឱ្យចូលធ្វើការងារ ការរក្សាទុក និងការជំរុញទឹកចិត្តគ្រូបង្រៀនឱ្យបានគ្រប់គ្រាន់។ ទោះយ៉ាងណាក្តី រដ្ឋាភិបាល និងដៃគូមនុស្សធម៌នានាដែលមានថវិកាស្តួចស្តើង និងវដ្តការផ្តល់មូលនិធិរយៈពេលខ្លី អាចជួបបញ្ហាក្នុងការដោះស្រាយលើការចំណាយផ្នែកបៀវត្ស។ ការប្រើប្រាស់គ្រូស្ម័គ្រចិត្ត ដែលជារឿយៗ គឺជាជនភៀសខ្លួន និងការបង់ប្រាក់ឧបត្ថម្ភឱ្យពួកគាត់ គឺត្រូវបានអនុវត្តជាញឹកញាប់ ប៉ុន្តែគម្លាតគ្នានៃប្រាក់ឈ្នួលរបស់គ្រូបង្រៀនអាចបង្កឱ្យមានភាពតានតឹង។ ក្នុងប្រទេសលីបង់ ៥៥% នៃគ្រូបង្រៀន និងបុគ្គលិកបានចូលរួមនៅក្នុងការអភិវឌ្ឍវិជ្ជាជីវៈអាជីពនៅក្នុងរយៈពេលពីរឆ្នាំកន្លងមក បើទោះបីជាវត្តមាននៃកុមារជនភៀសខ្លួនបានប៉ះពាល់ដល់ការបង្រៀនប្រចាំថ្ងៃរបស់ពួកគេក្តី។ គោលវិធីដែលត្រូវបានប្រើប្រាស់ ដើម្បីគាំទ្រដល់គ្រូបង្រៀននៅជំរុំ Kakuma ប្រទេសកេនយ៉ាមានចាប់តាំងពីកម្មវិធីឌីប្លូម៉ា និងវិញ្ញាបនបត្របង្រៀនផ្លូវការផ្តល់ដោយសាកលវិទ្យាល័យថ្នាក់ជាតិ រហូតដល់វគ្គសិក្សាក្រៅប្រព័ន្ធ ពុំមានការផ្តល់វិញ្ញាបនបត្រ បញ្ជាក់ សម្រាប់ គ្រូ បង្រៀន ថ្នាក់ បឋមសិក្សាក្នុងពេលមានវិបត្តិអនុវត្តឡើងដោយបណ្តាញអន្តរទីភ្នាក់ងារសម្រាប់ការអប់រំក្នុងគ្រាអាសន្ន។

## ដើម្បីបំពេញចន្លោះប្រហោងផ្នែកគ្រូបង្រៀនបង្កឡើងដោយលំហូរចូលជនភៀសខ្លួនក្នុងទ្រង់ទ្រាយធំ៖




គ្រូបង្រៀនជនភៀសខ្លួន ជារឿយៗ តែងត្រូវបានផាត់ចេញពីកម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិ ដោយសារតែលិខិតបទដ្ឋានគតិយុត្តិក្នុងវិជ្ជាជីវៈអាជីពស្តីពីសិទ្ធិក្នុងការទទួលបានការងារធ្វើ។ ប្រទេសមួយចំនួនគាំទ្រគ្រូបង្រៀនជាជនភៀសខ្លួនឱ្យត្រឡប់ទៅធ្វើការងារវិញ។ ប្រទេសឆាដបានបណ្តុះបណ្តាល និងផ្តល់វិញ្ញាបនបត្រដល់គ្រូបង្រៀនជនជាតិស៊ូដង់ឱ្យធ្វើការនៅក្នុងសាលារៀនរបស់ខ្លួន។ នៅប្រទេសអាល្លឺម៉ង់ កម្មវិធីគ្រូបង្រៀនជាជនភៀសខ្លួនរបស់សាកលវិទ្យាល័យPotsdamមានបំណងជំរុញសមត្ថភាពឱ្យគ្រូបង្រៀនជាជនភៀសខ្លួនស៊ីរី និងគ្រូបង្រៀនជាជនភៀសខ្លួនជាជនជាតិដទៃទៀតឱ្យវិលត្រឡប់មកកាន់ថ្នាក់រៀនវិញ។

អត្រារីកសាយភាយនៃបញ្ហាវិបត្តិភាពតានតឹងក្រោយការប៉ះទង្គិចធ្ងន់ធ្ងរក្នុងចំណោមសិស្ស គឺមានចាប់ពី ១០% ដល់ ២៥% នៅក្នុងបណ្តាប្រទេសដែលមានចំណូលខ្ពស់ និងឈានដល់កម្រិតខ្ពស់រហូតដល់ ៧៥% ក្នុងបណ្តាប្រទេសមានចំណូលទាប និងមធ្យម។ ក្នុងករណីមានការខ្វះខាតលទ្ធភាពទទួលបានសេវាសុខភាពផ្លូវចិត្តសម្រាប់កុមារ សាលារៀនអាចជាកន្លែងតែមួយគត់ដែលអាចមានជំនួយប្រភេទនេះផ្តល់ជូនបាន។ ទោះយ៉ាងណាក្តី អន្តរាគមន៍នៅតាមសាលារៀន ទាមទារឱ្យមានគ្រូពេទ្យព្យាបាល ដែលទទួលបានការបណ្តុះបណ្តាលពិសេស ហើយនៅហួសពីជំនាញរបស់គ្រូបង្រៀន។ ជំនួសមកវិញ គ្រូបង្រៀន អាចផ្តល់ការគាំទ្រផ្នែកចិត្តសង្គមតាមរយៈការបង្កើតឱ្យមានបរិយាកាសសុវត្ថិភាព និងមានការគាំទ្រតាមរយៈអន្តរទំនាក់ទំនងជាមួយអ្នកសិក្សា និងសកម្មភាពចិត្តសង្គមដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ។ ពួកគេត្រូវការការអភិវឌ្ឍវិជ្ជាជីវៈអាជីពស្តីពីការគ្រប់គ្រងថ្នាក់រៀន និងយន្តការបញ្ជូន។

## ជនភៀសខ្លួនត្រូវការសេវាអប់រំកុមារតូច

អន្តរាគមន៍សមស្រប រួមទាំងការអប់រំ និងការថែទាំកុមារតូច (ECEC) គឺមានភាពចាំបាច់ណាស់សម្រាប់កុមារតូចៗនៅក្នុងបរិបទហិង្សា ដែលច្រើនតែខ្វះខាតបរិស្ថានមានស្ថិរភាព មានការថែទាំយកចិត្តទុកដាក់ និងជួយជំរុញ។ ប៉ុន្តែក្នុងបរិយាកាសការផ្លាស់ទីលំនៅដោយបង្ខំជាច្រើន សេចក្តីត្រូវការផ្នែកការរៀនសូត្រតាំងពីកុមារ គឺពុំត្រូវបានឆ្លើយតបឡើយ។

ការសិក្សាមួយទៅលើបណ្តាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងប្រទេសមានចំណូលខ្ពស់ចំនួន ៨ ប្រទេស បានស្នើឱ្យឃើញថា ការឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន ក្មេងៗ នៅមានភាព "ទន់ខ្សោយយ៉ាងខ្លាំង" ជាការឆ្លុះបញ្ចាំងឱ្យឃើញនូវកង្វះអាទិភាពនៅក្នុងការធ្វើគោលនយោបាយថ្នាក់ជាតិ និងការបញ្ចូលការទទួលខុសត្រូវសម្រាប់ការធ្វើផែនការ និងការអនុវត្ត។ ការពិនិត្យឡើងវិញលើផែនការមនុស្សធម៌ និងផែនការឆ្លើយតបជនភៀសខ្លួនចំនួន ២៦ បានបង្ហាញថា ជិតពាក់កណ្តាលនៃផែនការទាំងអស់នេះ ពុំបានបញ្ជាក់អំពីការរៀនសូត្រ ឬការអប់រំរបស់កុមារអាយុក្រោម ៥ ឆ្នាំទេ ហើយតិចជាង មួយភាគបី បានបញ្ជាក់ដោយចំពោះអំពីការអប់រំមុនបឋមសិក្សា ឬ ECEC។

ជារឿយៗ NGOs តែងជួយបំពេញចន្លោះប្រហោង។ គណៈកម្មាធិការសង្គ្រោះអន្តរជាតិ (International Rescue Committee) បានអនុវត្តសាកល្បងនូវកម្មវិធីអប់រំ គ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សា មានឈ្មោះថា ថ្នាក់រៀនព្យាបាល (Healing Classrooms) សម្រាប់កុមារជនជាតិកុងហ្គោនៅក្នុងជំរុំក្នុងប្រទេសប៊ូរុនឌីក្នុងសាធារណៈរដ្ឋសហភាពតង់សានី។ កម្មវិធីត្រូវបានកែសម្រួលសម្រាប់កុមារលីបង់ក្នុងឆ្នាំ ២០១៤ ដោយគិតមកដល់ពេលបច្ចុប្បន្នកម្មវិធីនេះ បានបម្រើឱ្យកុមារថ្នាក់មត្តេយ្យសិក្សាចំនួន ៣២ ០០០ នាក់ ហើយបានបណ្តុះបណ្តាលគ្រូបង្រៀនចំនួន ១២៨ នាក់។ បន្ទាប់ពីការអនុវត្តសាកល្បងរយៈពេលបួនខែ អ្នកចូលរួមអាយុ ៣ ឆ្នាំបានបង្ហាញនូវបំណិនការធ្វើចលនាបំណិនចិត្តសង្គម មុខងារផ្នែកប្រតិបត្តិ និងអំណាន និងជំនាញលេខនព្វន្តសម្រាប់កុមារតូចមានភាពប្រសើរឡើង។

ប្រទេសមួយចំនួនបានបង្កើតភាពជាដៃគូជាមួយអ្នកដើរតួនាទីថ្នាក់មូលដ្ឋាន និង NGO ជាច្រើន។ រដ្ឋាភិបាលប្រទេសអេត្យូពីគាំទ្រកុមារជនភៀសខ្លួនបីនាក់ក្នុងចំណោម ៥ នាក់ អាយុចាប់ពី ៣ ឆ្នាំដល់ ៦ ឆ្នាំ នៅក្នុងមជ្ឈមណ្ឌលថែទាំ និងអប់រំកុមារតូចចំនួន ៨០ កន្លែងនៅក្នុងជំរុំ និងសាលាមត្តេយ្យឯកជន និងមត្តេយ្យរដ្ឋចំនួន ១៥០ កន្លែងនៅ Addis Ababa។ រដ្ឋាភិបាលអាល្លឺម៉ង់ បានអនុម័តឱ្យមានផែនការសព្វជ្រុងជ្រោយសម្រាប់ការអប់រំជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន ដោយធ្វើការជាដៃគូជាមួយអ្នកដើរតួនាទីថ្នាក់ក្រោមជាតិ និងមានផែនការវិនិយោគទឹកប្រាក់ជិត ៤០០ លានអឺរ៉ូក្នុងឆ្នាំ ២០១៧-២០២០ ដើម្បីពង្រីកកម្មវិធី និងបុគ្គលិក ECEC របស់ខ្លួន។

## ការអប់រំសម្រាប់ជនភៀសខ្លួនដែលពិការ គឺមានហានិភ័យជាពិសេស

លិខិតូបករណ៍ផ្នែកច្បាប់អន្តរជាតិ ធានាសិទ្ធិទទួលបានការអប់រំរបស់កុមារពិការជាជនភៀសខ្លួន ប៉ុន្តែការផ្តល់ការអប់រំសមស្របសម្រាប់កុមារពិការជាជនភៀសខ្លួនគឺកម្រមានណាស់។ជនពិការធ្លាប់ត្រូវបានវាយតម្លៃតាមរយៈការកំណត់អត្តសញ្ញាណដោយការមើលដោយភ្នែក ការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ ឬព័ត៌មានផ្តល់ដោយស្ម័គ្រចិត្ត ដែលនាំឱ្យមានការប៉ាន់ប្រមាណតិចជាងការពិតយ៉ាងច្រើនសន្ធឹកសន្ធាប់អំពីលក្ខណសម្បត្តិ និងអត្រាពិការភាពក្នុងចំណោមប្រជាជនដែលខ្វាត់ខ្វាយពីផ្ទះសម្បែង។ យន្តការនាពេលថ្មីៗនេះប្រើប្រាស់សំណួរជាប្រព័ន្ធផ្អែកលើការបំពេញមុខងារ ដូចជាសំណួរអភិវឌ្ឍឡើងដោយក្រុម វ៉ាស៊ីនតោន (Washington) ជាដើម។

> មានសាលាឯកទេសតិចតួចប៉ុណ្ណោះ នៅក្នុងទីតាំងរបស់ប្រជាជនដែលផ្លាស់ទីលំនៅដោយបង្ខំ ហើយសាលាទាំងនោះច្រើនតែយកថ្លៃឈ្នួលសាលា

បទពិសោធនៃពិការភាពអាចមានភាពខុសប្លែកគ្នាយ៉ាងទូលំទូលាយយោងទៅតាមកម្សោយ និងការជួយសម្រួលដែលមានផ្តល់ជូន។ការសិក្សាមួយក្នុងចំណោមជនជាតិអាហ្វហ្គានីស្ថាននៅប្រទេសប៉ាគីស្ថាន បានរកឃើញថា អ្នកដែលមានការលំបាកក្នុងការមើលឃើញ ច្រើនតែទៅសាលារៀនច្រើនជាងគេបំផុត (៥២%) អ្នកមានការលំបាកក្នុងការថែទាំខ្លួន ច្រើនតែទៅសាលារៀនជាងគេបំផុត (៧.៥%)។

ការផ្តល់លទ្ធភាពចេញចូលផ្នែករូបវន្តកម្រិតទាបទាក់ទងជាមួយចម្ងាយ ក៏ដូចជាបរិក្ខារ ព្រមទាំងកង្វះការបណ្តុះបណ្តាលគ្រូ គឺជាឧបសគ្គដ៏ធំសម្រាប់កុមារជនភៀសខ្លួនជាជនពិការ ដូចឃើញមានក្នុងប្រទេសឥណ្ឌូណេស៊ី និងម៉ាឡេស៊ី។ មានសាលាឯកទេសតិចតួចប៉ុណ្ណោះនៅក្នុងទីតាំងដែលមានការផ្លាស់ទីលំនៅដោយបង្ខំហើយជាទូទៅសាលាទាំងនោះតែងយកថ្លៃសេវា។ពិការភាពក៏អាចត្រូវបានលាក់បាំងឬរាយការណ៍ទាបជាងការពិតដោយភ័យខ្លាចការមាក់ងាយផ្នែកសង្គម ឬការបដិសេធដោយអាជ្ញាធរអន្តោប្រវេសន៍ ឬអាជ្ញាធររដ្ឋាភិបាល។ ប៉ុន្តែបញ្ហាប្រឈមទាំងអស់នេះ អាចដោះស្រាយបាន។ ជំរុំជនភៀសខ្លួនថ្មីៗ ដាក់បញ្ចូលហេដ្ឋារចនាសម្ព័ន្ធសម្រួលភាពងាយស្រួលកាន់តែច្រើនឡើងដូចជានៅប្រទេសស៊ូដង់ ជាដើម។

ការកំណត់រក និងដាក់បញ្ចូលនូវចំណុចខ្លាំងដែលមានស្រាប់របស់សហគមន៍ម្ចាស់ផ្ទះ និងសហគមន៍ជនភៀសខ្លួន គឺជារឿងដ៏ចាំបាច់។ គម្រោងមួយរបស់អង្គការដែលផ្តល់ជាជំនួយគ្របទូទៅឈ្មោះថា សហភាពជាតិជនពិការប្រទេសអ៊ូហ្គាន់ដា មានបំណងដាក់បញ្ចូលជនភៀសខ្លួនជាជនពិការនៅក្នុងសកម្មភាពអភិវឌ្ឍន៍។ សមាគមជាតិជនពិការ គ ថ្លង់ ប្រទេសអ៊ូហ្គាន់ដា បើកដំណើរការសាលាសម្រាប់កុមារមានកម្សោយផ្នែកការស្តាប់ឮ នៅជិតមូលដ្ឋានតាំងនៅរបស់ជនភៀសខ្លួនចំនួនពីរកន្លែង។

## បច្ចេកវិទ្យាអាចគាំទ្រការអប់រំសម្រាប់ប្រជាជនដែលផ្លាស់ទីលំនៅដោយបង្ខំ

ការផ្លាស់ទីលំនៅដោយបង្ខំ ជារឿយៗតែងធ្វើឱ្យប្រព័ន្ធអប់រំមានបន្ទុកធ្ងន់ហួសប្រមាណ។ ដំណោះស្រាយផ្នែកបច្ចេកវិទ្យា ព្រមជាមួយលក្ខណសម្បត្តិដែលអាចពង្រីកឱ្យធំទូលាយ ល្បឿន ការផ្លាស់ទី និងការអាចយកពីកន្លែងមួយទៅកន្លែងមួយទៀតបាន ក៏អាចមានភាពសមស្រប ដើម្បីជួយប៉ះប៉ូវសងចំពោះកង្វះធនធានអប់រំស្តង់ដារផងដែរ។ កម្មវិធីបណ្តាញអ៊ីនធឺណិតភ្លាមៗសម្រាប់សាលារៀន (Instant Network Schools) ដែលជាការផ្តួចផ្តើមគំនិតរួមគ្នារបស់អង្គការ UNHCR និងអង្គការ Vodafone បានចូលទៅដល់សិស្សចំនួនជាង ៤០,០០០នាក់ និងគ្រូបង្រៀន ៦០០នាក់ នៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ប្រទេសកេនយ៉ា ប្រទេសស៊ូដង់ខាងត្បូង និងសាធារណរដ្ឋសហភាពតង់សានី ដែលបានផ្តល់ដំណភ្ជាប់ទៅអ៊ីនធឺណិត អគ្គិសនី និងមេរៀនក្នុងទម្រង់ឌីជីថល។

បញ្ហាប្រឈមមួយរបស់អន្តរាគមន៍ប្រភេទនេះ គឺ ធនធានដែលផ្តល់ឱ្យជារឿយៗតែងតែមិនត្រូវបានបន្ស៊ីជាមួយកម្មវិធីសិក្សាជាតិ។មានករណីលើកលែងមួយចំនួនដូចជា Tabshoura (Chalk) នៅប្រទេសលីបង់ ដែលផ្តល់ធនធានតាមប្រព័ន្ធអ៊ីនធឺណិតសម្រាប់ថ្នាក់មត្តេយ្យសិក្សា អនុលោមតាមកម្មវិធីសិក្សាឆ្នាំ ២០១៥។ ឯកសារដែលមានជាភាសាអារ៉ាប់ អង់គ្លេស និងបារាំង ត្រូវបានស្ថាបនាឡើងនៅលើ Moodle ដែលជាប្រព័ន្ធគ្រប់គ្រងការសិក្សាមួយប្រភេទ។

បច្ចេកវិទ្យាក៏អាចផ្តល់ការគាំទ្រផ្នែកចិត្តសង្គមបានផងដែរ។ ប្រអប់គំនិតដែលជាកញ្ចប់មួយអភិវឌ្ឍឡើងដោយអង្គការក្រៅរដ្ឋាភិបាលឈ្មោះ បណ្ណាល័យគ្មានព្រំដែន (Libraries Without Borders) និងអង្គការ UNHCR គឺមានធនធានព័ត៌មាន និងធនធានផ្នែកវប្បធម៌ ព្រមជាមួយខ្លឹមសារបែបអប់រំ។ ការវាយតម្លៃបែបគុណភាពនៅក្នុងជំរុំ Burundi ចំនួនពីរកន្លែង ដែលជាជម្រកជនភៀសខ្លួនកុងហ្គោ បានបង្ហាញផលប៉ះពាល់ជាវិជ្ជមានមកលើភាពធន់។

វិធីភាគច្រើនគាំទ្រដល់ការអភិវឌ្ឍផ្នែកវិជ្ជាជីវៈអាជីពរបស់គ្រូបង្រៀន។ នៅប្រទេសនីហ្សេរីយ៉ា គម្រោងអប់រំគ្រូបង្រៀនរបស់អង្គការយូណេស្កូ សហការជាមួយក្រុមហ៊ុន Nokia បានផ្តល់ប្លង់មេរៀនដល់គ្រូបឋមសិក្សា សួរសំណួរដែលមានលក្ខណៈភ្ញោច ជំរុញឱ្យមានការឆ្លើយតបបែបឆ្លុះបញ្ចាំង និងវាយតម្លៃសិស្សលើមុខវិជ្ជាភាសាអង់គ្លេស និងថ្នាក់អក្ខរកម្ម។

ការផ្តួចផ្តើមគំនិតផ្នែកបច្ចេកវិទ្យាក៏មានបញ្ហាប្រឈមផងដែរ។ជាទូទៅការផ្តួចផ្តើមទាំងនេះទាមទារឱ្យមានការវិនិយោគជាមុនយ៉ាងខ្ពស់ ហើយមិនមែនមនុស្សគ្រប់រូបទាំងអស់សុទ្ធតែមានអគ្គិសនី និងការភ្ជាប់អ៊ីនធឺណិតគ្រប់គ្រាន់នោះឡើយ។ សំខាន់ជាងនេះទៀត បច្ចេកវិទ្យាពុំអាចចូលមកជំនួសឱ្យការចូលរួមក្នុងសាលារៀនក្នុងប្រព័ន្ធបានឡើយ។ អង្គការអន្តរជាតិ គួរជានាយ៉ាងណាឱ្យការផ្តួចផ្តើមគំនិតនេះ អាចសម្របសម្រួលបានកាន់តែប្រសើរ និងបម្រើឱ្យគោលបំណងចុងក្រោយក្នុងការដាក់បញ្ចូលជនភៀសខ្លួននៅក្នុងប្រព័ន្ធអប់រំថ្នាក់ជាតិ។

## ការផ្តួចផ្តើមគំនិតក្នុងការអប់រំថ្នាក់ឧត្តមសិក្សាជាច្រើនផ្តល់សេវាដល់ជនភៀសខ្លួន

ឱកាសអប់រំថ្នាក់ឧត្តមសិក្សាបង្កើនលទ្ធភាពទទួលបានការងាររបស់ជនភៀសខ្លួន និងចូលរួមចំណែកក្នុងការចុះឈ្មោះចូលរៀន និងការបន្តការសិក្សានៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា។ ទោះយ៉ាងណាក្តី ជនភៀសខ្លួនដែលចូលរួមក្នុងការសិក្សាថ្នាក់ឧត្តមសិក្សា ត្រូវបានប៉ាន់ប្រមាណថា មានចំនួនត្រឹមតែ ១% ប៉ុណ្ណោះ។ ជារឿយៗលទ្ធភាពចូលទៅទទួលការសិក្សានៅថ្នាក់ឧត្តមសិក្សា ច្រើនត្រូវបានបំភ្លេចចោលនៅក្នុងស្ថានភាពគ្រាអាសន្ន ហើយទទួលបានការចាប់អារម្មណ៍ដែលមានលក្ខណៈសម្របសម្រួលតែនៅក្នុងករណីនៃការខ្វាត់ខ្វាយពីផ្ទះសម្បែងដែលមានពេលអូសបន្លាយប៉ុណ្ណោះ។ សិទ្ធិទទួលបានការអប់រំឧត្តមសិក្សារបស់ជនភៀសខ្លួន ជារឿយៗត្រូវបានបកស្រាយថា ជាការពង្រីកទៅដល់ការមិនរើសអើងប៉ុណ្ណោះយ៉ាងច្រើនបំផុត។

> “មានជនភៀសខ្លួនត្រឹមតែ ១٪ ប៉ុណ្ណោះដែលសិក្សានៅឧត្តមសិក្សា”

ការផ្តួចផ្តើមគំនិតផ្អែកលើបច្ចេកវិទ្យា អាចចូលទៅដល់ប្រជាជនដែលខ្វាត់ខ្វាយពីផ្ទះសម្បែង។ កម្មវិធីការតភ្ជាប់ការសិក្សាក្នុងសមាគមដែលមានវិបត្តិដាក់សម្ពាធដោយអង្គការ UNHCR និងសាកលវិទ្យាល័យ Geneva បានបូកផ្សំគ្នារវាងការសិក្សាដែលមានវត្តមានដោយផ្ទាល់ និងការសិក្សាតាមប្រព័ន្ធអ៊ីនធឺណិត ហើយបានចូលទៅដល់សិស្សចំនួន ៦៥០០ នាក់ ចាប់តាំងពីឆ្នាំ ២០១០ មក។

កម្មវិធីអាហារូបករណ៍អន្តរជាតិសម្រាប់ជនភៀសខ្លួន រួមមានដូចជា មូលនិធិការផ្តួចផ្តើមគំនិតជនភៀសខ្លួន ការសិក្សាស្រាវជ្រាវអាល្លឺម៉ង់ អាល់បឺតអាំងស្តាញ (DAFI) ដែលបានផ្តល់ការគាំទ្រដល់ជនភៀសខ្លួនតាមរយៈអង្គការ UNHCR ចាប់ពីឆ្នាំ ១៩៩២ មក។ ការគ្របដណ្តប់ផ្នែកភូមិសាស្ត្រត្រូវបានកែសម្រួលយោងតាម ការផ្លាស់ទី និងសេចក្តីត្រូវការផ្នែកអប់រំ របស់ជនភៀសខ្លួន។ បច្ចុប្បន្នកម្មវិធីធំជាងគេបំផុត គឺនៅក្នុងប្រទេសអេត្យូពី សាធារណរដ្ឋឥស្លាមអ៊ីរ៉ង់ ប្រទេសលីបង់ និងតួកគី។

កម្មវិធីអាហារូបករណ៍ដទៃទៀត ផ្តល់ឱកាសដើម្បីសិក្សាក្នុងប្រទេសមានចំណូលខ្ពស់។ កម្មវិធីសិស្សជនភៀសខ្លួនរបស់សេវាសាកលវិទ្យាពិភពលោក ប្រទេសកាណាដា គាំទ្រដល់គណៈកម្មាធិការនៅតាមសាលារៀន ដែលមានបំណងចង់ឧបត្ថម្ភជនភៀសខ្លួនឱ្យតាំងលំនៅ និងសិក្សានៅក្នុងស្ថាប័នរបស់ខ្លួន។ ចាប់ពីឆ្នាំ ១៩៧៨ មក កម្មវិធីនេះ បាននាំជនភៀសខ្លួនជាង ១ ៨០០ នាក់មកពី ៣៩ ប្រទេស ឱ្យចូលទៅកាន់មហាវិទ្យាល័យ និងសាកលវិទ្យាចំនួន ៨០ នៅទូទាំងប្រទេសកាណាដា។

ស្ថាប័នសិក្សាស្រាវជ្រាវ ក៏អាចត្រូវការការគាំទ្រផងដែរ។ កម្មវិធីបញ្ញវន្តប្រឈមហានិភ័យ (Scholars at Risk) រៀបចំឱ្យមានមុខតំណែងស្រាវជ្រាវ និងបង្រៀនបណ្តោះអាសន្ន សម្រាប់អ្នកសិក្សាស្រាវជ្រាវដែលកំពុងត្រូវការការពារ។ ក្រុមប្រឹក្សាសម្រាប់អ្នកសិក្សាស្រាវជ្រាវប្រឈមហានិភ័យ (CARA) ក្នុងចក្រភពអង់គ្លេស ផ្តល់ការគាំទ្របន្ទាន់ ជាពិសេសដល់អ្នកសិក្សាស្រាវជ្រាវ ដែលកំពុងប្រឈមគ្រោះថ្នាក់ចំពោះមុខនៅក្នុងប្រទេសកំណើត។

អត្ថប្រយោជន៍នៃការគាំទ្រ គួរពង្រីកទៅដល់សហគមន៍ទូលំទូលាយថែមទៀត។ អាហារូបករណ៍ DAFI ទទួលស្គាល់សហគមន៍កំណើត ថាអ្នកទទួលផលគោលដៅនៅផុតពីអ្នកទទួលអាហារូបករណ៍នោះផ្ទាល់។ បណ្ដាញដើម្បីគាំទ្រអ្នកសិក្សាស្រាវជ្រាវជាជនភៀសខ្លួន ក៏អាចលើកកម្ពស់ការកសាងសមត្ថភាពបានដែរ។ CARA បានដាក់សម្ពោធកម្មវិធី ដើម្បីស្ដារសមត្ថភាពស្រាវជ្រាវ និងបង្រៀនក្នុងប្រទេសអ៊ីរ៉ាក់ សាធារណរដ្ឋអារ៉ាប់ សេរី និងប្រទេសស៊ីមបាវ៉េ។

## IDP ច្រើនតែជួបប្រទះបញ្ហាប្រឈមផ្នែកការអប់រំប្រហាក់ប្រហែល ជាមួយជនភៀសខ្លួនដែរ

ថ្វីបើគោលការណ៍មគ្គុទ្ទេសក៍អង្គការសហប្រជាជាតិ ស្ដីពីការផ្លាស់ទីលំនៅដោយបង្ខំ អន្តរជាតិចែងថា៖ មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការអប់រំ ប៉ុន្តែសមត្ថភាព និងនយោបាយ រារាំងការទទួលស្គាល់បញ្ហានេះ និងការសម្របសម្រួលដើម្បីឈានទៅរកដំណោះស្រាយ។ ការឆ្លើយតបផ្នែកផ្លូវច្បាប់ ផ្នែកអប់រំ និងផ្នែករដ្ឋបាលចំពោះការប្ដេជ្ញាចិត្តផ្នែកអប់រំរបស់អ្នកដែលត្រូវផ្លាស់ទីលំនៅដោយបង្ខំក្នុងប្រទេស ជារឿយៗ គឺមានលក្ខណៈប្រហាក់ប្រហែល ជាមួយការឆ្លើយតបដែលបានពិពណ៌នាសម្រាប់ជនភៀសខ្លួនដែរ។ រដ្ឋាភិបាលប្រទេសកូឡុំប៊ី ដោយក្នុងនោះមាន IDP ៦,៥ លាននាក់ រស់នៅក្នុងឆ្នាំ ២០១៧ បានផ្ដោតការយកចិត្តទុកដាក់លើក្របខ័ណ្ឌការងារខាងផ្នែកច្បាប់។ ក្នុងឆ្នាំ ២០០២ តុលាការធម្មនុញ្ញបានផ្ដល់ការណែនាំដល់អាជ្ញាធរអប់រំក្រុងឱ្យផ្ដល់ការអនុគ្រោះដល់កុមារដែលផ្លាស់ទីលំនៅដោយបង្ខំ ទាក់ទងជាមួយលទ្ធភាពទទួលបានការអប់រំ។ ក្នុងឆ្នាំ ២០០៤ តុលាការបានប្រកាសថាសិទ្ធិជាមូលដ្ឋានរបស់ IDP រួមទាំងសិទ្ធិទទួលបានការអប់រំផងដែរ គឺត្រូវបានរំលោភបំពាន។

ការផ្លាស់ទីលំនៅដោយបង្ខំមានន័យថាគន្លងវិថីនៃការអប់រំរបស់កុមារនិងមនុស្សវ័យជំទង់ជាច្រើនត្រូវបានរំខាន ហើយពួកគេត្រូវការការគាំទ្រដើម្បីវិលត្រលប់ចូលទៅក្នុងប្រព័ន្ធអប់រំវិញ។ ក្នុងប្រទេសអាហ្វហ្គានីស្ថាន អង្គការក្រៅរដ្ឋាភិបាល ឈ្មោះ Children in Crisis ដំណើរការកម្មវិធីពន្លឿនការសិក្សានៅថ្នាក់សហគមន៍ ដើម្បីជួយដល់សិស្សដែលផ្លាស់ទីលំនៅដោយបង្ខំ ក្នុងប្រទេសដែលនៅក្រៅសាលារៀន រស់នៅក្នុងបរិយាកាសក្រៅផ្លូវការនៅក្នុង និងនៅជុំវិញទីក្រុង Kabul ឱ្យអាចបញ្ចប់ការសិក្សានៅក្នុងថ្នាក់ទី ៦ និងផ្ទេរចូលទៅក្នុងការអប់រំក្នុងប្រព័ន្ធវិញ។

> “ គ្រូបង្រៀនផ្លាស់ទីលំនៅក្នុងស្រុកតែងតែប្រឈមនឹងហានិភ័យនិងឧបសគ្គផ្នែករដ្ឋបាលដែលធ្វើឱ្យការប្រមូលប្រាក់ខែមិនអាចទៅរួច ”

គ្រូបង្រៀនដែលផ្លាស់ទីលំនៅដោយបង្ខំក្នុងប្រទេស ជារឿយៗតែងស្ថិតក្រោមការមើលខុសត្រូវផ្នែករដ្ឋបាលរបស់ស្រុកជាកន្លែងកំណើតរបស់ខ្លួន ដែលធ្វើឱ្យការទៅបើកប្រាក់បៀវត្សស្ទើរតែមិនអាចធ្វើឡើងបាន ដូចជានៅក្នុងសាធារណរដ្ឋអារ៉ាប់ ស៊ីរី ជាដើម។ ក្នុងប្រទេសអ៊ីរ៉ាក់ ដៃគូចំនួន ៤៤ ផ្ដល់សេវាក្នុងតំបន់អភិបាលចំនួន ១៥ និងគាំទ្រដល់គ្រូបង្រៀនប្រមាណ

៥២០០នាក់ ដោយផ្តល់ប្រាក់ឧបត្ថម្ភ ឬប្រាក់លើកទឹកចិត្ត បើទោះបីជាការសម្របសម្រួលអន់ខ្សោយ បាននាំឱ្យមានគម្លាតផ្នែកសេវា ការបង់ប្រាក់ឈ្នួលខុសគ្នាក្នុងចំណោមចំណាត់ប្រភេទគ្រូផ្សេងៗ និងមានភាពតានតឹងក្នុងចំណោមដៃគូនានាក្តី។

## គ្រោះធម្មជាតិ និងការប្រែប្រួលអាកាសធាតុទាមទារឱ្យប្រព័ន្ធអប់រំត្រូវត្រៀមខ្លួនរួចជាស្រេច និងត្រូវមានលក្ខណៈឆ្លើយតប

ផែនការវិស័យអប់រំ ចាំបាច់ត្រូវពិចារណាលើហានិភ័យនៃការបាត់បង់ជីវិត ការខូចខាតហេដ្ឋារចនាសម្ព័ន្ធ និងការផ្លាស់ទីលំនៅដោយបង្ខំបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិ និងត្រូវធានាថា សេវាអប់រំត្រូវបានរំខានតិចតួចបំផុតតាមដែលអាចធ្វើបាន តាមរយៈការឆ្លើយតបគ្រាអាសន្នដើម្បីស្តារឡើងវិញ។ ក្នុងឆ្នាំ ២០១៧ ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុក ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងសម្ព័ន្ធភាពសាកល ដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងភាពធន់នៅក្នុងវិស័យអប់រំ បានដាក់សម្ពោធក្របខ័ណ្ឌការងារសុវត្ថិភាពសាលាសព្វជ្រុងជ្រោយបច្ចុប្បន្នភាពរបស់ខ្លួន។ សសរស្តម្ភទាំងបីរបស់ក្របខ័ណ្ឌការងារនេះ រួមមាន គ្រឹះស្ថានសិក្សារៀនសូត្រដែលមានសុវត្ថិភាព ការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន និងការកាត់បន្ថយហានិភ័យ និងការអប់រំដែលមានលក្ខណៈធន់ទ្រាំ។

ប្រទេសជាច្រើននៅតាមកោះប៉ាស៊ីហ្វិក បានពិចារណាលើហានិភ័យនៃការប្រែប្រួលអាកាសធាតុ នៅក្នុងផែនការអប់រំ។ ក្នុងឆ្នាំ ២០១១ សេចក្តីថ្លែងគោលនយោបាយ និងគោលការណ៍ណែនាំសម្រាប់ការត្រៀមខ្លួនចំពោះគ្រោះមហន្តរាយ និងការអប់រំក្នុងស្ថានភាពគ្រាអាសន្នរបស់កោះ Solomon មានគោលដៅដើម្បីធានាថាសិស្សបន្តមានលទ្ធភាពទទួលបានបរិស្ថានសិក្សារៀនសូត្រប្រកបដោយសុវត្ថិភាព នៅមុនពេល ក្នុងពេល និងក្រោយពេលគ្រាអាសន្ន ហើយសាលារៀនទាំងអស់ ត្រូវកំណត់រកទីកន្លែងរៀន និងបង្រៀនបណ្តោះអាសន្ន។

ក្នុងរយៈពេលប៉ុន្មានទសវត្សកន្លងមកនេះ អាកាសធាតុអាចជាមូលហេតុចម្បងមួយសម្រាប់ការផ្លាស់ទីលំនៅដោយបង្ខំ។ ធនាគារពិភពលោកប៉ាន់ប្រមាណថា ប្រជាជន ១៤០ លាននាក់ ត្រូវផ្លាស់ទីលំនៅដោយបង្ខំ ដោយសារតែការប្រែប្រួលអាកាសធាតុគិតត្រឹមឆ្នាំ ២០៥០។ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ ប្រទេសមួយចំនួន បានពិចារណារកការឆ្លើយតបផ្នែកគោលនយោបាយរួចហើយ។ គោលនយោបាយ "ជនចំណាកស្រុកប្រកបដោយសេចក្តីថ្លៃថ្នូរ" របស់រដ្ឋាភិបាលប្រទេសគីរីបាទី ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រផ្លាស់ប្តូរទីតាំងទូទាំងប្រទេសសម្រាប់រយៈពេលវែង មានគោលបំណងដើម្បីលើកកម្ពស់គុណវុឌ្ឍិរបស់ប្រជាជន និងផ្តល់ឧបករណ៍ឱ្យប្រជាជនអាចមានលទ្ធភាពទទួលបានឱកាសការងារសមរម្យនៅក្រៅប្រទេសនៅក្នុងអាជីពនានា ដូចជា គិលានុបដ្ឋាកជាដើម។

## ភាពចម្រុះគ្នា

ការអប់រំដែលឱ្យតម្លៃលើភាពចម្រុះគ្នា គឺមានសារៈសំខាន់ណាស់សម្រាប់គ្រប់ប្រទេសទាំងអស់ដែលជួយជំរុញឱ្យប្រទេសទាំងនោះ អាចស្ថាបនាសង្គមប្រកបដោយបរិយាប័ន្ន ដោយក្នុងនោះមានការទទួលស្គាល់ និងគោរពចំពោះភាពខុសគ្នា ហើយការអប់រំមានគុណភាពល្អ ត្រូវបានផ្តល់ជូនដល់មនុស្សគ្រប់រូប។

ជនចំណាកស្រុក និងជនភៀសខ្លួន ពេលខ្លះត្រូវបានគេវិនិច្ឆ័យផ្អែកលើមូលដ្ឋាននៃការយល់ឃើញចំពោះអត្តសញ្ញាណក្រុមរបស់ជនទាំងនោះ ជំនួសឱ្យគុណភាពបុគ្គលិក។ ជាពិសេស ប្រសិនបើពួកគេមើលទៅមានរូបរាងលក្ខណៈខុសប្លែកគ្នាពីប្រជាជនម្ចាស់ស្រុក នោះពួកគេអាចត្រូវបានមើលឃើញថាជា "អ្នកដទៃ" និង រងនូវផ្នត់គំនិតសង្គម និងបុរេនិច្ឆ័យ ដែលអាចនាំឱ្យមានការរើសអើង រួមទាំងការផាត់ចេញពីការអប់រំមានគុណភាពល្អ។

បុរេនិច្ឆ័យ និងការរើសអើង មានវត្តមាននៅក្នុងប្រព័ន្ធអប់រំជាច្រើន ថ្វីបើមានគោលនយោបាយប្រឆាំងការរើសអើងក្តី។ ការរើសអើងជាលក្ខណៈរចនាសម្ព័ន្ធចំពោះសិស្សមកពីគ្រួសារជនចំណាកស្រុកក្នុងសហរដ្ឋអាមេរិក រួមមានដូចជាកង្វះកម្មវិធីបង្រៀនពីរភាសាសម្រាប់កុមារតូច និងការធ្វើតេស្តកម្រិតការចេះអានសរសេរ មិនត្រូវបានផ្តល់ឱ្យជាភាសាកំណើតឡើយ។

ឥរិយាបថសាធារណៈ ជះឥទ្ធិពលលើការយល់ឃើញចំពោះខ្លួនឯង ចំពោះជនចំណាកស្រុក និងសុខុមាលភាពរបស់ពួកគេ។ ការរើសអើងដែលជនចំណាកស្រុក និងជនភៀសខ្លួន យល់ឃើញថាមានចំពោះខ្លួន ធ្វើឱ្យមានជំងឺធ្លាក់ទឹកចិត្ត ការខ្វល់ខ្វាយ និងការឱ្យតម្លៃខ្លួនឯងទាប។ ជនចំណាកស្រុក ច្រើនតែមិនសូវមើលឃើញខ្លួនឯងថាជាផ្នែកមួយនៃប្រទេសម្ចាស់ផ្ទះឡើយ នេះបើយោងតាមការសិក្សាស្ទាបស្ទង់មតិលើគុណតម្លៃពិភពលោកឆ្នាំ ២០១៤។

## ការអប់រំជះឥទ្ធិពលលើឥរិយាបថចំពោះជនចំណាកស្រុក និងជនភៀសខ្លួន

កម្រិតការអប់រំ គឺពាក់ព័ន្ធជាមួយឥរិយាបថចំពោះជនចំណាកស្រុក។ មនុស្សមានការអប់រំខ្ពស់ ច្រើនតែមានគំនិតប្រកាន់ជាតិពន្ធុតិច ឱ្យតម្លៃភាពចម្រុះគ្នាផ្នែកវប្បធម៌កាន់តែច្រើន និងមើលឃើញផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចរបស់ជនចំណាកស្រុកក្នុងក្រសែភ្នែកវិជ្ជមានជាង។ ការស្រាវជ្រាវបង្ហាញឱ្យឃើញថា អ្នកដែលមានការសិក្សាថ្នាក់ឧត្តមសិក្សា មានភាពធន់ទ្រាំចំនួនពីរភាគរយលើសពីអ្នកមានការអប់រំត្រឹមកម្រិតមធ្យម

សិក្សា ហើយអ្នកមានការអប់រំកម្រិតមធ្យមសិក្សាមានភាពធន់ទ្រាំពីរភាគរយលើសពីអ្នកមានការសិក្សាត្រឹមថ្នាក់បឋមសិក្សា។ មនុស្សវ័យក្មេង ជាពិសេសអ្នកបានទទួលការអប់រំខ្ពស់ ក៏ច្រើនតែមានឥរិយាបថកាន់តែវិជ្ជមានចំពោះការធ្វើចំណាកស្រុកផងដែរ។

> “ការអប់រំ អាចសម្របសម្រួល កុំឱ្យមានការបង្ហាញជាអវិជ្ជមានតាមប្រព័ន្ធផ្សព្វផ្សាយតាមរយៈការផ្តល់ចំណេះដឹងផ្នែកនយោបាយ និងជំនាញការគិតបែបរិះគន់ក្នុងការញែកព័ត៌មានពិតចេញពីព័ត៌មានប្រឌិត”

ការបង្ហាញតាមប្រព័ន្ធផ្សព្វផ្សាយក្នុងលក្ខណៈជាអវិជ្ជមានអំពីជនចំណាកស្រុក និងជនភៀសខ្លួន អាចជំរុញឱ្យមានបុរេនិច្ច័យ។ ការផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយអំពីបញ្ហាចំណាកស្រុក និងការផ្លាស់ទីលំនៅដោយបង្ខំ គឺកាន់តែមានភាពអវិជ្ជមានឡើងៗ និងកាន់ជើងម្ខាងៗ ដូចមានជា ឧទាហរណ៍នៅក្នុងប្រទេសកាណាដា សាធារណរដ្ឋឆែក ប្រទេសន័រវែស និងចក្រភពអង់គ្លេសជាដើម ដោយ ក្នុង នោះ ប្រព័ន្ធផ្សព្វផ្សាយ ជារឿយៗ តែងបង្ហាញរូបភាពជនចំណាកស្រុក និងជនភៀសខ្លួន ជាការគំរាមចំពោះវប្បធម៌ សន្តិសុខ និងប្រព័ន្ធសុខុមាលភាព ។ រឿងរ៉ាវពាក់ព័ន្ធជាមួយជនចំណាកស្រុកដែលផ្សព្វផ្សាយ តាមប្រព័ន្ធផ្សព្វផ្សាយ ជារឿយៗតែងមានបង្កប់ផ្នត់គំនិតសង្គម ផាត់ចេញនូវសំឡេងរបស់ជនចំណាកស្រុក ឬជនភៀសខ្លួន និងប្រើប្រាស់សព្ទមិនប្រាកដប្រជា។ ការអប់រំ អាចសម្របសម្រួល កុំឱ្យមានការបង្ហាញជាអវិជ្ជមានតាមប្រព័ន្ធផ្សព្វផ្សាយតាមរយៈការផ្តល់ចំណេះដឹងផ្នែកនយោបាយ និងជំនាញការគិតបែបរិះគន់ក្នុងការញែកព័ត៌មានពិតចេញពីព័ត៌មានប្រឌិត។

## បរិយាបន្នគួរស្ថិតនៅជាស្នូលនៃគោលនយោបាយ និងប្រព័ន្ធអប់រំ

ប្រទេសនានាប្រើប្រាស់គោលវិធីផ្សេងៗគ្នា ដើម្បីឆ្លើយតបភាពចម្រុះគ្នានៅក្នុងប្រព័ន្ធអប់រំ៖ ការច្របាច់បញ្ចូលឱ្យក្លាយទៅជាតែមួយ ពហុវប្បធម៌និយម/ការច្របាច់បញ្ចូលគ្នា និងអន្តរវប្បធម៌និយម/ការរួមបញ្ចូលគ្នា។ ការច្របាច់បញ្ចូលឱ្យក្លាយទៅជាតែមួយ អាចមានលក្ខណៈបំផ្លិចបំផ្លាញដល់អត្តសញ្ញាណជនចំណាកស្រុក។ ផ្ទុយទៅវិញ អន្តរវប្បធម៌និយម ជួយសិស្សឱ្យរៀនសូត្រមិនត្រឹមតែអំពីវប្បធម៌ដទៃតែប៉ុណ្ណោះទេ ប៉ុន្តែក៏សិក្សាអំពីឧបសគ្គជាលក្ខណៈរចនាសម្ព័ន្ធនៅក្នុងបណ្តាប្រទេសម្ចាស់ផ្ទះ ដែលធ្វើឱ្យវិសមភាពមានភាពសាយភាយ។

ប្រទេសមួយចំនួនតូច មានគោលនយោបាយជាក់លាក់ស្តីពីការអប់រំពហុវប្បធម៌ ឬអន្តរវប្បធម៌។ នៅប្រទេសអៀកឡង់ ដែលកុមារចំណាកស្រុកមានចំនួន ១៥% នៃប្រជាជនសរុបអាយុក្រោម ១៥ ឆ្នាំ ក្នុងឆ្នាំ ២០១៥ បានអភិវឌ្ឍយុទ្ធសាស្ត្រអប់រំអន្តរវប្បធម៌ ២០១០-២០១៥ ដោយមានបំណងក្នុងការអភិវឌ្ឍសមត្ថភាពរបស់អ្នកផ្តល់សេវា គាំទ្រសមត្ថភាពផ្នែកភាសា លើកទឹកចិត្តភាពជាដៃគូជាមួយសង្គមស៊ីវិល និង

កែលម្អការពិនិត្យតាមដាន។ បន្ថែមលើនេះ មានលិខិតបទដ្ឋានគតិយុត្តិដែលដកបាំងឧសគ្គរាំង ហាមឃាត់ការយកថ្លៃសេវា និងតម្រូវឱ្យសាលារៀនត្រូវផ្សព្វផ្សាយគោលនយោបាយទទួលសិស្សឱ្យចូលរៀន។ ការសិក្សារបស់សភាអឺរ៉ុប បានរកឃើញថា ប្រទេសអៀកឡង់ និងប្រទេសស៊ុយអែតមានក្របខ័ណ្ឌការងារពិនិត្យតាមដាន និងវាយតម្លៃរឹងមាំជាងគេបំផុតក្នុងទ្វីបអឺរ៉ុបសម្រាប់ការអប់រំរបស់ជនចំណាកស្រុក។

ការជះឥទ្ធិពលផ្នែកនយោបាយ អាចបំផ្លាញដល់គោលនយោបាយអប់រំអន្តរវប្បធម៌។ នៅប្រទេសហូឡង់ ឥរិយាបថកាន់តែអាក្រក់ឡើងចំពោះជនចំណាកស្រុក បានជំរុញឱ្យមានការដាក់បញ្ចូលគោលនយោបាយផ្តោតការយកចិត្តទុកដាក់លើភក្តីភាពចំពោះសង្គមហូឡង់ ដោយក្នុងនោះ ការអប់រំអន្តរវប្បធម៌ត្រូវបានជំនួសដោយការអប់រំភាពជាពលរដ្ឋសកល។

ទិដ្ឋភាពមួយទៀតនៅក្នុងការអភិវឌ្ឍអារម្មណ៍ជាផ្នែកមួយ នៃសង្គមរបស់សិស្សជាជនចំណាកស្រុក គឺសាលាចល័តតាមសិស្ស (diaspora schools) ដែលរក្សាចំណងទាក់ទងជាមួយប្រទេសកំណើត។ ការអនុវត្តនេះអាចមានចាប់តាំងពីសាលាស្ថិតក្រោមការគ្រប់គ្រង ឬសម្របសម្រួលដោយរដ្ឋាភិបាលរបស់ប្រទេសកំណើត ដូចក្នុងករណីប្រទេសប៉ូឡូញ សាលាឯកជនត្រូវបានបង្កើតឡើងដោយសហគមន៍ជនចំណាកស្រុក ដូចជាក្នុងករណីជនជាតិហ្វីលីពីននៅប្រទេសអារ៉ាប់សាអូឌីត ឬជនជាតិប្រេស៊ីលនៅប្រទេសជប៉ុន និងសាលារៀនក្រៅប្រព័ន្ធ ដែលបញ្ជូនបេតិកភណ្ឌផ្នែកភាសា និងវប្បធម៌របស់ប្រទេសកំណើត។

## កម្មវិធីសិក្សា និងសៀវភៅពុម្ពមានលក្ខណៈបរិយាបន្នកាន់តែច្រើនឡើង

កម្មវិធីសិក្សា និងសៀវភៅពុម្ពអាចកាត់បន្ថយបុរេនិច្ឆ័យ និងអភិវឌ្ឍអារម្មណ៍ជាផ្នែកមួយនៃសង្គមរបស់ជនចំណាកស្រុក។ ការរៀនសូត្រអំពីប្រវត្តិសាស្ត្ររបស់ប្រទេសដទៃ គឺពាក់ព័ន្ធជាមួយឥរិយាបថជាវិជ្ជមានឆ្ពោះទៅគាំទ្រសិទ្ធិរបស់ក្រុមជនជាតិដើមនៅក្នុងប្រទេសចំនួន ១២ ក្នុងចំណោមប្រទេសទាំង ២២ ដែលបានចូលរួមនៅក្នុងការស្ទាបស្ទង់មតិការអប់រំផ្នែកពលរដ្ឋ និងភាពជាពលរដ្ឋសកលឆ្នាំ ២០១៦។

ប្រទេសកាន់តែច្រើនឡើងកំពុងកែសម្រួលកម្មវិធីសិក្សា ដើម្បីឆ្លុះបញ្ចាំងនូវភាពចម្រុះគ្នាកាន់តែខ្លាំងក្នុងសង្គម។ ក្នុងចំណោមបណ្តាប្រទេសមានចំណូលខ្ពស់ទាំង ២១ ដែលត្រូវបានវិភាគសម្រាប់សន្ទស្សន៍គោលនយោបាយស្តីពីពហុវប្បធម៌និយមមានតែប្រទេសអូស្ត្រាលី និងប្រទេសកាណាដា តែប៉ុណ្ណោះដែលបានដាក់បញ្ចូលពហុវប្បធម៌និយមនៅក្នុងកម្មវិធីសិក្សាក្នុងឆ្នាំ ១៩៨០។ គិតត្រឹមឆ្នាំ ២០១០ ពហុវប្បធម៌និយមហាក់ស្ថិតលើរបៀបវារៈរបស់ប្រទេសចំនួនពីរភាគបី ហើយត្រូវបានដាក់បញ្ចូលយ៉ាងពេញលេញនៅក្នុងប្រទេសចំនួនបួនបន្ថែមទៀត មានប្រទេសហ្វាំងឡង់ អៀកឡង់ នូវែលសេឡង់ និងស៊ុយអែត (រូបភាពទី ៤)។

ក្នុងឆ្នាំ ២០១៥ ប្រទេស ២៧ ក្នុងចំណោមប្រទេសមានចំណូលខ្ពស់លេចធ្លោទាំង ៣៨ បានផ្តល់ការអប់រំអន្តរវប្បធម៌ជាមុខវិជ្ជាដាច់តែឯង ដាក់បញ្ចូលកម្មវិធីនេះទៅក្នុងកម្មវិធីសិក្សា ឬមានទាំងជាមុខវិជ្ជាដាច់តែឯងផង និងដាក់ក្នុងកម្មវិធីសិក្សាផងដែរ។ គុណតម្លៃពហុវប្បធម៌ និងអន្តរវប្បធម៌ អាចត្រូវបានដាក់បញ្ចូលនៅក្នុងមុខវិជ្ជាជាបុគ្គលផងដែរ។ កម្មវិធីសិក្សាប្រវត្តិសាស្ត្រ ជារឿយៗ តែងមានលក្ខណៈផ្តោតទៅលើពូជសាសន៍ជាក់លាក់ ប៉ុន្តែមុខវិជ្ជាដទៃទៀត អាចមានភាពខុសប្លែក ដូចជាភូមិវិទ្យាក្នុងប្រទេសអាល្លឺម៉ង់ និងភាពជាពលរដ្ឋនៅប្រទេសអង់គ្លេស (ចក្រភពអង់គ្លេស) ជាដើម។ សៀវភៅពុម្ពសម័យទំនើបមួយចំនួនបន្តផាត់ចេញនូវបញ្ហាពាក់ព័ន្ធជាមួយចំណាកស្រុកដែលមានលក្ខណៈចម្រូងចម្រាស។ នៅប្រទេសម៉ិកស៊ិក សៀវភៅពុម្ពមិនពិភាក្សាអំពីជនចំណាកស្រុកគ្មានឯកសារត្រឹមត្រូវ និងទំនាក់ទំនងជាមួយសហរដ្ឋអាមេរិកទេ។ ទោះយ៉ាងណាក្តី សៀវភៅពុម្ពនៅប្រទេសកូតឌីវ័រពិភាក្សាអំពីជនភៀសខ្លួន និងការខ្វាត់ខ្វាយពីផ្ទះសម្បែង ដែលមានលក្ខណៈលេចធ្លោចាប់តាំងពីវិបត្តិនយោបាយក្នុងឆ្នាំ ២០០២ មក។

**រូបភាពទី ៤៖**

**បណ្តាប្រទេសក្នុងចំនួនកាន់តែច្រើនដាក់បញ្ចូលមុខវិជ្ជាពហុវប្បធម៌នៅក្នុងកម្មវិធីសិក្សា**

ការដាក់បញ្ចូលមុខវិជ្ជាពហុវប្បធម៌នៅក្នុងកម្មវិធីសិក្សាក្នុងបណ្តាប្រទេសមានចំណូលខ្ពស់ចំនួន ២១ ឆ្នាំ ១៩៨០-២០១០




GEM StatLink: http://bit.ly/fig5_2

សម្គាល់៖ និយមន័យរបស់ពាក្យពហុវប្បធម៌ដែលត្រូវបានប្រើប្រាស់ក្នុងរូបភាពនេះ តំណាងឱ្យនិយមន័យរបស់ពាក្យពហុវប្បធម៌នៅក្នុងរូបភាពនេះ គឺប្រហាក់ប្រហែលជាមួយនិយមន័យរបស់ពាក្យអន្តរវប្បធម៌នៅក្នុងតារាង ៥.១។

ប្រភព៖ Westlake (2011).

កម្មវិធីសិក្សា អាចត្រូវបានកែសម្រួលនៅក្នុងមូលដ្ឋាន ដូចជានៅអាល់បឺតា ប្រទេសកាណាដា ដោយក្នុងនោះ ធនធានបង្រៀនគាំទ្រដល់ជនចំណាកស្រុក និងជនភៀសខ្លួននៅក្នុងការបង្រៀន និងការរៀន ដោយផ្តោតការយកចិត្តទុកដាក់លើសហគមន៍ជាក់លាក់ ដូចជាសហគមន៍ការ៉ែន សូម៉ាលី និងស៊ូដង់ខាងត្បូងជាដើម។ ថ្នាក់ដឹកនាំសាលារៀនរឹងមាំ ក៏អាចចូលរួមចំណែកជួយបន្ថែមទៀតផងដែរ។ នៅសហរដ្ឋអាមេរិក នៅពេលដែលថ្នាក់ដឹកនាំសាលារៀនឱ្យតម្លៃលើភាពចម្រុះគ្នា សិស្សច្រើនតែមានការចូលរួមក្នុងអន្តរទំនាក់ទំនងអន្តរវប្បធម៌។

ការបង្រៀនត្រូវដាក់បញ្ចូលសកម្មភាព ដែលលើកកម្ពស់ភាពបើកចំហចំពោះពហុ ទស្សនវិស័យ ដើម្បីជួយសិស្សអភិវឌ្ឍជំនាញការគិតប្រកបដោយការរិះគន់។ ការរៀនសូត្របែបពិសោធន៍ និងបែបសហការ អាចជួយកែលម្អទំនាក់ទំនងអន្តរវប្បធម៌ បង្កើនការទទួលយកភាពខុសប្លែកគ្នា និងកាត់បន្ថយបុរេនិច្ឆ័យ។

## ការបណ្តុះបណ្តាលដែលត្រៀមខ្លួនគ្រូបង្រៀនសម្រាប់ថ្នាក់រៀនដែលមានលក្ខណៈចម្រុះគ្នា គឺពុំមែនជាភាពចាំបាច់ដែលត្រូវអនុវត្តនៅក្នុងប្រទេសភាគច្រើន

គ្រូបង្រៀនត្រូវការការគាំទ្រ ដើម្បីបង្រៀនថ្នាក់រៀនដែលសិស្សមានលក្ខណៈចម្រុះគ្នា ប៉ុន្តែ ៥២% នៃគ្រូបង្រៀនដែលត្រូវបានសម្ភាសន៍នៅប្រទេសបារាំង អៀកឡង់ អ៊ីតាលី ឡេតូនី អេស្ប៉ាញ និងចក្រភពអង់គ្លេស មានអារម្មណ៍ថា ខ្លួនបានទទួលការគាំទ្រមិនគ្រប់គ្រាន់ពីថ្នាក់គ្រប់គ្រងក្នុងការគ្រប់គ្រងភាពចម្រុះគ្នា។ ទំហំដែលការអប់រំគ្រូដាក់បញ្ចូលភាពចម្រុះគ្នា គឺមានភាពប្លែកៗគ្នាទៅតាមប្រទេសនីមួយៗ។ នៅប្រទេសហូឡង់ នូវែលសេឡង់ និងន័រវែស បេក្ខភាពគ្រូបង្រៀន ត្រូវចូលរៀនវគ្គសិក្សាជាកាតព្វកិច្ចក្នុងការគាំទ្រសិស្សដែលមានពីសាវតារចម្រុះគ្នា។ ការបញ្ចប់វគ្គសិក្សាប្រភេទនេះ តាមធម្មតា គឺជាវគ្គសិក្សាជាជម្រើសនៅក្នុងទ្វីបអឺរ៉ុប។

កម្មវិធីអប់រំគ្រូបង្រៀន ច្រើនតែសង្កត់ធ្ងន់លើចំណេះដឹងទូទៅ ជាជាងលើគរុកោសល្យបែបអនុវត្តជាក់ស្តែង។ ការស្ទាបស្ទង់មតិមួយលើកម្មវិធីចំនួន ១០៥ ក្នុងប្រទេសចំនួន ៤៩ បានរកឃើញថា មានតែមួយភាគប្រាំប៉ុណ្ណោះនៃគ្រូបង្រៀនដែលបានត្រៀមខ្លួនក្នុងការរំពឹងទុក និងដោះស្រាយជម្លោះអន្តរវប្បធម៌ ឬយល់អំពីការប្រព្រឹត្តបែបចិត្តសាស្ត្រ និងជម្រើសដែលមានសម្រាប់ការបញ្ចូនសិស្សដែលមានតម្រូវការ។ គ្រូបង្រៀនកំពុងបំពេញការងារ ត្រូវការការអភិវឌ្ឍវិជ្ជាជីវៈបន្តទាក់ទងជាមួយទិដ្ឋភាពនេះ។ ការស្ទាបស្ទង់មតិលើការបង្រៀន និងការរៀនអន្តរជាតិរបស់ OECD ឆ្នាំ ២០១៣ បានរកឃើញថា មានតែ ១៦% ប៉ុណ្ណោះនៃគ្រូបង្រៀនថ្នាក់មធ្យមសិក្សាបឋមភូមិក្នុងប្រព័ន្ធអប់រំចំនួន ៣៤ ដែលបានផ្តល់វគ្គបណ្តុះបណ្តាលការអប់រំពហុវប្បធម៌ ឬពហុភាសានៅក្នុងឆ្នាំកន្លងទៅ។

មានការសិក្សាតិចតួចប៉ុណ្ណោះស្តីពីផលប៉ះពាល់នៃគ្រូបង្រៀនដែលមានសាវតារជាជនចំណាកស្រុក ហើយការសិក្សាដែលមាន ប្រហែលពុំបានញែកឱ្យដាច់ពីគ្នារវាងជនចំណាកស្រុកជំនាន់ទីមួយ និងជំនាន់បន្តបន្ទាប់ ឬញែកគ្នារវាងគ្រូបង្រៀនជាជនចំណាកស្រុក និងជាជនជាតិភាគតិចនោះទេ។ ភស្តុតាងមួយចំនួនស្នើឱ្យឃើញថា ភាពចម្រុះគ្នាក្នុងចំណោមគ្រូបង្រៀន គឺជាប់ទាក់ទងជាមួយការសម្រេចបានលទ្ធផលសិក្សារបស់សិស្សជាជនចំណាកស្រុក ការឱ្យតម្លៃខ្លួនឯង និងអារម្មណ៍សុវត្ថិភាពរបស់សិស្សជាជនចំណាកស្រុក។ ទោះយ៉ាងណាក្តី គ្រូបង្រៀនដែលមានសាវតារជាជនចំណាកស្រុក ច្រើនតែពុំសូវមានចំនួនច្រើន បើធៀបជាមួយចំនួនសិស្សនៅក្នុងទ្វីបអឺរ៉ុប។ គោលនយោបាយដែលមានលក្ខណៈរើសអើងក្នុងការចូលទៅក្នុងអាជីពនេះ និងភាពលម្អៀងក្នុងការជួលគ្រូបង្រៀន បានចូលរួមមួយផ្នែកក្នុងការជំរុញឱ្យមានកង្វះខាតនេះកើតឡើង។

## ការអប់រំមានតួនាទីក្នុងការទប់ស្កាត់អំពើហិង្សាជ្រុលនិយម

ស្របពេលដែលជ្រុលនិយមហិង្សា ការវាយប្រហារដោយភេរវជន និងការផ្តោតគោលដៅលើជនស៊ីវិលរបស់រដ្ឋ និងមិនមែនរដ្ឋ ជាបុព្វហេតុដោយផ្ទាល់ដោយគ្មានសង្ស័យធ្វើឱ្យមានចំណាកស្រុក និងការផ្លាស់ទីលំនៅដោយបង្ខំ ប៉ុន្តែទស្សនៈយល់ឃើញរបស់សាធារណជន ក្នុងបណ្តាប្រទេសមានចំណូលខ្ពស់

បានបែរជាឈានមកសង្កត់ធ្ងន់ហួសប្រមាណលើទិដ្ឋភាពបញ្ហាសពីនេះទៅវិញ ដោយបានផ្សារភ្ជាប់ចំណាក ស្រុកជាមួយភេរវកម្ម ។ ទោះយ៉ាងណាក្ដីការភ្ជាប់ទំនាក់ទំនងបែបនេះ គឺមានលក្ខណៈផុយស្រួយ យ៉ាង ខ្លាំង ដោយការវាយប្រហារធ្វើឡើងដោយជនបរទេសមានចំណែកដ៏តិចតួចប៉ុណ្ណោះក្នុងចំណោមការវាយ ប្រហារធ្វើឡើងដោយប្រជាជាតិនានា ហើយគន្លងវិថីឈានទៅមូលបដិវត្តនិយម អាចមានទម្រង់ផ្សេងៗគ្នា ជាច្រើន។

“តាមរយៈការលើកកម្ពស់ការគោរពភាពចម្រុះគ្នា សន្តិភាព និងការឈានឡើងផ្នែកសេដ្ឋកិច្ច ការអប់រំអាចជាទ្រនាប់ការពារប្រឆាំងមូលបដិវត្តនិយម”

ការទប់ស្កាត់ការកើតមានជ្រុលនិយម គឺជាបន្ទាត់គន្លឹះមួយនៃការការពារប្រឆាំងភេរវកម្ម។ ជនជ្រុលនិយមច្រើនតែប្រើប្រាស់បញ្ហាប្រឈមការអភិវឌ្ឍ ឬបំភ្លើសបញ្ហាប្រឈមទាំងអស់នោះ ដើម្បីបង្កើត និងទាញប្រយោជន៍ពីវដ្តអាក្រក់នៃការមើលចម្លងជាពិសេសបញ្ហាដែលជះឥទ្ធិពលលើជនក្រីក្របំផុត និងជនងាយរងគ្រោះបំផុត។

តាមរយៈការលើកកម្ពស់ការគោរពភាពចម្រុះគ្នា សន្តិភាព និងការឈានឡើងផ្នែកសេដ្ឋកិច្ច ការអប់រំ អាចជាទ្រនាប់ការពារប្រឆាំងមូលបដិវត្តនិយម។ ជនជ្រុលនិយមហិង្សា ជារឿយៗតែងមើលឃើញការអប់រំជា ការគំរាម និងផ្តោតគោលដៅការវាយប្រហារទៅលើសាលារៀននានា ដូចជាក្នុងករណីការវាយប្រហារលើ សាលាBoko Haram ក្នុងប្រទេសនីហ្សេរីយ៉ាជាដើម។

ផ្ទុយទៅវិញ ការផាត់ចេញពីការអប់រំអាចបង្កើតភាពងាយរងគ្រោះចំពោះមូលបដិវត្តនិយម។ ការផាត់ ចេញពីអត្ថប្រយោជន៍នៃការអប់រំ គឺបង្កគ្រោះថ្នាក់ដូចគ្នានេះផងដែរ។ ក្នុងបណ្ដាប្រទេសទាំង ៨ របស់អារ៉ាប់ ភាពគ្មានការងារធ្វើបានបង្កើនលទ្ធភាពនៃបញ្ហាមូលបដិវត្តនិយមក្នុងចំណោមអ្នកមានការអប់រំខ្ពស់ដែលមាន ក្តីរំពឹងថា ការឈានឡើងផ្នែកសេដ្ឋកិច្ច គឺមានលក្ខណៈគួរឱ្យខកចិត្ត។

បណ្ដាប្រទេសជាច្រើន បានដាក់បញ្ចូលកិច្ចខិតខំដើម្បីទប់ស្កាត់អំពើហិង្សាជ្រុលនិយមនៅក្នុងកម្មវិធីសិក្សា ប៉ុន្តែសម្ភារៈការបង្រៀន ពុំមែនជានិច្ចជាកាលតែងតែត្រូវគ្នាជាមួយកិច្ចខិតខំទាំងនេះឡើយ។ នៅទូទាំង ពិភពលោក សៀវភៅពុម្ពដែលពាក់ព័ន្ធមួយក្បាលក្នុងចំណោម ១០ ក្បាល គ្របដណ្ដប់លើការទប់ស្កាត់ជម្លោះ ប្រដាប់អាវុធ ឬពិភាក្សាអំពីការដោះស្រាយជម្លោះ ឬយន្តការដោះស្រាយជម្លោះ ដែលនេះជាចំនួនកើនឡើង ដ៏តិចតួច គិតចាប់ទីទសវត្សឆ្នាំ ១៩៥០ មក។

គ្រូបង្រៀន អាចជួយជំរុញឥរិយាបថអត់ឱន ប៉ុន្តែពួកគាត់ត្រូវការការបណ្ដុះបណ្ដាលឱ្យបានគ្រប់ គ្រាន់។ វិធីសាស្ត្របែបគរុកោសល្យ ដូចជាការរៀនសូត្រពីមិត្តភក្តិទៅវិញទៅមក ការសិក្សាបែបពិសោធន៍ ការ ធ្វើការងារជាក្រុម ការសម្ដែងតួ និងគោលវិធីដទៃទៀត ដែលជួយជំរុញការគិតបែបស៊ីជម្រៅ និងការពិភាក្សា បើកចំហ គឺមានប្រសិទ្ធភាពបំផុត។ ស្របពេលជាមួយគ្នានេះដែរ គ្រូបង្រៀនពុំគួរចាំឃ្លាំមើលសិស្សរបស់ខ្លួន គឺរឹតត្បិតសេរីភាពបុគ្គលរបស់សិស្សក្នុងបំណង ដើម្បីទទួលបានសន្តិសុខនោះឡើយ។

សាលារៀន អាចជាទីតាំងដ៏ប្រសើរសម្រាប់ការផ្តួចផ្តើមគំនិត ដើម្បីបង្ការជ្រុលនិយមហិង្សា ដោយមានការចូលរួមពីភាគីពាក់ព័ន្ធនានានៅក្រៅប្រព័ន្ធអប់រំ។ កម្មវិធីមួយចំនួនរួមមាននៅក្នុងប្រទេសឥណ្ឌូណេស៊ីជាដើម បានប្រើប្រាស់សំឡេងរបស់ជនរងគ្រោះ ដើម្បីធ្វើឱ្យប្រធានបទនេះកាន់តែមានភាពពាក់ព័ន្ធ និងមានសារៈសំខាន់ថែមទៀតចំពោះសិស្ស។ ការអប់រំប្រឆាំងជ្រុលនិយមហិង្សា គួរតែមានការយកចិត្តទុកដាក់ចំពោះផ្នែកយេនឌ័រ និងធ្វើឱ្យមានការចូលរួមពីស្ត្រី និងក្មេងស្រី។ ពេលខ្លះស្ត្រីដឹកនាំការផ្តួចផ្តើមគំនិតការអប់រំប្រភេទនេះ។ ឧទាហរណ៍ នៅក្នុងខេត្ត Khyber Pakhtunkhwa របស់ប្រទេសប៉ាគីស្ថាន អង្គការស្ត្រីមួយបានបង្រៀនអំពីការតាំងសមាធិ និងជំនាញក្នុងការផ្លាស់ប្រែជម្លោះដល់ស្ត្រីចំនួន ៣៥ ០០០ នាក់ និងយុវជន ២ ០០០ នាក់។

## ការអប់រំក្រៅផ្លូវការមានតួនាទីដ៏ចាំបាច់ ប៉ុន្តែត្រូវបានគេបំភ្លេចចោលនៅក្នុងការស្តាបនាសង្គមដែលមានភាពធន់ទ្រាំ

ការអប់រំ និងការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាចំណាកស្រុក និងការផ្លាស់ទីលំនៅដោយបង្ខំក៏បានធ្វើឡើងនៅក្រៅរបងសាលារៀនផងដែរ។ ការអប់រំក្រៅផ្លូវការ មានទម្រង់ និងគោលបំណងផ្សេងៗជាច្រើន។ គួរឲ្យសោកស្តាយ រដ្ឋាភិបាលកម្រនឹងធ្វើជាអ្នកផ្តល់ការអប់រំប្រភេទនេះណាស់ ដោយមានព័ត៌មានជាប្រព័ន្ធតិចតួចប៉ុណ្ណោះអំពីបញ្ហានេះ។

មជ្ឈមណ្ឌលសហគមន៍ដើរតួនាទីដ៏សំខាន់នៅក្នុងការអប់រំក្រៅផ្លូវការស្តីពីចំណាកស្រុក។ ក្នុងប្រទេសតួកគី អង្គការ NGO ឈ្មោះ សមាគម Yuva ផ្តល់វគ្គបង្រៀនភាសា និងសិក្ខាសាលាជំនាញតាមរយៈមជ្ឈមណ្ឌលសហគមន៍។ អ្នកសម្របសម្រួលផ្នែកវប្បធម៌ ឬឈ្មួញកណ្តាល អាចផ្តល់សេវាបកប្រែភាសា និងជួយក្នុងការតម្រង់ទិសប្រព័ន្ធអប់រំ។ ក្រុង Linköping របស់ប្រទេសស៊ុយអែត ផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្រៀនតាមផ្ទះនូវចំណេះដឹងអំពីភាសាសូម៉ាលី ឬភាសាអារ៉ាប់ ដើម្បីដើរតួនាទីជា "មនុស្សជាតំណភ្ជាប់" សម្រាប់កម្មវិធីសិក្សារួមគ្នារបស់ខ្លួន។ ក្រុងនានា អាចដឹកនាំកិច្ចខិតខំក្នុងការអប់រំប្រឆាំង និងការភ័យខ្លាចចំពោះជនបរទេស ដូចជានៅក្នុងក្រុង São Paulo ប្រទេសប្រេស៊ីលជាដើម ប៉ុន្តែគួរឱ្យមានការចូលរួមពីសហគមន៍ជនចំណាកស្រុកផងដែរ ដើម្បីអាចទទួលបានជោគជ័យ។

សិល្បៈ និងកីឡា គឺជាប្រព័ន្ធផ្សព្វផ្សាយដ៏មានឥទ្ធិពលខ្ពស់សម្រាប់ការអប់រំក្រៅប្រព័ន្ធ។ ពិធីបុណ្យក្នុងសហគមន៍របស់ប្រទេសន័រវែស និងប្រទេសអេស្ប៉ាញ ផ្តល់ឱកាសសម្រាប់ការផ្លាស់ប្តូរអន្តរវប្បធម៌។ ក្រុមកីឡាបាល់ទាត់ Kaizer Chiefs របស់ប្រទេសអាហ្វ្រិកខាងត្បូង បានជំរុញយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយសង្គមឱ្យមើលឃើញយ៉ាងច្បាស់នូវការចូលរួមចំណែកជាវិជ្ជមានរបស់ជនបរទេសចំពោះប្រទេសនេះ។

# ការផ្លាស់ទីរបស់សិស្ស និងអ្នកប្រកបវិជ្ជាជីវៈអាជីព

នៅក្នុងពិភពលោកដែលមានលក្ខណៈសាកលភាវូបនីយកម្មកាន់តែខ្លាំងឡើង មនុស្សវ័យក្មេងដែលសិក្សានៅបរទេស និងអ្នកប្រកបវិជ្ជាជីវៈអាជីពមានជំនាញ តាមច្បាមយកឱកាសមុខរបរឆ្លងដែន ដើម្បីបន្តទេពកោសល្យសមត្ថភាពរបស់ខ្លួន។ ការផ្លាស់ទីរបស់អ្នកធ្វើការជំនាញ មានអត្ថប្រយោជន៍ ការចំណាយ និងហានិភ័យគួរជាទីកត់សម្គាល់សម្រាប់បុគ្គល ស្ថាប័ន និងប្រទេស។

# អន្តរជាតិតូបនីយកម្មនៃការអប់រំថ្នាក់ឧត្តមសិក្សាកើតមានក្នុងទម្រង់ផ្សេងៗជាច្រើន

អន្តរជាតិតូបនីយកម្មនៃការអប់រំថ្នាក់ឧត្តមសិក្សា រួមមាន "គោលនយោបាយ និងការអនុវត្តនានាដែលត្រូវបានធ្វើឡើងដោយប្រព័ន្ធ និងស្ថាប័នសិក្សាស្រាវជ្រាវ និងបុគ្គលផងដែរ ដើម្បីទប់ទល់ជាមួយបរិស្ថានការសិក្សាស្រាវជ្រាវសាកល"។ អន្តរជាតិតូបនីយកម្មនៃការអប់រំថ្នាក់ឧត្តមសិក្សា គ្របដណ្តប់លើចលនារបស់សិស្ស និងបុគ្គលិកសិក្សា ក៏ដូចជាវគ្គសិក្សាកម្មវិធី និងស្ថាប័ននានា ដែលប៉ះពាល់មកដល់ការអប់រំនៅក្នុងប្រទេស និងនៅបរទេសផងដែរ។

ពាក់កណ្តាលនៃសិស្សអន្តរជាតិទាំងអស់ ផ្លាស់ទីទៅកាន់ប្រទេសនិយាយភាសាអង់គ្លេសចំនួនប្រាំ គឺ៖ អូស្ត្រាលី កាណាដា នូវែលសេឡង់ ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក។ សមាមាត្រនៃសិស្សអន្តរជាតិក្នុងប្រទេសបារាំង និងអាល្លឺម៉ង់ បានកើនឡើងដោយមានចំនួន ៨% ក្នុងប្រទេសបារាំង និង ៦% ក្នុងប្រទេសអាល្លឺម៉ង់ ការកើនឡើងនេះ កើតឡើងមួយផ្នែក ដោយសារតែប្រទេសទាំងនេះផ្តល់កម្មវិធីអប់រំក្រោយឧត្តមសិក្សាជាភាសាអង់គ្លេសកាន់តែច្រើនឡើង។ ប្រទេសចិន ឥណ្ឌា និងសាធារណរដ្ឋកូរ៉េ ទទួលការផ្លាស់ទីការចេញក្រៅប្រទេសចំនួន២៥%នៃចំនួនសរុបក្នុងឆ្នាំ២០១៦។ទ្វីបអឺរ៉ុបគឺជាតំបន់បញ្ជូនសិស្សចេញច្រើនជាងគេបំផុតទីពីរ ដោយក្នុងនោះមាន ២៣% នៃចំនួនសិស្សសរុបក្នុងឆ្នាំ ២០១៦ ប៉ុន្តែ ៧៦% នៃសិស្សអឺរ៉ុបដែលបានផ្លាស់ទីចំនួន ០,៩ លាននាក់ស្ថិតនៅក្នុងតំបន់អឺរ៉ុប។

សិស្សសម្រេចចិត្តអំពីទីកន្លែង ដើម្បីបន្តការអប់រំថ្នាក់ឧត្តមសិក្សា ផ្អែកលើកន្លែង សិក្សាល្អបំផុតដែលមានសម្រាប់ខ្លួននៅសាលាវិទ្យាល័យក្នុងប្រទេស សមត្ថភាពដើម្បីបង់ថ្លៃ និងគុណភាពនៃការអប់រំប្រៀបធៀបគ្នារវាងការអប់រំក្នុងប្រទេស និងនៅបរទេស។ គោលនយោបាយដែលគ្របដណ្តប់លើសមត្ថភាពរបស់សិស្សក្នុងការធ្វើការក៏អាចជាកត្តាជំរុញមួយផងដែរ។ ក្នុង ឆ្នាំ ២០១១-២០១៤ ចំនួនសិស្សឥណ្ឌាក្នុងចក្រភពអង់គ្លេស ធ្លាក់ចុះជិត ៥០% បន្ទាប់ពីគោលនយោបាយមានការផ្លាស់ប្តូរទាក់ទងជាមួយទិដ្ឋាការធ្វើ

ការងាររបស់សិស្សក្រោយថ្នាក់បរិញ្ញាបត្រដែលមានកម្រិតកំណត់ជាមុន ស្របពេលជាមួយគ្នានោះ ចំនួនបាន កើនឡើង ៧០% ក្នុងប្រទេសអូស្ត្រាលី និង ៣៧% នៅសហរដ្ឋអាមេរិក។ ប្រទេសមួយចំនួន រួមទាំងប្រទេស ចិន និងអាល្លឺម៉ង់ផងដែរ ព្យាយាមរក្សាសិស្សអន្តរជាតិ ឱ្យបន្តនៅក្នុងទីផ្សារការងាររបស់ខ្លួន ដើម្បីបំពេញ ចន្លោះប្រហោងផ្នែកជំនាញដែលមាននៅក្នុងប្រទេស។

សម្រាប់សាកលវិទ្យាល័យ ការបង្កើនចំណូលគឺជាកត្តាជំរុញចម្បងនៃការជ្រើសរើសសិស្សអន្តរជាតិ ឱ្យចូលរៀន។ ក្នុងឆ្នាំ ២០១៦ សិស្សអន្តរជាតិ បាននាំយកទឹកប្រាក់ប្រមាណ ៣៩ ,៤ ប៊ីលាន ដុល្លារអាមេរិក ចូលមកក្នុងសេដ្ឋកិច្ច សហរដ្ឋអាមេរិក ។ នៅក្នុងបណ្តា ប្រទេស អាស៊ានជាច្រើន ដែលមានអត្រាកំណើតថយចុះ និងចំនួនវ័យចំណាស់កើតមានឡើង ដូចជានៅប្រទេសជប៉ុនជាដើម វិស័យអប់រំឧត្តមសិក្សា កំពុងងាកទៅរកសិស្សបរទេស ដើម្បីរក្សាឱ្យស្ថាប័នឧត្តមសិក្សារបស់ខ្លួននៅបន្តបើកទ្វារ។

> “ពាក់កណ្តាលនៃសិស្សអន្តរជាតិ ផ្លាស់ទីទៅកាន់ប្រទេសនិយាយភាសាអង់គ្លេសចំនួនប្រាំ ចំណែកប្រទេសចំនួនបីនៅទ្វីបអាស៊ីទទួលបន្ទុកលើ ២៥% នៃសិស្សដែលចេញទៅក្រៅប្រទេសទាំងអស់។”

ប្រទេសម៉ិចស៊ិក និងសហរដ្ឋអាមេរិក គឺជាប្រទេសពីរក្នុងចំណោមបណ្តាប្រទេសនានា ដែលប្រើប្រាស់កម្មវិធីចល័តជាភ្នាក់ងារការទូតវប្បធម៌ និងជំនួយអភិវឌ្ឍន៍។ ប្រទេសមួយចំនួនដែលជាប្រទេសបញ្ជូនសិស្សរួមទាំងប្រទេសប្រេស៊ីល និងអារ៉ាប់សាអូឌីត ផ្តល់ការឧបត្ថម្ភទុនដល់ការសិក្សានៅប្រទេសជាយុទ្ធសាស្ត្រមួយសម្រាប់ការអភិវឌ្ឍ។

បុគ្គលិកសិក្សាដែលផ្លាស់ទីជាអន្តរជាតិ អាចជាអ្នកសិក្សាស្រាវជ្រាវ ដែលសាកលវិទ្យាល័យធ្មើមៗព្យាយាមចង់បានអ្នកសិក្សាស្រាវជ្រាវត្រូវបានជួលឱ្យមកធ្វើការ ដើម្បីបំពេញចន្លោះប្រហោង ដែលមាននៅក្នុងប្រទេស ឬ "អ្នកសិក្សាស្រាវជ្រាវឆ្លងកាត់" ដែលបន្តអាជីពការងាររបស់ខ្លួននៅតាមបណ្តាប្រទេសដែលពួកគេបានទទួលសញ្ញាបត្រថ្នាក់បណ្ឌិតរបស់ខ្លួន។ ការផ្លាស់ទីផ្នែកស្ថាប័ន អាចបង្កឱ្យការផ្លាស់ទីរបស់សិស្សតាមបែបប្រពៃណីមានការថយចុះ ប៉ុន្តែបម្រើឱ្យសិស្សច្រើនជាងមុន ដែលមានតម្រូវការផ្នែកការអប់រំផ្សេងៗគ្នា។ វគ្គសិក្សាបើកទូលាយតាមប្រព័ន្ធអ៊ីនធឺណិតក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ ជួយពង្រីកលទ្ធភាពទទួលបានការអប់រំ ជាពិសេសនៅក្នុងប្រកពប្រទេសកំពុងអភិវឌ្ឍ។ កម្មវិធីឯនាយសមុទ្រ កម្មវិធីឆ្លងដែន និងកម្មវិធីគ្មានព្រំដែន រួមទាំងមណ្ឌលសិក្សាសាខា និងមជ្ឈមណ្ឌលអប់រំថ្នាក់តំបន់ ជួយជំរុញឱ្យមានការអប់រំកម្រិតអន្តរជាតិនៅក្នុងប្រទេសកំណើត។

# ការធ្វើសុខដុមនីយកម្មបទដ្ឋាន និងការទទួលស្គាល់គុណវុឌ្ឍិជួយសម្របសម្រួលដល់អន្តរជាតូបនីយកម្មនៃការអប់រំថ្នាក់ឧត្តមសិក្សា

ដើម្បីជួយសម្រួលដល់ការផ្លាស់ទីរបស់សិស្ស ស្ថាប័ននានា អាចធ្វើឱ្យមានការចូលរួមក្នុងទំនាក់ទំនង និងកិច្ចព្រមព្រៀងស្មុគស្មាញ ឧ. កម្មវិធីផ្តល់វិញ្ញាបនបត្រពីរ និងផ្តល់វិញ្ញាបនបត្ររួមគ្នា ការផ្ទេរក្រេឌីត ភាពជាដៃគូជាយុទ្ធសាស្ត្រ និងការរួបរួមគ្នាជាសមាគម។ បណ្តាប្រទេសនានា ព្យាយាមកាន់តែខ្លាំងឡើងក្នុងការធ្វើសុខដុមនីយកម្មបទដ្ឋាន និងយន្តការធានាគុណភាពនៅកម្រិតទ្វេភាគី ថ្នាក់តំបន់ ឬថ្នាក់សាកល។

ការដាក់ឱ្យមានបទដ្ឋានកម្រិតសិក្សាដូចគ្នា ការទទួលស្គាល់គុណភាព យន្តការទទួលស្គាល់គុណវុឌ្ឍិ និងកម្មវិធីផ្លាស់ប្តូរការផ្លាស់ទីផ្នែកសិក្សាស្រាវជ្រាវ អនុញ្ញាតឱ្យបណ្តាប្រទេសអឺរ៉ុប និងបណ្តាប្រទេសជាដៃគូ អាចបង្កើតតំបន់អប់រំឧត្តមសិក្សាអឺរ៉ុប (EHEA) ក្នុងឆ្នាំ ២០១០។ នេះគឺជាការឈានឡើងមួយកម្រិតទៀត នៃដំណើរការ Bologna ដែលបានដាក់សម្ពោធក្នុងឆ្នាំ ១៩៩៩ ដោយក្នុងនោះ មានការចូលរួមពីគណៈកម្មការអឺរ៉ុប ក្រុមប្រឹក្សាអឺរ៉ុប និងអ្នកតំណាងរបស់ស្ថាប័នអប់រំឧត្តមសិក្សា ទីភ្នាក់ងារធានាគុណភាព សិស្សនិស្សិត បុគ្គលិក និងនិយោជកមកពីបណ្តាប្រទេសចំនួន ៤៨ ដែលមានបច្ចុប្បន្ន។ អនុសញ្ញាការទទួលស្គាល់ Lisbon អភិបាលលើការទទួលស្គាល់គុណវុឌ្ឍិរវាងបណ្តាប្រទេស EHEA ហើយត្រូវបានផ្តល់សច្ចាប័នដោយប្រទេស ចំនួន ៥៣។

តំបន់ដទៃទៀត កំពុងខិតខំដើម្បីប្រជែងជាមួយ ការផ្តួចផ្តើមគំនិតទាំងអស់នេះ រួមទាំងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងសហគមន៍អាហ្វ្រិកបូព៌ា។ នៅក្នុងសន្និសីទថ្នាក់តំបន់លើកទីបី ស្តីពីការអប់រំថ្នាក់ឧត្តមសិក្សា បណ្តាប្រទេសក្នុងតំបន់អាមេរិកឡាទីន និងការ៉ាប៊ីន បានព្រមព្រៀងគ្នាពង្រឹងសមាហរណកម្មថ្នាក់តំបន់ក្នុងវិស័យអប់រំឧត្តមសិក្សា។ ដើម្បីស្ថាបនាបន្ថែមលើការផ្តួចផ្តើមគំនិតទាំងអស់នេះ អង្គការយូណេស្កូបានសរសេរសេចក្តីព្រាងអនុសញ្ញាសាកលស្តីពីការទទួលស្គាល់គុណវុឌ្ឍិការអប់រំថ្នាក់ឧត្តមសិក្សាសម្រាប់ដាក់ឱ្យផ្តល់សច្ចាប័នក្នុងឆ្នាំ ២០១៩។

## កម្មវិធីផ្តោះប្តូរសិស្សក្នុងទ្វីបអឺរ៉ុបផ្តល់ជាមេរៀនសម្រាប់តំបន់អាស៊ីអាគ្នេយ៍

ការដាក់ឱ្យមានជាស្ថាប័នកម្មវិធីផ្តោះប្តូរសិស្ស នៅថ្នាក់តំបន់ បានពង្រីកឱកាសដ៏ធំធេងសម្រាប់ការផ្លាស់ទីសិស្សរយៈពេលខ្លី។ នៅក្រោមកម្មវិធី Erasmus ដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩៨៧ និងបានពង្រីកឱ្យក្លាយទៅជា Erasmus+ ក្នុងឆ្នាំ ២០១៤ សិស្សដែលចូលរួមក្នុងកម្មវិធីនេះ សិក្សារយៈពេល ៣ ដល់ ១២ ខែ នៅក្នុងប្រទេសអឺរ៉ុបដទៃមួយផ្សេងទៀត ហើយស្ថាប័នម្ចាស់ផ្ទះ យករយៈពេលនេះដាក់ទៅអនុវត្តក្នុងវិញ្ញាបនបត្របញ្ជាក់ការសិក្សារបស់ខ្លួន។ កម្មវិធីនេះ មានបំណងពង្រឹងការយល់ដឹងផ្នែកអន្តរវប្បធម៌ បំណិន និងលទ្ធភាពទទួលបានការងាររបស់អ្នកចូលរួម និងលើកកម្ពស់សាមគ្គីភាពសង្គមនៅទ្វីបអឺរ៉ុប។

អ្នកចូលរួមប្រមាណ ៩ នាក់ក្នុងចំណោម ១០ នាក់ បានរាយការណ៍ថា កម្មវិធីនេះ បានបង្កើនភាពធន់ ការបើកចិត្តទូលាយ និងភាពអត់ឱនរបស់ពួកគេ។ មានភស្តុតាងចង្អុលបង្ហាញឱ្យឃើញថា ការផ្លាស់ទីរបស់សិស្សអឺរ៉ុប បានបង្កើនលទ្ធភាពទទួលបានការងារធ្វើ។ ទោះយ៉ាងណាក្តី ការវាយតម្លៃដោយប្រើប្រាស់ទិន្នន័យរយៈពេលវែង ដែលត្រួតពិនិត្យលើកត្តាកំណត់នៃការផ្លាស់ទីរបស់សិស្ស បានផ្តល់រូបភាពលាយឡំគ្នាទាក់ទងជាមួយសមធម៌។ ប្រមាណ ៤,៤% នៃសិស្សចក្រភពអង់គ្លេស ដែលមានឪពុកម្តាយជាអ្នកប្រកបវិជ្ជាជីវៈ ចូលរួមនៅក្នុងកម្មវិធី Erasmus+ ក្នុងឆ្នាំ ២០១៥/១៦ បើធៀបជាមួយ ២,៨% នៃឪពុកម្តាយដែលមានជំនាញទាប។ គម្លាតនេះកើនឡើងកាន់តែធំសម្រាប់រយៈពេលកាន់តែយូរ។

ក្នុងឆ្នាំ ២០១៥ អាស៊ាន និងសហភាពអឺរ៉ុប បានដាក់សម្ពោធកម្មវិធីការគាំទ្ររបស់ EU ចំពោះការអប់រំថ្នាក់ឧត្តមសិក្សានៅក្នុងតំបន់អាស៊ាន (SHARE) ដើម្បីគាំទ្រដល់ការធ្វើសុខដុមនីយកម្មប្រព័ន្ធឧត្តមសិក្សាថ្នាក់តំបន់។ ឧសបគ្គរារាំងកំណើនការផ្លាស់ទី គឺជាលទ្ធផលកើតចេញពីកង្វះកិច្ចខិតខំរួមគ្នាក្នុងចំណោមភាគីពាក់ព័ន្ធថ្នាក់តំបន់។ ខុសប្លែកពីទ្វីបអឺរ៉ុប ប្រព័ន្ធផ្ទេរក្រេឌីតមានភាពខុសប្លែកគ្នាយ៉ាងធំធេងក្នុងចំណោមបណ្តាប្រទេសអាស៊ាន។

---

## ការទទួលស្គាល់គុណវុឌ្ឍិវិជ្ជាជីវៈអាជីពជួយបង្កើនជាអតិបរិមាដល់អត្ថប្រយោជន៍នៃការផ្លាស់ទីផ្នែកពលកម្មអន្តរជាតិជាអតិបរមា

ការទទួលស្គាល់គុណវុឌ្ឍិវិជ្ជាជីវៈអាជីពជួយសម្របសម្រួល និងបង្កើនអត្ថប្រយោជន៍នៃការធ្វើចំណាកស្រុកផ្នែកការងារជំនាញបានជាអតិបរមា។ ក្នុងបណ្តាប្រទេស OECD ជនចំណាកស្រុកជាងមួយភាគបីដែលមានការអប់រំថ្នាក់ឧត្តមសិក្សា គឺមានគុណវុឌ្ឍិលើសពីតម្រូវការនៅក្នុងការងាររបស់ខ្លួន បើធៀបជាមួយមួយភាគបួននៃជនម្ចាស់ស្រុក។ នៅក្នុងសហរដ្ឋអាមេរិក ការលះបង់ការរកចំណូលរបស់សិស្សថ្នាក់ក្រោយបរិញ្ញាបត្រជាជនចំណាកស្រុកគ្មានការងារធ្វើអាចមានទំហំទឹកប្រាក់ ១០,២ ប៊ីលានដុល្លារ ជាការខាតបង់នៅក្នុងចំណូលពន្ធប្រចាំឆ្នាំ។

ប៉ុន្តែប្រព័ន្ធទទួលស្គាល់ ជារឿយៗតែងមានការអភិវឌ្ឍមិនពេញលេញ ឬមិនឯកភាពគ្នា ដើម្បីឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ជនចំណាកស្រុក។ ដំណើរការមានលក្ខណៈស្មុគស្មាញ ចំណាយពេលច្រើន និងអស់ថ្លៃខ្ពស់ ដូច្នេះ ជារឿយៗ មានតែមនុស្សភាគតិចប៉ុណ្ណោះដែលដាក់ពាក្យ។ ដើម្បីកែលម្អប្រសិទ្ធភាព ទីភ្នាក់ងារវាយតម្លៃ ស្ថាប័នផ្តល់អាជ្ញាប័ណ្ណ និងស្ថាប័នសិក្សាស្រាវជ្រាវ អាចធ្វើសុខដុមនីយកម្មលើតម្រូវការ និងនីតិវិធីនានាបាន។ រដ្ឋាភិបាលអាចធានាឱ្យទីភ្នាក់ងារទាំងឡាយ ត្រូវអនុវត្តតាមដោយប្រើនីតិវិធីយុត្តិធម៌ មានតម្លាភាព និងប្រកាន់ខ្ជាប់តាមការអនុវត្តល្អ។ ការបង្កើតឱ្យមានសិទ្ធិស្របច្បាប់ក្នុងការទទួលស្គាល់ ក៏អាចជួយកែលម្អការទទួលយកប្រព័ន្ធមកប្រើប្រាស់ និងប្រសិទ្ធិផលផងដែរ ដូចជាក្នុងប្រទេសដាណឺម៉ាកជាដើម។

ច្បាប់ក្នុងប្រទេសអាល្លឺម៉ង់ ដែលបានចេញឆ្នាំ ២០១២ អនុញ្ញាតឱ្យជនបរទេសអាចបានការទទួលស្គាល់ដោយមិនគិតអំពីស្ថានភាពលំនៅដ្ឋាន ឬភាពជាពលរដ្ឋរបស់ជននោះឡើយ។

នៅពេលគុណវុឌ្ឍិរបស់ខ្លួនពុំត្រូវបានគេទទួលស្គាល់ ជនចំណាកស្រុកពុំអាចប្រកបវិជ្ជាជីវៈដោយស្របច្បាប់នៅក្នុងអាជីពដែលស្ថិតក្រោមនិយ័តកម្ម ដូចជា ការបង្រៀន និងការងារថែទាំព្យាបាលបានឡើយ បើទោះបីជាមានមុខតំណែងទំនេរនៅក្នុងបណ្តាប្រទេសគោលដៅជាច្រើនក្តី។ ការទទួលស្គាល់តែមួយផ្នែកអាចចូលរួមចំណែកជួយបាន។ អ្នកដាក់ពាក្យចាំបាច់ត្រូវប្រឡងជាប់ ធ្វើការក្រោមការមើលខុសត្រូវមួយរយៈ ឬត្រូវតែចៀសវាងមិនត្រូវអនុវត្តមុខងារជាក់លាក់មួយចំនួន។ សេចក្តីណែនាំគុណវុឌ្ឍិវិជ្ជាជីវៈអាជីពសហភាពអឺរ៉ុប អនុញ្ញាតឱ្យក្រុមអ្នកប្រកបវិជ្ជាជីវៈអាជីពមួយចំនួន ដែលមានគុណវុឌ្ឍិដែលត្រូវបានអនុម័តឱ្យប្រកបវិជ្ជាជីវៈនៅក្នុងសហភាពអឺរ៉ុបទាំងមូល។ ការបង្កើត និងការរក្សាឱ្យមានការទទួលស្គាល់ជាស្វ័យប្រវត្តិបែបនេះតម្រូវឱ្យមានការប្តេជ្ញាចិត្តផ្នែកនយោបាយ និងធនធានយ៉ាងធំធេង ហេតុនេះហើយ ទើបមិនសូវមានកិច្ចព្រមព្រៀងប្រហាក់ប្រហែលនេះច្រើនទេ។

## ចំណាកស្រុករបស់គ្រូបង្រៀននាំមកនូវអត្ថប្រយោជន៍ផង និងហានិភ័យផង

គ្រូបង្រៀនអាចត្រូវបានជំរុញទឹកចិត្តឱ្យធ្វើចំណាកស្រុកដោយសារតែប្រាក់ឈ្នួលទាប ភាពគ្មានការងារធ្វើអស្ថិរភាពនយោបាយ លក្ខខណ្ឌធ្វើការងារអន់ខ្សោយ និងកង្វះហេដ្ឋារចនាសម្ព័ន្ធ។ ប៉ុន្តែការបង្រៀនជារឿយៗគឺជាអាជីពស្ថិតក្រោមការមើលខុសត្រូវរបស់និយ័តកម្ម ជាកម្មវត្ថុនៃការតម្រូវគុណវុឌ្ឍិថ្នាក់ជាតិដែលធ្វើឱ្យជនចំណាកស្រុកជួបបញ្ហាប្រឈម។

ដោយហេតុថា លិខិតបទដ្ឋានគតិយុត្តិស្តីពីគុណវុឌ្ឍិរបស់គ្រូបង្រៀន ជារឿយៗ តែងពាក់ព័ន្ធជាមួយជំនាញផ្នែកភាសា មានលំហូរធំៗជាច្រើនកើតមានរវាងបណ្តាប្រទេសដែលមានភាសា និងវប្បធម៌ប្រហាក់ប្រហែលគ្នា។ គ្រូបង្រៀនមកពីប្រទេសអេហ្ស៊ីប និងបណ្តាប្រទេសអារ៉ាប់ដទៃទៀត ត្រូវបានទាក់ទាញដោយប្រាក់ឈ្នួលខ្ពស់ បានជួយពង្រីកប្រព័ន្ធអប់រំនៅបណ្តារដ្ឋក្នុងក្រុមប្រឹក្សាកិច្ចសហប្រតិបត្តិការឈូងសមុទ្រ។ ឥឡូវនេះ បណ្តាប្រទេសនានា ជំនួសភាសាអារ៉ាប់ដោយភាសាអង់គ្លេស ជាភាសាសម្រាប់ការបង្រៀនវិញ ហើយធ្វើឱ្យអ្នកនិយាយភាសាអង់គ្លេស កំពុងចូលមកជំនួសឱ្យគ្រូបង្រៀនជនជាតិអេហ្ស៊ីប និងហ្ស៊កដានី។

ចំណាកស្រុករបស់គ្រូបង្រៀនអាចបង្កើតឱ្យមានផលបន្តគ្នា ធ្វើឱ្យមានកង្វះខាតគ្រូនៅក្នុងប្រទេសប្រភព។ ឧទាហរណ៍ ចក្រភពអង់គ្លេសជ្រើសរើសគ្រូបង្រៀនពីបណ្តាប្រទេសនានា ដូចជា ហ្សាម៉ាអ៊ីក និងអាហ្វ្រិកខាងត្បូង។ ជាលទ្ធផល ដោយប្រឈមមុខជាមួយកង្វះគ្រូបង្រៀនក្នុងប្រទេសរបស់ខ្លួន ប្រទេសអាហ្វ្រិកខាងត្បូងបានជ្រើសរើសគ្រូបង្រៀនពីបរទេសជាពិសេសគឺពីប្រទេសស៊ីមបាវ៉េ។បណ្តាប្រទេសការីប៊ីនក៏ជួបបញ្ហាចំណាកស្រុកខ្ពស់របស់គ្រូបង្រៀននៅក្នុងទសវត្សថ្មីៗនេះផងដែរ ដោយពួកគេត្រូវបានទាក់ទាញដោយកិច្ចខិតខំក្នុងការជ្រើសរើសគ្រូបង្រៀនយ៉ាងសកម្មនៅចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក មិនចាញ់ប្រទេសខាងលើនោះដែរ។

ការបាត់បង់សម្រាប់ប្រទេសបញ្ជូន អាចមានទំហំធំជេងទាំងក្នុងការវិនិយោគលើការបណ្តុះបណ្តាលគ្រូបង្រៀន និងការអប់រំ ព្រមទាំងសម្រាប់ប្រព័ន្ធអប់រំទាំងមូលផងដែរ។ កង្វល់នេះបានជំរុញឱ្យមានការផ្តួចផ្តើមគំនិតអន្តរជាតិដែលទទួលស្គាល់ផលប្រយោជន៍របស់ប្រទេសបញ្ជូន ដូចជាពិធីសារការជ្រើសរើសគ្រូបង្រៀនក្នុងបណ្តាប្រទេសដែលស្ថិតក្រោមអាណានិគមចក្រភពអង់គ្លេស (ប្រទេសខំមិនវែល)។ ទោះយ៉ាងណាក្តី ដោយសារពិធីសារនេះ គឺជាពិធីសារមិនជាប់កាតព្វកិច្ច ពិធីសារនេះ ពុំរារាំងគ្រូបង្រៀនជាបុគ្គលដែលមានបំណងចង់ធ្វើចំណាកស្រុកនោះឡើយ។

ការជ្រើសរើសគ្រូបង្រៀនអន្តរជាតិ គឺជាអាជីវកម្មផ្តល់កម្រៃច្រើនដែលទាក់ទាញទីភ្នាក់ងារពាណិជ្ជកម្មនានា។ ភ្នាក់ងារទាំងនេះ កម្រស្ថិតក្រោមនិយ័តកម្មតឹងរឹង ហើយអាចយកថ្លៃសេវាខ្ពស់ក្នុងការផ្តល់ការងារ ឬផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ ជាហេតុញុំាងឱ្យមានការអំពាវនាវពីការចុះបញ្ជីអ្នកជ្រើសរើសបុគ្គលិកនៅក្នុងប្រទេសបញ្ជូន និងប្រទេសទទួល។

## ការបាត់បង់ទេពកោសល្យ អាចបង្កផលអាក្រក់សម្រាប់បណ្តាប្រទេសក្រីក្រ

អត្រាចំណាកស្រុករបស់អ្នកមានជំនាញខ្ពស់ គឺមានអត្រាលើស ២០% នៅក្នុងបណ្តាប្រទេសជាងមួយភាគបួនក្នុងចំណោមប្រទេស និងដែនដី ១៧៤ រួមទាំងហ្គ្រើណាដ និងហ្គីយ៉ានក្នុងតំបន់អាមេរិកឡាទីន និងការីប៊ីន អាល់បាល់នី និងម៉ាល់ត៍នៅទ្វីបអឺរ៉ុប និងអេរីត្រេ និងសូម៉ាលីនៅអនុតំបន់សាហារ៉ាទ្វីបអាហ្វ្រិក (រូបភាពទី ៥)។

បណ្តាប្រទេសអ្នកមានប្រជែងយ៉ាងសកម្មដើម្បីដណ្តើមយកពលករជំនាញជាហេតុធ្វើឱ្យមានកង្វល់ថា ចំណាកស្រុកអាចរារាំងការអភិវឌ្ឍនៅក្នុងបណ្តាប្រទេសបញ្ជូន អាស្រ័យដោយការបាត់បង់ជំនាញ។ ទោះយ៉ាងណាក្តី ក្រៅពីឥទ្ធិពលបង្កឡើងដោយការបញ្ជូនសាច់ប្រាក់ លទ្ធភាពនៃចំណាកស្រុកបុគ្គលិកជំនាញក៏អាចជំរុញឱ្យមានការវិនិយោគផ្នែកការអប់រំនៅក្នុងបណ្តាប្រទេសបញ្ជូនផងដែរ។ ការវិភាគលើរបាយការណ៍នេះ បង្ហាញឱ្យឃើញថា អត្រាចំណាកស្រុករបស់ពលករជំនាញខ្ពស់ក្នុងកម្រិត ១៤% បង្កើតឱ្យមានឥទ្ធិពលវិជ្ជមានខ្ពស់បំផុតលើកំណើនមូលធនមនុស្ស។ បន្ទាប់ពីការគណនាលើលក្ខណសម្បត្តិនៃបណ្តាប្រទេសកំណើត និងប្រទេសគោលដៅ លទ្ធភាពនៃការធ្វើចំណាកស្រុក បង្កើតឱ្យមានផលចំណេញផ្នែកខួរក្បាលក្នុងបណ្តាប្រទេសចំនួន ៩០ ក្នុងចំណោមប្រទេសទាំង ១៧៤។

ប្រទេសមួយចំនួន ជាពិសេសប្រទេសក្នុងទ្វីបអាស៊ី កំពុងទទួលបានពលរដ្ឋវិលត្រលប់មកវិញព្រមជាមួយជំនាញដ៏មានតម្លៃ។ ប្រទេសហ្វីលីពីន បានដាក់គោលនយោបាយសម្រាប់អ្នកវិលត្រលប់មកប្រទេសកំណើតវិញ និងតភ្ជាប់អ្នកបានវិលត្រលប់មកប្រទេសកំណើតវិញជាមួយការទទួលស្គាល់សេវា និងអនាគតនិយោជក។

**រូបភាពទី ៥៖**
**ក្នុងបណ្តាប្រទេសជាច្រើន មនុស្សលើសពីម្នាក់ក្នុងចំណោមមនុស្សប្រាំនាក់ដែលមានជំនាញខ្ពស់ នឹងធ្វើចំណាកស្រុក**
អត្រាចំណាកស្រុកអ្នកមានជំនាញក្នុងបណ្តាប្រទេសដែលបានជ្រើសរើស ឆ្នាំ ២០១០




GEM StatLink: http://bit.ly/fig6_1

ប្រភព៖ Deuster and Docquier (2018).

## ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ គឺជាឧបករណ៍មួយសម្រាប់ជនចំណាកស្រុក និងជនភៀសខ្លួន

កង្វល់ចំនួនពីរជះឥទ្ធិពលលើកម្មវិធីការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) សម្រាប់ជនចំណាកស្រុក និងជនភៀសខ្លួន។

ទីមួយ ឧបសគ្គជាច្រើនកាត់បន្ថយតម្រូវការការអភិវឌ្ឍជំនាញរបស់ជនចំណាកស្រុក និងជនភៀសខ្លួនតាមរយៈ TVET។ ភាពគ្មានការងារធ្វើនៅពេលដំបូង និងការមានមុខរបរមិនទៀងទាត់នៅក្នុងប្រភេទការងារដែលមិនសូវត្រូវជាមួយពួកគេ ជាហេតុដែលបន្ទាបចំណូលរបស់ជនចំណាកស្រុកលើការវិនិយោគក្នុងជំនាញរបស់ខ្លួន។ ជនចំណាកស្រុកគ្មានឯកសារត្រឹមត្រូវ និងអ្នកស្វែងរកសិទ្ធិជ្រកកោន អាចពុំមានសិទ្ធិស្របច្បាប់ដើម្បីធ្វើការងារ ដូចជានៅក្នុងប្រទេសអៀកឡង់ និងលីទុយអានី ដែលបន្ទប់បង្អាក់ដល់ការចូលរួមក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ពហុអ្នកផ្តល់សេវា និងពហុប្រភពចូល អាចធ្វើឱ្យការតម្រង់ទិសប្រព័ន្ធ TVET



មីណា(អាយុ ១១ ឆ្នាំ) ថ្នាក់ទី ៥ នៅកោះបឹងខ្សាង ខេត្តកោះកុង
ប្រទេសកម្ពុជា

ក្រេឌីតរូបថត៖ Shallendra Yashwant/Save the Children

មានការលំបាក។ ទោះយ៉ាងណាក្តី អ្នកផ្តល់សេវា TVET និងសេវាស្វែងរកការងារសាធារណៈអាចតភ្ជាប់ជនចំណាកស្រុកជាមួយនិយោជកដែលពាក់ព័ន្ធ ដើម្បីជួយពួកគេឱ្យទទួលបានបទពិសោធន៍ការងារ។ កម្មវិធី "គ្រូបង្វឹកស្វាគមន៍" (Welcome mentors) ក្នុងប្រទេសអាល្លឺម៉ង់ ជួយគាំទ្រដល់សហគ្រាសខ្នាតតូច និងខ្នាតមធ្យមក្នុងការជ្រើសរើសកម្មករនិយោជិតជំនាញពីអ្នកទើបនឹងមកដល់ថ្មី ដោយឡែកក្នុងឆ្នាំ ២០១៦ មានជនភៀសខ្លួនចំនួន ២៤៤១ នាក់ ដែលត្រូវបានដាក់ចូលក្នុងការបណ្តុះបណ្តាល។

ទីពីរ ការមិនទទួលស្គាល់ការរៀនសូត្រពីមុនមក ជាហេតុកាត់បន្ថយសមត្ថភាពរបស់ជនភៀសខ្លួនដើម្បីទទួលបានការងារសមរម្យ ឬពង្រឹងការអប់រំ និងការបណ្តុះបណ្តាលបន្ថែមទៀត។ ជនចំណាកស្រុក និងជនភៀសខ្លួន ច្រើនតែពុំបានយកលិខិតបញ្ជាក់គុណវុឌ្ឍិ និងវិញ្ញាបនបត្រមកតាមខ្លួន ហើយសញ្ញាបត្រ TVET ច្រើនតែមិនសូវអាចយកតាមខ្លួនបាន ដូចសញ្ញាបត្រការសិក្សាស្រាវជ្រាវ ដោយសារតែមានភាពខុសប្លែកគ្នាធំធេងនៅក្នុងប្រព័ន្ធការអប់រំវិជ្ជាជីវៈមួយទៅប្រព័ន្ធមួយទៀត។ ក្នុងឆ្នាំ ២០១៣ ប្រទេសន័រវែសបានដាក់ឱ្យមាននីតិវិធីការទទួលស្គាល់សម្រាប់ជនពុំមានឯកសារផ្ទៀងផ្ទាត់។ ជាងពាក់កណ្តាលនៃជនភៀសខ្លួនដែលជំនាញរបស់ពួកគាត់ត្រូវបានទទួលស្គាល់ក្នុងឆ្នាំ ២០១៣ អាចរកបានការងារពាក់ព័ន្ធ ឬអាចចូលទៅទទួលបានការអប់រំបន្ថែមទៀត។ ការទទួលស្គាល់ ការផ្តល់សុពលភាព និងការទទួលស្គាល់គុណភាព ក៏អាចត្រូវបានជួយសម្រួលបន្ថែមទៀត តាមរយៈកិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាល។ កិច្ចព្រមព្រៀងការទទួលស្គាល់អន្តរជាតិ គឺមានរវាងសាធារណរដ្ឋអារ៉ាប់ស៊ីរី និងប្រទេសអេហ្ស៊ីប អ៊ីរ៉ាក់ ហ្ស៊កដានី និងលីបង់។

## ការតាមដានវឌ្ឍនភាពនៅក្នុង SDG 4

ក្របខ័ណ្ឌការងារពិនិត្យតាមដាន ដែលគាំទ្រដល់ SDG 4 ស្ដីពីការអប់រំ គឺមានលក្ខណៈប្រកបដោយមហិច្ឆតាយ៉ាងខ្លាំង បើទោះបីជាមានសំណួរដ៏សែនពិបាកមួយចំនួននៅសេសសល់ក្នុងការអភិវឌ្ឍការអប់រំក្ដី។ ក្របខ័ណ្ឌការងារពិនិត្យតាមដានមានតួនាទីផ្ដល់មេរៀនសិក្សារៀនសូត្រ ដើរតួនាទីក្នុងការផ្ដល់សញ្ញាតឿនដែលសក្ដិសមទទួលបានការយកចិត្តទុកដាក់ ហើយប្រទេសនានាគួរវិនិយោគនៅក្នុងការពិនិត្យតាមដាន។ ស្របពេលជាមួយគ្នានេះដែរ កិច្ចខិតខំធំៗជាច្រើន កំពុងត្រូវបានធ្វើឡើងដើម្បីអភិវឌ្ឍសូចនាករ បទដ្ឋាន និងឧបករណ៍នានា ដើម្បីពង្រឹងភាពអាចប្រៀបធៀបគ្នាបាននៃទិន្នន័យពីប្រទេសមួយទៅប្រទេសមួយ ដំណើរការនេះ ទាមទារឱ្យមានកិច្ចសហការយ៉ាងជិតស្និទ្ធក្នុងចំណោមទីភ្នាក់ងារអន្តរជាតិ បណ្ដាប្រទេសនានា អ្នកផ្ដល់មូលនិធិ និងអ្នកឯកទេស។

> “គិតត្រឹមឆ្នាំ ២០១៨ សូចនាករចំនួនបួន នឹងត្រូវបានរាយការណ៍ជាលើកដំបូង ដែលក្នុងនោះ រួមមានសូចនាករសរុបចំនួន ៣៣ ក្នុងចំណោមសូចនាករទាំង ៤៣”

មានសូចនាករសាកលចំនួន ១១ សម្រាប់ SDG 4។ វិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូ (UIS) គឺជាទីភ្នាក់ងារមើលខុសត្រូវតែមួយគត់សម្រាប់សូចនាករចំនួន ៨ និងសហការជាមួយសហជីពទូរគមនាគមន៍អន្តរជាតិ (ITU) ចំពោះសូចនាករ ស្ដីពីបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទង (ICT)។ ទីភ្នាក់ងារមើលខុសត្រូវចំពោះសូចនាករមួយស្ដីពីការអភិវឌ្ឍកុមារតូច គឺអង្គការយូនីសេហ្វ និងអ្នកមើលខុសត្រូវចំពោះសូចនាករស្ដីពីជំនួយ ដើម្បីទទួលបានអាហារូបករណ៍ គឺ OECD។ ដោយមានសូចនាករតាមវិស័យចំនួន ៣២ បន្ថែមទៀត ក្របខ័ណ្ឌការងារពិនិត្យតាមដាន SDG 4 មានសូចនាករសរុបចំនួន ៤៣។

UIS សម្របសម្រួលលើការអភិវឌ្ឍសូចនាករសាកលនិងសូចនាករតាមវិស័យជាមួយរដ្ឋសមាជិកនិងទីភ្នាក់ងារនានាតាមរយៈក្រុមកិច្ចសហប្រតិបត្តិការបច្ចេកទេសទទួលបន្ទុកសូចនាករសម្រាប់ SDG 4 ពោលគឺក្រុមទទួលបន្ទុកការអប់រំឆ្នាំ ២០៣០ (TCG) ដែលបានផ្ដួចផ្ដើមឡើងរួមជាមួយអង្គការយូណេស្កូ។ គិតត្រឹមឆ្នាំ ២០១៨ សូចនាករចំនួនបួន នឹងត្រូវបានរាយការណ៍ជាលើកដំបូង (ការចូលរួមក្នុងកម្មវិធីអក្ខរកម្មមនុស្សពេញវ័យ ការអប់រំផ្លូវភេទសព្វជ្រុងជ្រោយ អំពើហិង្សានៅតាមសាលារៀន និងការវាយប្រហារលើសាលារៀន) ដែលក្នុងនោះរួមមានសូចនាករសរុបចំនួន ៣៣ ក្នុងចំណោមសូចនាករទាំង ៤៣។ ការងារបន្ត ឬការងាររៀបនឹងចាប់ផ្ដើមលើផ្នែកភាសាបង្រៀន ការចែកចាយធនធាន និងការអភិវឌ្ឍវិជ្ជាជីវៈអាជីពគ្រូបង្រៀន។

សម្ព័ន្ធភាពសាកលដើម្បីពិនិត្យតាមដានការសិក្សា (Global Alliance to Monitor Learning) ក៏ត្រូវបានផ្ដួចផ្ដើមឡើងដោយ UIS សម្របសម្រួលការងារលើសូចនាករលទ្ធផលការសិក្សាដែលមានលក្ខណៈស្មុគស្មាញថែមទៀត គឺសមត្ថភាពបឋមអប្បបរមាក្នុងការអាន និងគណិតវិទ្យា អក្ខរកម្មមនុស្សពេញវ័យ និងចំណេះដឹងខាងផ្នែកឌីជីថល។ UIS កំពុងឈានទៅធ្វើការងារដើម្បីសម្រេចបានយុទ្ធសាស្ត្រជាជម្រើសចំនួនបីឆ្ពោះទៅតភ្ជាប់ និងបង្កើតស្ដង់ដារគំរូសម្រាប់សមត្ថភាពផ្នែកការអាន និងគណិតវិទ្យា។ ទីមួយ UIS គាំទ្រការ

ផ្តួចផ្តើមគំនិតដែលនឹងធ្វើឱ្យសិស្សនៅក្នុងប្រទេសអាមេរិកឡាទីន និងអាហ្វ្រិកខាងលិចដែលត្រូវបានជ្រើសរើសអាចចូលរួមនៅក្នុងការវាយតម្លៃថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ដើម្បីជំរុញឱ្យមានការប្រៀបធៀបកាន់តែរឹងមាំថែមទៀតនៅក្នុងការស្ទាបស្ទង់មតិនានា។ ទីពីរ UIS បានធ្វើផែនទីលើខ្លឹមសារការវាយតម្លៃផ្សេងៗ ដោយក្នុងនោះអ្នកជំនាញ នឹងចាត់កម្រិតភាពពិបាកទៅលើចំណុចនានានៅក្នុងការស្ទាបស្ទង់មតិ ដើម្បីដាក់កម្រិតទាំងនោះនៅក្នុងកម្រិតវាស់សម្រាប់ការរាយការណ៍។ ទីបី UIS បន្តកិច្ចខិតខំដើម្បីតភ្ជាប់ការវាស់វែងកម្រិតសមត្ថភាពដោយប្រើប្រាស់បច្ចេកទេសផ្អែកស្ថិតិ។

# ការប្រមូលទិន្នន័យការអប់រំឱ្យបានច្រើនសន្ធឹកសន្ធាប់សម្រាប់គ្រប់យុគសម័យឆ្នាំ ២០០០-២០១៥

*របាយការណ៍ពិនិត្យតាមដានសាកលសម្រាប់ទាំងអស់គ្នា* ឆ្នាំ ២០១៥ (EFA GMR) បានវាយតម្លៃកំណត់ត្រា EFA ប៉ុន្តែ គឺផ្អែកភាគច្រើនទៅលើទិន្នន័យឆ្នាំ ២០១២។ ការវាយតម្លៃបច្ចុប្បន្នភាពមួយ ត្រូវបានធ្វើឡើងផ្អែកលើទិន្នន័យឆ្នាំ ២០១៥។ ការវាយតម្លៃនេះ ពុំបានផ្លាស់ប្តូរសេចក្តីសន្និដ្ឋានឡើយ សេចក្តីសន្និដ្ឋានទាក់ទងជាមួយវឌ្ឍនភាពក្នុងអំឡុងយុគសម័យ EFA នោះឡើយ ប៉ុន្តែនៅទីបំផុតគួរជាទីកត់សម្គាល់ថាវឌ្ឍនភាពហាក់ពុំបានចូលទៅដល់ចំណុចដៅ ប៉ុន្តែនេះគឺជាលំហាត់ការប្រមូលផ្តុំទិន្នន័យឱ្យច្រើនដ៏សំខាន់មួយ ដោយពិនិត្យឆ្ពោះទៅមុខរហូតដល់ឆ្នាំ ២០៣០។

ការរកឃើញចំណុចសំខាន់ៗពីរបានលេចធ្លោឡើង។ ទាក់ទងជាមួយ EFA គោលដៅទីពីរស្តីពីការបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សាបន្ទាប់ពីការចូលរួមមានលក្ខណៈថេរ និងអត្រាការបញ្ចប់ការសិក្សារហូតដល់ឆ្នាំប្រមាណ ១៩៩៧ អត្រារួមនៃការចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សា អត្រាពិតនៃការចុះឈ្មោះចូលរៀនសុទ្ធ និងអត្រារួមពិតនៃសិស្សចូលនៅក្នុងថ្នាក់ចុងក្រោយនៃកម្រិតបឋមសិក្សា បានកើនឡើងរហូតដល់ឆ្នាំ ២០០៨ ប៉ុន្តែបន្ទាប់មកក៏បាននៅថេរ (រូបភាពទី ៦ក)។ ផ្ទុយមកវិញ ទាក់ទងជាមួយគោលដៅទី ៥ ស្តីពីសមភាពយេនឌ័រថ្មីបើចំណុចដៅស្តីពីគម្លាតការចុះឈ្មោះចូលរៀនគិតត្រឹមឆ្នាំ ២០០៥ ពុំទាន់អាចសម្រេចបានក្តី ប៉ុន្តែវឌ្ឍនភាពនៅតែបន្តក្នុងអំឡុងទសវត្សឆ្នាំ១៩៩០ និងទសវត្សឆ្នាំ ២០០០ ដោយឈានដល់ភាពប្រជំត្រសងគ្នាក្នុងឆ្នាំ ២០០៩ នៅក្នុងការអប់រំថ្នាក់បឋមសិក្សា និងមធ្យមសិក្សា ហើយឈានជិតដល់ភាពប្រហាក់ប្រហែលគ្នានៅក្នុងទិដ្ឋភាពផ្នែកអំណានរបស់យុវជនក្នុងឆ្នាំ ២០១៥។ គម្លាតរវាងយេនឌ័រនៅតែបន្តមានក្នុងវិស័យអក្ខរកម្មមនុស្សពេញវ័យ ដោយក្នុងនោះ ៦៣% នៃអ្នកមិនចេះអក្សរ គឺជាស្ត្រី ហើយមានទិដ្ឋភាពបញ្ច្រាសគ្នានៅក្នុងការអប់រំថ្នាក់ឧត្តមសិក្សា ដោយឥឡូវនេះ បុរសមិនសូវចូលរួមក្នុងការអប់រំថ្នាក់ឧត្តមសិក្សាដូចស្ត្រីឡើយ (រូបភាពទី ៦ខ)។

**រូបភាពទី ៦៖**

**នៅចន្លោះឆ្នាំ ២០០០ ដល់ ២០១៥ ពិភពលោកបានសង្កត់ធ្ងន់ជាបន្តបន្ទាប់ឈានឆ្ពោះទៅស្ថាបនាឱ្យមានភាពស្មើគ្នាផ្នែកយេនឌ័រ ប៉ុន្តែពុំមែនឈានឆ្ពោះទៅឱ្យមានការបញ្ចប់ការអប់រំថ្នាក់បឋមសិក្សាជាសាកលទេ**

ក. លទ្ធភាពទទួលបានការអប់រំថ្នាក់បឋមសិក្សា ដែលត្រូវបានជ្រើសរើស សូចនាករការចូលរួម និងការបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សានៅចន្លោះឆ្នាំ ១៩៩០-២០១៥

ខ. សន្ទស្សន៍ភាពស្មើគ្នាផ្នែកយេនឌ័រដែលត្រូវបានកែសម្រួលសម្រាប់សមាមាត្រការចុះឈ្មោះចូលរៀនដុល និងអត្រាការចេះអានសរសេរ ឆ្នាំ ១៩៩០-២០១៥




GEM StatLink: http://bit.ly/fig7_1

ប្រភព៖ ដេតាបេស UIS ។

# ការពិនិត្យតាមដានលើស្ថានភាពការអប់រំរបស់ជនចំណាកស្រុក និងប្រជាជនដែលបានផ្លាស់ទីលំនៅដោយបង្ខំ ស្តែងឱ្យឃើញនូវបញ្ហាប្រឈមជាច្រើន

ក្របខ័ណ្ឌការងារពិនិត្យតាមដាន SDG ផ្តោតការយកចិត្តទុកដាក់យ៉ាងច្បាស់លាស់លើការញែកសូចនាករទៅតាមលក្ខណសម្បត្តិផ្សេងៗពាក់ព័ន្ធជាមួយស្ថានភាពជួបការលំបាក។ ទោះយ៉ាងណាក្តី ទិន្នន័យជាប្រព័ន្ធស្តីពីស្ថានភាពការអប់រំរបស់ជនចំណាកស្រុក និងជនភៀសខ្លួន គឺនៅមានលក្ខណៈរប៉ាត់រប៉ាយនៅឡើយ។ នៅក្នុងកាតាឡុកមីក្រូទិន្នន័យរបស់ធនាគារពិភពលោក ការស្ទាបស្ទង់មតិគ្រួសារជាង ២០០០ ក្នុងចំណោមការស្ទាបស្ទង់មតិប្រមាណ ២៥០០ គឺមានព័ត៌មានស្តីពីការអប់រំ ប៉ុន្តែមានតែប្រមាណមួយភាគប្រាំពីរនៃទិន្នន័យទាំងនោះប៉ុណ្ណោះ ដែលរួមមានទិន្នន័យស្តីអំពីចំណាកស្រុក ហើយបំបែកកាន់តែតិចថែមទៀត ដែលមានទិន្នន័យអំពីការផ្លាស់ទីលំនៅដោយបង្ខិតបង្ខំ។

> “គ្រួសារជនចំណាកស្រុក តែងចល័តហើយច្រើនតែមិនសូវមានវត្តមាននៅពេលអ្នកសម្ភាសន៍សម្រាប់ធ្វើការស្ទាបស្ទង់មតិគ្រួសារចុះទៅកាន់ទីនោះ ឬត្រូវបានសម្ភាសន៍អាស្រ័យដោយឧបសគ្គផ្នែកភាសា ឬកង្វល់ផ្នែកផ្លូវច្បាប់”

គ្រួសារជនចំណាកស្រុក តែងចល័តហើយច្រើនតែមិនសូវមានវត្តមាននៅពេលអ្នកសម្ភាសន៍សម្រាប់ធ្វើការស្ទាបស្ទង់មតិគ្រួសារចុះទៅកាន់ទីនោះឬត្រូវបានសម្ភាសន៍អាស្រ័យដោយឧបសគ្គផ្នែកភាសា ឬកង្វល់ផ្នែកផ្លូវច្បាប់ ។ ម្យ៉ាងទៀតដោយហេតុថាលំហូរចំណាកស្រុក អាចប្រែប្រួលយ៉ាងឆាប់រហ័សក្របខ័ណ្ឌនៃការជ្រើសរើសសំណាក ប្រហែលជាពុំអាចចាប់ទាន់បច្ចុប្បន្នភាព។ ទិដ្ឋភាពនេះ ជះឥទ្ធិពលជាពិសេសលើប្រជាជនដែលបានផ្លាស់ទីលំនៅដោយបង្ខំ៖ ទិន្នន័យច្រើនត្រូវបានប្រមូលក្នុងលក្ខណៈជាប្រព័ន្ធនៅក្នុងជំរុំជនភៀសខ្លួន ប៉ុន្តែតិចជាង ៤០% នៃជនភៀសខ្លួន ហើយ IDPs កាន់តែតិចជាងនេះថែមទៀត ដែលរស់នៅក្នុងជំរុំជនភៀសខ្លួន។

ការធានាឱ្យមានការរួមបញ្ចូលជនចំណាកស្រុក និងជនភៀសខ្លួននៅក្នុងបទដ្ឋាន ការស្ទាបស្ទង់មតិដែលផ្តោតគោលបំណងទូទៅ ប្រហែលជាពុំអាចដោះស្រាយបញ្ហាការជ្រើសរើសសំណាក និងការប្រមូលទិន្នន័យបានដោយជានិច្ចជាកាលឡើយ។ ការស្ទាបស្ទង់មតិស្តង់ដារ ពុំចាប់យកនូវភាពបត់បែននៃបាតុភូតចំណាកស្រុក ហើយអាចមានភាពញឹកញាប់មិនគ្រប់គ្រាន់ ដើម្បីបង្កើតឱ្យមានព័ត៌មានទាន់ពេលវេលា។ គោលវិធីដែលមានលក្ខណៈបត់បែនជាងនេះ រួមមានដូចជា ការស្ទាបស្ទង់មតិផ្តោតការយកចិត្តទុកដាក់ការស្រាវជ្រាវ ដែលតភ្ជាប់សហគមន៍បញ្ជូនជាមួយសហគមន៍ទទួល ក៏ដូចជាការប្រមូលទិន្នន័យរហ័ស ដោយប្រើប្រាស់សំណាកមិនមែនចោះៗ អាចមានប្រសិទ្ធិភាពជាងនេះថែមទៀត។ ជាចុងក្រោយ ការស្ទាបស្ទង់មតិប្រហែលពុំអាចចាប់យកលើទំនាក់ទំនងរវាងការអប់រំជាមួយចំណាកស្រុក ឬគុណវុឌ្ឍិក្នុងប្រទេសកំណើតឡើយ។

ក្នុងខែមីនា ឆ្នាំ ២០១៦ គណៈកម្មការស្ថិតិជាតិអង្គការសហប្រជាជាតិ បានចាប់ផ្តើមធ្វើជាម្ចាស់ផ្ទះនៃក្រុមការងារឯកទេសទទួលបន្ទុកស្ថិតិជនភៀសខ្លួន និង IDP។ ក្រុមជំនាញការនេះ រួមមានរដ្ឋសមាជិកចំនួន ៤០ ហើយមានអង្គការអន្តរជាតិ ថ្នាក់តំបន់ យ៉ាងហោចណាស់ ១៥ ហើយក្រុមនេះ បានផ្តល់អនុសាសន៍ស្តីពីការកែលម្អការប្រមូលទិន្នន័យ ។ អង្គការ UNESCO និង UNHCR កំពុងអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំជនភៀសខ្លួន ដែលជាឧបករណ៍នៅលើប្រព័ន្ធអ៊ីនធឺណិត ប្រភេទ open-source ដើម្បីជួយដល់ប្រទេសនានាក្នុងការប្រមូលចងក្រង វិភាគ និងរាយការណ៍អំពីទិន្នន័យការអប់រំរបស់ជនភៀសខ្លួន។




ចំណុចដៅ ៤.១

# ការអប់រំថ្នាក់ឧត្តមសិក្សា និងមធ្យមសិក្សា

កុមារដែលកើតនៅចន្លោះឆ្នាំ ២០១០ ដល់ ២០១៤ អាចត្រូវបានចាត់ទុកជាមនុស្សជំនាន់ SDG 4 ។ កុមារអាយុច្រើនបំផុត នឹងមានអាយុ ៥ ឆ្នាំនៅក្នុងឆ្នាំ ២០១៥ ហើយក្នុងបណ្ដាប្រទេសជាច្រើន កុមារទាំងនេះត្រូវបានរំពឹងថា  នឹងទទួលការអប់រំថ្នាក់មត្តេយ្យសិក្សាក្នុងឆ្នាំ ២០១៥/២០១៦ ពោលគឺជាពេលចាប់ផ្ដើមនៃដំណាក់កាល SDG ( ២០១៥-២០៣០ ) ។ កុមារតូចជាងគេបំផុត នឹងមានអាយុ ១៦ ឆ្នាំត្រឹមឆ្នាំ ២០៣០ ដែលមានសក្ដានុពលជាអាយុបញ្ចប់ការអប់រំថ្នាក់មធ្យមសិក្សាបឋមភូមិយ៉ាងទាន់ពេលវេលា។ សម្រាប់មនុស្សជំនាន់ SDG ដើម្បីសម្រេចបានការបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាជាសាកលត្រឹមឆ្នាំ ២០៣០ ក្រុមកុមារនាពេលបច្ចុប្បន្ន ចាំបាច់ត្រូវចូលរៀនថ្នាក់បឋមសិក្សាឱ្យបានទាន់ពេលវេលា។ អត្រាចូលរៀនសុទ្ធដែលត្រូវបានកែសម្រួលកម្រិតសាកលទៅក្នុងថ្នាក់បឋមសិក្សាដំបូង គឺ ៨៦% ក្នុងឆ្នាំ ២០១៧។

> “ ដើម្បីសម្រេចបាននូវការបញ្ចប់មធ្យមសិក្សាជាសកលនៅឆ្នាំ ២០៣០ ក្រុមអ្នកស្រាវជ្រាវបច្ចុប្បន្នត្រូវតែចូលរៀននៅកម្រិតបឋមសិក្សា ”

កុមារប្រមាណ ៦៤ លាននាក់ក្នុងអាយុចូលរៀនថ្នាក់បឋមសិក្សា ឬ ៩% គឺស្ថិតនៅក្រៅសាលារៀនក្នុងឆ្នាំ ២០១៧ ក៏ដូចជាមនុស្សវ័យជំទង់ចំនួន ៦១ លាននាក់នៅក្នុងអាយុចូលរៀនថ្នាក់មធ្យមសិក្សាបឋមភូមិ ( ១៦% ) និងយុវជន ១៣៨ លាននាក់ ក្នុងអាយុចូលរៀនថ្នាក់មធ្យមសិក្សាទុតិយភូមិ ( ៣៦% ) ។ អត្រាចូលរៀនថ្នាក់បឋមសិក្សា គឺស្ទើរតែមិនប្រែប្រួលទាល់តែសោះចាប់ពីឆ្នាំ២០០៨ មក។ អនុតំបន់សាហារ៉ានៃទ្វីបអាហ្វ្រិក មានការកើនឡើងសមាមាត្រច្រើនជាងគេ លើកលែងតែសម្រាប់អាយុចូលរៀនក្នុងថ្នាក់បឋមសិក្សាជម្លោះបាននាំឱ្យកុមារចាកចេញពីសាលារៀនក្នុងតំបន់ដទៃទៀត ជាពិសេសក្នុងតំបន់អាស៊ីភាគខាងលិច (រូបភាពទី ៧ ) ។

ការស្ទាបស្ទង់មតិស្ដីពីវឌ្ឍនភាពនៃការសិក្សាអំណានអន្តរជាតិបានវាយតម្លៃសិស្សថ្នាក់ទី ៤ រៀងរាល់ប្រាំឆ្នាំម្ដង ដោយផ្ដល់ទិន្នន័យស្ទាបស្ទង់មតិឆ្លងប្រទេសថ្មីៗសំខាន់ៗសម្រាប់សូចនាករសាកលស្ដីពីលទ្ធផលនៃការសិក្សារៀនសូត្រ។ នៅក្នុងសាធារណរដ្ឋឥស្លាមអ៊ីរ៉ង់ ភាគរយនៃការឆ្លើយតបបានកម្រិតស្ដង់ដារផ្នែកខាងក្រោមមានការកើនឡើងចាប់ពី ៥៦% ក្នុងឆ្នាំ២០០១ ទៅដល់ ៦៥% ក្នុងឆ្នាំ២០១៦ ពោលគឺតិចជាង ១% ក្នុងមួយឆ្នាំ។ ប្រទេសមួយចំនួន រួមមានដូចជា ប្រទេសម៉ារ៉ុក និងអូម៉ង់ មានភាពប្រសើរឡើងក្នុងអត្រាដែលនាំឱ្យប្រទេសទាំងនេះ ស្ថិតក្នុងរង្វង់ការចូលទៅសម្រេចបានតាមចំណុចដៅត្រឹមឆ្នាំ ២០៣០ ចំណែកប្រទេសមួយចំនួនទៀត ឧទាហរណ៍ដូចជា ប្រទេស Azerbaijan អារ៉ាប់សាអូឌីត និងអាហ្វ្រិកខាងត្បូង សមាមាត្រសិស្សសម្រេចបានសមត្ថភាពអប្បបរមាពុំបានកើនឡើងឡើយ  ដែលមានន័យថាប្រទេសទាំងនេះ នឹងមានការលំបាកក្នុងការសម្រេចបានតាមចំណុចដៅ។

**រូបភាពទី ៧៖**

**អនុតំបន់សាហារ៉ានៃទ្វីបអាហ្វ្រិកមានសមាមាត្រកាន់តែច្រើនឡើងនៃប្រជាជននៅក្រៅសាលារៀនរបស់សាកលលោក**

របាយប្រជាជននៅក្រៅសាលារៀនចែកតាមតំបន់ ឆ្នាំ ២០០០-២០១៥




GEM StatLink: http://bit.ly/fig8_2

ប្រភព៖ ដេតាបេស UIS។

## ការប៉ាន់ប្រមាណអត្រាបញ្ចប់ការសិក្សាថ្មីសម្រាប់របៀបវារៈការអប់រំឆ្នាំ ២០៣០

យោងតាមទិន្នន័យការស្ទាបស្ទង់មតិគ្រួសារឆ្នាំ ២០១៣-២០១៧ អត្រាបញ្ចប់ការសិក្សា គឺមានចំនួន ៨៥% សម្រាប់ថ្នាក់បឋមសិក្សា ៧៣% សម្រាប់ថ្នាក់មធ្យមសិក្សាបឋមភូមិ និង ៤៩% សម្រាប់ការអប់រំថ្នាក់មធ្យមសិក្សាទុតិយភូមិ។ ទោះយ៉ាងណាក្ដី មានការយឺតយ៉ាវពេលវេលាមួយចំនួនសម្រាប់ការស្ទាបស្ទង់មតិគ្រួសារ និងទិន្នន័យជំរឿន ហើយប្រភពព័ត៌មានផ្សេងៗគ្នា អាចផ្ដល់ព័ត៌មានភាពមិនចុះសម្រុងគ្នា។ ដោយអនុវត្តតាមឧទាហរណ៍នៃសហគមន៍ពិនិត្យតាមដានសុខភាព ក្រុមការងារធ្វើរបាយការណ៍ GEM បានបង្កើតគំរូមួយ ដើម្បីប៉ាន់ប្រមាណអត្រាការបញ្ចប់ការសិក្សា។ តាមរយៈការព្យាករណ៍អត្រាបញ្ចប់ការសិក្សារបស់ក្រុមដែលមានអាយុច្រើនជាងគេបំផុតត្រឡប់ក្រោយ អាចផ្ដល់នូវទស្សនៈមើលឃើញរយៈពេលវែងអំពីគន្លងវិថីពង្រីកបន្ថែមនៃអត្រាបញ្ចប់ការសិក្សាក្នុងប្រទេសមួយ។ កម្រិតបច្ចុប្បន្ននៃសូចនាករ អាចត្រូវបានប៉ាន់ប្រមាណដោយការបូកសរុបរយៈពេលខ្លីពីទិន្នន័យនាពេលថ្មីៗបំផុត។ គោលវិធីនេះ ជួយផ្សះផ្សាទម្រង់ និងមាននិន្នាការទូទៅសម្រាប់ប្រភពទិន្នន័យទាំងអស់ជំនួសឱ្យគ្រាន់តែការយកអត្រាប៉ាន់ប្រមាណចុងក្រោយបំផុតដែលមានតាមតម្លៃដែលស្ដែងឱ្យឃើញ។




# ការអប់រំកុមារតូច

**ចំណុចដៅ ៤.២**

ការអប់រំ និងការថែទាំកុមារតូច គឺមានភាពចាំបាច់ណាស់សម្រាប់ការអភិវឌ្ឍផ្នែកចំណេះដឹង និងផ្នែកចិត្តសង្គម ហើយបំពេញមុខងារដ៏មានសារៈសំខាន់ ជាពិសេសក្នុងការការពារកុមារនៅក្នុងបរិយាកាសដែលមានវិបត្តិប៉ះទង្គិចធ្ងន់ធ្ងរ។

សូចនាករសាកលស្តីពីការចូលរួមក្នុងការរៀនសូត្រដែលមានការរៀបចំរយៈពេលមួយឆ្នាំ មុនពេលអាយុចូលរៀនថ្នាក់បឋមសិក្សាផ្លូវការ គឺមានចាប់ពី ៤២% នៅក្នុងបណ្តាប្រទេសមានចំណូលទាបរហូតដល់ ៩៣% ក្នុងបណ្តាប្រទេសមានចំណូលខ្ពស់ ដោយអត្រាមធ្យមភាគពិភពលោក គឺ ៦៩% ជាការបន្តកើនឡើងយឺតៗ ប៉ុន្តែមានស្ថេរភាពនៅក្នុងនិន្នាការដែលមានការកើនឡើង។ ផ្ទុយទៅវិញ អត្រារួមពិតនៃការចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យសិក្សា ដែលត្រូវបានកំណត់សម្រាប់កម្រិតការអប់រំ ដែលមានរយៈពេលតិចជាងមួយឆ្នាំក្នុងបណ្តាប្រទេសមួយចំនួន ហើយអាចមានច្រើនរហូតដល់ ៤ ឆ្នាំក្នុងប្រទេសមួយចំនួនទៀតដោយបានឈានដល់ ៥០% ក្នុងឆ្នាំ២០១៧ (រូបភាពទី ៨)។

សូចនាករសាកលដទៃទៀតស្តីពីការអភិវឌ្ឍកុមារតូច គឺពឹងផ្អែកលើសន្ទស្សន៍ការអភិវឌ្ឍកុមារតូច (ECDI) របស់យូនីសេហ្វ ដែលត្រូវបានគណនាដោយផ្អែកជាចម្បងលើទិន្នន័យការស្ទាបស្ទង់មតិចង្កោមពហុសូចនាករ (MICS) របស់យូនីសេហ្វ ថ្វីបើយូនីសេហ្វកំពុងពិនិត្យឡើងវិញលើវិធីសាស្ត្រ ECDI ដើម្បីឆ្លើយតបចំពោះចំណុចខ្សោយ ដែលមានពេលគឺ ជាដំណើរការដែលត្រូវបានរំពឹងថានឹងត្រូវបញ្ចប់ត្រឹមចុងឆ្នាំ២០១៨។លទ្ធផលដែលបានមកពីបណ្តាប្រទេសដែលបានចូលរួមនៅក្នុងជុំទាំងពីរនៃ MICS ក្នុងរយៈពេលប្រាំឆ្នាំ ស្នើឱ្យឃើញថា ភាគរយនៃកុមារអាយុ

**រូបភាពទី ៨៖**

**កុមារ ៧ នាក់ ក្នុងចំណោម ១០ នាក់ ចូលរៀនថ្នាក់មត្តេយ្យសិក្សានៅមុនពេលចូលទៅក្នុងការអប់រំថ្នាក់បឋមសិក្សា**

អត្រាការចូលរួមក្នុងការសិក្សាដែលមានការរៀបចំ (មួយឆ្នាំមុនអាយុចូលរៀនថ្នាក់បឋមសិក្សាជាផ្លូវការ) និងសមាមាត្រការចុះឈ្មោះចូលរៀនដុលនៅថ្នាក់មុនបឋមសិក្សា ២000-២០១៦




GEM StatLink: http://bit.ly/fig9_2
ប្រភព៖ ដេតាបេស UIS។

ចាប់ពី ៣ ដល់ ៤ ឆ្នាំដែលស្ថិតលើគន្លងនៃវិស័យអក្ខរកម្ម និងលេខបានកើនឡើងក្នុងអត្រាតិចជាង ១% ក្នុងមួយឆ្នាំជាមធ្យម។

ទោះយ៉ាងណាក្តី "ការត្រៀមខ្លួនរួចជាស្រេច" សម្រាប់ការចូលសាលារៀន និង "ការស្ថិតក្នុងគន្លងការអភិវឌ្ឍត្រឹមត្រូវ" គឺជាទស្សនាទានផ្តាច់មុខ ដែលត្រូវបានមើលឃើញផ្សេងៗគ្នានៅជុំវិញពិភពលោក។ ប្រទេសនានា អាចចាំបាច់ត្រូវការធន្ទានុសិទ្ធិបន្ថែមទៀត ដើម្បីប្រើប្រាស់វិធានការនានាដែលបម្រើឱ្យសេចក្តីត្រូវការរបស់ខ្លួន ហើយដែលមានភាពស៊ីគ្នាជាមួយរចនាសម្ព័ន្ធស្ថាប័ន និងលក្ខណសម្បត្តិផ្នែកវប្បធម៌។

ទោះយ៉ាងណាក្តី ប្រព័ន្ធថ្នាក់ជាតិ ដើម្បីពិនិត្យតាមដានការត្រៀមខ្លួនរួចជាស្រេច សម្រាប់ការទៅសាលារៀន គឺកម្រមានណាស់។ ជាទូទៅ ប្រទេសនានាច្រើនមានក្របខ័ណ្ឌការងារថ្នាក់ជាតិ និងនីតិវិធី ដើម្បីពិនិត្យតាមដានលើបុគ្គលិក ការបណ្តុះបណ្តាល គ្រឹះស្ថានសិក្សា និងបទដ្ឋានកម្មវិធីសិក្សារបស់អ្នកផ្តល់សេវានានា (ឧ. គោលនយោបាយជាតិស្តីពីការថែទាំ និងការអប់រំកុមារតូចឆ្នាំ ២០១៣ របស់ប្រទេសឥណ្ឌា) ឬការវាយតម្លៃផលប៉ះពាល់កម្មវិធី (ឧ. សមាសធាតុប្រព័ន្ធរាយការណ៍ថ្នាក់ជាតិរបស់កម្មវិធីមត្តេយ្យសិក្សាចាប់ផ្តើមដំបូងរបស់សហរដ្ឋអាមេរិក)។ នៅក្នុងម៉ូឌុលការអភិវឌ្ឍកុមារតូចរបស់គោលវិធីប្រព័ន្ធធនាគារពិភពលោកសម្រាប់លទ្ធផលការអប់រំកាន់តែប្រសើរ មានប្រទេសតែប្រមាណ ៨ ក្នុងចំណោមប្រទេសមានចំណូលទាប និងចំណូលមធ្យមចំនួន ៣៤ ប៉ុណ្ណោះ ដែលបានប្រមូលទិន្នន័យស្តីពីកុមារនៅក្នុងវិស័យទាំងបួនដែលត្រូវបានគ្របដណ្តប់ (ការអភិវឌ្ឍផ្នែកចំណេះដឹង ភាសា កាយសម្បទា និងចិត្តសង្គម)។

ក្របខ័ណ្ឌការងារកម្មវិធីសិក្សាជាតិឆ្នាំ ២០១៤ របស់អាហ្វ្រិកខាងត្បូង បានប្រមើលមើលឃើញថា ការវាយតម្លៃក្រៅផ្លូវការ ការវាយតម្លៃបែបសង្កេត និងការវាយតម្លៃជាបន្ត ផ្អែកលើវិស័យការសិក្សារៀនសូត្រ និងការអភិវឌ្ឍកុមារតូចទាំង ៦ ពុំដាក់ឱ្យមានពិន្ទុ ឬភាគរយនោះឡើយ ប៉ុន្តែធ្វើការកត់ត្រាភាពត្រៀមខ្លួនរួចជាស្រេចសម្រាប់ពិន្ទុដែលអាចទទួលយកនៅថ្នាក់បឋមសិក្សា។ ចាប់ពីឆ្នាំ ២០១៤ មកប្រទេសម៉ាសេដ្វាន ដែលជាអតីតសាធារណរដ្ឋយូហ្គោស្លាវី បានរក្សាផតហ្វូលីយ៉ូការអភិវឌ្ឍកុមារសម្រាប់កុមារទាំងអស់ ដែលបានចុះឈ្មោះចូលរៀនក្នុងមជ្ឈមណ្ឌល ECEC។

ចំណុចដៅ ៤.៣

# ការអប់រំបច្ចេកទេស ការអប់រំវិជ្ជាជីវៈ ការអប់រំឧត្ដមសិក្សា និងការអប់រំមនុស្សពេញវ័យ

សូចនាករសាកលស្ដីពីការចូលរួមក្នុងការអប់រំរបស់មនុស្សពេញវ័យត្រូវបានកែសម្រួល ដើម្បីចាប់យកឱកាសការអប់រំក្រៅប្រព័ន្ធ និងក្រៅផ្លូវការទាំងអស់ មិនថា ការអប់រំទាំងនោះពាក់ព័ន្ធជាមួយការងារ ឬមិនពាក់ព័ន្ធក្ដី។ ភាពចម្រុះ និងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៃអ្នកផ្ដល់សេវា ធ្វើឱ្យមានលក្ខណៈអំណោយផលដល់ការស្ទាបស្ទង់មតិកម្លាំងពលកម្មនៅក្នុងទិន្នន័យរដ្ឋបាលជាប្រភពទិន្នន័យមួយ ទោះយ៉ាងណាក្ដី សំណួរនៅក្នុងការស្ទាបស្ទង់មតិទាំងអស់នេះ មានភាពខុសប្លែកគ្នាគួរជាទីកត់សម្គាល់ពីប្រទេសមួយទៅប្រទេសមួយ ហើយមានសំណួរមួយចំនួនតូចប៉ុណ្ណោះដែលអាចប្រៀបធៀបគ្នាបាន ជាមួយនិយមន័យសូចនាករដែលត្រូវបានធ្វើបច្ចុប្បន្នភាព។ ការធ្វើឱ្យសំណួរទាំងអស់នោះមានស្ដង់ដារ ដើម្បីអាចពង្រីកចំនួនប្រទេសដែលមានទិន្នន័យប្រៀបធៀបគ្នាបាន គឺពុំមែនជារឿងងាយស្រួលឡើយ។

**រូបភាពទី ៩៖**

**ការចូលរួមនៅក្នុងការអប់រំមនុស្សពេញវ័យនៅទ្វីបអឺរ៉ុបនៅមានកម្រិតថេរ ប៉ុន្តែមាននិន្នាការខុសៗគ្នាទៅតាមប្រទេស**

អត្រាការចូលរួមរបស់មនុស្សពេញវ័យក្នុងការអប់រំ និងការបណ្ដុះបណ្ដាលក្នុងអំឡុង ៤ សប្ដាហ៍កន្លងមក សហគមន៍ និងប្រទេសដែលត្រូវបានជ្រើសរើស ២០០៨-២០១៧




GEM StatLink: http://bit.ly/fig10_1

ប្រភព៖ Eurostat (2018).

ការស្ទាបស្ទង់មតិកម្លាំងពលកម្មសហគមន៍អឺរ៉ុបផ្ដោតការយកចិត្តទុកដាក់លើការអប់រំក្នុងប្រព័ន្ធ និងការបណ្ដុះបណ្ដាលក្នុងប្រព័ន្ធ នៅក្នុងរយៈពេលបួនសប្ដាហ៍កន្លងមក (ធៀបជាមួយសូចនាកររយៈពេល ១២ ខែ)។ អត្រាការចូលរួមនៅមានកម្រិតថេរ ដោយជាមធ្យម គឺ ១១% ថ្វីបើនិន្នាការមានភាពខុសប្លែកគ្នាពីប្រទេសមួយទៅប្រទេសមួយក្ដី (រូបភាពទី ៩)។ ការស្ទាបស្ទង់មតិទីផ្សារការងារបែបរួមបញ្ចូលក្នុងប្រទេសអេហ្ស៊ីប ហ្ស៊កដានី និងទុយនីស៊ីគឺមានកម្រិតកំណត់នៅត្រឹមអ្នកដែលមានការងារធ្វើការចូលរួមពេញមួយជីវិត និង TVET ពាក់ព័ន្ធជាមួយការងារ។

ការស្ទាបស្ទង់មតិទាំងនេះ ស្នើឱ្យឃើញថា អត្រាចូលរួមបណ្តុះបណ្តាលប្រចាំឆ្នាំ មានរហូតដល់ ៤% ក្នុងចំណោមនិយោជិតដែលមានបច្ចេកទេស។

សមាមាត្រការចុះឈ្មោះចូលរៀនដុលនៅថ្នាក់ឧត្តមសិក្សាបានឈានដល់ ៣៨% ក្នុងឆ្នាំ ២០១៧ប៉ុន្តែសមាមាត្រនៃការចំណាយជាឯកជននៅក្នុងការចំណាយសរុបសម្រាប់ការអប់រំថ្នាក់ឧត្តមសិក្សាមានការកើនឡើង។ ជំនួយហិរញ្ញវត្ថុក្នុងទម្រង់ជាកម្ចីសម្រាប់សិស្សហិរញ្ញប្បទានការឧត្តម្ភទុន និងអាហារូបករណ៍មានន័យថា ការអប់រំថ្នាក់ឧត្តមសិក្សាជាទូទៅគឺមានតម្លៃសមរម្យជាងគេបំផុតក្នុងទ្វីបអឺរ៉ុបហើយមានតម្លៃខ្ពស់ជាងគេបំផុតនៅអនុតំបន់សាហារ៉ាទ្វីបអាហ្វ្រិកដោយក្នុងនោះការចំណាយ គឺមានអត្រាលើសពី ៦០% នៃចំណូលមធ្យមរបស់ជាតិនៅក្នុងបណ្តាប្រទេសភាគច្រើន ហើយឈានទៅដល់ជិត ៣០០% នៅក្នុងប្រទេសហ្គីនេ និងអ៊ូហ្គង់ដា។

> “ការស្ទាបស្ទង់មតិកម្លាំងពលកម្ម គឺជាប្រភពទិន្នន័យគួរជាទីចង់បានជាងទិន្នន័យរដ្ឋបាលដើម្បីវាស់វែងលើការអប់រំរបស់មនុស្សពេញវ័យ បើគិតទៅលើភាពចម្រុះគ្នា និងចំនួនអ្នកផ្តល់សេវា។”

ប្រព័ន្ធអប់រំភាគច្រើនមានគោលដៅផ្តោតលើការគាំទ្រផ្នែកហិរញ្ញវត្ថុដែលកំណត់គោលដៅជាក់លាក់ប៉ុន្តែប្រសិទ្ធភាពនៃការកំណត់គោលដៅគឺមានភាពខុសប្លែកគ្នាយ៉ាងខ្លាំង។ ទិន្នន័យរបស់ធនាគារពិភពលោកបង្ហាញឱ្យឃើញថា ក្នុងបណ្តាប្រទេសមានចំណូលទាប និងចំណូលមធ្យមជាច្រើន គ្រួសារនៅក្នុងក្រុមក្រីក្របំផុត ច្រើនតែមិនសូវមានលទ្ធភាពទទួលបានអាហារូបករណ៍របស់រដ្ឋាភិបាល បើប្រៀបជាមួយក្រុមប្រជាជនដែលមានជីវភាពធូរធារខ្លាំងជាងគេបំផុត។ កញ្ចប់គោលនយោបាយសព្វជ្រុងជ្រោយ ដោយរួមមានគោលវិធីផ្សេងៗជាច្រើន ដូចនៅក្នុងប្រទេសកម្ពុជា និងប្រទេសវៀតណាម អាចទទួលបានជោគជ័យច្រើនជាងការប្រើប្រាស់អាហារូបករណ៍តែមួយមុខ។




# ជំនាញដើម្បីធ្វើការងារ

**ចំណុចដៅ ៤.៤**

សូចនាករសាកល និងសូចនាករតាមវិស័យស្តីពី ICT និងចំណេះដឹងផ្នែកឌីជីថលមានបំណងចាប់យកចំណេះដឹងដែលលើសពីជំនាញ ផ្នែកអានសរសេរ និងនព្វន្តដែលបានក្លាយជាមានសារៈសំខាន់ស្ទើរតែជាសាកលសម្រាប់ពិភពការងារ។ សូចនាករទាំងអស់នេះ តម្រូវឱ្យរដ្ឋាភិបាលត្រូវពិចារណាលើការទទួលបានជំនាញនៅក្រៅសាលារៀន។

សូចនាករសាកលស្តីពីយុវជន និងមនុស្សពេញវ័យដែលមានជំនាញ ICT ផ្អែកលើមូលដ្ឋាននៃការរាយការណ៍ដោយខ្លួនឯងនៅក្នុងការស្ទាបស្ទង់មតិគ្រួសារទៅលើសកម្មភាពដែលត្រូវបានជ្រើសរើសនៅក្នុងរយៈពេលបីខែកន្លងមក។ ទិន្នន័យ ITU ចុងក្រោយបំផុតបង្ហាញឱ្យឃើញថា ការចម្លង និងការភ្ជាប់ឯកសារជាមួយអ៊ីម៉ែល គឺជាជំនាញតែពីរគត់ ដែលអ្នកឆ្លើយតបលើសពីម្នាក់ក្នុងចំណោមអ្នកឆ្លើយតបបីនាក់ បានធ្វើនៅក្នុងបណ្តាប្រទេសមានចំណូលមធ្យមជាទូទៅអត្រានោះគឺ ៥៨% នៅក្នុងប្រទេសមានចំណូលមធ្យម និង ៧០% នៅប្រទេសមានចំណូលខ្ពស់ (**រូបភាពទី ១០**)។ ការធ្វើកម្មវិធីនៅតែជាសកម្មភាពធ្វើឡើងតិចតួចបំផុត បើទោះបីជានៅក្នុងប្រទេសមានចំណូលខ្ពស់ក្តី។

**រូបភាពទី ១០៖**

**ជំនាញ ICT នៅតែមានរបាយមិនស្មើភាពគ្នា**

*ភាគរយនៃមនុស្សពេញវ័យដែលអនុវត្តសកម្មភាពពាក់ព័ន្ធជាមួយកុំព្យូទ័រក្នុងរយៈពេលបីខែកន្លងមកចែកទៅតាមប្រទេសតាមក្រុមចំណូល ២០១៤-២០១៧*




GEM StatLink: http://bit.ly/fig11_1
សម្គាល់៖ មេដ្យានសម្រាប់បណ្តាប្រទេសមានចំណូលមធ្យម គឺផ្អែកលើប្រទេសក្នុងចំនួនតិច (ចំណូលមធ្យមកម្រិតទាបចំនួន ៥ ចំណូលមធ្យមកម្រិតខ្ពស់ចំនួន ១៥)។
ប្រភព៖ ដេតាបេស ITU ។

សូចនាករ តាមវិស័យស្តីពីជំនាញ ផ្នែកចំណេះដឹង ឌីជីថល គឺ រាប់បញ្ចូលទិដ្ឋភាពច្រើនលើសពីសមត្ថភាព ក្នុងការប្រើប្រាស់ឧបករណ៍ ICT ។ ក្របខ័ណ្ឌការងារសាកលសម្រាប់ ចំណេះដឹងផ្នែកឌីជីថល គឺបានពង្រីកក្របខ័ណ្ឌការងារ DigComp របស់គណៈកម្មាធិការអឺរ៉ុបដើម្បីដាក់បញ្ចូលនូវកម្រងទូលំទូលាយនិងមានលក្ខណៈកាន់តែស្មុគស្មាញ ឡើងនៃការប្រើប្រាស់ ឧទាហរណ៍ ដែលឆ្លុះបញ្ចាំងអំពីបរិយាកាសផ្នែកវប្បធម៌ សេដ្ឋកិច្ចនិងបច្ចេកវិទ្យារបស់បណ្តាប្រទេសមានចំណូលទាប និង មធ្យម ឧ. ជំនាញដែលកសិករត្រូវការដើម្បីធ្វើសេចក្តីសម្រេចចិត្តលើផ្នែកកសិកម្មនិងពាណិជ្ជកម្មដោយប្រើប្រាស់សេវាទូរសព្ទដៃ ទិញ និង លក់ផលិតផលតាមរយៈកម្មវិធីរបស់ទូរសព្ទឆ្លាតវៃ ឬស្ថាបនាប្រព័ន្ធធារាសាស្ត្រដែលជំរុញដោយទិន្នន័យដោយប្រើប្រាស់ឧបករណ៍វាស់សំណើមស្វ័យប្រវត្តិតភ្ជាប់ជាមួយកុំព្យូទ័រយួរដៃ។

> “មនុស្សពេញវ័យបីនាក់ក្នុងចំណោមមនុស្សពេញវ័យដប់នាក់ ពុំចេះរបៀបភ្ជាប់ឯកសារជាមួយអ៊ីម៉ែលនោះទេនៅក្នុងប្រទេសមានចំណូលខ្ពស់”

ការកំណត់រកឧបករណ៍មានប្រសិទ្ធភាពចំណាយ ដើម្បីវាស់វែងសមត្ថភាពទាំងអស់នេះ នៅតែជាបញ្ហាប្រឈមដ៏ធំបំផុត។ ការវាយតម្លៃលើចំណេះដឹង ឌីជីថល គឺមានលក្ខណៈខុសប្លែក

គ្នាទៅតាមគោលបំណង ក្រុមគោលដៅ មុខទំនិញ ការដឹកជញ្ជូន ការចំណាយ និងអាជ្ញាធរទទួលខុសត្រូវ។ ឧទាហរណ៍នៅក្នុង ប្រទេសបារាំង មានការផ្ដល់ឱ្យពលរដ្ឋនូវលទ្ធភាពដោយឥតគិតថ្លៃក្នុងការ ទទួលបាន ការវាយតម្លៃជំនាញឌីជីថល ការធ្វើរោគវិនិច្ឆ័យទៅលើចំណុចខ្លាំង និងចំណុចខ្សោយ និងផ្ដល់អនុសាសន៍ សម្រាប់ធនធានការសិក្សារៀនសូត្រ អាចជាវិធីមួយដើម្បីឈានឆ្ពោះទៅមុខ។

ការវាយតម្លៃលើសមត្ថភាពសហគ្រិនភាព ដែលមាននៅក្នុងការយកចិត្តទុកដាក់របស់ចំណុចដៅ ៤.៤ ដែលពុំមានសូចនាករត្រូវបានបង្កើតឡើងទេ ជួបប្រទះបញ្ហាប្រឈមប្រហាក់ប្រហែលគ្នានេះដែរ។ ជំនាញផ្នែកសង្គម និងអារម្មណ៍រួមទាំងការតស៊ូជម្នះឧបសគ្គ និងស្វ័យគ្រប់គ្រង គឺជាជំនាញមួយក្នុងចំណោមជំនាញជាច្រើនរបស់សហគ្រិនភាព ប៉ុន្តែការវាស់វែងជំនាញទាំងអស់នេះ ទាមទារការប្រុងប្រយ័ត្នខ្ពស់ក្នុងការបកស្រាយលក្ខណៈខុសប្លែកគ្នាពីវប្បធម៌មួយទៅវប្បធម៌។ OECD កំពុងបង្កើតឱ្យមានការសិក្សាអន្តរជាតិស្ដីពី




ជំនាញផ្នែកចិត្តសង្គមក្នុងចំណោមមនុស្សដែលមានអាយុ ១០ ដល់ ១៥ ឆ្នាំ។

**ចំណុចដៅ ៤.៥**

# សមធម៌

ជាទូទៅ មានភាពស្មើគ្នាផ្នែកយេនឌ័រនៅក្នុងការចុះឈ្មោះចូលរៀនទូទាំងសាកលលោកនៅក្នុងការអប់រំថ្នាក់បឋមសិក្សា និងមធ្យមសិក្សា។ ទោះយ៉ាងណាក្ដី មធ្យមភាគនេះ បិទបាំងភាពមិនស្មើគ្នា ដែលកំពុងកើតមានជាបន្តនៅកម្រិតប្រទេសនីមួយៗ។ ក្នុងឆ្នាំ ២០១៦ ប្រទេសចំនួន ៥៤% សម្រេចបានភាពស្មើគ្នានៅក្នុងការចុះឈ្មោះចូលរៀនថ្នាក់មធ្យមសិក្សាបឋមភូមិ និង ២២% នៅក្នុងថ្នាក់មធ្យមសិក្សាទុតិយភូមិ។ បន្ថែមលើនេះទៀតពុំមែនគ្រប់ប្រទេសទាំងអស់ដែលសម្រេចបានភាពស្មើគ្នាអាចរក្សាបានស្ថានភាពនេះទាំងអស់នោះទេ។មានភាពមិនស្មើគ្នាគួរជាទីកត់សម្គាល់នៅក្នុងអត្រាបញ្ចប់ការសិក្សាទៅតាមទីតាំងនិងធនធាន។ សិស្សនៅតំបន់ជនបទ ជាទូទៅមានតែប្រមាណពាក់កណ្ដាលប៉ុណ្ណោះ ដែលមានឱកាសបញ្ចប់ការអប់រំថ្នាក់មធ្យមសិក្សាទុតិយភូមិ បើធៀបជាមួយមនុស្សអាយុស្របាលគ្នានៅតំបន់ទីប្រជុំជនក្នុងប្រទេសមានចំណូលទាបនិងចំណូលមធ្យម (រូបភាពទី ១១)។

**រូបភាពទី ១១៖**

**បណ្តាប្រទេសជាច្រើនស្ថិតនៅឆ្ងាយពីការអាចសម្រេចបានភាពស្មើគ្នាយោងទៅតាមទីតាំង និងធនធានសម្រាប់ការបញ្ចប់ការសិក្សា ជាពិសេសនៅថ្នាក់មធ្យមសិក្សា**

សន្ទស្សន៍ភាពដូចគ្នាដែលត្រូវបានកែសម្រួលផ្នែកយេនឌ័រ ទីតាំង ធនធានស្តីពីអត្រាការបញ្ចប់ការសិក្សាចែកទៅតាមកម្រិតសិក្សា ២០១៤-២០១៧




GEM StatLink: http://bit.ly/fig12_1

ប្រភព៖ UIS និងការគណនារបស់ក្រុមការងារធ្វើរបាយការណ៍ GEM ដោយប្រើប្រាស់ការស្ទាបស្ទង់មតិតាមផ្ទះ។

> “សិស្សជនបទមានឱកាសប្រមាណពាក់កណ្តាលប៉ុណ្ណោះបើធៀបនឹងសិស្សនៅតំបន់ទីប្រជុំជនក្នុងការបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាទុតិយភូមិ នៅក្នុងបណ្តាប្រទេសមានចំណូលទាប និងចំណូលមធ្យម។”

ភាពអាចប្រៀបធៀបគ្នាបានកម្រិតទាបរារាំងការវាស់វែងភាពខុសប្លែកគ្នាទៅតាមទីតាំង៖ សមាមាត្រការងារដែលត្រូវចូលរួមក្នុងវិស័យកសិកម្ម ចំនួនប្រជាជន ដង់ស៊ីតេប្រជាជន លក្ខខណ្ឌវិនិច្ឆ័យជាលក្ខណៈពិសេសថ្នាក់ជាតិឬបន្ស៊ីដទៃទៀតក្នុងចំណោមលក្ខខណ្ឌវិនិច្ឆ័យខាងលើ អាចកំណត់អំពីការចាត់ប្រភេទ “ទីប្រជុំជន” និង “ជនបទ” នៅទូទាំងប្រទេស។

ក្នុងកិច្ចគាំទ្រចំពោះការពិនិត្យតាមដាន SDGs សន្និសីទលើកទីបីរបស់អង្គការ UN Habitat III ឆ្នាំ ២០១៦ នៅគីតូ និយមន័យសាកលយោងទៅតាមប្រជាជននៃតំបន់ទីក្រុង និងការតាំងលំនៅ ត្រូវបានបង្កើតឡើង ដើម្បីសុំការអនុម័តក្នុងឆ្នាំ ២០១៩។ និយមន័យនេះ ប្រៀបធៀបការចាត់ប្រភេទផ្នែករដ្ឋបាលជាមួយទិន្នន័យការស្ទាបស្ទង់មតិពីចម្ងាយ និងព័ត៌មានជំរឿន។ គួរឱ្យចាប់អារម្មណ៍ថា ស្របពេលដែលនិយមន័យថ្នាក់ជាតិស្នើឱ្យឃើញថា ប្រជាជនតិចជាងពាក់កណ្តាលនៅទ្វីបអាហ្វ្រិក និងទ្វីបអាស៊ីរស់នៅក្នុងតំបន់ទីប្រជុំជន ការប៉ាន់ប្រមាណក្នុងឆ្នាំ ២០១៨ ស្នើឱ្យឃើញថា ជាង ៨០% រស់នៅក្នុងតំបន់ប្រជុំជន។ ការប៉ាន់ប្រមាណនាពេលបច្ចុប្បន្ន អំពីលទ្ធផលការអប់រំនៅតំបន់ជនបទ អាចរួមមានទីតាំងជាច្រើន ដែលអាចប្រដូចបានថា ជាតំបន់ទីប្រជុំជន ដែលជាការបិទបាំងស្ថានភាពនៃតំបន់ជនបទពិតប្រាកដ។

4.6

# ការចេះអាន និងចំណេះដឹងលេខ

**ចំណុចដៅ ៤.៦**

អត្រាអក្ខរកម្មរបស់ពិភពលោក បានឈានដល់ ៨៦% ក្នុងឆ្នាំ ២០១៧ ថ្វីបើអត្រានេះ នៅមានកម្រិតទាបត្រឹម ៦៥% ក្នុងអនុ តំបន់សាហារ៉ាក្នុងប្រទេសអាហ្វ្រិកក្តី។ វឌ្ឍនភាពក្នុង ផ្នែកអំណានរបស់យុវជន និងការថយចុះនៃក្រុមយុវជន មានភាពធាប់រហ័សគ្រប់គ្រាន់ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដើម្បីឈានទៅដល់ការថយចុះដាច់ខាតក្នុងចំនួនទូទៅនៃអនក្ខរភាពក្នុងចំណោមយុវជនអាយុ ១៥ ដល់ ២៤ ឆ្នាំ ជាទូទៅត្រូវបានជំរុញនៅទ្វីបអាស៊ី។ ប៉ុន្តែចំនួនមនុស្សចាស់មិនចេះអានសរសេរ មនុស្សចាស់អាយុ ៦៥ ឡើងទៅ ដែលមិនចេះអាន សរសេរបន្តកើនឡើង ឥឡូវនេះ មានជាង ៤០% នៃមនុស្សចាស់ច្រើនជាងយុវជនដែលមិនចេះអានសរសេរ (រូបភាពទី ១២)។

អនក្ខរជនដែលនៅដាច់តែឯងរស់នៅក្នុងគ្រួសារដែលពុំមានសមាជិកគ្រួសារចេះអាន ច្រើនតែមានទីផ្សារការងារ និងលទ្ធផលគុណភាពជីវិតទាបជាងអ្នកមិនចេះអានសរសេរនៅក្បែរខាងដែលរស់នៅជាមួយសមាជិកគ្រួសារម្នាក់ ឬច្រើននាក់ដែលចេះអានសរសេរ។

អនក្ខរជនដែលនៅដាច់តែឯង ច្រើនតែមានអត្រាខ្ពស់ក្នុងចំណោមអ្នករស់នៅក្នុងតំបន់ជនបទ។ ក្នុងបណ្តាប្រទេសអ្នកមាន អ្នកមិនចេះអានសរសេរដែលនៅដាច់តែឯង ច្រើនតែជាមនុស្សចាស់ច្រើនជាងអ្នកមិនចេះអានសរសេរនៅក្បែរខាង ប៉ុន្តែទិដ្ឋភាពនេះ មានលក្ខណៈបញ្ច្រាសគ្នាមកវិញនៅក្នុងបណ្តាប្រទេសក្រីក្រ។ការពន្យល់មួយចំពោះទិដ្ឋភាពនេះគឺដោយសារ

**រូបភាពទី ១២៖**

**មានមនុស្សចាស់មិនចេះអានសរសេរ ៤០٪ ច្រើនជាងយុវជនមិនចេះអានសរសេរ**

ចំនួនយុវជន និងមនុស្សចាស់មិនចេះអានសរសេរ ២០១០-២០១៦




GEM StatLink: http://bit.ly/fig13_1
ប្រភព៖ ដេតាបេស UIS។

អ្នកមិនចេះអក្សរភាគច្រើនក្នុងបណ្ដាប្រទេសក្រីក្រ ច្រើនរស់នៅក្នុងគ្រួសារពហុជំនាន់ ជាហេតុធ្វើឱ្យពួកគេច្រើនតែរស់នៅព្រមជាមួយសមាជិកគ្រួសារវ័យក្មេង និងមានការអប់រំប្រសើរជាង។

ដោយសារហេតុនេះ អន្តរាគមន៍ផ្នែកអក្ខរកម្ម គួរផ្ដោតគោលដៅលើមនុស្សពេញវ័យជាមនុស្សចាស់រស់នៅក្នុងគ្រួសារដែលមានមនុស្សម្នាក់ ឬពីរនាក់រស់នៅ ក្នុងបណ្ដាប្រទេសអ្នកមាន ហើយនៅក្នុងក្រុមជួយជូរមនុស្សពេញវ័យ ជាមនុស្សវ័យក្មេងដែលជួបការលំបាកផ្នែកសេដ្ឋកិច្ចរស់នៅក្នុងតំបន់ជនបទក្នុងប្រទេសក្រីក្រ។

# ការអភិវឌ្ឍប្រកបដោយចីរភាព និងភាពជាពលរដ្ឋសាកល

**ចំណុចដៅ ៤.៧**

ការរាយការណ៍ស្ដីពីសូចនាករសាកល គឺផ្អែកលើប្រទេសចំនួន ៨៣ ដែលបានចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់លើកទី ៦ ស្ដីពីការអនុវត្តអនុសាសន៍អង្គការយូណេស្កូឆ្នាំ ១៩៧៤ ស្ដីអំពីការអប់រំសម្រាប់ការយល់ដឹងជាអន្តរជាតិកិច្ចសហប្រតិបត្តិការ និងការអប់រំសន្តិភាពទាក់ទងជាមួយសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ ជាង ៨០% នៃបណ្ដាប្រទេសបានរាយការណ៍ថា បានដាក់បញ្ចូលគោលការណ៍ណែនាំនៅក្នុងអនុសាសន៍ទៅក្នុងការវាយតម្លៃសិស្ស ហើយប្រទេសស្ទើរតែទាំងអស់ បានរាយការណ៍ថា បានដាក់បញ្ចូលគោលការណ៍ណែនាំទាំងអស់នោះទៅក្នុងកម្មវិធីសិក្សា។ ទោះជាយ៉ាងណាក្ដី មានតែបណ្ដាប្រទេស ១៧% ប៉ុណ្ណោះ ដែលបានឆ្លុះបញ្ចាំងគោលការណ៍ទាំងអស់នេះយ៉ាងពេញលេញនៅក្នុងកម្មវិធីវិក្រឹតការគ្រូបង្រៀន (រូបភាពទី ១៣ )។

ការសិក្សាអំពីពលរដ្ឋវិជ្ជា និងភាពជាពលរដ្ឋសកលរបស់ IEA ឆ្នាំ ២០១៦ បានវិភាគលើចំណេះដឹងការយល់ដឹង ឥរិយាបថ ការយល់ឃើញ និងសកម្មភាពរបស់សិស្សថ្នាក់ទី ៨ នៅក្នុងប្រទេសចំនួន ២៤ ដែលភាគច្រើនជាប្រទេសមានចំណូលខ្ពស់។សិស្សប្រមាណ៣៥%បានពិន្ទុខ្ពស់បំផុតក្នុងចំណោមកម្រិតទាំងបួនដែលជាការបង្ហាញឱ្យឃើញនូវសមត្ថភាពក្នុងការធ្វើការផ្សារភ្ជាប់រវាងដំណើរការនៃស្ថាប័នផ្នែកសង្គម និងនយោបាយជាមួយយន្តការផ្នែកច្បាប់ និងផ្នែកស្ថាប័ន ដែលគ្រប់គ្រងលើស្ថាប័នទាំងនោះ ស្របពេលនោះមានតែសិស្ស ១៣% ប៉ុណ្ណោះ ដែលបានពិន្ទុទាបបំផុត ឬទាប។

ប្រទេសចំនួន ១១ មានពិន្ទុប្រសើរឡើងគួរជាទីកត់សម្គាល់នៅក្នុងការស្ទាបស្ទង់មតិក្នុងជុំចន្លោះឆ្នាំ ២០០៩ ដល់ ២០១៦ ហើយពុំមានប្រទេសណាមួយដែលបានបង្ហាញការថយចុះគួរជាទីកត់សម្គាល់ទេ។ ការគាំទ្រសិទ្ធិស្មើគ្នា និងឥរិយាបថជាវិជ្ជមានរបស់អ្នកចូលរួមចំពោះក្រុមជាតិពន្ធុ/ជាតិសាស្ត្រក៏មានភាពប្រសើរឡើងផងដែរ។ ស្ត្រី សិស្សមានចំណាប់អារម្មណ៍ច្រើនលើបញ្ហាពលរដ្ឋវិជ្ជា និងនយោបាយ និងអ្នកដែលមានចំណេះដឹងកម្រិតខ្ពស់ផ្នែកពលរដ្ឋវិជ្ជា ប្រកាន់យកឥរិយាបថជាវិជ្ជមានជាងក្រុមដទៃ ។ អថេរបុគ្គលពាក់ព័ន្ធយ៉ាងស៊ីសង្វាក់បំផុតជាមួយឥរិយាបថជាវិជ្ជមាន ទាក់ទងជាមួយទស្សនៈយល់ឃើញអំពីគុណភាពនៃដំណើរការសាលារៀន ដូចជាទំនាក់ទំនងរវាងគ្រូ និងសិស្ស ការសិក្សាពលរដ្ឋវិជ្ជា និងការបើកចំហនៅក្នុងការពិភាក្សាក្នុងសាលារៀន និងក្នុងថ្នាក់រៀន។

**រូបភាពទី ១៣៖**

**មានតែប្រទេសចំនួន ១៧៪ ប៉ុណ្ណោះ ដែលឆ្លុះបញ្ចាំងតាមគោលការណ៍សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានបានពេញលេញនៅក្នុងការធ្វើវិក្រឹតការគ្រូបង្រៀន**

ភាគរយនៃបណ្តាប្រទេសដែលឆ្លុះបញ្ចាំងគោលការណ៍ដែលមានចែងក្នុងអនុសាសន៍អង្គការយូណេស្កូឆ្នាំ ១៩៧៤ នៅក្នុងគោលនយោបាយបណ្តុះបណ្តាលគ្រូបង្រៀន និងកម្មវិធីសិក្សារបស់ខ្លួន ឆ្នាំ ២០១២-២០១៦




GEM StatLink: http://bit.ly/fig14_1
ប្រភព៖ យូណេស្កូ (២០១៨)។




# គ្រឹះស្ថានអប់រំ និងបរិស្ថានការសិក្សារៀនសូត្រ

**ចំណុចដៅ ៤.ក**

នៅទូទាំងសាកលលោក ៦៩% នៃសាលារៀនមានទឹកសម្រាប់ផឹក ៦៦% មានអនាម័យសាធារណៈ និង ៥៣% មានអនាម័យខ្លួនប្រាណនៅក្នុងកម្រិតសេវាមូលដ្ឋាន ឬប្រសើរជាងនេះ (រូបភាពទី ១៩)។ ក្នុងប្រទេសហ្សកដានី ៩៣% នៃសាលារៀន មានទឹកផឹកស្អាតជាមូលដ្ឋាន ប៉ុន្តែ ៣៣% មានអនាម័យសាធារណៈកម្រិតមូលដ្ឋាន។ នៅប្រទេសលីបង់ ជិត ៩៣% មានអនាម័យសាធារណៈជាមូលដ្ឋាន ប៉ុន្តែ ៦០% មានទឹកផឹកកម្រិតមូលដ្ឋាន។ សាលារៀនថ្នាក់បឋមសិក្សា ច្រើនតែមានគុណភាពសេវាទាបជាងថ្នាក់មធ្យមសិក្សា។

> “ចន្លោះឆ្នាំ ២០១៣ ដល់ ២០១៧ មានការវាយប្រហារចំនួន ១២ ៧០០ លើកនៅក្នុងការអប់រំ”

ទិដ្ឋភាពមួយចំនួនស្តីពីសុវត្ថិភាព និងបរិយាបន្នក្នុងបរិស្ថានការសិក្សារៀនសូត្រ ត្រូវបានពិនិត្យតាមដានយ៉ាងពេញលេញទូទាំងសាកលលោក។ ទស្សនាទានផ្សេងៗដូចជាការធ្វើបាប ខ្វះនិយមន័យស្តង់ដារជាសាកល ហើយការស្ទាបស្ទង់មតិមានភាពខុសប្លែកគ្នាយ៉ាងធំធេង។ ការសិក្សាមួយបានប៉ាន់ប្រមាណថាជិត ៤០% នៃក្មេងប្រុស និង ៣៥% នៃក្មេងស្រី អាយុ ១១ ដល់ ១៥ ឆ្នាំ បានរាយការណ៍ថា ធ្លាប់ជាជនរងគ្រោះ នៃការ ធ្វើ បាប ។ ចំនួន បណ្តា ប្រទេស ដែលមាន ច្បាប់ហាមឃាត់ការដាក់ពិន័យផ្នែករាងកាយក្នុងសាលារៀន បានកើនឡើងដល់ ១៣១ ប្រទេស បើធៀបនឹងចំនួន ១២២ ប្រទេសនៅចុងឆ្នាំ ២០១៤។

ចន្លោះឆ្នាំ ២០១៣ ដល់ ២០១៧ មានការវាយប្រហារចំនួន ១២ ៧០០ លើកនៅក្នុងការអប់រំបង្កគ្រោះថ្នាក់ដល់សិស្ស និងអ្នកអប់រំចំនួន ២១ ០០០ នាក់ នេះបើយោងតាមទិន្នន័យរបស់សម្ព័ន្ធភាពសាកលដើម្បីការពារការអប់រំពីការវាយប្រហារ។ ករណីដែលបានរាយការណ៍ រួមមានការវាយប្រហារផ្នែករាងកាយ ឬការគំរាមវាយប្រហារមកលើសាលារៀន សិស្ស និងបុគ្គលិកអប់រំ ការប្រើប្រាស់អគារអប់រំសម្រាប់គោលបំណងយោធា ការជ្រើសរើសកុមារ ឬអំពើហិង្សាផ្លូវភេទនៅកន្លែង ឬនៅក្នុងដំណាក់កាលអន្តរកាលទៅកាន់សាលារៀន ឬសាកលវិទ្យាល័យពីសំណាក់ក្រុមប្រដាប់អាវុធ និងការវាយប្រហារលើការអប់រំឧត្តមសិក្សា។ ប្រទេសចំនួន ២៨ បានរងការវាយប្រហារយ៉ាងហោចណាស់ ២០ ដង ប្រទេសនីហ្សេរីយ៉ា ហ្វីលីពីន និងយេម៉ែន គឺជាប្រទេសដែលរងគ្រោះលើសពី ១០០០ ដង។

ទិន្នន័យរបស់សម្ព័ន្ធភាព ពុំបានចាប់ការវាយប្រហារដាក់លាក់នោះទេ រួមទាំងការវាយប្រហារដោយក្រុមបងធំឧក្រិដ្ឋជន និងការបាញ់មកលើសាលារៀន ដោយខ្មាន់កាំភ្លើងតែម្នាក់។ នៅសហរដ្ឋអាមេរិក មានសិស្សយ៉ាងហោចណាស់ ១៨៧ ០០០ នាក់ក្នុងសាលារៀនចំនួន ១៩៣ ដែលធ្លាប់ជួបបទពិសោធន៍ការបាញ់ប្រហារនៅសាលារៀន ចាប់ពីឆ្នាំ ១៩៩៩ មក។

**រូបភាពទី ១៤៖**

**សាលារៀនតិចជាង ៧ ក្នុងចំណោម ១០ សាលារៀនមានទឹកផឹកនៅកម្រិតសេវាមូលដ្ឋាន**

ការចែកចាយទឹកស្អាត អនាម័យទូទៅ និងអនាម័យខ្លួនប្រាណនៅតាមសាលារៀន ចែកទៅតាមកម្រិតសេវា ២០១៦




GEM StatLink: http://bit.ly/fig15_1

សំគាល់៖ តួរលេខយកជាចំនួនគត់ ហេតុនេះ ផលបូកសរុបអាចមិនស្មើ ១០០%

ប្រភព៖ យូនីសេហ្វ និង WHO (២០១៨)។




# អាហារូបករណ៍

**ចំណុចដៅ ៤.ខ**

ទំហំអាហារូបករណ៍ដែលផ្ដល់មូលនិធិដោយកម្មវិធីផ្ដល់ជំនួយ មានភាពនៅនឹងថ្កល់ចាប់ពីឆ្នាំ២០១០ មកក្នុងបរិមាណប្រមាណ១.១ប៊ីលានដុល្លារដល់១.២ប៊ីលានដុល្លារ (មិនរួមថ្លៃចំណាយលើកម្ចីរបស់សិស្ស)។ ប៉ុន្តែសូចនាករនេះ ពុំផ្ដល់ព័ត៌មានស្ដីពីចំនួនអ្នកទទួលអាហារូបករណ៍ ឬចំនួនអ្នកទទួលអាហារូបករណ៍ដែលត្រូវបានបង់ប្រាក់ឱ្យនៅក្រៅកម្មវិធីជំនួយនោះទេ។

ស្របពេលដែលសមាមាត្រសិស្សចល័តអន្តរជាតិមានការកើនឡើង ការផ្លាស់ទីចេញទៅក្រៅតំបន់របស់ខ្លួនដែលភាគច្រើនជាសិស្សចល័តមកពីអឺរ៉ុបស្នាក់នៅក្នុងតំបន់របស់ខ្លួន ការផ្លាស់ទីរបស់ពួកគេត្រូវបានលើកកម្ពស់យ៉ាងសកម្មតាមរយៈកម្មវិធីផ្លាស់ប្ដូរសិស្ស។ អត្រាផ្លាស់ទីចេញទៅខាងក្រៅរបស់ពួកគេ គិតទៅតាមកម្រិតសិក្សារបស់សិស្ស ចាប់ពី ៣% សម្រាប់ថ្នាក់បរិញ្ញាបត្ររហូតដល់ ៦% សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និង ១០% សម្រាប់ថ្នាក់បណ្ឌិត (**រូបភាពទី ១៥**)។

> “ យុទ្ធសាស្ត្រអប់រំឧត្តមសិក្សារបស់ EU កំណត់គោលដៅយ៉ាងតិច ២០% នៃអ្នកបានបញ្ចប់ការសិក្សាត្រូវមានបទពិសោធន៍ទទួលការសិក្សាមួយផ្នែកនៅបរទេស។ ”

ស្តង់ដារគំរូការផ្លាស់ទីសម្រាប់ការរៀនសូត្រថ្នាក់ឧត្តមសិក្សារបស់សហគមន៍អឺរ៉ុបឆ្នាំ ២០២០ ស្នើឱ្យឃើញថា យ៉ាងហោចណាស់ ២០% នៃអ្នកបញ្ចប់ការអប់រំថ្នាក់ឧត្តមសិក្សានៅក្នុងសហគមន៍អឺរ៉ុប គួរតែបានសិក្សានៅក្រៅប្រទេសយ៉ាងហោចណាស់ ៣ ខែ ឬសមមូលជាមួយ ១៥ ក្រេឌីតនៅក្នុងប្រព័ន្ធផ្ទេរក្រេឌីតអឺរ៉ុប។

ស្ថាប័នក្នុងស្រុកអាចផ្ដល់ទិន្នន័យ ដើម្បីធ្វើការប៉ាន់ប្រមាណការផ្លាស់ទីបណ្ដោះអាសន្នសម្រាប់ក្រេឌីត ប្រទេសគោលដៅចាំបាច់ត្រូវផ្ដល់ទិន្នន័យសម្រាប់ការផ្លាស់ទីកម្រិតសិក្សា។ សម្រាប់បណ្ដាប្រទេសអឺរ៉ុប ការរាយការណ៍គឺត្រូវធ្វើឡើងជាកាតព្វកិច្ច ប៉ុន្តែក្នុងចំណោមបណ្ដាប្រទេសគោលដៅសំខាន់ៗសម្រាប់សិស្សអឺរ៉ុបនៅក្រៅពីទ្វីបអឺរ៉ុប គឺមានតែប្រទេសអូស្ត្រាលី ប្រេស៊ីល កាណាដា ស៊ីលី អ៊ីស្រាអែល និងណូវែលសេឡង់ប៉ុណ្ណោះ ដែលផ្ដល់ទិន្នន័យដែលចាំបាច់។ សហរដ្ឋអាមេរិក គឺជាកន្លែងដែលបាត់ប្រភពទិន្នន័យសំខាន់ជាងគេ ព្រមជាមួយប្រទេសចិន ឥណ្ឌា ជប៉ុន ម៉ិកស៊ិក និងសាធារណរដ្ឋកូរ៉េ។ អាស្រ័យដោយការគ្របដណ្ដប់មិនពេញលេញ ការប៉ាន់ប្រមាណដែលមាន (បច្ចុប្បន្ន គឺនៅទាបជាង ២០% យ៉ាងច្រើន) ទំនងជាបង្ហាញទាបជាងការពិតយ៉ាងខ្លាំងទាក់ទងជាមួយការផ្លាស់ទីចេញក្រៅប្រទេស។

**រូបភាពទី ១៥៖**

## នៅទ្វីបអឺរ៉ុប ការផ្លាស់ទីរបស់សិស្ស មានការកើនឡើងយោងទៅតាមកម្រិតសិក្សា

អត្រាការផ្លាស់ទីនៃសញ្ញាបត្រនៅខាងក្រៅចែកទៅតាមចំណាត់ប្រភេទស្តង់ដារអន្តរជាតិនៃកម្រិតការអប់រំក្នុងបណ្តាប្រទេសអឺរ៉ុបដែលត្រូវបានជ្រើសរើស ឆ្នាំ ២០១៣




GEM StatLink: http://bit.ly/fig16_3

សម្គាល់៖ ISCED = ចំណាត់ប្រភេទស្តង់ដារអន្តរជាតិនៃការអប់រំ រួមមាន៖ ថ្នាក់បរិញ្ញាបត្រ (ISCED 6); កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ឬកម្រិតសមាមូល (ISCED 7); និងថ្នាក់បណ្ឌិត ឬថ្នាក់សមមូល (ISCED 8)។

ប្រភព៖ Flisi et al. (2015).




**ចំណុចដៅ ៤.គ**

# គ្រូបង្រៀន

ការប្រមូលទិន្នន័យអន្តរជាតិស្តីពីសូចនាករពាក់ព័ន្ធជាមួយគ្រូបង្រៀន ដែលអាចប្រៀបធៀបគ្នាបាន នៅតែជាបញ្ហាប្រឈម។ មានប្រទេសតិចតួចប៉ុណ្ណោះ ដែលបង្កើតទិន្នន័យដែលអាចប្រៀបធៀបគ្នាបាន ជាពិសេសសម្រាប់ការអប់រំថ្នាក់មធ្យមសិក្សា សូម្បីតែការប្រើប្រាស់និយមន័យជាមូលដ្ឋានយ៉ាងខ្លាំងបំផុតនៃការរាប់ចំនួនគ្រូបង្រៀនដែលមិនរាប់បញ្ចូលចំនួនម៉ោងបង្រៀន និងចំនួនគ្រូបង្រៀននៅក្នុងមុខតំណែងរដ្ឋបាល។

បណ្តាប្រទេសមានចំណូលទាប និងប្រទេសមានចំណូលមធ្យមកម្រិតទាប បន្តជួបការខ្វះខាតគ្រូបង្រៀនថ្នាក់បឋមសិក្សាដែលមានការបណ្តុះបណ្តាល និងមានគុណវុឌ្ឍិយ៉ាងធ្ងន់ធ្ងរ។ បណ្តាប្រទេសមួយចំនួនក្នុងអនុតំបន់សាហារ៉ានៃទ្វីបអាហ្វ្រិក មានអត្រាជ្រើសរើសឱ្យចូលធ្វើការងារខ្ពស់ ដែលមានសក្តានុពលបំផ្លាញដល់បទដ្ឋាននៃការជ្រើសរើសឱ្យចូលធ្វើការ ប្រសិនបើសមត្ថភាពអប់រំរបស់គ្រូ មានកម្រិតកំណត់។ ក្នុងប្រទេសនីហ្សេ ដោយក្នុងនោះ ១៣% នៃគ្រូបង្រៀនថ្នាក់បឋមសិក្សា ត្រូវបានជ្រើសរើសឱ្យចូលធ្វើការនាពេលថ្មីៗក្នុងឆ្នាំ ២០១៣ មានតែ ៣៧% ប៉ុណ្ណោះ ដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ (**រូបភាពទី ១៦**)។

អត្រាជ្រើសរើសឱ្យចូលធ្វើការងារខ្ពស់ ពុំមែនគ្រាន់តែជាការបង្ហាញនូវការពង្រីកវិស័យអប់រំប៉ុណ្ណោះទេ ប៉ុន្តែការជ្រើសរើសទាំងអស់នេះ អាចមានភាពចាំបាច់ ដើម្បីមានបុគ្គលិកជំនួសឱ្យអ្នកដែលបានចាកចេញពីការងារ។ ទិន្នន័យគួរឱ្យទុកចិត្តបានស្តីពីការបោះបង់ការងារ គឺនៅមានលក្ខណៈរាយប៉ាយ និងពិបាកបកស្រាយ។ ការប៉ាន់ប្រមាណយ៉ាងសុក្រឹត ទាមទារនូវទិន្នន័យអំពីបុគ្គលិកដែលមានដាក់លេខសម្គាល់អត្តសញ្ញាណ ដើម្បីឱ្យអាចតាមដានមើលប្រភពរបស់បុគ្គល នៅពេលដែលពួកគេមានគុណវុឌ្ឍិគ្រប់គ្រាន់ចូលមកក្នុងវិស័យការងារ ចាកចេញ និងវិលត្រលប់ចូលមកក្នុងអាជីពការងារវិញ។ ទិន្នន័យគួរញែករវាងអ្នកចាកចេញពីការងារ និងអ្នកចូលមកធ្វើការងារប្រភេទផ្សេងៗគ្នា រួមទាំងអ្នកវិលចូលមកក្នុងការងារវិញម្តងទៀតផងដែរ។ ការពិនិត្យតាមដានលើការបោះបង់ការងារ ទាមទារនូវប្រព័ន្ធថ្នាក់ជាតិ និងព័ត៌មានអំពីសាលារៀនគ្រប់ប្រភេទទាំងអស់នៅក្នុងប្រព័ន្ធ ដែលមានបទប្បញ្ញត្តិចម្រុះគ្នាជាច្រើន ប៉ុន្តែជារឿយៗ ព័ត៌មានដែលមាន គឺមានតែព័ត៌មានអំពីសាលារៀនក្នុងមូលដ្ឋាន (ឧ. ប្រទេសប្រេស៊ីល) ឬយកចិត្តទុកដាក់តែទៅលើសាលារដ្ឋប៉ុណ្ណោះ (ឧ. ប្រទេសអ៊ូហ្គង់ដា)។

ការស្រាវជ្រាវពីបណ្ដាប្រទេសនានា ដូចជា ស៊ីលី ស៊ុយអែត និងសហរដ្ឋអាមេរិក បានរកឃើញអត្រាការបោះបង់ការងារខ្ពស់ក្នុងចំណោមគ្រូបង្រៀនដែលមិនសូវមានបទពិសោធន៍ មានគុណវុឌ្ឍិខ្ពស់ (និងជាហេតុធ្វើឱ្យកាន់តែមានលទ្ធភាពអាចរកការងារធ្វើបាននៅកន្លែងផ្សេងទៀត) គ្រូដែលត្រូវបានដាក់នៅក្នុងសាលារៀន ជួបការលំបាក ឬសាលារៀនជនបទ គ្រូដែលពុំបានទទួលបៀវត្សគ្រប់គ្រាន់ ឬគ្រូកិច្ចសន្យារយៈពេលខ្លី។ ទោះយ៉ាងណាក្ដី ភស្តុតាងដែលបានទទួលមកពីការសិក្សារយៈពេលវែងនៅក្នុងប្រទេសអូស្ត្រាលីបញ្ជាក់ឱ្យឃើញថា គ្រូជាច្រើនដែលបានចាកចេញ ហាក់បានចាកចេញដោយសារតែមូលហេតុគ្រួសារ រួចបានវិលត្រលប់មកអាជីពការងារនេះវិញក្នុងរង្វង់រយៈពេលពីរឆ្នាំ។

**រូបភាពទី ១៦៖**

**បទដ្ឋានការអប់រំគ្រូបង្រៀន គឺមានការលំបាកក្នុងការថែរក្សាឱ្យបាននៅពេលមានអត្រាជ្រើសរើសចូលធ្វើការងារកម្រិតខ្ពស់**

អត្រាការជ្រើសរើសគ្រូបង្រៀនថ្មីៗ និងភាគរយនៃគ្រូដែលមានការបណ្ដុះបណ្ដាល ក្នុងការអប់រំថ្នាក់បឋមសិក្សានៅក្នុងបណ្ដាប្រទេសអនុតំបន់អាហារ៉ានៃទ្វីបអាហ្វ្រិកដែលត្រូវបានជ្រើសរើស ២០១០-២០១៤




GEM StatLink: http://bit.ly/fig17_1

ប្រភព៖ ដេតាបេស UIS ។

# ការអប់រំ និង SDGs ដទៃទៀត

របាយការណ៍នេះ ពិនិត្យមើលថាតើការអប់រំ អាចពន្លឿនការសម្រេចបាន SDGs ទាក់ទងជាមួយការងារសមរម្យ ទីក្រុងប្រកបដោយចីរភាព និងយុត្តិធម៌តាមវិធីផ្សេងៗដោយរបៀបណា រួមទាំងតាមរយៈការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជំនាញផងដែរ។

ប្រទេសជាច្រើនមានបុគ្គលិកសង្គមកិច្ចមានការបណ្តុះបណ្តាលគ្រប់គ្រាន់តិចជាងការចាំបាច់ ដើម្បីអាចសម្រេចបាន SDG 8 ស្តីពីការងារសមរម្យ និងកំណើនសេដ្ឋកិច្ច។ នៅប្រទេសអេត្យូពី ៦០% នៃបុគ្គលិកសង្គមកិច្ចក្នុងវិស័យសាធារណៈដែលត្រូវបានសម្ភាសន៍បាននិយាយថា ពួកគាត់ខ្វះការអប់រំដែលពាក់ព័ន្ធ។ ប្រទេសមួយចំនួនកំពុងបង្កើនកិច្ចខិតខំក្នុងការបណ្តុះបណ្តាល៖ ប្រទេសចិនមានបំណងធ្វើឱ្យមានបុគ្គលិកសង្គមកិច្ចថ្មីៗចំនួន ២៣០ ០០០នាក់ ត្រឹមឆ្នាំ ២០២០។ នៅប្រទេសអាហ្វ្រិកខាងត្បូង ចំនួនបុគ្គលិកសង្គមកិច្ចបានកើនឡើង ៧០% នៅចន្លោះឆ្នាំ ២០១០ ដល់ ២០១៥។

ដោយប្រជាជនជាងពាក់កណ្តាលរបស់ពិភពលោក កំពុងរស់នៅតាមក្រុងនានា ការសម្រេចបាន SDG 11 ស្តីពីទីក្រុង និងសហគមន៍ប្រកបដោយចីរភាព ទាមទារឱ្យអ្នកធ្វើផែនការទីក្រុង ចាំបាច់ត្រូវកែលម្អការតាំងលំនៅក្រៅផ្លូវការ និងត្រៀមរៀបចំសម្រាប់កំណើនប្រជាជនក្នុងទីក្រុងនាពេលអនាគត។ បណ្តាប្រទេសជាច្រើន ជួបប្រទះកង្វះខាតអ្នកវិជ្ជាជីវៈអាជីពផ្នែកធ្វើផែនការយ៉ាងស្រួចស្រាវ (**រូបភាពទី ១៧**)។ ប្រទេសឥណ្ឌា ត្រូវការអ្នកធ្វើផែនការទីក្រុង និងអ្នកធ្វើផែនការប្រទេសចំនួន ៣០០ ០០០ នាក់ គិតត្រឹមឆ្នាំ ២០៣១ នៅឆ្នាំ ២០១១ ប្រទេសឥណ្ឌា មានអ្នកធ្វើផែនការទីក្រុង និងជនបទចំនួន ៤៥ ០០០ នាក់។ កម្មវិធីការធ្វើផែនការ ចាំបាច់ត្រូវរួមបញ្ចូលការធ្វើផែនការរូបវន្ត ការធ្វើផែនការផ្នែកបរិស្ថាន និងការធ្វើផែនការផ្នែកសង្គមរួមទាំងការអប់រំផងដែរ។ មន្ត្រីថ្នាក់មូលដ្ឋានក្នុងបណ្តាប្រទេសនានារួមមានដូចជា ម៉ាឡាវី ម៉ូសំប៊ិក និងណាមីប៊ី ចាំបាច់ត្រូវពង្រឹងសមត្ថភាពធ្វើផែនការបន្ថែមទៀត។

ដើម្បីសម្រេចបាន SDG 16 ស្តីពីសន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ តម្រូវការផ្នែកការអប់រំ និងការបណ្តុះបណ្តាលរបស់មន្ត្រីជំរុញការអនុវត្តច្បាប់ ចាំបាច់ត្រូវកែលម្អបន្ថែមទៀត ដើម្បីជួយស្ថាបនាការទុកចិត្ត និងកាត់បន្ថយភាពលម្អៀង និងការប្រើប្រាស់កម្លាំង។ ក្នុងសហរដ្ឋអាមេរិក ការបណ្តុះបណ្តាលនគរបាលជាមធ្យមមានរយៈពេល ១៩ សប្តាហ៍ បើប្រៀបធៀបជាមួយរយៈពេល ១៣០ សប្តាហ៍ក្នុងប្រទេសអាល្លឺម៉ង់។ មានតែ ១% ប៉ុណ្ណោះនៃការិយាល័យនគរបាលសហរដ្ឋអាមេរិក ដែលទាមទារឱ្យមានកម្រិតសិក្សាសាកលវិទ្យាល័យរយៈពេលបួនឆ្នាំ មន្ត្រីដែលមានសញ្ញាបត្រថ្នាក់សាកលវិទ្យាល័យ ច្រើនតែមិនសូវប្រើកម្លាំងបាយ។

ប្រទេសមួយចំនួន រួមទាំងប្រទេសសិង្ហបុរីផងដែរ បានប្រើប្រាស់ការបណ្តុះបណ្តាល ដើម្បីទប់ស្កាត់អំពើពុករលួយរបស់នគរបាល ហើយប្រទេសដទៃទៀត ដូចជាឥណ្ឌូណេស៊ីជាដើម បានសហការជាមួយដៃគូអន្តរជាតិ ដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈអាជីពរបស់នគរបាល។

មនុស្សប្រមាណ ៤ ប៊ីលាននាក់ទូទាំងពិភពលោកខ្វះលទ្ធភាពទទួលបានយុត្តិធម៌ដែលជាការស្តែងឱ្យឃើញនូវតម្រូវការដើម្បីអភិវឌ្ឍន៍សមត្ថភាពផ្នែកច្បាប់។ ការអប់រំផ្នែកយុត្តិធម៌មានលក្ខណៈប្លែកៗគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ជាទូទៅការបណ្តុះបណ្តាលមានរយៈពេលបីទៅប្រាំឆ្នាំ ប៉ុន្តែសញ្ញាបត្រច្បាប់ពុំមែនជានិច្ចជាកាលសុទ្ធតែជាបុរេលក្ខខណ្ឌដើម្បីក្លាយជាចៅក្រមនោះទេ សូម្បីតែនៅក្នុងប្រទេសមានចំណូលខ្ពស់ក្តី។ ប្រទេសមួយចំនួន រួមទាំងប្រទេសបារាំងផងដែរ ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈអាជីព នៅពេលចាប់ផ្តើមការងារដំបូងដ៏ច្រើនសន្ធឹកសន្ធាប់នៅពេលចៅក្រមត្រូវបានជ្រើសរើសឱ្យធ្វើការ។ ប្រទេសមួយចំនួន ដូចជាហ្គាណានិងហ្សិកដានីមានស្ថាប័នអប់រំបន្តសម្រាប់ចៅក្រម។

**រូបភាពទី ១៧៖**

**មានអ្នកធ្វើផែនការនគរូបនីយកម្មចំនួនតិចពេកក្នុងទ្វីបអាហ្វ្រិក និងអាស៊ី**

ចំនួនអ្នកធ្វើផែនការនគរូបនីយកម្មក្នុងសមាមាត្រប្រជាជន ១០០ ០០០ នាក់ និងអត្រានគរូបនីយកម្មក្នុងបណ្តាប្រទេសដែលត្រូវបានជ្រើសរើស ឆ្នាំ ២០១១




GEM StatLink: http://bit.ly/fig18_2

សម្គាល់៖ ទិន្នន័យបានមកពីចំនួន អ្នកធ្វើផែនការឆ្នាំ ២០១១ និងអត្រានគរូបនីយកម្មឆ្នាំ ២០១៤។

ប្រភព៖ UNDESA (2014); UN-Habitat (2016b).

# ហិរញ្ញវត្ថុ

ប្រភពចម្បងបីនៃការផ្តល់ហិរញ្ញវត្ថុការអប់រំ គឺរដ្ឋាភិបាល ម្ចាស់ជំនួយ និងគ្រួសារ។ ការវិភាគសម្រាប់របាយការណ៍នេះ ប៉ាន់ប្រមាណការចំណាយប្រចាំឆ្នាំ លើការអប់រំក្នុងទឹកប្រាក់ ៤,៧ ទ្រីលានដុល្លារអាមេរិកទូទាំងសាកលលោក។ ក្នុងចំនួនទឹកប្រាក់នេះទឹកប្រាក់ចំនួន ៣ ទ្រីលាន (៦៥%នៃទឹកប្រាក់សរុប) ត្រូវបានចំណាយនៅក្នុងបណ្តាប្រទេសមានចំណូលខ្ពស់ ហើយ ២២ ប៊ីលានដុល្លារអាមេរិក (០,៥% នៃទឹកប្រាក់សរុប) ត្រូវបានចំណាយនៅក្នុងប្រទេសមានចំណូលទាប (**រូបភាពទី ១៨ក**) បើទោះបីជាក្រុមទាំងពីរនេះ មានចំនួនកុមារក្នុងអាយុចូលរៀនប្រហាក់ប្រហែលគ្នាក្តី។ រដ្ឋាភិបាលទទួលបន្ទុកចំនួន ៧៩% នៃការចំណាយសរុប ចំណែកគ្រួសារទទួលបន្ទុក ២១%។ម្ចាស់ជំនួយទទួលបន្ទុក១២%នៃការចំណាយសរុបលើការអប់រំនៅក្នុងបណ្តាប្រទេសមានចំនណូលទាប និង ២%នៅក្នុងបណ្តាប្រទេសមានចំណូលមធ្យមកម្រិតទាប (**រូបភាពទី ១៨ខ**)។

> **“ ការចំណាយជាសាកលប្រចាំឆ្នាំលើការអប់រំ គឺមានទឹកប្រាក់ប្រមាណ ៤,៧ ទ្រីលានដុល្លារអាមេរិក ដោយក្នុងនោះ ៦៥% នៃទឹកប្រាក់នេះត្រូវបានចំណាយក្នុងបណ្តាប្រទេសមានចំណូលខ្ពស់ ”**

**រូបភាពទី ១៨៖**

**ទឹកប្រាក់បួនដុល្លារនៃទឹកប្រាក់ប្រាំដុល្លារដែលចំណាយលើវិស័យអប់រំ គឺចេញមកពីរដ្ឋាភិបាល**

ក. ការចំណាយសរុបលើការអប់រំដោយចែកទៅតាមក្រុមចំណូលរបស់ប្រទេស និងប្រភពការផ្តល់ហិរញ្ញវត្ថុ ក្នុងឆ្នាំ ២០១៤ ឬក្នុងឆ្នាំចុងក្រោយបំផុត

ខ. របាយការណ៍ការចែកចាយនៃការចំណាយសរុបលើវិស័យអប់រំ ចែកទៅតាមក្រុមចំណូលប្រទេស និងប្រភពការផ្តល់ហិរញ្ញវត្ថុ ក្នុងឆ្នាំ២០១៤ ឬក្នុងឆ្នាំចុងក្រោយបំផុត




GEM StatLink: http://bit.ly/fig19_1

សម្គាល់៖ ការវិភាគនេះ ផ្អែកលើមូលដ្ឋានបី៖ (ក) សម្រាប់បណ្តាប្រទេសដែលពុំមានទិន្នន័យការចំណាយសាធារណៈ ចំនួនទឹកប្រាក់ត្រូវបានគណនាចេញពី GDP ដោយក្នុងនោះ ការចំណាយសាធារណៈ ជាចំណែកមួយនៃ GDP និងសមាមាត្រមធ្យមនៃការចំណាយសាធារណៈដែលត្រូវចែកទៅឱ្យវិស័យអប់រំនៅក្នុងប្រទេសតាមក្រុមប្រាក់ចំណូលនីមួយៗ (ខ) ៦០% នៃការចំណាយថវិកាជំនួយត្រូវបានពិចារណាឆ្លុះបញ្ចាំងនៅក្នុងថវិកាសាធារណៈ (ដូច្នេះ ត្រូវបានដកចេញពីការចំណាយរបស់រដ្ឋាភិបាល) ដោយក្នុងនោះទឹកប្រាក់ ៤០% ដែលនៅសល់ត្រូវបានចាត់ជាថវិកាតាមរយៈបណ្តាញដទៃទៀត និង (គ) សមាមាត្រតាមគ្រួសារនៅក្នុងការចំណាយសរុបក្នុងវិស័យអប់រំ ត្រូវបានប៉ាន់ប្រមាណថា មានចំនួន ១៨% ក្នុងបណ្តាប្រទេសមានចំណូលខ្ពស់ ២៥% នៅក្នុងប្រទេសមានចំណូលមធ្យម និង ៣៣% នៅក្នុងបណ្តាប្រទេសមានចំណូលទាប។

# ការចំណាយសាធារណៈ

នៅទូទាំងសកលលោក មេដ្យាននៃការចំណាយលើការអប់រំសាធារណៈគឺមានចំនួន ៤,៤% នៃ GDP ក្នុងឆ្នាំ ២០១៧ ពោលគឺមានអត្រាខ្ពស់ជាងស្តង់ដារគំរូអប្បបរមា ៤% ដូចមានចែងក្នុងក្របខ័ណ្ឌការងារសកម្មភាពការអប់រំឆ្នាំ ២០៣០ បើគិតទៅតាមតំបន់ អត្រានេះមានចាប់ពី ៣,៤% នៅតំបន់អាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ រហូតដល់ ៥,១% នៅតំបន់អាមេរិកឡាទីន និងការីប៊ីន។ មេដ្យានភាគរយនៃការចំណាយសាធារណៈសរុបផ្តោតចំពោះការអប់រំ គឺមាន ១៤,១% ពោលគឺស្ថិតក្រោមបន្ទាត់ស្តង់ដារគំរូអប្បបរមាក្នុងអត្រា ១៥% ដោយក្នុងនោះអត្រាតាមតំបន់គឺមានចាប់ពី ១១,៦% នៅអឺរ៉ុប និងអាមេរិកខាងជើង រហូតដល់ ១៨% នៅតំបន់អាមេរិកឡាទីន និងការីប៊ីន។ ជាសរុប ប្រទេសចំនួន ៤៣ ក្នុងចំណោមប្រទេស ១៤៨ ពុំបានឆ្លើយតបតាមស្តង់ដារគំរូទាំងពីរ។

មេដ្យានភាគរយ នៃការចំណាយក្នុងវិស័យអប់រំសាធារណៈ ដែលផ្តោតសម្រាប់ការអប់រំថ្នាក់បឋមសិក្សា មានអត្រា ៣៥% ដោយក្នុងនោះគឺមានចាប់ពី ៤៧% ក្នុងបណ្តាប្រទេសមានចំណូលទាប រហូតដល់ ៤៦% នៅក្នុងបណ្តាប្រទេសមានចំណូលខ្ពស់។ មេដ្យានមធ្យមក្នុងអត្រា ៣០% នៃការចំណាយសរុបលើការអប់រំ ត្រូវបានចាត់កញ្ចប់ថវិកាសម្រាប់ការអប់រំថ្នាក់មធ្យមសិក្សា ដោយក្នុងនោះគឺមានចាប់ពី ២៧% នៅក្នុងប្រទេសមានចំណូលទាប ដល់ ៣៧% ក្នុងប្រទេសមានចំណូលខ្ពស់។ បណ្តាប្រទេសនៅទ្វីបអឺរ៉ុប និងអាមេរិកខាងជើងចំណាយថវិកាក្នុងទឹកប្រាក់ប្រហាក់ប្រហែលគ្នាសម្រាប់សិស្សម្នាក់ក្នុងថ្នាក់បឋមសិក្សា និងក្រោយមធ្យមសិក្សា។ ការចំណាយរបស់ប្រទេសក្នុងអនុតំបន់សាហារ៉ានៃទ្វីបអាហ្វ្រិកលើសិស្សក្រោយមធ្យមសិក្សាម្នាក់មានចំនួនស្មើនឹង ១០ ដងនៃសិស្សបឋមសិក្សាម្នាក់។

កិច្ចពិភាក្សាដេញដោលសាធារណៈជារឿយៗតែងផ្តោតការយកចិត្តទុកដាក់លើផលប៉ះពាល់អវិជ្ជមានរបស់ចំណាកស្រុក មកលើសុខុមាលភាពរបស់សហគមន៍ម្ចាស់ផ្ទះ។ ផ្ទុយទៅវិញ ជនចំណាកស្រុកច្រើនតែស្ថិតក្នុងអាយុពេញកម្លាំងធ្វើការងារជាងជនម្ចាស់ស្រុក ប៉ុន្តែជាទូទៅពួកគេតែងបង្កើតឱ្យមានចំណូលពន្ធតិចជាងជនម្ចាស់ស្រុក ដោយសារតែពួកគេរកចំណូលបានតិចជាង។ ផ្ទុយទៅវិញ ជនអន្តោប្រវេសន៍ច្រើនតែពឹងផ្អែកលើអត្ថប្រយោជន៍សង្គម និងប្រើប្រាស់សេវាសាធារណៈ ដូចជាការអប់រំជាដើម។ ទោះយ៉ាងណាក្តី ការចំណាយលើការអប់រំសាធារណៈសម្រាប់កុមារអន្តោប្រវេសន៍ ត្រូវបានគេយល់ច្បាស់ថា គឺជាការវិនិយោគៈ ពួកគេច្រើនតែចូលរួមចំណែកច្រើនទៅលើពន្ធ និងការចូលរួមវិភាគទានផ្នែកសន្តិសុខសង្គម ជាងអ្វីដែលពួកគេបានទទួលពេញមួយជីវិតរបស់ខ្លួន។ ផលវិបាកផ្នែកហិរញ្ញវត្ថុរបស់ចំណាកស្រុក ជារឿយៗតែងមានលក្ខណៈតិចតួច ដែលជាទូទៅស្ថិតក្នុងចំនួន ១% នៃ GDP មិនថានោះជាផលវិបាកវិជ្ជមាន ឬអវិជ្ជមានក្តី។

# ការចំណាយថវិកាជំនួយ

ក្នុងឆ្នាំ ២០១៦ ថវិកាជំនួយសម្រាប់ការអប់រំបានឡើងដល់កម្រិតខ្ពស់បំផុត ចាប់តាំងពីការចាប់ផ្ដើមកត់ត្រាដំបូងក្នុងឆ្នាំ ២០០២ មក។ បើប្រៀបធៀបជាមួយឆ្នាំ ២០១៥ ថវិកាជំនួយសម្រាប់ការអប់រំបានកើនឡើងចំនួន ១,៥ ពាន់លានដុល្លាអាមេរិក ឬស្មើនឹង ១៣% តាមន័យជាក់ស្ដែងធ្វើឱ្យកើនឡើងដល់ ១៣,៤ ពាន់លានដុល្លាអាមេរិក។ ថវិកាជំនួយសម្រាប់ការអប់រំកម្រិតមូលដ្ឋាន គឺមានចំនួនស្មើនឹង ២/៣ នៃកំណើនថវិកាជំនួយ ចំណែកក្នុងថ្នាក់មធ្យមសិក្សា និងក្រោយមធ្យមសិក្សាវិញ ថវិកាជំនួយបានកើនឡើងក្នុងអត្រាទាបជាងនៅថ្នាក់អប់រំមូលដ្ឋាន ហេតុនេះចំណែកនៃការអប់រំថ្នាក់មូលដ្ឋានក្នុងថវិកាជំនួយក្នុងវិស័យអប់រំសរុបបានកើនឡើងក្នុងកម្រិតខ្ពស់បំផុត រហូតដល់ ៤៥%។

> សមមាត្រថវិកាជំនួយសម្រាប់ការអប់រំថ្នាក់មូលដ្ឋានដែលផ្ដល់ទៅឱ្យប្រទេសមានចំណូលទាបបានធ្លាក់ចុះពីចំនួន ៣៦% ក្នុងឆ្នាំ ២០០២ មកនៅត្រឹម ២២% ក្នុងឆ្នាំ ២០១៦

ការបញ្ចេញថវិកាជំនួយទៅឱ្យការអប់រំកម្រិតមូលដ្ឋាន គឺនៅពុំទាន់បានចាត់ទៅឱ្យបណ្ដាប្រទេសដែលមានតម្រូវការបំផុតនៅឡើយ។ សមាមាត្រនៃថវិកាជំនួយលើការអប់រំមូលដ្ឋានសម្រាប់បណ្ដាប្រទេសមានចំណូលទាបបានធ្លាក់ចុះពីចំនួន ៣៦% ក្នុងឆ្នាំ ២០០២ មកនៅត្រឹម ២២% ក្នុងឆ្នាំ ២០១៦។ សមាមាត្រផ្ដល់ឱ្យសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួច គឺមានចំនួន ៣៤% ក្នុងឆ្នាំ ២០១៦ ដែលបានធ្លាក់ចុះពីកម្រិតខ្ពស់បំផុត ៤៧% ក្នុងឆ្នាំ ២០០៤។

ប្រទេសមានចំណូលមធ្យមកម្រិតទាបក៏ប្រឈមជាមួយគម្លាតក្នុងការផ្ដល់ហិរញ្ញវត្ថុផងដែរ។ ការផ្ដល់កម្ចីពីធនាគារអភិវឌ្ឍន៍ពហុភាគីសម្រាប់ការអប់រំក្នុងបណ្ដាប្រទេសទាំងអស់នេះនៅមានកម្រិតទាបនៅឡើយ។ ឧ. មេធ្យានសមាមាត្រនៃការអប់រំក្នុងចន្លោះឆ្នាំ ២០០២ ដល់ ២០១៧ គឺមានចំនួន ១០,៥% សម្រាប់កម្ចីសម្បទានពីសមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) ប៉ុន្តែមានចំនួនត្រឹមតែ ៦,៤% ប៉ុណ្ណោះសម្រាប់កម្ចីមិនមែនសម្បទានពីធនាគារអន្តរជាតិសម្រាប់ការស្ដារ និងការអភិវឌ្ឍឡើងវិញ (IBRD)។បន្ថែមលើនេះទៀត សមាមាត្រនៃការអប់រំនៅក្នុងកម្ចី IBRD បានធ្លាក់ចុះពី ៨,២% ក្នុងឆ្នាំ ២០១២ មកនៅត្រឹម ៤,៧% ក្នុងឆ្នាំ ២០១៧ ឬស្មើនឹង ១/៤ នៃចំនួនទឹកប្រាក់សម្រាប់វិស័យថាមពល និងនិស្សារណកម្ម (**រូបភាពទី ១៩**)។ ការពិភាក្សានៅតែបន្ត លើសំណើរបស់គណកម្មាធិការអន្តរជាតិស្ដីពីហិរញ្ញប្បទាន សំរាប់ឱកាសអប់រំសកល ដើម្បីបង្កើតឱ្យមានគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិសម្រាប់ការអប់រំដើម្បីបង្កើនកម្ចីធនាគារអភិវឌ្ឍន៍សម្រាប់ការអប់រំក្នុងបណ្ដាប្រទេសមានចំណូលមធ្យមកម្រិតទាប។

**រូបភាពទី ១៩៖**
**សមាមាត្រទាប នឹងកាន់តែថយចុះនៃកម្ចីមិនមែនសម្បទានរបស់ធនាគារពិភពលោក ផ្តល់សម្រាប់វិស័យអប់រំ**
សមាមាត្រសរុបនៃកម្ចីរបស់ IDA និង IBRD ការប្រៀបធៀបវិស័យអប់រំជាមួយវិស័យថាមពល និងនិស្សារណកម្ម ឆ្នាំ ២០០២-២០១៧




GEM StatLink: http://bit.ly/fig19_9
ប្រភព៖ ការវិភាគរបស់ក្រុមការងារធ្វើរបាយការណ៍GEM ផ្អែកលើរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារពិភពលោកដែលត្រូវបានជ្រើសរើស

## ការប្រើប្រាស់ថវិកាជំនួយជាឧបករណ៍ដើម្បីកាត់បន្ថយចំណាកស្រុក

គំនិតដែលចាត់ទុកថាថវិកាជំនួយពីខាងក្រៅអាចកាត់បន្ថយចំណាកស្រុក បានទទួលការគាំទ្រមួយចំនួននៅក្នុងរង្វង់គោលនយោបាយ។ ការបង្កើនចំណូលដែលអាចរកបាននៅក្នុង ប្រទេសកំណើតនឹងអាចកាត់បន្ថយការលើកទឹកចិត្តសំខាន់ៗមួយចំនួនដែលជំរុញ ឱ្យប្រជាជនធ្វើចំណាកស្រុក។ របៀបវារៈរបស់សហគមន៍អឺរ៉ុបស្តីពីចំណាកស្រុក និងគោលនយោបាយថវិកាជំនួយរបស់ប្រទេសមួយចំនួន គាំទ្រដល់គំនិតនេះ។

> ផលប៉ះពាល់នៃថវិកាជំនួយផ្នែកការអប់រំមកលើចំណាកស្រុក គឺពិបាកបែងចែកខ្លាំងណាស់

ការសិក្សាមួយអំពីលំហូរចំណាកស្រុកពីបណ្តាប្រទេសប្រភពចំនួន ២១០ ទៅកាន់ប្រទេសម្ចាស់ជំនួយ (និងប្រទេសគោលដៅ) ចំនួន ២២ បានបង្ហាញឱ្យឃើញថា បណ្តាប្រទេសដែលបញ្ជូនជនចំណាកស្រុកក្នុងចំនួនច្រើន បានទទួលជំនួយបរទេសក្នុងទឹកប្រាក់ច្រើនជាងគេបំផុត។ ទោះយ៉ាងណាក្តី បុព្វហេតុនៃទំនាក់ទំនងនេះគឺពិបាកកំណត់ខ្លាំងណាស់។ ប្រសិនបើថវិកាជំនួយបានទៅដល់ដៃគ្រួសារក្រីក្រនោះថវិកាទាំងនេះប្រហែលជាអាចជួយពួកគេក្នុងការផ្តល់ហិរញ្ញវត្ថុសម្រាប់ការចំណាយលើការធ្វើចំណាកស្រុករបស់ពួកគេ។ ថវិកាជំនួយក៏អាចបង្កើនព័ត៌មានស្តីពីបណ្តាប្រទេសម្ចាស់ជំនួយ និងបន្ទាបការចំណាយប្រតិបត្តិការ

របស់ជនចំណាកស្រុក ដែលជាការលើកទឹកចិត្តឱ្យមានការធ្វើចំណាកស្រុកផងដែរ។ ហេតុនេះ អ្នកធ្វើគោលនយោបាយប្រហែលជាចាំបាច់ត្រូវតែបន្ថយការរំពឹងទុកលើតួនាទីរបស់ថវិកាជំនួយ ដែលអាចចូលរួមចំណែកក្នុងការទប់ស្កាត់ការធ្វើចំណាកស្រុក។

ដោយឡែក ផលប៉ះពាល់នៃថវិកាជំនួយ ផ្នែកការអប់រំមកលើចំណាកស្រុក គឺពិបាកបែងចែកខ្លាំងណាស់ អាស្រ័យដោយថវិកានេះមានទំហំតិច។ បើទោះបីជាជំនួយសម្រាប់ការអប់រំចូលរួមចំណែកក្នុងការកាត់បន្ថយចំណាកស្រុកក្តី ប៉ុន្តែលទ្ធផលនេះទំនងជាពុំអាចកើតមានយ៉ាងឆាប់រហ័សនោះទេ។ ទោះយ៉ាងណាក្តីការអប់រំអាចមានតួនាទីសម្របសម្រួលដ៏សំខាន់នៅក្នុងការធ្វើចំណាកស្រុកទាំងនៅក្នុងប្រទេសប្រភព និងប្រទេសគោលដៅ។ ការសិក្សាមួយអំពីនិន្នាការនៅក្នុងការធ្វើចំណាកស្រុកពីតំបន់អាហ្វ្រិកខាងជើងទៅបណ្តាប្រទេស OECD បានស្នើឱ្យឃើញថា កំណើនប្រាក់ចំណូលដែលកើតមានឡើងដោយសារថវិកាជំនួយនៅក្នុងប្រទេសប្រភព គឺជាកត្តាជំរុញសម្រាប់ជនចំណាកស្រុកដែលមានការអប់រំទាប។ ប៉ុន្តែការពេញចិត្តជាមួយសេវាសាធារណៈក្នុងមូលដ្ឋាន រួមទាំងសាលារៀនផងដែរ អាចជួយរារាំងចំណាកស្រុកកុំឱ្យកើតមានបាន។ ម្យ៉ាងវិញទៀត ជាទូទៅលក្ខណសម្បត្តិផ្នែកប្រជាសាស្ត្រនៃប្រទេសគោលដៅ ដូចជាដង់ស៊ីតេប្រជាជន កំណើនប្រជាជននៅតំបន់ទីប្រជុំជន សមាមាត្រភាពពឹងផ្អែកផ្នែកអាយុ និងការផ្តល់រង្វាន់សម្រាប់ការអប់រំនៅក្នុងប្រទេសគោលដៅ គឺមានសារៈសំខាន់ក្នុងការកំណត់អត្រាចំណាកស្រុកជាងចំនួនទឹកប្រាក់ថវិកាជំនួយ។

## ការកែលម្អប្រសិទ្ធភាពជំនួយមនុស្សធម៌សម្រាប់ការអប់រំ

ជំនួយមនុស្សធម៌បានកើនឡើងក្នុងឆ្នាំ ២០១៧ ជាឆ្នាំទីបួនបន្តបន្ទាប់គ្នា នៅក្នុងការផ្តល់មូលនិធិមនុស្សធម៌សម្រាប់ការអប់រំដែលបានឡើងដល់ ៤៥០ លានដុល្លាអាមេរិក។ ទោះយ៉ាងណាក្តី សមាមាត្ររបស់ការអប់រំនៅក្នុងជំនួយមនុស្សធម៌សរុប គឺមានចំនួនប្រមាណ ២,១% ដែលទាបជាងអត្រាគោលដៅ ៤% យ៉ាងខ្លាំង។ បើយោងតាមប្រវត្តិសាស្ត្រ ការអប់រំមានសមាមាត្រទាបជាងគេបំផុតនៅក្នុងការតម្រូវសម្រាប់ការផ្តល់មូលនិធិ បើធៀបជាមួយវិស័យដទៃទៀត។ ប៉ុន្តែកិច្ចប្រជុំកំពូលមនុស្សធម៌ពិភពលោកឆ្នាំ ២០១៦ បានដាក់បញ្ចូលការប្តេជ្ញាចិត្តថ្មីមួយទៀតចំពោះការអប់រំក្នុងគ្រាអាសន្ន តាមរយៈការបង្កើតមូលនិធិការអប់រំមិនអាចរង់ចាំ (ECW) ពហុភាគី។

យន្តការសម្របសម្រួលដែលមានច្រើនជាន់ ទាំងក្នុងទម្រង់ជាខ្សែបញ្ឈរ (ពីថ្នាក់សកល ទៅថ្នាក់មូលដ្ឋាន) និងខ្សែផ្តេក (ពីវិស័យនិងអ្នកដើរតួនាទីផ្សេងៗ) ធ្វើឱ្យស្ថាបត្យកម្មជំនួយមនុស្សធម៌មានភាពស្មុគស្មាញ និងចូលរួមចំណែកធ្វើឱ្យមានការលំបាកនៅក្នុងការឆ្លើយតបក្នុងគ្រាអាសន្នចំពោះការអប់រំដែលមានការលំបាកកាន់តែច្រើនឡើង។ អន្តរាគមន៍សម្របសម្រួលដោយអង្គការសហប្រជាជាតិត្រូវបានរៀបចំឡើងតាមលក្ខណៈពីរបែប។ ផែនការឆ្លើយតបផ្នែកមនុស្សធម៌ (HRP) ផ្តល់យុទ្ធសាស្ត្រតាមប្រទេស ដោយតាមធម្មតាមានរយៈពេលមួយឆ្នាំ។ ការអំពាវនាវរហ័សស្នើឱ្យមានការឆ្លើយតបចំពោះគ្រាអាសន្នភ្លាមៗ ដើម្បីឆ្លើយតបចំពោះសេចក្តីត្រូវការស្រួចស្រាវក្នុងរយៈពេល ៣ ទៅ ៦ ខែ។ HRP មានខ្លឹមសារក្នុងកម្រិតកំណត់ពាក់ព័ន្ធជាមួយការអប់រំ ហើយជារឿយៗការអប់រំពុំត្រូវបានសង្កត់ធ្ងន់នៅក្នុងការអំពាវនាវទេ។

ពុំមានប្រព័ន្ធការរាយការណ៍ជាកាតព្វកិច្ចសម្រាប់ការចំណាយផ្នែកជំនួយមនុស្សធម៌អន្តរជាតិទេ ដែលជាហេតុធ្វើឱ្យមានការលំបាកក្នុងការពិនិត្យតាមដានឱ្យបានពេញលេញលើការចំណាយក្នុងការអប់រំ។ដេតាបេសប្រព័ន្ធរាយការណ៍អ្នកផ្តល់ឥណទានគណៈកម្មាធិការជំនួយអភិវឌ្ឍ OECD ពុំបានញែកទិន្នន័យជំនួយមនុស្សធម៌លម្អិតទៅតាមវិស័យទេ ថ្វីបើដេតាបេសនេះ ស្នើឡើងថា មានទឹកប្រាក់ជំនួយផ្នែកការអភិវឌ្ឍប្រមាណ ៤០០ លានដុល្លារអាមេរិក ត្រូវបានចំណាយលើការអប់រំរបស់ជនភៀសខ្លួនក្នុងឆ្នាំ ២០១៦ ក្តី។ ការិយាល័យអង្គការសហប្រជាជាតិសម្រាប់ការសម្របសម្រួលសេវាតាមដានប្រភពហិរញ្ញវត្ថុកិច្ចការមនុស្សធម៌ដោយស្ម័គ្រចិត្ត ធ្វើការតាមដានប្រភពលើវិស័យអប់រំ ប៉ុន្តែ ៤២% នៃហិរញ្ញប្បទានក្នុងឆ្នាំ ២០១៧ គឺនៅក្នុងចំណាត់ប្រភេទពហុវិស័យ ដោយចែករំលែកក្នុងចំណោមវិស័យជាច្រើន ឬពុំមានបញ្ជាក់ជាក់លាក់ ជាលទ្ធផលធ្វើឱ្យមានការប៉ាន់ប្រមាណលើការចំណាយក្នុងវិស័យអប់រំមិនមានសុក្រឹតភាព។

ការផ្តល់មូលនិធិមិនគ្រប់គ្រាន់សម្រាប់វិស័យអប់រំ ជាលទ្ធផលកើតចេញពីភាពមិនគ្រប់គ្រាន់នៅក្នុងវិស័យជាច្រើន៖ ធន្ធៈនយោបាយ ការសម្របសម្រួលពីលើចុះក្រោម និងតាមសម្របសម្រួលតាមខ្សែបណ្តោយ និងខ្សែទទឹង សមត្ថភាពរបស់អ្នកដើរតួនាទីផ្នែកមនុស្សធម៌ និងព័ត៌មាន ឬយន្តការគណនេយ្យភាព។

ការសិក្សាកំណត់ការចំណាយក្នុងឆ្នាំ ២០១៥ បានគណនាគម្លាតការផ្តល់ហិរញ្ញវត្ថុក្នុងចំនួនទឹកប្រាក់ ៨.៥ ប៊ីលានដុល្លារអាមេរិក ដែលចាំបាច់ត្រូវគ្របដណ្តប់ដោយសហគមន៍អន្តរជាតិ។ ទឹកប្រាក់នេះ គឺស្មើនឹង ១១៣ ដុល្លារអាមេរិកសម្រាប់កុមារម្នាក់ ពោលគឺជាកំណើន ១០ ដងលើសការចំណាយក្នុងកុមារម្នាក់នាពេលបច្ចុប្បន្ន។ ECW មានបំណងបង្កើនទឹកប្រាក់ ១.៥ ប៊ីលានដុល្លារអាមេរិកក្នុងមួយឆ្នាំ និងបង្កើតចំណែកនៃការអប់រំនៅក្នុងជំនួយមនុស្សធម៌ចំនួន ១,២ % ត្រឹមឆ្នាំ ២០២១។ ដៃគូរបស់ ECW ចាំបាច់ត្រូវចែករំលែកកិច្ចខិតខំក្នុងការកៀងគរមូលនិធិ មិនថាតាមរយៈការចាត់អាទិភាពលើគោលបំណងមនុស្សធម៌នៅក្នុងជំនួយអភិវឌ្ឍន៍ ឬត្រូវបង្កើនអាទិភាពនៃការអប់រំនៅក្នុងជំនួយមនុស្សធម៌។

ផែនការពុំគួរត្រូវបានកំណត់ដោយសកម្មភាពដែលអង្គការនានាធ្លាប់អនុវត្តសកម្មភាពទាំងនោះទេ ផ្ទុយទៅវិញ ចាំបាច់ត្រូវមានសកម្មភាពដែលបម្រើឱ្យការអប់រំប្រកបដោយបរិយាបន្ន និងមានសមធម៌ដែលមានគុណភាពល្អ។ ចង្កោមការអប់រំសាកល (Global Education Cluster) បានបង្កើតគោលការណ៍ណែនាំសម្រាប់វាយតម្លៃសេចក្តីត្រូវការ។ ក្នុងនាមជាអ្នកដើរតួនាទីថ្មីដ៏សំខាន់មួយ ECW អាចជំរុញការអនុវត្តគោលការណ៍ទាំងអស់នេះបានតាមរយៈការតម្រូវឱ្យដៃគូត្រូវប្រើប្រាស់គោលការណ៍ណែនាំទាំងអស់នេះនៅក្នុងការតាក់តែងកម្មវិធី និងអភិវឌ្ឍសមត្ថភាពរបស់ពួកគេ។

ជំនួយមនុស្សធម៌បានប្រឈមការលំបាក ដោយសារបញ្ហាក្នុងការសម្របសម្រួលរវាងអ្នកដើរតួនាទីសំខាន់ៗ។ ការអប់រំគួរតែជាវិស័យគន្លឹះមួយ នៅក្នុងផែនការអន្តរាគមន៍មនុស្សធម៌ពហុវិស័យ។ នៅក្នុងវិបត្តិជនជាតិរ៉ូហ៊ីងយ៉ាក្នុងប្រទេសបង់ក្លាដែស ការអប់រំត្រូវបានដាក់បញ្ចូលតាំងពីជំហានដំបូងនៃការឆ្លើយតបក្នុងជំនួយមនុស្សធម៌ ហើយការផ្តល់សេវាអប់រំ បានចាប់ផ្តើមយ៉ាងរហ័ស។ ទោះយ៉ាងណាក្តី កង្វះការសម្របសម្រួលមានន័យថា មជ្ឈមណ្ឌលសិក្សារៀនសូត្រពេលខ្លះត្រូវនៅទំនេរ ដោយហេតុថាអន្តរាគមន៍ផ្នែកអប់រំបានប្រជែងយកពេលវេលារបស់កុមារ។




ការធ្វើផែនការរួមគ្នា ក៏ចាំបាច់ផងដែររវាងអ្នកដើរតួនាទីផ្នែកមនុស្សធម៌ និងផ្នែកការអភិវឌ្ឍ។ ស្រប ពេលដែលការធ្វើផែនការពហុវិស័យជួយជានា ឱ្យមានការអប់រំនៅក្នុងការឆ្លើយតបផ្នែកមនុស្សធម៌ក្នុងវិបត្តិ ជនជាតិរ៉ូហ៊ីនយ៉ា ការធ្វើផែនការបែបនោះ ពុំបានជួយធានាឱ្យមានការដាក់បញ្ចូលក្នុងប្រព័ន្ធអប់រំបង់ក្លាដែសទេ។ ការអំពាវនាវរយៈពេលច្រើនឆ្នាំនៅក្នុងវិបត្តិដ៏អូសបន្លាយ គឺពុំមានថវិកាគ្រប់គ្រាន់ ហើយផែនការអប់រំជាតិនា ពេលកន្លងមក ពុំបានផ្តោតការយកចិត្តទុកដាក់លើភាពធន់ទ្រាំ ឬការឆ្លើយតបជាមួយវិបត្តិទេ។ ក្របខ័ណ្ឌការងារ ការធ្វើផែនការអប់រំក្រោមជំនួយមនុស្សធម៌រយៈពេលខ្លី ចាំបាច់ត្រូវបូករួមផ្សំជាមួយកង្វល់ដែលមានលក្ខណៈ ជារចនាសម្ព័ន្ធថែមទៀត ដូចជានៅក្នុងប្រទេសអ៊ូហ្គង់ដា ដោយក្នុងនោះផែនការឆ្លើយតបផ្នែកការអប់រំ សម្រាប់ជនភៀសខ្លួន និងជនម្ចាស់ស្រុករបស់រដ្ឋាភិបាលដែលបានប្រកាសឱ្យប្រើក្នុងខែឧសភា ឆ្នាំ ២០១៨ បានចាត់ថវិកាក្នុងទឹកប្រាក់ ៣៩៥ លានដុល្លារសម្រាប់រយៈពេលបីឆ្នាំ ដើម្បីអាចចូលទៅដល់សិស្សជនភៀស ខ្លួន និងសិស្សក្នុងសហគមន៍ម្ចាស់ផ្ទះក្នុងចំនួនប្រមាណ ៦៧៥ ០០០ នាក់ក្នុងមួយឆ្នាំ។

ម្ចាស់ជំនួយនានា ដូចជាប្រទេសអូស្ត្រាលី កាណាដា ន័រវែស និងចក្រភពអង់គ្លេសជាដើម បានងាក ទៅរកក្របខ័ណ្ឌការងារការផ្តល់មូលនិធិរយៈពេលច្រើនឆ្នាំ ដើម្បីជួយធានាឱ្យមានការផ្តល់មូលនិធិដែលអាច ព្យាករណ៍ទុកជាមុនបានជាមួយដៃគូផ្នែកមនុស្សធម៌ ហើយ ECW មានឧបករណ៍ "ភាពធន់ទ្រាំជាច្រើនឆ្នាំ" ដែលមានគោលដៅក្នុងការបិទភ្ជិតគម្លាតគ្នារវាងវិស័យមនុស្សធម៌ជាមួយវិស័យអភិវឌ្ឍផងដែរ។ ចាំបាច់ត្រូវ ពង្រឹងគណនេយ្យភាពនៅក្នុងជំនួយមនុស្សធម៌ផងដែរ។ ECW បានសង្កត់ធ្ងន់លើតម្លាភាព និងលទ្ធផល តាមរយៈការបង្កើតឱ្យមានបទដ្ឋានកម្រិតខ្ពស់នៅក្នុងក្របខ័ណ្ឌការងារលទ្ធផលជាយុទ្ធសាស្ត្រ ដែលមិនត្រឹម តែគ្របដណ្តប់លើលទ្ធផលចុងក្រោយបំផុតរបស់ខ្លួនតែប៉ុណ្ណោះទេ ប៉ុន្តែក៏គ្របដណ្តប់លើវិធីក្នុងការធ្វើ ការងារ និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពផងដែរ។

# ចំណាយរបស់គ្រួសារ

អស់ពេលជាយូរមកហើយ កង្វះទិន្នន័យស្តីពីការចូលរួមចំណែករបស់គ្រួសារបានរឹតត្បិតការវិភាគលើការ ចំណាយ សរុប ផ្នែកការ អប់រំ។ UIS បានផ្សព្វផ្សាយទិន្នន័យសម្រាប់គ្រួសារលើកដំបូង ក្នុងឆ្នាំ ២០១៧ ប៉ុន្តែការគ្របដណ្តប់របស់ទិន្នន័យនេះ នៅមានកម្រិតកំណត់នៅឡើយ។ សមាមាត្រនៃការចូលរួមចំណែក របស់ គ្រួសារ នៅក្នុងការ ចំណាយ សរុប លើ ការ អប់រំ អាចមាន កម្រិត ខ្ពស់ យ៉ាង ខ្លាំង នៅក្នុងបណ្តា ប្រទេស មានចំណូល ទាប និងមធ្យមមួយចំនួន ឧ. ប្រទេសអែលសាល់វ៉ាឌ័រ (៥០%) និងឥណ្ឌូណេស៊ី (៤៩%) (រូបភាពទី ២០)។

ជាទូទៅ ទិន្នន័យការចំណាយរបស់គ្រួសារ ហាក់ពុំផ្លាស់ប្តូរធំធេងនោះទេពីមួយឆ្នាំទៅមួយឆ្នាំ ដោយមានករណីលើកលែងមួយចំនួន។នៅប្រទេសស៊ីលីមានការតវ៉ាដ៏ធំធេងធ្វើឡើងដោយសិស្សានុសិស្សស្តីពីការផ្តល់ហិរញ្ញវត្ថុមិនគ្រប់គ្រាន់លើវិស័យអប់រំពីសំណាក់រដ្ឋាភិបាល ដែលបង្កឱ្យមានការផ្លាស់ប្តូរនៅក្នុងគោលនយោបាយសាធារណៈ។ ជាលទ្ធផលសមាមាត្រនៃការចំណាយសរុបរបស់គ្រួសារលើការអប់រំ បានថយចុះនៅចន្លោះឆ្នាំ ២០០៥ ដល់ ២០១៥ ចាប់ពីប្រមាណ ៥០% មកនៅត្រឹមក្រោម ២០%។

**រូបភាពទី ២០៖**

**ការចំណាយលើការអប់រំរបស់គ្រួសារ មានទឹកប្រាក់គួរជាទីកត់សម្គាល់នៅក្នុងបណ្តាប្រទេសមានចំណូលទាប និងចំណូលមធ្យមមួយចំនួន**

ការចំណាយលើការអប់រំ គិតជាភាគរយនៃ GDP ចែកទៅតាមប្រភពមូលនិធិ និងប្រទេសតាមក្រុមចំណូលក្នុងប្រទេសដែលត្រូវបានជ្រើសរើស ឆ្នាំ ២០១៣-២០១៧




GEM StatLink: http://bit.ly/fig19_13
ប្រភព៖ ដេតាបេស UIS។

# អនុសាសន៍

របាយការណ៍នេះ អំពាវនាវឱ្យរដ្ឋាភិបាលទាំងឡាយត្រូវឆ្លើយតបចំពោះសេចក្ដីត្រូវការផ្នែកការអប់រំរបស់ជនចំណាកស្រុក ប្រជាជនផ្លាស់ប្ដូរទីលំនៅដោយបង្ខំ និងរបស់កុមារ ដោយផ្ដល់ការយកចិត្តទុកដាក់ស្មើជាមួយអ្វីដែលរដ្ឋាភិបាលផ្ដល់សម្រាប់ប្រជាជនម្ចាស់ផ្ទះ។

## ការពារសិទ្ធិទទួលបានការអប់រំរបស់ជនចំណាកស្រុក ប្រជាជនផ្លាស់ប្ដូរទីលំនៅដោយបង្ខំ

គោលការណ៍មិនរើសអើងក្នុងការអប់រំ ត្រូវបានទទួលស្គាល់ក្នុងអនុសញ្ញាអន្តរជាតិនានា។ ឧបសគ្គដែលមានលក្ខណៈរើសអើង ដូចជាការតម្រូវឱ្យមានសំបុត្រកំណើតជាដើម គួរត្រូវបានហាមឃាត់យ៉ាងច្បាស់លាស់នៅក្នុងច្បាប់ជាតិ។ លិខិតបទដ្ឋានគតិយុត្តិដែលមានស្រាប់ពុំគួរមានចន្លោះប្រហោង ឬចំណុចស្រពិចស្រពិល ដែលទុកចន្លោះឱ្យមានការបកស្រាយពីសំណាក់មន្ត្រីថ្នាក់មូលដ្ឋាន ឬមន្ត្រីនៅថ្នាក់សាលារៀនជាលក្ខណៈបុគ្គលនោះឡើយ។ រដ្ឋាភិបាលចាំបាច់ត្រូវការពារសិទ្ធិទទួលបានការអប់រំរបស់ជនចំណាកស្រុក និងជនភៀសខ្លួនដោយមិនគិតអំពីឯកសារបញ្ជាក់អត្តសញ្ញាណឬស្ថានភាពលំនៅដ្ឋានហើយត្រូវអនុវត្តច្បាប់ដោយគ្មានការលើកលែង។

ការគោរពសិទ្ធិទទួលបានការអប់រំមិនមែនមានត្រឹមតែនៅក្នុងច្បាប់ និងដំណើរការរដ្ឋបាលតែប៉ុណ្ណោះទេ ។ អាជ្ញាធរថ្នាក់ជាតិ ចាំបាច់ត្រូវធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹង ដើម្បីជម្រាបប្រាប់ដល់គ្រួសារជនចំណាកស្រុក និងគ្រួសារផ្លាស់ប្ដូរទីលំនៅដោយបង្ខំ អំពីសិទ្ធិរបស់ពួកគេ និងអំពីដំណើរការនៃការចុះឈ្មោះចូលរៀននៅសាលា។ អាជ្ញាធរទទួលបន្ទុកការធ្វើផែនការ ត្រូវធានាឱ្យបានថា សាលារដ្ឋស្ថិតក្នុងរង្វង់ដែលអ្នកតាំងលំនៅក្រៅផ្លូវការ និងនៅតំបន់ទីប្រជុំជនអនាធិបតេយ្យអាចចូលទៅដល់បាន ហើយពួកគេពុំគួរត្រូវបានបំភ្លេចចោលនៅក្នុងផែនការស្ដារទីប្រជុំជនឡើងវិញនោះឡើយ។

## ដាក់បញ្ចូលជនចំណាកស្រុក និងប្រជាជនផ្លាស់ប្ដូរទីលំនៅដោយបង្ខំនៅក្នុងប្រព័ន្ធអប់រំជាតិ

ប្រព័ន្ធអប់រំមួយចំនួនចាត់ទុកជនចំណាកស្រុក និងជនភៀសខ្លួនជាប្រជាជនបណ្ដោះអាសន្ន ឬប្រជាជនឆ្លងកាត់ ដែលមានលក្ខណៈខុសប្លែកពីជនម្ចាស់ស្រុក។ នេះជាទង្វើខុសឆ្គង ដោយហេតុថា ការធ្វើបែបនេះ អាចរារាំងវឌ្ឍនភាពផ្នែកការសិក្សារៀនសូត្ររបស់ពួកគេ ការចូលរួមជាសង្គម និងឱកាសនាពេលអនាគតរបស់អ្នកទាំងនោះ ព្រមទាំងបំផ្លាញវឌ្ឍនភាពឆ្ពោះទៅស្ថាបនាសង្គមដែលមានលក្ខណៈចម្រុះ និងមានសាមគ្គីភាព។ គោលនយោបាយសាធារណៈ ចាំបាច់ត្រូវដាក់បញ្ចូលប្រជាជនទាំងអស់នេះនៅគ្រប់កម្រិតទាំងអស់នៅក្នុងការអប់រំជាតិ។

ការដាក់បញ្ចូលជនចំណាកស្រុកមានទិដ្ឋភាពផ្សេងៗជាច្រើន។ ថ្វីបើភាសាបង្រៀនថ្មីមួយ គឺជាការចាំបាច់នៅក្នុងថ្នាក់ត្រៀមដំបូងក្តី ប៉ុន្តែសិស្សគួរត្រូវបានបំបែកចេញឱ្យបានតិចបំផុតតាមដែលអាចធ្វើបានពីមិត្តភក្តិជាជនចំណាកស្រុក។ ប្រព័ន្ធអប់រំពុំគួរតម្រង់ទិសសិស្សដែលមានការសម្រេចបានកម្រិតទាប ដោយក្នុងនោះភាគច្រើនលើសលប់ គឺជាជនចំណាកស្រុកទៅក្នុងទិសដៅផ្សេងខុសពីគេនោះឡើយ។ អាស្រ័យដោយការប្រមូលផ្តុំផ្នែកភូមិសាស្ត្ររបស់សិស្សចំណាកស្រុកក្នុងបណ្តាប្រទេសជាច្រើន ដូចជាអ្នកធ្វើផែនការផ្នែកអប់រំ គួរប្រើប្រាស់វិធីសាស្ត្រ ដូចជាការឧបត្ថម្ភទុនសម្រាប់មធ្យោបាយធ្វើដំណើរ និងការចាត់សាលារៀនតាមលក្ខណៈចោះៗ ដើម្បីធានាឱ្យការបែងចែកផ្នែកលំនៅដ្ឋានពុំផ្តល់លទ្ធផលឱ្យមានការបែងចែកផ្នែកការអប់រំផងដែរ។

រដ្ឋាភិបាលចាំបាច់ត្រូវធានាឱ្យបានថា ការអប់រំរបស់ជនភៀសខ្លួន ត្រូវបានរំខានតិចបំផុតតាមដែលអាចធ្វើបាន។ ថ្វីបើមានស្ថានភាពលើកលែងមួយចំនួន ឧ. ដូចជាភាពឯកោផ្នែករូបវន្តរបស់សហគមន៍ជនភៀសខ្លួន ឬភាពរឹតត្បិតផ្នែកសុវត្ថិភាពក្នុងប្រព័ន្ធរបស់ប្រទេសម្ចាស់ផ្ទះ ដែលអាចរារាំងមិនឱ្យមានបរិយាបន្នពេញលេញក្តី ប៉ុន្តែរដ្ឋាភិបាល ចាំបាច់ត្រូវកាត់បន្ថយពេលវេលាដែលត្រូវចំណាយនៅសាលារៀន ដែលមិនអនុវត្តតាមកម្មវិធីសិក្សាថ្នាក់ជាតិ ឬដែលមិនមានវឌ្ឍនភាពឆ្ពោះទៅទទួលបានវិញ្ញាបនបត្រដែលមានការទទួលស្គាល់ឱ្យមានជាអប្បបរមា ដោយហេតុថា ពេលវេលាទាំងអស់នេះ អាចប៉ះពាល់ដល់គន្លងវិថីការអប់រំ។

## យល់ច្បាស់ និងធ្វើផែនការសម្រាប់សេចក្តីត្រូវការផ្នែកការអប់រំរបស់ជនចំណាកស្រុក និងរបស់ប្រជាជនដែលផ្លាស់ទីលំនៅដោយបង្ខំ

បណ្តាប្រទេសដែលមានលំហូរជនចំណាកស្រុក និងជនភៀសខ្លួនចូលច្រើន ចាំបាច់ត្រូវចាប់យកទិន្នន័យស្តីពីប្រជាជនទាំងអស់នេះនៅក្នុងប្រព័ន្ធព័ត៌មានការគ្រប់គ្រងដើម្បីធ្វើផែនការ និងធ្វើថវិកាអនុលោមតាមស្ថានភាពជាក់ស្តែង។ ការផ្តល់ទីកន្លែងនៅសាលារៀន ឬឱកាសការងារសម្រាប់ជនចំណាកស្រុក និងជនភៀសខ្លួន គឺគ្រាន់តែជាជំហានដំបូងប៉ុណ្ណោះ ដើម្បីឈានទៅសម្រេចបានបរិយាប័ន្ន។

បរិយាកាសសាលារៀន ចាំបាច់ត្រូវសម្រប និងគាំទ្រដល់សេចក្តីត្រូវការរបស់សិស្ស។ សិស្សដែលកំពុងផ្លាស់ទៅទទួលការបង្រៀនដោយភាសាថ្មី ចាំបាច់ត្រូវមានកម្មវិធីស្ពានតភ្ជាប់ដែលបង្រៀនដោយគ្រូមានគុណវុឌ្ឍិគ្រប់គ្រាន់។ ចំណែកសិស្សដែលការអប់រំរបស់ពួកគេរងការរំខាន នឹងទទួលអត្ថប្រយោជន៍ពីកម្មវិធីអប់រំពន្លឿន ដែលអនុញ្ញាតឱ្យពួកគេអាចរៀនទាន់សិស្សផ្សេងទៀត និងវិលត្រលប់ចូលទៅសាលារៀនវិញក្នុងកម្រិតសមស្រប។ ការដាក់បញ្ចូលជនភៀសខ្លួននៅក្នុងការអប់រំ ច្រើនតែបានទទួលជោគជ័យ ប្រសិនបើកម្មវិធីទាំងអស់នេះ បានពង្រីកបន្ថែមនូវកម្មវិធីកិច្ចគាំពារសង្គម ដើម្បីអនុញ្ញាតឱ្យជនភៀសខ្លួនអាចទទួលអត្ថប្រយោជន៍បានដូចជា ពួកគេអាចទទួលអត្ថប្រយោជន៍ពីការឧបត្ថម្ភសាច់ប្រាក់ដោយមានលក្ខខណ្ឌដែលគ្របដណ្តប់លើការចំណាយលាក់មុខសម្រាប់ការទៅសាលារៀន។ ក្នុងករណីជនចំណាកស្រុកក្នុងប្រទេសជាពិសេសសម្រាប់កូនរបស់កម្មករនិយោជិតពនេចរ ឬកម្មករនិយោជិតតាមរដូវ រដ្ឋាភិបាលគួរពិចារណាបង្កើតឱ្យមានកាលវិភាគសិក្សាដែលមានភាពបត់បែន ប្រព័ន្ធតាមដានការអប់រំ និងកម្មវិធីសិក្សាដែលពាក់ព័ន្ធជាមួយជីវភាពរស់នៅរបស់ពួកគេ។

មនុស្សពេញវ័យត្រូវការការគាំទ្រ ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួនតាមរយៈការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងដើម្បីជម្នះលើការលំបាកនានា ដូចជាមុខរបរមានជំនាញទាប ឬការបណ្តុះបណ្តាលមានថ្លៃខ្ពស់ ដែលបន្ទច់បង្អាក់ការវិនិយោគរបស់ពួកគេទៅលើជំនាញ។ ពួកគេត្រូវការកម្មវិធីអប់រំហិរញ្ញវត្ថុ ដើម្បីឱ្យពួកគេអាចគ្រប់គ្រងលើស្ថានភាពផ្នែកសេដ្ឋកិច្ចរបស់ខ្លួន ទាញប្រយោជន៍ឱ្យបានច្រើនបំផុតពីការបញ្ញើសាច់ប្រាក់ និងការចៀសវាងការបោកបន្លំ ឬការកេងប្រវ័ញ្ចផ្នែកហិរញ្ញវត្ថុ។ កម្មវិធីអប់រំក្រៅប្រព័ន្ធដែលអាចត្រូវបានផ្តល់ជូននៅកម្រិតរដ្ឋាភិបាលថ្នាក់មូលដ្ឋានអាចជួយបំពេញបន្ថែមកិច្ចខិតខំដើម្បីពង្រឹងសាមគ្គីភាពសង្គម។

## បង្ហាញប្រវត្តិនៃចំណាកស្រុក និងផ្លាស់ប្តូរទីលំនៅដោយបង្ខំនៅក្នុងការអប់រំឱ្យមានភាពសុក្រឹត ដើម្បីជម្នះលើបុរេនិច្ឆ័យ

ការស្ថាបនាសង្គមប្រកបដោយបរិយាបន្ន និងជួយមនុស្សឱ្យរស់នៅជាមួយគ្នា ទាមទារឱ្យមានមិនត្រឹមតែភាពអត់ឱនគ្នាតែប៉ុណ្ណោះទេ។ រដ្ឋាភិបាលចាំបាច់ត្រូវពិនិត្យឡើងវិញលើខ្លឹមសារអប់រំ និងការបង្រៀនកែសម្រួលកម្មវិធីសិក្សា និងគិតឡើងវិញអំពីសៀវភៅពុម្ពដើម្បីឆ្លុះបញ្ចាំងអំពីប្រវត្តិសាស្ត្រ និងភាពចម្រុះគ្នាដែលមានក្នុងពេលបច្ចុប្បន្ន។ ខ្លឹមសារការអប់រំចាំបាច់ត្រូវ បង្ហាញចេញមកអំពីការចូលរួមចំណែករបស់ចំណាកស្រុកទៅក្នុងធនធាន និងវិបុលភាព។ ខ្លឹមសារការអប់រំក៏ចាំបាច់ត្រូវទទួលស្គាល់បុព្វហេតុនៃភាពតានតឹង និងជម្លោះក៏ដូចជាកេរដំណែលនៃចំណាកស្រុកដែលបានធ្វើឱ្យប្រជាជនត្រូវផ្លាស់ប្តូរទីលំនៅដោយបង្ខំ ឬជួបការលំបាក។ គោលវិធីបែបគរុកោសល្យគួរលើកកម្ពស់ភាពបើកទូលាយចំពោះពហុទស្សនវិស័យ លើកកម្ពស់នៃគុណតម្លៃនៃការរស់នៅជាមួយគ្នា និងឱ្យតម្លៃលើអត្ថប្រយោជន៍នៃភាពចម្រុះគ្នា។ គោលវិធីគរុកោសល្យគួរជម្នះនូវបុរេនិច្ឆ័យ និងអភិវឌ្ឍជំនាញការគិតប្រកបដោយការរិះគន់ ដើម្បីឱ្យអ្នកសិក្សាអាចយកឈ្នះលើភាពមិនច្បាស់លាស់នៅក្នុងអន្តរទំនាក់ទំនងជាមួយវប្បធម៌ដទៃ និងប្រឆាំងចំពោះការបង្ហាញក្នុងលក្ខណៈអវិជ្ជមានតាមប្រព័ន្ធផ្សព្វផ្សាយអំពីជនចំណាកស្រុក និងជនភៀសខ្លួន។ រដ្ឋាភិបាលត្រូវស្វែងឱ្យឃើញនូវបទពិសោធន៍ជាវិជ្ជមាននៃការអប់រំបែបអន្តរវប្បធម៌។

## ត្រៀមខ្លួនគ្រូបង្រៀនរបស់ជនចំណាកស្រុក និងជនភៀសខ្លួនឱ្យឆ្លើយតបជាមួយភាពចម្រុះគ្នា និងការលំបាក

គ្រូបង្រៀនត្រូវការការគាំទ្រដើម្បីក្លាយជាភ្នាក់ងារនៃការផ្លាស់ប្តូរនៅក្នុងបរិស្ថានសាលារៀនដែលត្រូវបានកំណត់រូបរាងកាន់តែច្រើនឡើងៗ ដោយចំណាកស្រុក និងការផ្លាស់ប្តូរទីលំនៅដោយបង្ខំ។

កម្មវិធីអប់រំគ្រូបង្រៀនបច្ចុប្បន្ន ដែលឆ្លើយតបចំពោះបញ្ហាចំណាកស្រុក ច្រើនតែមានលក្ខណៈបណ្តោះអាសន្ន ហើយពុំមែនជាផ្នែកមួយនៃកម្មវិធីសិក្សាគោល។ រដ្ឋាភិបាលចាំបាច់ត្រូវវិនិយោគនៅក្នុងការអប់រំបណ្តុះបណ្តាលគ្រូមុនពេលចាប់ផ្តើមការងារ និងការបណ្តុះបណ្តាលបន្ត ដែលអាចស្ថាបនាសមត្ថភាពស្នូល និងលទ្ធភាព ដើម្បីគ្រប់គ្រងបរិបទដែលមានលក្ខណៈចម្រុះពហុភាសា និងពហុវប្បធម៌ ហើយដែលជះឥទ្ធិពល

ផងដែរទៅលើសិស្សម្ចាស់ស្រុក។ ត្រូវលើកកម្ពស់ការយល់ដឹងរបស់គ្រូបង្រៀនទាំងអស់អំពីចំណាកស្រុក និងការផ្លាស់ប្តូរទីលំនៅដោយបង្ខំ ពោលគឺពុំមែនត្រឹមតែគ្រូដែលត្រូវបង្រៀននៅក្នុងថ្នាក់រៀនដែលមានលក្ខណៈចម្រុះគ្នាប៉ុណ្ណោះទេ។ គ្រូបង្រៀនដែលមានក្តីប្រាថ្នា និងគ្រូបង្រៀនដែលកំពុងហ្វឹកហាត់ប្រកបវិជ្ជាជីវៈអាជីព ព្រមទាំងអ្នកដឹកនាំសាលារៀន គួរបានទទួលឧបករណ៍នានា ដើម្បីតតាំងជាមួយផ្នត់គំនិតសង្គម បុរេនិច្ឆ័យ និងការរើសអើងនៅក្នុងថ្នាក់រៀន ទីធ្លាសាលា និងសហគមន៍ និងដើម្បីពង្រឹងដល់ការឱ្យតម្លៃចំពោះខ្លួនឯង និងអារម្មណ៍ជាផ្នែកមួយនៃសង្គមរបស់សិស្សជាជនចំណាកស្រុក និងជនភៀសខ្លួន។

គ្រូបង្រៀនក្នុងបរិបទការផ្លាស់ទីលំនៅដោយបង្ខំក៏ចាំបាច់ត្រូវតែយល់ច្បាស់អំពីការលំបាកជាក់លាក់ដែលសិស្សផ្លាស់ប្តូរទីលំនៅដោយបង្ខំ និងឪពុកម្តាយរបស់ពួកគេត្រូវជួបប្រទះ និងត្រូវទំនាក់ទំនងទៅដល់សហគមន៍របស់ពួកគេផងដែរ។ ថ្វីបើគ្រូបង្រៀនពុំមែនជាអ្នកប្រឹក្សាយោបល់ក្តី ប៉ុន្តែពួកគេគាត់ក៏អាចទទួលការបណ្តុះបណ្តាល ដើម្បីឱ្យស្គាល់ពីអារម្មណ៍តានតឹងចិត្ត និងការប៉ះទង្គិចធ្ងន់ធ្ងរ និងអាចបញ្ជូនអ្នកត្រូវការសេវាទៅរកអ្នកឯកទេសផងដែរ។ ប្រសិនបើពុំមានអ្នកឯកទេសទេ គ្រូបង្រៀនគួរត្រៀមខ្លួន ដើម្បីបម្រើសេវាផងដែរ ដោយហេតុថា គ្រួសារមួយចំនួនមានលទ្ធភាពត្រឹមតែអាចទទួលបានសេវាប្រភេទនេះប៉ុណ្ណោះ។ គ្រូបង្រៀនរបស់គ្រូជនភៀសខ្លួននិងគ្រូដែលផ្លាស់ប្តូរទីលំនៅដោយបង្ខំក៏រងនូវភាពតានតឹងចិត្តបន្ថែមដោយខ្លួនឯងផ្ទាល់ផងដែរ។ គោលនយោបាយគ្រប់គ្រងចាំបាច់ត្រូវទទួលស្គាល់ និងបន្ធូរបន្ថយការលំបាកហួសប្រមាណដែលគ្រូមួយចំនួនត្រូវធ្វើការ គ្រប់គ្រង និងធានាឱ្យមានសមភាពក្នុងចំណោមអ្នកប្រកបវិជ្ជាជីវៈអាជីពបង្រៀន ដើម្បីរក្សាស្មារតី និងវិនិយោគក្នុងការអនុវត្តវិជ្ជាជីវៈអាជីព ។

## ជួយជំរុញសក្តានុពលរបស់ជនចំណាកស្រុក និងប្រជាជនផ្លាស់ប្តូរទីលំនៅដោយបង្ខំ

ជនចំណាកស្រុក និងជនភៀសខ្លួនមានជំនាញផ្សេងៗ ដែលមិនត្រឹមតែអាចជួយផ្លាស់ប្រែជីវិតរបស់ខ្លួន និងគ្រួសារខ្លួនផ្ទាល់តែប៉ុណ្ណោះទេ ប៉ុន្តែក៏អាចជួយផ្លាស់ប្រែដល់សេដ្ឋកិច្ច និងសង្គមរបស់ប្រទេសម្ចាស់ផ្ទះ និងប្រទេសកំណើតបានផងដែរ មិនថាពួកគេវិលត្រលប់ទៅវិញ ឬផ្តល់ការគាំទ្រពីចម្ងាយក្តី។ ការប្រើប្រាស់សក្តានុពលនេះ ទាមទារយន្តការសាមញ្ញមានតម្លៃទាប និងមានតម្លាភាពខ្ពស់ ដើម្បីទទួលស្គាល់គុណវុឌ្ឍិផ្នែកការសិក្សាស្រាវជ្រាវ និងជំនាញវិជ្ជាជីវៈអាជីព (រួមទាំងជំនាញវិជ្ជាជីវៈអាជីពរបស់គ្រូបង្រៀនផងដែរ) និងទទួលស្គាល់ការរៀនសូត្រពីមុនមករបស់ពួកគេ ដែលពុំត្រូវបានផ្តល់សុពលភាព ឬមានលិខិតបញ្ជាក់។

បណ្តាប្រទេសនានា ចាំបាច់ត្រូវតាមដានបន្តលើការប្តេជ្ញាចិត្តនៅក្នុងកិច្ចព្រមព្រៀងសាកលស្តីពីចំណាកស្រុកដោយសុវត្ថិភាពមានសណ្តាប់ធ្នាប់ និងជាប្រចាំ ទាក់ទងជាមួយការទទួលស្គាល់គុណវុឌ្ឍិគ្នាទៅវិញទៅមក និងបង្កើតឱ្យមានការចរចានៅក្រោមអនុសញ្ញាសាកលស្តីពីការទទួលស្គាល់គុណវុឌ្ឍិការអប់រំថ្នាក់ឧត្តមសិក្សា ដើម្បីឱ្យអនុសញ្ញានេះ អាចត្រូវបានអនុម័តក្នុងឆ្នាំ ២០១៩។ ទីភ្នាក់ងារវាយតម្លៃ ស្ថាប័នផ្តល់អាជ្ញាប័ណ្ណ និងវិទ្យាស្ថានសិក្សាស្រាវជ្រាវគួរធ្វើសុខដុមនីយកម្មការតម្រូវ និងនីតិវិធីនានានៅថ្នាក់ទ្វេភាគី ថ្នាក់តំបន់ និងថ្នាក់សាកលដោយធ្វើការជាមួយរដ្ឋាភិបាល និងអង្គការថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។ បទដ្ឋានសញ្ញាបត្ររួម យន្តការធានាគុណភាព និងកម្មវិធីផ្លោះប្តូរផ្នែកសិក្សាស្រាវជ្រាវ អាចគាំទ្រដល់ការទទួលស្គាល់គុណវុឌ្ឍិបាន។

## គាំទ្រសេចក្តីត្រូវការផ្នែកអប់រំរបស់ជនចំណាកស្រុក និងប្រជាជនផ្លាស់ប្តូរទីលំនៅ ដោយបង្ខំនៅក្នុងជំនួយមនុស្សធម៌ និងជំនួយអភិវឌ្ឍន៍

ថ្វីបើពីរភាគបីនៃជនចំណាកស្រុកអន្តរជាតិ ផ្តោតគោលដៅលើបណ្តាប្រទេសមានចំណូលខ្ពស់ក្តី ប៉ុន្តែជនភៀសខ្លួន ៩ នាក់ក្នុងចំណោមជនភៀសខ្លួន ១០ នាក់ គឺត្រូវបានទទួលឱ្យស្នាក់នៅក្នុងបណ្តាប្រទេសមានចំណូលទាប និងចំណូលមធ្យម ដែលទាមទារការគាំទ្រពីដៃគូអន្តរជាតិ។ ការឆ្លើយតបចំពោះសេចក្តីត្រូវការទាមទារឱ្យមានការបង្កើនសមាមាត្រនៃការអប់រំនៅក្នុងជំនួយមនុស្សធម៌អន្តរជាតិចំនួន១០ដង។ដំណោះស្រាយប្រកបដោយចីរភាពបន្ថែមទៀត គឺមានភាពចាំបាច់ណាស់ ដែលសហគមន៍អន្តរជាតិត្រូវបំពេញតាមការប្តេជ្ញាចិត្តកិច្ចព្រមព្រៀងសាកលស្តីពីជនភៀសខ្លួន និងក្របខ័ណ្ឌការងារការឆ្លើយតបចំពោះជនភៀសខ្លួនសព្វជ្រុងជ្រោយ ដើម្បីផ្សារភ្ជាប់ជំនួយមនុស្សធម៌ និងជំនួយអភិវឌ្ឍន៍តាំងពីដំណាក់ដំបូងនៃវិបត្តិ ដែលគាំទ្រចំពោះការផ្តល់ការអប់រំប្រកបដោយបរិយាបន្នសម្រាប់ជនភៀសខ្លួន និងប្រជាជនម្ចាស់ស្រុក។ ការអប់រំគួរត្រូវបានដាក់បញ្ចូលនៅក្នុងការតាក់តែងការឆ្លើយតប ជាពិសេស ទាក់ទងជាមួយការអប់រំ និងការថែទាំកុមារតូច។ ការអប់រំ ក៏គួរតែជាផ្នែកមួយនៃកញ្ចប់ដំណោះស្រាយសព្វជ្រុងជ្រោយពាក់ព័ន្ធជាមួយវិស័យដទៃទៀត ឧ. ទីជម្រក អាហារូបត្ថម្ភ ទឹកស្អាត អនាម័យទូទៅ និងកិច្ចគាំពារសង្គម។ ម្ចាស់ជំនួយចាំបាច់ត្រូវឆ្លុះបញ្ចាំងកំណែទម្រង់ទាំងអស់នេះនៅក្នុងអន្តរាគមន៍មនុស្សធម៌របស់ខ្លួន។ តាមរយៈការប្រើប្រាស់ឱកាសដែលមានផ្តល់ជូនតាមរយៈមូលនិធិការអប់រំ មិនអាចរង់ចាំបាន (Education Cannot Wait) ម្ចាស់ជំនួយចាំបាច់ត្រូវអភិវឌ្ឍសមត្ថភាពវាយតម្លៃសេចក្តីត្រូវការរបស់ខ្លួននិងការធ្វើផែនការរួមគ្នាដើម្បីបិទភ្ជិតគម្លាតផ្នែកជំនួយមនុស្សធម៌ជាមួយការអភិវឌ្ឍ និងជួយជំរុញឱ្យមានការផ្តល់មូលនិធិរយៈពេលច្រើនឆ្នាំដែលអាចព្យាករណ៍ទុកជាមុនបាន។

# ការធ្វើចំណាកស្រុក ការផ្លាស់ប្តូរទីលំនៅដោយបង្ខំ និងការអប់រំ

## សង់ស្ពានចម្លង មិនមែនសង់ជញ្ជាំងនោះទេ

*របាយការណ៍ពិនិត្យតាមដានការអប់រំសាកល* ឆ្នាំ ២០១៩ ពិនិត្យទៅលើផលប៉ះពាល់ផ្នែកការអប់រំបណ្តាលមកពីចំណាកស្រុក និងការផ្លាស់ប្តូរទីលំនៅដោយបង្ខំ ទាក់ទងនឹងការផ្លាស់ទីប្រជាជនគ្រប់ប្រភេទទាំងអស់៖ ការផ្លាស់ទីនៅក្នុងប្រទេស និងការផ្លាស់ទីឆ្លងដែន, ការផ្លាស់ទីដោយស្ម័គ្រចិត្ត និងដោយបង្ខំ, ការផ្លាស់ទីដើម្បីរកការងារធ្វើ និងការផ្លាស់ទីដើម្បីស្វែងរកការអប់រំ។ របាយការណ៍នេះ ក៏ពិនិត្យឡើងវិញលើវឌ្ឍនភាពក្នុងវិស័យអប់រំដូចមានចែងក្នុងរបៀបវារៈសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ ២០៣០ ផងដែរ។

ដោយមើលឃើញនូវទិដ្ឋភាពចម្រុះគ្នាកាន់តែច្រើនឡើង របាយការណ៍នេះផ្តល់ការវិភាគថាតើការអប់រំអាចស្ថាបនាសង្គមប្រកបដោយបរិយាបន្ន និងជួយប្រជាជនឱ្យឈានមួយជំហានទៀតពីការអត់ឱនទៅដល់ការរៀនរស់នៅជាមួយគ្នាបានដោយរបៀបណា។ ការអប់រំដែលត្រូវបានផ្តល់ឱ្យប្រកបដោយសមភាពអាចជួយសាងស្ពានតភ្ជាប់ប៉ុន្តែការអប់រំដែលមិនមានលក្ខណៈស្មើភាពអាចបង្កើតឱ្យមានជញ្ជាំងខណ្ឌចែករវាងជនចំណាកស្រុក និងជនភៀសខ្លួន ជាមួយសហគមន៍ម្ចាស់ផ្ទះរបស់ខ្លួន។

កិច្ចព្រមព្រៀងសាកលថ្មីៗចំនួនពីរ ស្តីពីជនចំណាកស្រុក និងជនភៀសខ្លួន ទទួលស្គាល់តួនាទីរបស់ការអប់រំ និងកំណត់គោលបំណងដែលត្រូវបានបន្សីជាមួយការប្តេជ្ញាចិត្តកម្រិតសាកលក្នុងការមិនទុកនរណាម្នាក់ចោល។ របាយការណ៍នេះគឺជាកញ្ចប់ឧបករណ៍ដ៏មានសារៈសំខាន់សម្រាប់កិច្ចព្រមព្រៀងទាំងពីរនេះ។ របាយការណ៍នេះ គ្របដណ្តប់លើបញ្ហាផ្នែកគោលនយោបាយ ដែលឆ្លើយតបចំពោះចំណាកស្រុកតាមរដូវ ការប្រមូលផ្តុំ ការប្របាច់បញ្ចូលគ្នានៃសាលាជនបទ កម្មវិធីសិក្សាអន្តរវប្បធម៌ បរិយាបន្នជនភៀសខ្លួននៅក្នុងប្រព័ន្ធអប់រំជាតិ និងការលុបបំបាត់ការបែងចែកគ្នា ការទទួលស្គាល់គុណវុឌ្ឍិ ការផ្តោតគោលដៅមូលនិធិសាលារៀន ជំនួយមនុស្សធម៌លើផ្នែកការអប់រំកាន់តែមានប្រសិទ្ធភាព និងការត្រៀមខ្លួនរួចជាស្រេចរបស់គ្រូសម្រាប់ថ្នាក់រៀនដែលមានលក្ខណៈចម្រុះក្នុងស្ថានភាពអាសន្ន បរិបទអូសបន្លាយ និង "រឿងប្រក្រតីបែបថ្មី"។

ខ្លឹមសារសង្ខេបរបាយការណ៍GEMឆ្នាំ២០១៩អំពាវនាវឱ្យបណ្តាប្រទេសទាំងឡាយត្រូវចាត់ទុកការអប់រំជាឧបករណ៍មួយក្នុងការគ្រប់គ្រងចំណាកស្រុក និងការផ្លាស់ប្តូរទីលំនៅដោយបង្ខំ ហើយជាឱកាសមួយសម្រាប់អ្នកដែលកំពុងមានតម្រូវការ។

ការអប់រំ គឺជាសិទ្ធិមនុស្ស និងជាកម្លាំងប្រែក្លាយឲ្យកាន់តែប្រសើរ ដើម្បីលុបបំបាត់ភាពក្រីក្រស្ថាបនាចីរភាព និងសន្តិភាព។ ប្រជាជនដែលផ្លាស់ទី មិនថាជាការផ្លាស់ទីដើម្បីរកការងារធ្វើ ឬស្វែងរកការអប់រំ និងមិនថាផ្លាស់ទីដោយស្ម័គ្រចិត្ត ឬដោយបង្ខំក្តី គឺពុំមានន័យថាពួកគេបានបាត់បង់សិទ្ធិទទួលបានការអប់រំឡើយ។ របាយការណ៍ពិនិត្យតាមដានការអប់រំសាកលឆ្នាំ ២០១៩ គូសបញ្ជាក់អំពីសក្តានុពល និងឱកាសដ៏ធំធេងក្នុងការធានាឱ្យបានថាជនចំណាកស្រុកនិងផ្លាស់ប្តូរទីលំនៅដោយបង្ខំមានលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព។

António Guterres អគ្គលេខាធិការអង្គការសហប្រជាជាតិ

របាយការណ៍នេះ នាំយកភស្តុតាងដែលមានស្រាប់ស្តីពីចំណាកស្រុក និងការអប់រំមករួមបញ្ចូលគ្នា ដើម្បីគូសបង្ហាញឱ្យឃើញនូវឱកាសដ៏ធំធេង ក៏ដូចជាចង្អុលបង្ហាញឱ្យឃើញថាតើការលំបាកផ្នែកការអប់រំអាចកើតមាននៅទីណាខ្លះ និងដោយមូលហេតុអ្វីខ្លះ។ ម្យ៉ាងទៀតនេះគឺជាពេលវេលាមួយដែលសហគមន៍អន្តរជាតិកំពុងព្រះពារដើម្បីឆ្លើយតបចំពោះ SDGs និងបង្កើនអត្ថប្រយោជន៍ដ៏គួរជាទីកត់សម្គាល់របស់ការធ្វើចំណាកស្រុកទូទាំងសាកលលោកឱ្យបានច្រើនជាអតិបរមា។

William Lacy Swing, អគ្គនាយកអង្គការអន្តរជាតិសម្រាប់ទេសន្តប្រវេសន៍ (ថ្ងៃទី១ខែតុលាឆ្នាំ២០០៨ដល់ថ្ងៃទី៣០ខែកញ្ញា ឆ្នាំ ២០១៨)

របាយការណ៍នេះផ្តល់មូលដ្ឋានហេតុផលដ៏គួរជាទីទាក់ទាញឱ្យមានការសង្កត់ធ្ងន់លើការអប់រំនៅក្នុងសន្ធិសញ្ញាសាកល ស្តីពីជនភៀសខ្លួន និងភាពចាំបាច់មិនអាចខ្វះបានក្នុងការដាក់បញ្ចូលជនភៀសខ្លួនទៅក្នុងប្រព័ន្ធអប់រំជាតិ និងផែនការវិស័យអប់រំ។

Filippo Grandi, ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន។

Global Education Monitoring Report

United Nations Educational, Scientific and Cultural Organization · Sustainable Development Goals